ព័ត៌មានអំពី
ការបោះឆ្នោតតាមសំបុត្រ
ត្រូវបានភ្ជាប់មកជាមួយ!

## រដ្ឋម៉ាសាឈូសិត

# ព័ត៌មានសម្រាប់អ្នកបោះឆ្នោត

## សំណួរអំពីសន្លឹកឆ្នោតឆ្នាំ 2024

## ការបោះឆ្នោតរបស់រដ្ឋ

### ថ្ងៃអង្គារ ទី 5 ខែវិច្ឆិកា ឆ្នាំ 2024

**VoteInMA.com**

*បោះពុម្ពដោយ*

**William Francis Galvin (វីល្លាម ហ្វ្រាន់ស៊ីស ហ្គាល់វីន)**

រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ

# *The Commonwealth of Massachusetts*

*Secretary of the Commonwealth*

*State House, Boston, Massachusetts 02133*

*William Francis Galvin*
*Secretary of the Commonwealth*

អ្នកបោះឆ្នោតជាទីរាប់អាន!

នៅថ្ងៃអង្គារ ទី 5 ខែវិច្ឆិកា ឆ្នាំ 2024 អ្នកមានឱកាសបញ្ចេញសំឡេងរបស់អ្នកហើយ។ ប្រសិនបើអ្នកចង់បោះឆ្នោតឱ្យបានឆាប់ អ្នក
មានជម្រើសក្នុងការបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ ឬក្នុងអំឡុងពេលនៃការបោះឆ្នោតដំបូងក្នុងសហគមន៍របស់អ្នក។ ការបោះ
ឆ្នោតមុនថ្ងៃបោះឆ្នោត នឹងត្រូវធ្វើឡើងចាប់ពីថ្ងៃទី 19 ខែតុលា ដល់ថ្ងៃទី 1 ខែវិច្ឆិកា។ នៅថ្ងៃបោះឆ្នោត ការិយាល័យបោះឆ្នោតទាំង
អស់ នឹងបើកទ្វារចាប់ពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់។

ប្រសិនបើអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយ ឬត្រូវការចុះឈ្មោះសាជាថ្មីដោយសារអ្នកបានផ្លាស់ទីលំនៅ អ្នកអាចចុះឈ្មោះ
បោះឆ្នោតតាមរយៈ **www.VoteInMA.com**។ ច្បាប់របស់រដ្ឋតម្រូវឱ្យអ្នកចុះឈ្មោះបោះឆ្នោតត្រឹមថ្ងៃទី 26 ខែតុលា ឆ្នាំ 2024
ដើម្បីឱ្យឈ្មោះរបស់អ្នកមាននៅលើបញ្ជីបោះឆ្នោត។ អ្នកក៏អាចត្រួតពិនិត្យស្ថានភាពនៃការចុះឈ្មោះបោះឆ្នោតរបស់អ្នកបានផងដែរនៅ
លើគេហទំព័រដូចគ្នានេះ។

នៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតរបស់រដ្ឋ នឹងមាន**សំណួរអំពីការបោះឆ្នោតនៅទូទាំងរដ្ឋចំនួនប្រាំ**។ កូនសៀវភៅណែនាំអំពី
ព័ត៌មានផ្លូវការសម្រាប់អ្នកបោះឆ្នោតឆ្នាំ 2024 មានរៀបរាប់អំពីសំណួរនីមួយៗដែលមាន**អត្ថបទពង្រាងច្បាប់ដែលបានស្នើឡើង**
សេចក្ដីថ្លែងការណ៍ដែលពិពណ៌នាអំពី**ឥទ្ធិពលនៃការបោះឆ្នោតគាំទ្រ និងការបោះឆ្នោតជំទាស់** និង**ខ្លឹមសារសង្ខេប និងអំណះ**
**អំណាងគាំទ្រ និងប្រឆាំងទៅនឹង**សំណួរនីមួយៗ។ ព័ត៌មាននេះនឹងជួយអ្នកក្នុងការសម្រេចចិត្តនៅមុនពេលបោះឆ្នោត។
ប្រសិនបើអ្នកចង់ អ្នកអាចយកកូនសៀវភៅណែនាំនេះតាមខ្លួនចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោត។

សៀវភៅណែនាំនេះមានព័ត៌មានសំខាន់ៗអំពីការបោះឆ្នោតដែលនឹងមកដល់ក្នុងពេលខាងមុខ។ ជម្រើសដែលអ្នកជ្រើសរើសនៅក្នុង
ការបោះឆ្នោតនេះ នឹងបង្កើតបានជាដំណើរការរបស់រដ្ឋាភិបាលសម្រាប់ប្រទេសយើង រដ្ឋ និងសហគមន៍ក្នុងមូលដ្ឋានរបស់យើង។ ថ្នាក់
ដឹកនាំដែលអ្នកជ្រើសរើស នឹងធ្វើការសម្រេចចិត្តសំខាន់ៗដែលមានឥទ្ធិពលទៅលើអ្នកនិងគ្រួសាររបស់អ្នក។ ខ្ញុំសូមទទូចឱ្យអ្នកចូល
រួមក្នុងដំណើរការនេះ ដោយសារការបោះឆ្នោតរបស់អ្នកពិតជាមានសារៈសំខាន់ណាស់។

សូមទៅបោះឆ្នោត និងអនុវត្តសិទ្ធិសំខាន់បំផុតនៃប្រព័ន្ធប្រជាធិបតេយ្យរបស់យើង។

ដោយសេចក្ដីគោរពអំពីខ្ញុំ

William Francis Galvin (វីល្លាម ហ្វ្រាន់ស៊ីស ហ្គាល់វីន)
រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ

# តារាងមាតិកា


មុខតំណែងដែលត្រូវបោះឆ្នោតក្នុងឆ្នាំ 2024 .......... 4

កាលបរិច្ឆេទសំខាន់ៗដែលត្រូវចងចាំ .......... 5

សំណួរទី 1 - សិទ្ធិអំណាចរបស់សវនកររដ្ឋ ដើម្បីធ្វើសវនកម្មអង្គនីតិប្បញ្ញត្តិ .......... 6

សំណួរទី 2 - ការលុបបំបាត់ MCAS ជាលក្ខខណ្ឌប្រឡងបញ្ចប់ថ្នាក់វិទ្យាល័យ .......... 10

សំណួរទី 3 - ការចូលសហជីពសម្រាប់អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន .......... 13

សំណួរទី 4 - នីត្យានុកូលកម្មនិងបទប្បញ្ញត្តិមានដែនកំណត់ស្តីពីសារធាតុវលីវាយធម្មជាតិជាក់លាក់មួយចំនួន .......... 25

សំណួរទី 5 - ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ .......... 41

ចុះឈ្មោះបោះឆ្នោត .......... 46

ការបោះឆ្នោតក្នុងឆ្នាំ 2024 .......... 47

ការបោះឆ្នោតតាមសំបុត្រ .......... 47

ការបោះឆ្នោតដោយផ្ទាល់មុនថ្ងៃបោះឆ្នោត .......... 48

ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត .......... 49

សំណួរដែលត្រូវបានសាកសួរជាញឹកញាប់ .......... 50

សុវត្ថិភាពនៃការបោះឆ្នោត .......... 51

ធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត! .......... 52

អ្នកបោះឆ្នោតជាមន្ត្រីយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស .......... 52

សេវានានារបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ .......... 53

បញ្ជីត្រួតពិនិត្យសម្រាប់អ្នកបោះឆ្នោត .......... 55


---

¡Atención! Si desea recibir este folleto en Español, llame al 617-727-2828 o al 1-800-462-VOTE (8683).

請注意！如果您希望索取本手冊的中文譯本，請致電 617-727-2828 或 1-800-462-8683。

Chú ý! Nếu bạn muốn nhận tập sách này bằng tiếng Việt, vui lòng gọi 617-727-2828 hoặc 1-800-462-VOTE (8683)

សូមយកចិត្តទុកដាក់! ប្រសិនបើអ្នកចង់បានឯកសារនេះជាភាសាខ្មែរ សូមអ្នកទូរស័ព្ទទៅលេខ 617-727-2828 ឬ 1-800-462-VOTE (8683) ។

## មុខតំណែងដែលត្រូវបោះឆ្នោតក្នុងឆ្នាំ 2024

**អ្នកបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតី**

**សមាជិកព្រឹទ្ធសភានៅក្នុងសភាជាន់ខ្ពស់**

**សមាជិកសភាសហរដ្ឋអាមេរិក**

**ទីប្រឹក្សាអភិបាលរដ្ឋ**

**សមាជិកព្រឹទ្ធសភាប្រចាំរដ្ឋម៉ាសាឈូសិត**

**សមាជិកសភាប្រចាំរដ្ឋម៉ាសាឈូសិត**

**មន្ត្រីចុះបញ្ជីកម្មសិទ្ធិ**

**ក្រឡាបញ្ជី**

**សមាជិកក្រុមប្រឹក្សាភិបាលប្រចាំខោនធី**
(ខោនធី Barnstable, Bristol, Dukes, Norfolk និង Plymouth តែប៉ុណ្ណោះ)
ឬក្រុមប្រឹក្សាភិបាលនៃខោនធី Franklin (ខោនធី Franklin តែប៉ុណ្ណោះ)

**មន្ត្រីតុលាការមរតកសាសន៍**
(ខោនធី Hampshire និងខោនធី Suffolk)

# *កាលបរិច្ឆេទសំខាន់ៗដែលត្រូវចងចាំ*

**ថ្ងៃទី 11 ខែតុលា៖ មានកាលវិភាគសម្រាប់ការបោះឆ្នោតមុនកាលកំណត់នៅក្នុងតំបន់**

ការបោះឆ្នោតមុនកាលបរិច្ឆេទកំណត់ និងទីតាំងបោះឆ្នោតសម្រាប់ទីក្រុងនិងទីប្រជុំជននីមួយៗ នឹងត្រូវប្រកាសឱ្យដឹងនៅលើគេហទំព័រ **www.VoteInMA.com** មិនឱ្យលើសពីថ្ងៃទី 11 ខែតុលា ឡើយ។ ពិនិត្យមើលព័ត៌មានរបស់សហគមន៍របស់អ្នក ដើម្បីឈ្វេងយល់ថាតើអ្នកអាចបោះឆ្នោតមុនថ្ងៃបោះឆ្នោតនៅកន្លែងណា និងនៅពេលណាបាន។

**ថ្ងៃទី 19 ខែតុលា ទៅដល់ ថ្ងៃទី 1 ខែវិច្ឆិកា៖ រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត**

ការបោះឆ្នោតមុនថ្ងៃបោះឆ្នោតទី 5 ខែវិច្ឆិកា ឆ្នាំ 2024 ចាប់ផ្តើមពីថ្ងៃទី 19 ខែតុលា និងបញ្ចប់នៅថ្ងៃទី 1 ខែវិច្ឆិកា។

រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត រួមមានពេលពីរសប្តាហ៍ ហើយសហគមន៍នីមួយៗ នឹងផ្តល់ម៉ោងមួយចំនួនសម្រាប់ការបោះឆ្នោតនៅថ្ងៃចុងសប្តាហ៍។

តារាងពេលវេលានៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ខុសគ្នាទៅតាមទីក្រុងនិងទីប្រជុំជន។ សូមកុំភ្លេចពិនិត្យមើលតារាងពេលវេលាសហគមន៍របស់អ្នក នៅពេលអ្នកមានផែនការទៅបោះឆ្នោត។

**ថ្ងៃទី 26 ខែតុលា៖ កាលបរិច្ឆេទផុតកំណត់សម្រាប់ការចុះឈ្មោះបោះឆ្នោត**

ថ្ងៃចុងក្រោយសម្រាប់ចុះឈ្មោះបោះឆ្នោត ធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន ប្តូរឈ្មោះ ឬប្តូរគណបក្សរបស់អ្នកសម្រាប់ការបោះឆ្នោតនៅថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024 គឺមានរយៈពេល 10 ថ្ងៃ នៅមុនថ្ងៃបោះឆ្នោត។

ម៉ោងសម្រាប់ការចុះឈ្មោះបោះឆ្នោតដោយផ្ទាល់ នឹងត្រូវធ្វើឡើងនៅតាមទីក្រុង និងទីប្រជុំជន រហូតដល់ម៉ោង 5 ល្ងាច នៅថ្ងៃទី 26 ខែតុលា។

ការចុះឈ្មោះអ្នកបោះឆ្នោតតាមអនឡាញ នឹងត្រូវបើករហូតដល់ម៉ោង 11:59 យប់ នៅថ្ងៃទី 26 ខែតុលា។

ទម្រង់នៃការចុះឈ្មោះអ្នកបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍ត្រូវវាយត្រាប្រៃសណីយ៍ កំណត់ត្រឹមថ្ងៃទី 26 ខែតុលា។

**ថ្ងៃទី 29 ខែតុលា៖ កាលបរិច្ឆេទផុតកំណត់សម្រាប់ដាក់ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ**

ការបោះឆ្នោតតាមសំបុត្ររបស់អ្នក ត្រូវមកដល់ការិយាល័យបោះឆ្នោតត្រឹមម៉ោង 5 ល្ងាច នៅថ្ងៃទី 29 ខែតុលា ដើម្បីឱ្យគេផ្ញើសន្លឹកឆ្នោតទៅអ្នក។ ត្រាប្រៃសណីយ៍ មិនគ្រប់គ្រាន់ទៅតាមកាលបរិច្ឆេទកំណត់ទេ។ ប្រសិនបើអ្នកផ្ញើពាក្យស្នើសុំរបស់អ្នក ត្រូវប្រាកដថា អ្នកបានដាក់ពាក្យស្នើសុំយ៉ាងហោចណាស់មួយសប្តាហ៍មុនកាលបរិច្ឆេទផុតកំណត់។

សូមផ្តល់អនុសាសន៍ឱ្យអ្នកដាក់ពាក្យសុំសន្លឹកឆ្នោតឱ្យបានមុនកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី 29 ខែតុលា ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកត្រូវផ្ញើចេញទៅក្រៅទីប្រជុំជន ឬប្រសិនបើអ្នកមានផែនការផ្ញើសន្លឹកឆ្នោតត្រឡប់មកវិញតាមប្រៃសណីយ៍។

**ថ្ងៃទី 5 ខែវិច្ឆិកា៖ ថ្ងៃបោះឆ្នោត**

ថ្ងៃបោះឆ្នោតគឺធ្វើឡើងនៅថ្ងៃទី 5 ខែវិច្ឆិកា។ ការបោះឆ្នោតនឹងចាប់ផ្តើមនៅម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់ នៅទូទាំងរដ្ឋម៉ាសាឈូសិត។

ប្រសិនបើអ្នកនឹងបោះឆ្នោតតាមសំបុត្រ សន្លឹកឆ្នោតរបស់អ្នកត្រូវវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី 5 ខែវិច្ឆិកា ដើម្បីអាចរាប់បញ្ចូលបាន។ ដោយសារសន្លឹកឆ្នោតអាចត្រូវការពេលរហូតដល់ 7 ថ្ងៃ ដើម្បីឱ្យសេវាប្រៃសណីយ៍អាមេរិកអាចប្រគល់ជូនបាន យើងសូមណែនាំឱ្យអ្នកផ្ញើសន្លឹកឆ្នោតរបស់អ្នកយ៉ាងតិចមួយសប្តាហ៍មុនថ្ងៃបោះឆ្នោត។

ការប្រគល់សន្លឹកឆ្នោតដោយផ្ទាល់ដៃជូនដល់ការិយាល័យបោះឆ្នោត ឬប្រអប់សំបុត្រ អាចធ្វើឡើងត្រឹមពេលបិទការបោះឆ្នោតនៅម៉ោង 8 យប់ នៅថ្ងៃបោះឆ្នោត។

**ថ្ងៃទី 8 ខែវិច្ឆិកា៖ ថ្ងៃចុងក្រោយដែលសន្លឹកឆ្នោតក្នុងស្រុកមកដល់**

ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកមកពីទីតាំងនៅក្នុងសហរដ្ឋអាមេរិក សន្លឹកឆ្នោតនោះត្រូវមកដល់ការិយាល័យបោះឆ្នោតក្នុងតំបន់ត្រឹមម៉ោង 5 ល្ងាច នៅថ្ងៃទី 8 ខែវិច្ឆិកា ដើម្បីរាប់បញ្ចូល។

សន្លឹកឆ្នោតដែលមកដល់ បន្ទាប់ពីការបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត នឹងអាចរាប់បញ្ចូលបានតែក្នុងករណីដែលសន្លឹកឆ្នោតទាំងនោះ មានវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី 5 ខែវិច្ឆិកា ប៉ុណ្ណោះ។

**ថ្ងៃទី 15 ខែវិច្ឆិកា៖ ថ្ងៃចុងក្រោយដែលសន្លឹកឆ្នោតមកពីក្រៅប្រទេសត្រូវមកដល់**

ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកមកពីទីតាំងនៅក្រៅសហរដ្ឋអាមេរិក សន្លឹកឆ្នោតនោះត្រូវមកដល់ការិយាល័យបោះឆ្នោតក្នុងស្រុក ត្រឹមម៉ោង 5 ល្ងាច នៅថ្ងៃទី 15 ខែវិច្ឆិកា ដើម្បីរាប់បញ្ចូល។

សន្លឹកឆ្នោតដែលផ្ញើមកពីក្រៅប្រទេសដែលមកដល់ក្រោយពីការបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត នឹងអាចរាប់បញ្ចូលបានតែក្នុងករណីដែលសន្លឹកឆ្នោតទាំងនោះ មានវាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី 5 ខែវិច្ឆិកា ប៉ុណ្ណោះ។ សន្លឹកឆ្នោតដែលមកដល់ក្រោយថ្ងៃទី 8 ខែវិច្ឆិកា ក៏ត្រូវមានវាយត្រាប្រៃសណីយ៍ច្បាស់ៗពីក្រៅប្រទេសផងដែរ។

# 1

## សំណួរទី១ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# *សិទ្ធិអំណាចរបស់សវនកររដ្ឋ ដើម្បីធ្វើសវនកម្មអង្គនីតិប្បញ្ញត្តិ*

*តើលោកអ្នកយល់ស្របតាមច្បាប់ដែលបានសង្ខេបនៅខាងក្រោមទេ ដែលចែងថាគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយព្រឹទ្ធសភា ឬសភាតំណាងរាស្ត្រឡើយ នៅមុនថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៤?*

---

**សេចក្តីសង្ខេប** ▶

តាមច្បាប់តម្រូវ សេចក្តីសង្ខេបគឺសរសេរឡើងដោយអគ្គរដ្ឋអាជ្ញា។

សេចក្តីស្នើច្បាប់នេះនឹងបញ្ជាក់ថា សវនកររបស់រដ្ឋមានសិទ្ធិអំណាចក្នុងការធ្វើសវនកម្មលើអង្គនីតិបញ្ញត្តិ។

---

**ឥទ្ធិពលពីការបោះឆ្នោតរបស់អ្នក** ▶

តាមរយៈការតម្រូវដោយច្បាប់ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងបញ្ជាក់ថា សវនកររបស់រដ្ឋមានសិទ្ធិធ្វើសវនកម្មលើអង្គនីតិបញ្ញត្តិ។

***ការបោះឆ្នោតជំទាស់*** នឹងមិនធ្វើអោយមានការផ្លាស់ប្តូរក្នុងច្បាប់ទាក់ទងនឹងសិទ្ធិអំណាចរបស់សវនកររដ្ឋឡើយ។

---

**របាយការណ៍នៃការប៉ះពាល់លើសារពើពន្ធ** ▶

តាមច្បាប់កំណត់ របាយការណ៍ផលប៉ះពាល់សារពើពន្ធត្រូវសរសេរដោយក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើ ពុំអាចដឹងពីផលប៉ះពាល់សារពើពន្ធជាសារវន្តចំពោះហិរញ្ញវត្ថុរដ្ឋ និងហិរញ្ញវត្ថុរដ្ឋាភិបាលក្រុងឡើយ។

---

**ទឡ្ហីករណ៍** ▶

ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវសរសេរដោយអ្នកគាំទ្រ និងអ្នកបដិសេធលើសំណួរនីមួយៗ និងឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិត ពុំបានគាំទ្រចំពោះទឡ្ហីករណ៍ទាំងនេះទេ ហើយក៏មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃសេចក្តីថ្លែងការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះរបស់បុគ្គល និងស្ថាប័នដែលបានសរសេរសេចក្តីថ្លែងការនីមួយៗ និងមតិយោបល់ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃផ្សេងទៀតអំពីសេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***បោះឆ្នោតគាំទ្រ៖*** **ការបោះឆ្នោតគាំទ្រ** លើសំណួរទី 1 ផ្តល់សិទ្ធិឱ្យ **សវនកររដ្ឋដើម្បីធ្វើសវនកម្មលើសភានីតិប្បញ្ញត្តិរដ្ឋម៉ាសាឈូសិត។**

សវនកររដ្ឋត្រូវបានជ្រើសរើសដោយប្រជាជននៃរដ្ឋម៉ាសាឈូសិតដោយឯករាជ្យដើម្បីធ្វើសវនកម្មគ្រប់អង្គភាពរដ្ឋ ដើម្បីជួយធ្វើឱ្យរដ្ឋាភិបាលធ្វើការបានកាន់តែប្រសើរឡើង។ អង្គនីតិប្បញ្ញត្តិរបស់រដ្ឋគឺជាស្ថាប័នរដ្ឋតែមួយគត់ដែលបដិសេធមិនធ្វើសវនកម្មដោយការិយាល័យសវនកររបស់រដ្ឋ។ អ្នកដឹកនាំអង្គនីតិប្បញ្ញត្តិអះអាងថា វាគ្រប់គ្រាន់សម្រាប់អង្គនីតិប្បញ្ញត្តិក្នុងការធ្វើសវនកម្មដោយខ្លួនឯងតាមរយៈអ្នកផ្តល់សេវាឯកជនដែលបានធ្វើលទ្ធកម្ម។ ទោះជាយ៉ាងណាក៏ដោយ អង្គនីតិប្បញ្ញត្តិរដ្ឋម៉ាសាឈូសិត ជាប់ចំណាត់ថ្នាក់ជាបន្តបន្ទាប់ថាជាអង្គនីតិប្បញ្ញត្តិដែលមានប្រសិទ្ធភាព និងតម្លាភាពតិចបំផុតនៅអាមេរិក ហើយជាអង្គនីតិប្បញ្ញត្តិមួយក្នុងចំណោមអង្គនីតិប្បញ្ញត្តិចំនួន 4 ដែលលើកលែងខ្លួនឯងពីច្បាប់កំណត់ត្រាសាធារណៈ។

ការគាំទ្រចំពោះគំនិតផ្តួចផ្តើមនេះនឹងជួយឱ្យការិយាល័យសវនកររបស់រដ្ឋពិនិត្យនិងរាយការណ៍អំពីរបៀបដែលប្រាក់របស់អ្នកបង់ពន្ធត្រូវបានចំណាយ ដើម្បីជួយបង្កើនតម្លាភាព គណនេយ្យភាព និងភាពងាយស្រួលសម្រាប់ប្រជាជននៃរដ្ឋម៉ាសាឈូសិត។

***បោះឆ្នោតជំទាស់៖*** អ្នកជំនាញផ្នែករដ្ឋធម្មនុញ្ញ និងអ្នកអប់រំពលរដ្ឋទទូចយ៉ាងខ្លាំងកុំឱ្យបោះឆ្នោតលើសំណួរទី 1។

សវនកម្មអង្គនីតិប្បញ្ញត្តិដែលធ្វើឡើងដោយសវនកររដ្ឋ ដែលជាមន្ត្រីសាខាប្រតិបត្តិ ដោយគ្មានការយល់ព្រមពីអង្គនីតិប្បញ្ញត្តិ នឹងបំពានលើ*ការបែងចែកអំណាច* និង*បរមានុភាព* ដែលចែង និងកំណត់ដោយរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត។

សវនកម្មការអនុវត្តដែលធ្វើឡើងដោយសវនកររដ្ឋ វាស់វែងការអនុវត្តរបស់អ្នកគ្រប់គ្រងក្នុងការសម្រេចបាននូវគោលដៅដែលបានកំណត់ដោយច្បាប់នៃគោលនយោបាយសាធារណៈដែលពួកគេគ្រប់គ្រង។ សវនកររដ្ឋមិនអាចជំនួសការបកស្រាយរបស់ខ្លួនអំពីគោលដៅទាំងនោះសម្រាប់អង្គនីតិប្បញ្ញត្តិដោយមិនប៉ះពាល់ដល់ឯករាជ្យភាពនៃរដ្ឋធម្មនុញ្ញ និងភាពលេចធ្លោរបស់អង្គនីតិប្បញ្ញត្តិនោះទេ។

ប្រសិនបើបានអនុម័តនោះ សំណួរទី 1 នឹងធ្វើឱ្យសវនកររដ្ឋក្លាយជាតួអង្គនយោបាយ និងជាអ្នកចូលរួមដ៏មានសក្តានុពលក្នុងដំណើរការនីតិប្បញ្ញត្តិ ជាតួនាទីពីរដែលនឹងធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់សវនកររដ្ឋយ៉ាងច្បាស់ក្នុងការបំពេញកាតព្វកិច្ចតាមរដ្ឋធម្មនុញ្ញជាមូលដ្ឋានរបស់ខ្លួន ក្នុងការធ្វើសវនកម្មក្រសួងនិងកម្មវិធីរបស់រដ្ឋាភិបាល

**ទឡ្ហីករណ៍ (ត)** ▶ បោះឆ្នោត **គាំទ្រ** ដើម្បីផ្តល់សិទ្ធិអំណាចយ៉ាងច្បាស់លាស់ដល់សវនករ រដ្ឋដើម្បីធ្វើសវនកម្មអង្គនីតិប្បញ្ញត្តិ។

**Neil Morrison**
**គណៈកម្មាធិការសម្រាប់ប្រជាធិបតេយ្យប្រកបដោយតម្លាភាព**
**P.O. Box 364**
**Raynham, MA 02767**
**617-297-8476**
**www.auditthelegislature.com**

រដ្ឋ ប្រកបដោយភាពជឿទុកចិត្តបាន ឯករាជ្យភាព ជាសត្យានុម័ត និង មិនប្រកាន់បក្សពួក។

**Jerold Duquette**
**សាស្ត្រាចារ្យវិទ្យាសាស្ត្រនយោបាយ សាកលវិទ្យាល័យ Central Connecticut State**
**សហស្ថាបនិក & អ្នកចូលរួមវិភាគទានជាន់ខ្ពស់**
**MassPoliticsProfs.org**
**1516 Stanley Street**
**New Britain, CT 05060**
**860-832-2964**
**www.masspoliticsprofs.org**

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ**

ត្រូវអនុម័តដោយប្រជាជន និងតាមសិទ្ធិអំណាចរបស់ពួកគេ៖

ច្បាប់អនុញ្ញាតឱ្យសវនករធ្វើសវនកម្មលើអង្គនីតិប្បញ្ញត្តិ

ប្រយោគទី 1 នៃផ្នែកទី 12 ក្នុងជំពូកទី 11 នៃច្បាប់ទូទៅ ដូចមាននៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការឆ្នាំ 2022 តាមរយៈនេះ ត្រូវបានលុបចោល និងជំនួសដូចខាងក្រោម៖

ផ្នែក 12. នាយកដ្ឋានសវនកររដ្ឋត្រូវធ្វើសវនកម្មលើគណនី កម្មវិធី សកម្មភាព និងមុខងារដែលទាក់ទងដោយផ្ទាល់ទៅនឹងគណនីខាងលើរបស់នាយកដ្ឋាន ការិយាល័យ គណៈកម្មការ ស្ថាប័ន និងសកម្មភាពរបស់រដ្ឋម៉ាសាឈូសិត រួមទាំងសកម្មភាពរបស់មណ្ឌល និងអាជ្ញាធរដែលបង្កើតឡើងដោយសភាប្រចាំរដ្ឋម៉ាសាឈូសិត ហើយសភាខ្លួនឯង និងរួមទាំងផ្នែកពន្ធលើប្រាក់ចំណូលនៃនាយកដ្ឋានចំណូល ហើយសម្រាប់គោលបំណងបែបនេះ មន្ត្រី និងនិយោជិតនៃនាយកដ្ឋានសវនកររដ្ឋត្រូវមានសិទ្ធិចូលប្រើគណនីទាំងនោះតាមពេលវេលាសមស្រប ហើយនាយកដ្ឋាននេះអាចតម្រូវឱ្យមានការបង្កើតសៀវភៅ ឯកសារ បណ្ណទូទាត់ និងរបាយការណ៍ផ្សេងទៀត ដែលទាក់ទងនឹងបញ្ហាណាមួយក្នុងវិសាលភាពនៃសវនកម្មដែលធ្វើឡើងក្រោមផ្នែកនេះ ឬផ្នែកទី 13 លើកលែងតែការប្រកាសពន្ធ។

**របាយការណ៍មតិភាគច្រើន**

*របាយការណ៍ខាងក្រោមត្រូវបានរៀបចំឡើងដោយចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា ដែលជាគណៈកម្មាធិការសភានៃរដ្ឋម៉ាសាឈូសិត។ តាមរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិតបានកំណត់ របាយការណ៍មតិភាគច្រើននេះ ត្រូវបានបោះពុម្ពដូចខាងក្រោម។ សេចក្តីថ្លែងការណ៍នានានៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីមតិយោបល់របស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា (ហៅកាត់ថា "គណៈកម្មាធិការ") ផ្តល់អនុសាសន៍ថា ញត្តិលេខ 23-34 សភាតំណាងរាស្ត្រលេខ 4251 "ច្បាប់ដែលអនុញ្ញាតឱ្យសវនករធ្វើសវនកម្មលើអង្គនីតិប្បញ្ញត្តិ" ("ញត្តិផ្តួចផ្តើម") ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិ នៅពេលនេះទេ។

គោលបំណងនៃរបាយការណ៍នេះគឺដើម្បីផ្តល់ជាអនុសាសន៍ដល់ស្ថាប័ននីតិប្បញ្ញត្តិពេញអង្គ អំពីថាតើត្រូវទទួលយកញត្តិផ្តួចផ្តើមដូចដែលបានព្រាងសម្រាប់ការពិចារណា និងអនុម័តដែរឬទេ។

ញត្តិផ្តួចផ្តើមនានាដែលបានស្នើឡើងនឹងផ្តល់សិទ្ធិអំណាចដល់សវនករដើម្បីធ្វើសវនកម្មផ្នែកហិរញ្ញវត្ថុ និងការងាររបស់អង្គនីតិប្បញ្ញត្តិរដ្ឋ។

***សក្ខីភាព***

គណៈកម្មាធិការនេះបានឮពីអ្នកជំនាញដែលមានបទពិសោធន៍ អ្នកគាំទ្រ និងអ្នកជំទាស់ចំពោះញត្តិផ្តួចផ្តើម ក៏ដូចជាសមាជិកសាធារណជនទូទៅផងដែរ។

គណៈកម្មាធិការបានស្តាប់សក្ខីកម្មដំបូងពីអ្នកជំនាញដែលមានបទពិសោធន៍។ លោក Christopher Rogers ជាគណនេយ្យកររដ្ឋ (CPA) និងជានាយកគ្រប់គ្រងរដ្ឋាភិបាលរដ្ឋនិងរដ្ឋាភិបាលតំបន់នៅក្រុមហ៊ុនគណនេយ្យ CliftonLarsonAllen LLC បានផ្តល់សក្ខីកម្មថា ក្រុមហ៊ុនរបស់លោកធ្វើសវនកម្មព្រឹទ្ធសភានិងសភារដ្ឋម៉ាសាឈូសិត។ លោកត្រូវបានផ្តល់សក្ខីកម្មតាមពីក្រោយដោយអ្នកគ្រប់គ្រងរដ្ឋម៉ាសាឈូសិត William McNamara ដែលពន្យល់ពីទំនួលខុសត្រូវរបស់ការិយាល័យរបស់លោក រួមទាំងការគ្រប់គ្រងកម្មវិធីតម្លាភាពនៃកំណត់ត្រាហិរញ្ញវត្ថុរបស់រដ្ឋម៉ាសាឈូសិត។ បន្ទាប់មក គណៈកម្មាធិការបានស្តាប់ពីអ្នកសិក្សាធិការពីររូប។ លោក David C. King ជាសាស្ត្រាចារ្យជាន់ខ្ពស់ ផ្នែកគោលនយោបាយសាធារណៈនៅសាលារដ្ឋាភិបាល Harvard Kennedy និងលោក Jeremy Paul សាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យ Northeastern បានផ្តល់សក្ខីកម្មដែលទាក់ទងនឹងបញ្ហារដ្ឋធម្មនុញ្ញដែលត្រូវបានលើកឡើងនៅក្នុងញត្តិផ្តួចផ្តើម។

សវនករ Diana DiZoglio បានផ្តល់សក្ខីកម្មក្នុងការគាំទ្រលើញត្តិផ្តួចផ្តើម ដូចដែលក្រុមមួយដែលមានអតីតអ្នកតំណាងរាស្ត្រ Daniel Winslow, Mary Connaughton នៃវិទ្យាស្ថាន Pioneer និង Paul Craney នៃសម្ព័ន្ធសារពើពន្ធរដ្ឋម៉ាសាឈូសិត។

អតីតសវនការិនី Suzanne Bump និង Jerold J. Duquette ជាសាស្ត្រាចារ្យវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យ Central Connecticut State បានផ្តល់សក្ខីកម្មជំទាស់ទៅនឹងការធ្វើវិសោធនកម្មនេះ។

**របាយការណ៍មតិភាគច្រើន (ត)**

***សន្និដ្ឋាន***

ការកែប្រែលក្ខន្តិកៈនឹងធ្វើឱ្យខូចដល់សមតុល្យនៃអំណាចរដ្ឋធម្មនុញ្ញដែលបានគិតគូរយ៉ាងល្អរវាងស្ថាប័នរដ្ឋាភិបាល ដូចដែលបានបង្កើតឡើងដោយអ្នកធ្វើពង្រាងរដ្ឋធម្មនុញ្ញរបស់រដ្ឋម៉ាសាឈូសិត។ ដូចដែល David C. King ជាសាស្ត្រាចារ្យជាន់ខ្ពស់ ផ្នែកគោលនយោបាយសាធារណៈ នៅសាលា Harvard Kennedy និងជាប្រធានកម្មវិធីពីរគណបក្ស (Bi-Partisan Program) របស់សាលា Harvard សម្រាប់សមាជិកសភាសហរដ្ឋអាមេរិកដែលទើបជាប់ឆ្នោតថ្មី បានធ្វើសក្ខីកម្មនៅក្នុងសវនាការសាធារណៈរបស់គណៈកម្មាធិការ " . . . ខ្ញុំចង់ព្រមានអ្នកបោះឆ្នោតនិងអង្គនីតិប្បញ្ញត្តិនេះថាសភាតំណាងរាស្ត្រ 4251 គឺគ្មានប្រាជ្ញាលើសគេ. . . ការបំបែកអំណាចរដ្ឋម៉ាសាឈូសិត បានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់រដ្ឋធម្មនុញ្ញជាតិរបស់យើង។ សំណើរបស់សវនករបានធ្វើឱ្យមូលដ្ឋានគ្រឹះនេះចុះខ្សោយ។ ខ្ញុំជឿថា វាធ្ងន់ធ្ងរណាស់។ សវនកររូបនេះកំពុងស្នើឱ្យមានការផ្ទេរអំណាចដែលមិនធ្លាប់មានពីមុនពីអ្នកតំណាងរាស្ត្រទៅក្នុងស្ថាប័នប្រតិបត្តិ" វិញ។

ការិយាល័យសវនកររដ្ឋគឺជាសមាជិកនៃស្ថាប័នប្រតិបត្តិនៃរដ្ឋាភិបាលរដ្ឋម៉ាសាឈូសិត។ ទាំងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក និងរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត បង្ហាញពីការបែងចែកអំណាចក្នុងចំណោមស្ថាប័នទាំងបីនៃរដ្ឋាភិបាល ខណៈពេលដែលបង្កើតការត្រួតពិនិត្យ និងតុល្យភាពផ្សេងៗលើអំណាចទាំងនោះ។ យ៉ាងណាក៏ដោយ អ្វីដែលញត្តិផ្តួចផ្តើមនេះចង់ធ្វើគឺផ្ទេរសិទ្ធិអំណាចតាមលក្ខន្តិកៈ ដែលបានប្រគល់ជូនជាក់លាក់តាមរដ្ឋធម្មនុញ្ញក្នុងស្ថាប័ននីតិប្បញ្ញត្តិ មិនមែនឱ្យទៅអ្នកបោះឆ្នោតទេ ប៉ុន្តែឱ្យទៅស្ថាប័នប្រតិបត្តិដោយបំពានលើគោលការណ៍រដ្ឋធម្មនុញ្ញជាមូលដ្ឋាននៃការបែងចែកអំណាច។ ដូចដែល Jeremy R. Paul ជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យ Northeastern បានថ្លែងនៅក្នុងសក្ខីកម្មដែលបានដាក់ជូនគណៈកម្មាធិការ "ខ្ញុំជឿថាមានហេតុផលដ៏រឹងមាំក្នុងការសន្និដ្ឋានថា វាអាចនឹងមានការប្រើអំណាចហួសប្រមាណ ហើយដែលនាំឱ្យតុលាការរដ្ឋម៉ាសាឈូសិតមានលទ្ធភាពខ្ពស់នៅក្នុងការបង្ខំឱ្យលុបចោលលក្ខន្តិកៈដែលញត្តិផ្តួចផ្តើមបានអនុម័តដោយអនុលោមតាមបទបញ្ញត្តិច្បាប់បច្ចុប្បន្ន។"

គួរកត់សម្គាល់ដែរថា វិធានការថ្មីៗដែលចាត់ឡើងដោយសាលាដំបូង គាំទ្រដល់ការសន្និដ្ឋានដែលថា សវនកម្មទៅលើសភាប្រចាំរដ្ឋម៉ាសាឈូសិតដែលបានស្នើឡើងរបស់សវនករ នឹងបំពានលើការបែងចែកអំណាចដែលបានបង្កើតឡើងនៅក្នុងរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត។ នៅក្នុងលិខិតមួយផ្ញើទៅកាន់ការិយាល័យសវនកម្មរដ្ឋនៅថ្ងៃទី 24 ខែសីហា ឆ្នាំ 2023 តុលាការសាលាដំបូងបានសរសេរថា ខ្លួនបដិសេធមិនបន្តឆ្លើយតបទៅនឹងសំណើដែលទាក់ទងនឹងសវនកម្មរបស់ការិយាល័យគណៈចៅក្រមរបស់សាលាដំបូងឡើយ។ ទោះបីជាសាលាដំបូងគឺជាផ្នែកមួយនៃស្ថាប័នរដ្ឋាភិបាលដាច់ដោយឡែកពីសវនករ ដូចគ្នានឹងសភាប្រចាំរដ្ឋម៉ាសាឈូសិត ហើយមិនស្ថិតនៅក្រោមសិទ្ធិអំណាចរបស់សវនករយ៉ាងណាក៏ដោយ ក៏សាលាដំបូងបានយល់ព្រមលើសំណើរបស់សវនករសម្រាប់សវនកម្មទៅហើយ។ បន្ទាប់ពីសវនករបានពង្រីកវិសាលភាពនៃសវនកម្មរបស់ខ្លួនជាងកតោភាគីរួចមក ទើបសាលាដំបូងបានលុបចោលការយល់ព្រមរបស់ខ្លួន ដោយបញ្ជាក់យ៉ាងច្បាស់ថាសវនករបានប្រើសិទ្ធិអំណាចលើសរបស់ខ្លួនលើសកំណត់ ហើយបានរំលោភលើគោលការណ៍បែងចែកអំណាច។

នៅក្នុងលទ្ធិប្រជាធិបតេយ្យតំណាងរាស្ត្រ អំណាចគឺស្ថិតនៅលើអ្នកតំណាងរាស្ត្រដែលជ្រើសរើសតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា ហើយឱ្យពួកគេជាអ្នកទទួលខុសត្រូវ។ ជាជាងសម្រេចបាននូវគោលដៅដែលបានបញ្ជាក់របស់ខ្លួន ញត្តិផ្តួចផ្តើមដែលបានស្នើឡើងនឹងកំណត់អំណាចរបស់អ្នកបោះឆ្នោតដែលជ្រើសរើសសមាជិកសភាដោយពង្រីកអំណាចរបស់ស្ថាប័នប្រតិបត្តិ។ ជាការសំខាន់ សវនករនឹងដើរតួនាទីដោយខ្លួនឯងផ្ទាល់ជំនួសឱ្យប្រជាជនក្នុងការជំរុញឱ្យអង្គនីតិប្បញ្ញត្តិទទួលខុសត្រូវ។ តាមពិត សមាជិកម្នាក់នៃក្រុមដែលបានផ្តល់សក្ខីកម្មក្នុងការគាំទ្រញត្តិផ្តួចផ្តើម អតីតតំណាងរាស្ត្រ Dan Winslow បានបង្ហាញថា ប្រសិនបើញត្តិផ្តួចផ្តើមត្រូវបានអនុម័តដោយអ្នកបោះឆ្នោត វាទំនងជានឹងត្រូវបានជំទាស់ផ្អែកលើមូលដ្ឋានរដ្ឋធម្មនុញ្ញ ព្រោះតែបទបញ្ញត្តិច្បាប់នោះទូលំទូលាយពេក។ លោកបានបន្តផ្តល់យោបល់ថា អង្គនីតិប្បញ្ញត្តិគួរតែកែប្រែញត្តិផ្តួចផ្តើម ដើម្បីកុំឱ្យ "រំលោភលើមុខងារច្បាប់ស្នូល"។

ដោយសារហេតុផលទាំងនេះហើយ ទើបប្រធានផ្នែកអនុវត្តច្បាប់របស់រដ្ឋម៉ាសាឈូសិត លោកអគ្គរដ្ឋអាជ្ញា Andrea Campbell បានប្រកាសនៅក្នុងការវាយតម្លៃអំណះអំណាងរបស់សវនករអំពីសិទ្ធិអំណាចដើម្បីធ្វើសវនកម្មលើមុខងារទាំងអស់របស់អង្គនីតិប្បញ្ញត្តិនោះថា សំណើនេះ "បានលើកឡើងពីបញ្ហាបែងចែកអំណាច" និង "កង្វល់ផ្នែករដ្ឋធម្មនុញ្ញ" អំពីការជ្រៀតជ្រែកដែលមិនអាចអនុញ្ញាតបាន ឬការរំលោភលើ "អំណាចដែលផ្តល់ដល់អង្គនីតិប្បញ្ញត្តិតែមួយគត់"។

នៅក្រោមច្បាប់គ្រប់គ្រងរបស់ខ្លួន សភានិងព្រឹទ្ធសភា តម្រូវឱ្យមានការធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំដោយក្រុមហ៊ុនសវនកម្មឯករាជ្យ។ មានរបាយការណ៍សវនកម្មទាំងនេះសម្រាប់សធារណជន។

គណនីនិងកំណត់ត្រាហិរញ្ញវត្ថុរបស់អង្គនីតិប្បញ្ញត្តិមាននៅក្នុងវេទិកាតម្លាភាពរបាយការណ៍របស់រដ្ឋម៉ាសាឈូសិត ("CTHRU") ដែលគ្រប់គ្រងដោយ William McNamara ជាអ្នកត្រួតពិនិត្យរដ្ឋម៉ាសាឈូសិតបានធ្វើសក្ខីកម្មនៅក្នុងសវនាការសាធារណៈរបស់គណៈកម្មាធិការ។ CTHRU រួមបញ្ចូលព័ត៌មានលម្អិត និងគ្រប់ជ្រុងជ្រោយទាក់ទងនឹងបញ្ជីប្រាក់បៀវត្សរ៍ ការចំណាយ និងព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត រួមទាំងចំនួនទឹកប្រាក់ដែលបានបង់ទៅឱ្យអ្នកលក់របស់រដ្ឋផងដែរ។ ជាងនេះទៀត រាល់សម័យប្រជុំអង្គនីតិប្បញ្ញត្តិ និងសវនាការរបស់គណៈកម្មាធិការទាំងអស់ ត្រូវបានផ្សាយបន្តផ្ទាល់ និងថតទុក ហើយអាចរកបាននៅលើគេហទំព័ររបស់សភានៃរដ្ឋម៉ាសាឈូសិត។ លទ្ធភាពទទួលបានព័ត៌មានអំពីសេចក្តីព្រាងច្បាប់និងវិសោធនកម្មទាំងអស់ រួមទាំងការបោះឆ្នោតដោយការហៅឈ្មោះ និងទិនានុប្បវត្តិ ព្រមទាំងប្រតិទិនពីសភានិងព្រឹទ្ធសភាក៏មានតាមអនឡាញផងដែរ។

ជាផ្នែកមួយនៃសក្ខីកម្មរបស់ខ្លួនក្នុងការគាំទ្រដល់ញត្តិផ្តួចផ្តើម សវនករ DiZoglio បានផ្តល់ជូនការបង្ហាញឯកសារជារូបភាពបញ្ជាក់ ដែលគាត់បានពិពណ៌នាថាជាសវនកម្មកន្លងមក ដើម្បីអះអាងថាមានគំរូពីមុនមកសម្រាប់សវនកម្មអង្គនីតិប្បញ្ញត្តិ។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវបន្ថែមបានបង្ហាញថា សវនកម្មចំនួន 74 ក្នុងចំណោមសវនកម្មចំនួន 113 ទាំងនោះ (ភាគច្រើនមានតាំងពីសតវត្សទី 19) គឺគ្រាន់តែជារបាយការណ៍គណនេយ្យហិរញ្ញវត្ថុដែលស្រដៀងគ្នានឹងអ្វីដែលឥឡូវនេះមានជាសាធារណៈនៅលើគេហទំព័រ CTHRU របស់អ្នកត្រួតពិនិត្យ។

## សំណួរទី១ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

ចំណែកដែលនៅសល់គឺជារបាយការណ៍ហិរញ្ញវត្ថុនៃផ្នែកជាក់លាក់នៅក្នុងអង្គនីតិប្បញ្ញត្តិ។ ដូចដែលអគ្គរដ្ឋអាជ្ញា Campbell បានបញ្ជាក់ ទោះបីជាមានរបាយការណ៍ជាច្រើនរបស់សវនករលើវិធានការដាច់ដោយឡែក ឬអង្គភាពមួយចំនួននៅក្នុងស្ថាប័ននីតិប្បញ្ញត្តិក៏ដោយ ក៏មិនមាន “គំរូជាប្រវត្តិសាស្ត្រពីមុនទាល់តែសោះសម្រាប់ប្រភេទនៃសវនកម្មដែល [សវនករ] ចង់ចុះអនុវត្តនៅពេលនេះដែរ៖ គឺសវនកម្មដ៏ទូលំទូលាយនៃអង្គនីតិប្បញ្ញត្តិលើការជំទាស់របស់ខ្លួន ដែលនឹងរួមបញ្ចូលការពិនិត្យឡើងវិញនូវមុខងារនីតិប្បញ្ញត្តិស្នូលជាច្រើនរបស់ខ្លួន”។

ភាគច្រើននៃគណៈកម្មាធិការកត់សម្គាល់ថា សវនករក្នុងអំឡុងពេលយុទ្ធនាការរបស់ខ្លួន និងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ បានលើកឡើងជាញឹកញាប់អំពីការធ្វើបាបផ្នែកនយោបាយនៅក្នុងអង្គនីតិប្បញ្ញត្តិ។ Suzanne Bump អតីតសវនកររបស់រដ្ឋម៉ាសាឈូសិតបានផ្តល់សក្ខីកម្មថា ប្រធានបទត្រឹមត្រូវនៃសវនកម្មរបស់រដ្ឋាភិបាលគឺជាកម្មវិធីរបស់រដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតដោយអង្គនីតិប្បញ្ញត្តិដើម្បីបម្រើដល់គោលបំណងសាធារណៈ មិនមែនជាមុខងាររបស់ស្ថាប័ននីតិប្បញ្ញត្តិរបស់រដ្ឋាភិបាលនោះទេ។ ដូចដែល Bump បានបញ្ជាក់ ដោយសារតែរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិតអនុញ្ញាតឱ្យស្ថាប័ននីតិប្បញ្ញត្តិគ្រប់គ្រងខ្លួនឯងតាមរយៈវិធាន និងនីតិវិធីរបស់ខ្លួនផ្ទាល់ មិនមានលក្ខណៈវិនិច្ឆ័យ*ជាសត្យានុម័ត* ណាមួយដែលសវនករអាចវាយតម្លៃបានទេ។ សវនកម្មបែបនេះនឹងមានលក្ខណៈជាអត្តនោម័ត ដូច្នេះហើយគឺមិនសមស្របនឹងស្តង់ដាសវនកម្មដែលបានបង្កើតឡើងយ៉ាងល្អនោះទេ។ លើសពីនេះទៀត សវនករ DiZoglio ខ្វះភាពសត្យានុម័តដែលទាមទារឱ្យមានដើម្បីធ្វើសវនកម្មអង្គនីតិប្បញ្ញត្តិស្របតាមស្តង់ដាសវនកម្មរបស់រដ្ឋាភិបាលដែលទទួលយកជាទូទៅ (GAGAS) ដែលស្គាល់ជាទូទៅផងដែរជាសៀវភៅលឿង ដោយសារតែសេរាថ្មីៗរបស់សវនករនៅក្នុងអង្គនីតិប្បញ្ញត្តិ ក៏ដូចជាបុរេវិច្ឆ័យច្បាស់ដែលថា សវនករបានសម្តែងការប្រឆាំងជាសាធារណៈទៅនឹងអង្គនីតិប្បញ្ញត្តិ។

សម្រាប់ហេតុផលទាំងនេះ យើងខ្ញុំ ដែលជាសមាជិកភាគច្រើននៃគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា សូមផ្តល់អនុសាសន៍ថា “ច្បាប់អនុញ្ញាតឱ្យសវនករធ្វើសវនកម្មលើអង្គនីតិប្បញ្ញត្តិ” (សូមមើលសភាតំណាងរាស្ត្រលេខ 4251) ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះទេ។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Paul R. Feeney | Michael S. Day |
| Jason M. Lewis | Kenneth I. Gordon |

# 2

## សំណួរទី២ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# *ការលុបបំបាត់ MCAS ជាលក្ខខណ្ឌប្រឡងបញ្ចប់ថ្នាក់វិទ្យាល័យ*

*តើលោកអ្នកយល់ស្របតាមច្បាប់ដែលបានសង្ខេបខាងក្រោមទេ ដែលចែងថាគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយសមាជិកព្រឹទ្ធសភា ឬសភាតំណាងរាស្រ្តឡើយ នៅមុនថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៤?*

---

**សេចក្តីសង្ខេប ▶**
តាមច្បាប់តម្រូវ សេចក្តីសង្ខេបគឺសរសេរឡើងដោយអគ្គរដ្ឋអាជ្ញា។

សេចក្តីស្នើច្បាប់នេះនឹងលុបបំបាត់នូវលក្ខខណ្ឌដែលតម្រូវអោយសិស្សប្រឡងជាប់ការវាយតម្លៃគ្រប់ជ្រុងជ្រោយនៃរដ្ឋម៉ាសាឈូសេត (MCAS) (ឬការវាយតម្លៃនៅទូទាំងរដ្ឋ ឬទូទាំងសង្កាត់ផ្សេងៗ) សម្រាប់មុខវិជ្ជាគណិតវិទ្យា, វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា និង ភាសាអង់គ្លេស ដើម្បីទទួលបានសញ្ញាបត្រវិទ្យាល័យ។ ជាជំនួសវិញ ដើម្បីអោយសិស្សទទួលបានសញ្ញាបត្រវិទ្យាល័យ ច្បាប់ដែលគេបានស្នើឡើងមកនេះនឹងតម្រូវអោយសិស្សបញ្ចប់វគ្គសិក្សាដែលបញ្ជាក់ទទួលស្គាល់ដោយមណ្ឌលសិក្សារបស់សិស្សនៅតាមសង្កាត់ថាមានកម្រិតសមត្ថភាពត្រូវតាមស្តង់ដាសិក្សារបស់រដ្ឋ សម្រាប់មុខវិជ្ជាគណិតវិទ្យា, វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា និង ភាសាអង់គ្លេស ក៏ដូចជាមុខវិជ្ជាបន្ថែមទាំងឡាយដែលបានកំណត់ដោយក្រុមប្រឹក្សាអប់រំកម្រិតបឋមសិក្សា និង មធ្យមសិក្សា។

---

**ឥទ្ធិពល ពីការបោះឆ្នោតរបស់អ្នក ▶**
តាមរយៈការតម្រូវដោយច្បាប់ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត “គាំទ្រ” និងការបោះឆ្នោត “ជំទាស់” ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងលុបចោលនូវលក្ខខណ្ឌដែលតម្រូវអោយសិស្សប្រឡងជាប់ការវាយតម្លៃគ្រប់ជ្រុងជ្រោយនៃរដ្ឋម៉ាសាឈូសេត (MCAS) ដើម្បីបានបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យ ប៉ុន្តែនៅតែតម្រូវអោយសិស្សបំពេញវគ្គសិក្សាតាមស្តង់ដារបស់រដ្ឋ។

***ការបោះឆ្នោតជំទាស់*** នឹងមិនធ្វើអោយមានការកែប្រែក្នុងច្បាប់ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវអោយសិស្សប្រឡងជាប់ MCAS ដើម្បីបានបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យឡើយ ។

---

**របាយការណ៍ នៃការប៉ះពាល់ លើសារពើពន្ធ ▶**
តាមច្បាប់កំណត់ របាយការណ៍ផលប៉ះពាល់សារពើពន្ធត្រូវសរសេរដោយក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ។

សំណើច្បាប់នេះ ពុំអាចដឹងពីផលប៉ះពាល់សារពើពន្ធជាសារវន្តចំពោះហិរញ្ញវត្ថុរដ្ឋ និងហិរញ្ញវត្ថុរដ្ឋាភិបាលក្រុងឡើយ។

---

**ទឡ្ហីករណ៍ ▶**
ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវសរសេរដោយអ្នកគាំទ្រ និងអ្នកបដិសេធលើសំណួរនីមួយៗ និងឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។ **រដ្ឋម៉ាសាឈូសិតពុំបានគាំទ្រចំពោះទឡ្ហីករណ៍ទាំងនេះទេ ហើយក៏មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃសេចក្តីថ្លែងការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះរបស់បុគ្គល និងស្ថាប័នដែលបានសរសេរសេចក្តីថ្លែងការណ៍នីមួយៗ និងមតិយោបល់ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃផ្សេងទៀតអំពីសេចក្តីថ្លែងការណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***បោះឆ្នោតគាំទ្រ៖*** ការបោះឆ្នោតគាំទ្រចំពោះសំណួរទី 2 ផ្តល់ឱ្យសិស្សទាំងអស់នូវឱកាសដើម្បីរីកចម្រើន និងឈានដល់សក្តានុពលពេញលេញរបស់ពួកគេ។ យើងទាំងអស់គ្នាយល់ស្របថា ស្តង់ដាខ្ពស់ជួយរក្សាឧត្តមភាពសាលារដ្ឋរបស់យើង ហើយការវាយតម្លៃគឺចាំបាច់ដើម្បីធានាថា សិស្សរៀនសូត្រចំណេះដឹងនិងជំនាញដើម្បីជោគជ័យក្នុងជីវិតបន្ទាប់ពីមធ្យមសិក្សា។ ទោះជាយ៉ាងណាក៏ដោយ MCAS គឺជាការប្រឡងគម្រូស្តង់ដាតែមួយសម្រាប់សិស្សទាំងអស់ (one-size-fits-all exam) ដែលមិនបានវាស់វែងលទ្ធផលសម្រេចបានរបស់សិស្សផ្សេងទៀតដូចជា ពិន្ទុមធ្យមភាគ (GPA) វគ្គសិក្សា និងការវាយតម្លៃរបស់គ្រូក្នុងការកំណត់ថាតើសិស្សត្រូវបានអនុញ្ញាតឱ្យបញ្ចប់ការសិក្សាដែរឬអត់។ ការជំនួសលក្ខខណ្ឌប្រឡងបញ្ចប់ការសិក្សាតាមប្រព័ន្ធ MCAS ដោយវាស់វែងគ្រប់ជ្រុងជ្រោយបន្ថែមទៀត នឹងអនុញ្ញាតឱ្យគ្រូបង្រៀនបញ្ឈប់ការបង្រៀនសម្រាប់តែការប្រឡង ហើយមិនដាក់បន្ទុកដល់សិស្សពីការធ្វើតេស្តស្តង់ដាប្រឡងសម្រេចជាប់ធ្លាក់ (make-or-break) នោះឡើយ។ ការបោះឆ្នោតគាំទ្រនឹងអនុញ្ញាតឱ្យសាលារៀននិងគ្រូបង្រៀន ធ្វើការជាមួយឪពុកម្តាយនិងសិស្ស ដើម្បីផ្តោតលើជំនាញ និងចំណេះដឹងសំខាន់បំផុត ដើម្បីជួយសិស្សឱ្យ

***បោះឆ្នោតជំទាស់៖*** បោះឆ្នោតជំទាស់

**សំណួរទី 2 គឺអយុត្តិធម៌ចំពោះកុមារ ហើយនឹងបង្កើនវិសមភាព។** មណ្ឌលសិក្សាធិការមួយចំនួននឹងប្រកាន់យកស្តង់ដាទាបជាង ដើម្បីឱ្យសិស្ស "បញ្ចប់ការសិក្សា" ទោះបីជាពួកគេមិនបានរៀនសូត្រចំណេះដឹងនិងជំនាញដែលពួកគេត្រូវការដើម្បីបានជោគជ័យក៏ដោយ។

**វាមិនយុត្តិធម៌ទេក្នុងការផ្តល់វិញ្ញាបនបត្រដល់កុមារដែលមិនទាន់បានត្រៀមខ្លួនបញ្ចប់ការសិក្សា។** ប្រសិនបើសិស្សមិនអាចឆ្លងកាត់ការវាយតម្លៃជាមូលដ្ឋានអំពីគណិតវិទ្យា ភាសាអង់គ្លេស ឬវិទ្យាសាស្ត្រទេ ពួកយើងជាមនុស្សពេញវ័យគួរតែខិតខំធ្វើយ៉ាងណាឱ្យពួកគេទទួលបានកម្រិតយល់ដឹងចាំបាច់អំពីមុខវិជ្ជាទាំងនេះ។ ជំនួសឱ្យការគាំទ្រដល់កុមារ **សំណួរទី 2 នឹងបោះបង់ពួកគេចោល។**

**សំណួរទី 2 នឹងដកចេញនូវស្តង់ដាបញ្ចប់ការសិក្សាតែមួយគត់ក្នុងរដ្ឋរបស់យើង។** រដ្ឋម៉ាសាឈូសិត នឹងមានលក្ខខណ្ឌបញ្ចប់ថ្នាក់វិទ្យាល័យមិនសូវតឹងរ៉ឹងជាងរដ្ឋ Mississippi និងរដ្ឋ Alabama។

**សំណួរទី 2 គឺជាសំណើបែបរ៉ាឌីកាល់ និងមិនបានសាកល្បង ហើយគួរតែត្រូវបានបដិសេធ។** ការផ្លាស់ប្តូរសំខាន់ៗចំពោះប្រព័ន្ធអប់រំរបស់

**ទឡ្ហីករណ៍ (ត)** ▶ មានជោគជ័យក្នុងជីវិត ជាជាងការកំណត់ឱ្យផ្តោតលើជំនាញដែលអាចវាស់វែងដោយការធ្វើតេស្តស្តង់ដាណាមួយ។

**Shelley Scruggs**
**ឪពុក/ម្តាយស្ម័គ្រចិត្ត**
**សមាគមគ្រូបង្រៀនរដ្ឋម៉ាសាឈូសិត (MTA)**
**2 Heritage Drive, 8th Floor**
**Quincy, MA 02171-2119**
**617-878-8000**

យើងគួរតែត្រូវបានសិក្សា រៀបចំ និងអនុវត្តដោយអ្នកជំនាញ ដើម្បីធានាថាគោលនយោបាយទាំងនេះពិតជាល្អប្រសើរសម្រាប់កូនៗរបស់យើង។

**បោះឆ្នោតជំទាស់ចំពោះសំណួរទី 2**

**ការពារអនាគតរបស់កូនយើង៖ សូមបោះឆ្នោតជំទាស់លើសេចក្តីស្នើទី 2**
**P.O. Box 130041**
**Boston, MA 02113**
**www.protectourkidsfuture.com**

### អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ

ត្រូវអនុម័តដោយប្រជាជន និងតាមសិទ្ធិអំណាចរបស់ពួកគេ៖

ច្បាប់ដែលតម្រូវឱ្យមណ្ឌលសិក្សាធិការផ្តល់វិញ្ញាបនបត្របញ្ជាក់ថា សិស្សបានទទួលជំនាញ សមត្ថភាព និងចំណេះដឹងតាមស្តង់ដាររដ្ឋ ជាជំនួសឱ្យលក្ខខណ្ឌការបញ្ចប់ការសិក្សារបស់ MCAS ។

ផ្នែកទី 1 D ក្នុងជំពូកទី 69 នៃច្បាប់ទូទៅ ដូចដែលមាននៅក្នុងអត្ថបទបោះពុម្ពជាផ្លូវការឆ្នាំ 2022 តាមរយៈនេះ ត្រូវបានកែសម្រួលដោយដកចេញពីប្រយោគទីមួយនៃកថាខណ្ឌរង (i) នូវពាក្យ "ដូចដែលបានវាស់វែងដោយឧបករណ៍វាយតម្លៃដែលបានពិពណ៌នានៅក្នុងផ្នែកទីមួយ I ។" ហើយជំនួសពាក្យទាំងនេះដោយពាក្យដូចខាងក្រោម៖ "ដោយការបំពេញគ្រប់លក្ខខណ្ឌរបស់វគ្គសិក្សាដែលត្រូវបានបញ្ជាក់ដោយមណ្ឌលសិក្សាធិការរបស់សិស្សថាទទួលបានជំនាញ សមត្ថភាព និងចំណេះដឹងដែលមាននៅក្នុងស្តង់ដាសិក្សារបស់រដ្ឋ និងក្របខណ្ឌកម្មវិធីសិក្សាក្នុងមុខវិជ្ជាដែលវាស់វែងដោយការធ្វើតេស្តកម្រិតវិទ្យាល័យ MCAS ដែលបានពិពណ៌នានៅក្នុងផ្នែកទីមួយ I ដែលបានធ្វើឡើងនៅក្នុងឆ្នាំ 2023 និងនៅក្នុងមុខវិជ្ជាបន្ថែមណាមួយដែលកំណត់ដោយក្រុមប្រឹក្សា។"

### របាយការណ៍មតិភាគច្រើន

*របាយការណ៍ខាងក្រោមត្រូវបានរៀបចំឡើងដោយចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា ដែលជាគណៈកម្មាធិការសភានៃរដ្ឋម៉ាសាឈូសិត។ តាមរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិតបានកំណត់ របាយការណ៍មតិភាគច្រើននេះ ត្រូវបានបោះពុម្ពដូចខាងក្រោម។ សេចក្តីថ្លែងការណ៍នានានៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីមតិយោបល់របស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា (ហៅកាត់ថា "គណៈកម្មាធិការ") ផ្តល់អនុសាសន៍ថា ញត្តិលេខ 23-36 សភាតំណាងរាស្ត្រលេខ 4252 "ច្បាប់ដែលតម្រូវឱ្យមណ្ឌលសិក្សាធិការត្រូវបញ្ជាក់ថាសិស្សមានទទួលបានជំនាញ សមត្ថភាព និងចំណេះដឹងតាមស្តង់ដាររដ្ឋ ជំនួសឱ្យលក្ខខណ្ឌបញ្ចប់ការសិក្សារបស់ MCAS" ("ញត្តិផ្តួចផ្តើម") ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះទេ។

គោលបំណងនៃរបាយការណ៍នេះគឺដើម្បីផ្តល់អនុសាសន៍មួយដល់ស្ថាប័ននីតិប្បញ្ញត្តិពេញអង្គថាតើត្រូវទទួលយកញត្តិផ្តួចផ្តើមដូចដែលបានសរសេរសម្រាប់ការពិចារណា និងអនុម័តនោះដែរឬទេ។

ញត្តិផ្តួចផ្តើមដែលបានស្នើ នឹងធ្វើវិសោធនកម្មផ្នែកទី 1D ក្នុងជំពូកទី 69 នៃច្បាប់ទូទៅ ដោយលុបបំបាត់ការកំណត់សមត្ថភាពទូទាំងរដ្ឋដែលមានស្តង់ដារួមតែមួយដែលកំណត់ដោយក្រុមប្រឹក្សាអប់រំផ្នែកបឋមសិក្សានិងមធ្យមសិក្សា ហើយជំនួសវាដោយលក្ខខណ្ឌសមត្ថភាពដែលបង្កើតឡើងដោយមណ្ឌលសិក្សាធិការនីមួយៗក្នុងចំណោមមណ្ឌលសិក្សាធិការជាង 300 នៅក្នុងរដ្ឋម៉ាសាឈូសិត។

#### *សក្ខីភាព*

គណៈកម្មាធិការបានស្តាប់ពីអ្នកជំនាញដែលមានបទពិសោធន៍ អ្នកគាំទ្រ និងអ្នកជំទាស់ញត្តិផ្តួចផ្តើម ក៏ដូចជាសមាជិកនៃសាធារណជនទូទៅដែរ។

អ្នកជំនាញ Robert Curtin ជាប្រធានមន្ត្រីទទួលបន្ទុកទិន្នន័យ ការវាយតម្លៃ និងគណនេយ្យភាពនៃនាយកដ្ឋានអប់រំបឋមសិក្សា និងមធ្យមសិក្សារដ្ឋម៉ាសាឈូសិត ("DESE") បានផ្តល់សក្ខីកម្មថា ភាគច្រើនលើសលប់នៃសិស្សវិទ្យាល័យអាចបញ្ចប់ការសិក្សាដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ចសង្គម ប្រវត្តិជាតិពន្ធុ/ពូជសាសន៍ ឬស្ថានភាពពិការរបស់ពួកគេឡើយ។ អនុក្រុមទាំងអស់នេះបានបញ្ចប់ការសិក្សាក្នុងអត្រាលើសពី 90 ភាគរយ លើកលែងតែអ្នកដែលមានបញ្ហាផ្នែកសតិបញ្ញាខ្លាំង។ លោក Curtin បានផ្តល់សក្ខីកម្មបន្ថែមទៀតថា 99 ភាគរយនៃសិស្ស អាចបញ្ចប់ការសិក្សាដោយឆ្លងកាត់ប្រព័ន្ធវាយតម្លៃគ្រប់ជ្រុងជ្រោយរបស់រដ្ឋម៉ាសាឈូសិត ("MCAS") ថ្នាក់ទី 10 ឬពុំនោះទេត្រូវបន្តស្វែងរកជម្រើសជំនួសដែលមានសម្រាប់ពួកគេ។ យោងតាមទិន្នន័យអំពីសិស្សដែលបានប្រឡងបញ្ចប់ថ្នាក់វិទ្យាល័យ ឆ្នាំ 2019 សិស្សដែលបញ្ចប់ការសិក្សាចុងក្រោយដែលមិនរងផលប៉ះពាល់ដោយ COVID-19 ក្នុងចំណោមសិស្សវិទ្យាល័យចំនួន 70,000 នៅទូទាំងរដ្ឋ 700 បានខកខានមិនបានបញ្ចប់ការសិក្សាដោយសារតែពួកគេមិនបានបំពេញតាមលក្ខខណ្ឌ ហើយនៅក្នុងទីក្រុង Boston ដែលជាទីក្រុងធំបំផុតនៅក្នុងរដ្ឋដែលមានភាគរយខ្ពស់នៃសិស្សដែលមានប្រាក់ចំណូលទាប និងសិស្សក្នុងក្រុមជាតិពន្ធុ មានតែ 7 នាក់ប៉ុណ្ណោះក្នុងចំណោមសិស្សទាំងនោះដែលមិនបានបញ្ចប់ការសិក្សាដោយសារហេតុផលនេះ។ ជាង 88 ភាគរយនៃសិស្សថ្នាក់ទី 12 ប្រឡងបញ្ចប់ការសិក្សាឆ្នាំ 2019 ទទួលបានពិន្ទុ "ជាប់" លើការធ្វើតេស្ត MCAS ថ្នាក់ទី 10 ។ លោក Curtin បានពន្យល់លម្អិតអំពីមតិយោបល់ពីមុន ដោយពន្យល់ថា អ្នកដែលមិនទទួលបានពិន្ទុនោះ នៅពេលសាកល្បងលើកដំបូង អាចបន្តមានជម្រើសជាច្រើន ដើម្បីបង្ហាញថាពួកគេបានទទួលចំណេះដឹងនិងជំនាញចាំបាច់។ សិស្សអាចប្រឡងឡើងវិញបានរហូតដល់ពួកគេសម្រេចបានពិន្ទុប្រឡងជាប់ ពួកគេអាចដាក់ពាក្យ "ប្តឹងតវ៉ាលើលទ្ធផលសិក្សា/ក្នុងជំនាន់ (Performance/Cohort Appeal)" ដោយបង្ហាញដល់នាយកដ្ឋាន DESE ថាការសិក្សាក្នុងថ្នាក់របស់ពួកគេគឺស្មើនឹងសិស្សក្នុងថ្នាក់របស់ពួកគេដែលបានប្រឡងជាប់ ឬពួកគេអាចបញ្ចប់ផែនការជំនាញអប់រំដែលបង្កើតឡើងដោយមណ្ឌលសិក្សាធិការក្នុងតំបន់ ប្រសិនបើពិន្ទុ MCAS របស់ពួកគេទាបជាងពិន្ទុជាប់បន្តិច។ ដោយសារតែមានវិធីច្រើនយ៉ាងទាំងនេះ លោក Curtin បានផ្តល់សក្ខីកម្មថា

**របាយការណ៍មតិភាគច្រើន (ត)**

ជាមធ្យម សិស្សវិទ្យាល័យតិចជាង 1 ភាគរយមិនបានបញ្ចប់ការសិក្សាដោយសារតែពួកគេមិនបានបំពេញតាមលក្ខខណ្ឌបញ្ចប់ការសិក្សាតែម្យ៉ាងនោះទេ។

អ្នកជំនាញផ្សេងទៀតបានផ្តល់សក្ខីកម្មពីទស្សនៈយល់ឃើញរបស់តួនាទីអ្នកដឹកនាំផ្នែកអប់រំ។ Paul Reville ដែលជាសាស្ត្រាចារ្យប្រតិបត្តិគោលនយោបាយអប់រំ និងការគ្រប់គ្រង Francis Keppel នៅសាលាអប់រំ Harvard Graduate School និងជាអតីតរដ្ឋមន្ត្រីក្រសួងអប់រំរដ្ឋម៉ាសាឈូសិត បានផ្តល់មតិថា ការអនុម័តលើញត្តិផ្តួចផ្តើមនានា "នឹងនាំទៅរកយុគសម័យថ្មីនៃស្តង់ដាមិនស្របគ្នា ហើយធ្វើឱ្យខូចដល់កំណែទម្រង់អប់រំជាច្រើនទសវត្សរ៍មកហើយនេះ។" Stephen Zrike បច្ចុប្បន្នជានាយកសាលា Salem Public Schools និងជាអតីតនាយកសាលា Holyoke Pulic Schools បានផ្តល់សក្ខីកម្មថា ការតម្រូវឱ្យសិស្សបំពេញតាមលក្ខខណ្ឌសមត្ថភាពរបស់ក្រុមប្រឹក្សាអប់រំផ្នែកបឋមសិក្សា និងមធ្យមសិក្សា ("BESE") គឺជាការរៀបចំដ៏ល្អសម្រាប់ពិភពលោកលើសពីកម្រិតវិទ្យាល័យដែលសិស្សបញ្ចប់ការសិក្សារំពឹងថានឹងត្រូវអនុវត្តដើម្បីឈានទៅមុខក្នុងវិស័យដែលពួកគេបានជ្រើសរើស។

ក្រុមអ្នកគាំទ្រ រួមទាំងប្រធាននិងអនុប្រធានសមាគមគ្រូបង្រៀនរដ្ឋម៉ាសាឈូសិត ("MTA") Max Page និង Deb McCarthy ដែលពួកគេនីមួយៗសុទ្ធតែជាអ្នកអប់រំបច្ចុប្បន្ន និងជានិស្សិតមហាវិទ្យាល័យ បានផ្តល់សក្ខីកម្មថា លក្ខខណ្ឌបញ្ចប់ការសិក្សា "បង្កើតបរិយាកាសថ្នាក់រៀនដែលពោរពេញទៅដោយភាពធុញថប់ និងការតប់ប្រមល់" រហូតដល់ការបំផ្លាញ "សេចក្តីរំភើបនឹងការរៀនសូត្រ"។ ក្រុមនោះបានផ្តល់សក្ខីកម្មបន្ថែមថា លក្ខខណ្ឌបញ្ចប់ការសិក្សា "បានធ្វើឱ្យប៉ះពាល់ដល់សិស្សានុសិស្សភាគច្រើនបំផុតរបស់យើង ជាពិសេសសិស្សក្រុមជាតិពន្ធ សិស្សភាសាអង់គ្លេស សិស្សដែលមានប្រាក់ចំណូលទាប និងសិស្សពិការរបស់យើង"។ Rebecca Pringle ជាប្រធានសមាគមអប់រំជាតិ បានផ្តល់សក្ខីកម្មថា ពិន្ទុ MCAS មិនមែនជារង្វាស់ត្រឹមត្រូវ ពេញលេញ ឬយុត្តិធម៌ចំពោះលទ្ធផលសម្រេចរបស់សិស្សឡើយ ហើយការវាស់ស្ទង់លទ្ធផលសម្រេច គួរផ្តោតលើវិធីសាស្ត្ររួមដើម្បីកំណត់ពីចំណុចខ្លាំង និងផែនការសម្រាប់ការលូតលាស់របស់សិស្ស។ អ្នកនាង Pringle បានសង្កត់ធ្ងន់ថា ដោយសារសិស្សមិនមានលក្ខណៈស្តង់ដាក្នុងបែបបទនៃការសិក្សារបស់ពួកគេ ការធ្វើតេស្តស្តង់ដាមិនផ្តល់រូបភាពពេញលេញលើសមត្ថភាពដោះស្រាយបញ្ហា និងសមត្ថភាពក្នុងការគិតស៊ីជម្រៅរបស់សិស្សនោះទេ។

អ្នកជំទាស់ទៅនឹងញត្តិផ្តួចផ្តើមបានជំទាស់នឹងសក្ខីកម្មរបស់អ្នកគាំទ្រ ដោយកត់សម្គាល់ថា នៅពេលដែលសិស្សមានការរីកចម្រើននៅកម្រិតថ្នាក់វិទ្យាល័យ និងលើសពីនេះ ពួកគេត្រូវបានរំពឹងថានឹងបង្ហាញចំណេះដឹង និងជំនាញរបស់ពួកគេតាមរយៈការវាយតម្លៃផ្សេងៗដែលមានឥទ្ធិពលយ៉ាងខ្លាំង។ ពួកគេក៏បានរក្សាជំហរដែរថា ការលុបបំបាត់លក្ខខណ្ឌបញ្ចប់ការសិក្សានឹងនាំឱ្យមានវិសមភាពច្រើន មិនតិចនោះទេ។ Jeff Howard ជាអតីតសមាជិក BESE រដ្ឋ និងជាស្ថាបនិក និងជាប្រធានវិទ្យាស្ថាន Efficacy បានផ្តល់សក្ខីកម្មថា "ស្តង់ដាជំនាញគឺជាមធ្យោបាយសម្រាប់ការលើកកម្ពស់សមភាពសង្គម និងសេដ្ឋកិច្ច.... 'បង្ហាញពីជំនាញទាំងនេះ ហើយអ្នកនឹងមានការត្រៀមខ្លួនដើម្បីប្រឈមមុខនឹងបញ្ហាប្រឈមនានាក្នុងពិភពលោក"។ លោកក៏បានបញ្ជាក់ផងដែរថា "លក្ខខណ្ឌបញ្ចប់ការសិក្សារបស់ MCAS គឺជាការណែនាំឱ្យស្គាល់ [ពិភព] នៃការទទួលបានវិញ្ញាបនបត្រ និងទំនួលខុសត្រូវដែលសិស្សរបស់យើងទាំងអស់នឹងត្រូវមានបន្ទាប់ពីវិទ្យាល័យ"។ Jill Norton ជាឪពុកសិស្សដែលមានតម្រូវការពិសេស និងជាអ្នកប្រឹក្សាផ្នែកអប់រំ បាននិយាយគាំទ្រការរក្សាលក្ខខណ្ឌបញ្ចប់ការសិក្សាបច្ចុប្បន្ន ដើម្បីកុំឱ្យសាលារៀនដើរថយក្រោយរហូតដល់ពេលមួយដែលសិស្សមានតម្រូវការពិសេស បានបញ្ចប់ការសិក្សាដោយមិនអាចបំពេញតាមស្តង់ដាជាមូលដ្ឋាន។

***សន្និដ្ឋាន***

ច្បាប់កំណែទម្រង់ការអប់រំឆ្នាំ 1993 បានបង្កើតប្រព័ន្ធបច្ចុប្បន្នសម្រាប់ការអប់រំកម្រិត K-12 នៅក្នុងសហគមន៍រដ្ឋម៉ាសាឈូសិត រួមទាំងលក្ខខណ្ឌបញ្ចប់ការសិក្សាស្តង់ដារួមតែមួយ។ មុនពេលអនុវត្តច្បាប់នោះ រដ្ឋម៉ាសាឈូសិតមិនមានស្តង់ដាកម្មវិធីសិក្សាទូទាំងរដ្ឋទេ មណ្ឌលសិក្សាធិការតាមតំបន់នីមួយៗកំណត់លក្ខខណ្ឌបញ្ចប់ការសិក្សារបស់ពួកគេ ហើយគុណភាពនៃការអប់រំកម្រិត K-12 មានការប្រែប្រួលយ៉ាងខ្លាំងពីមណ្ឌលមួយទៅមណ្ឌលមួយទូទាំងរដ្ឋ។

ច្បាប់នេះតម្រូវឱ្យមានការបង្កើនថវិការដ្ឋយ៉ាងច្រើនដល់មណ្ឌលសិក្សាធិការក្នុងតំបន់ ដើម្បីគាំទ្រដល់ការអនុវត្តស្តង់ដានេះ ក៏ដូចជាប្រព័ន្ធវាយតម្លៃ MCAS រួមតែមួយដែលត្រូវបានបង្កើតឡើងដើម្បីវាស់វែងវឌ្ឍនភាពឆ្ពោះទៅរកគោលដៅនៃលទ្ធផលល្អប្រសើរសម្រាប់សិស្សទាំងអស់។ ថ្មីៗនេះ អង្គនីតិប្បញ្ញត្តិបានបង្កើនថវិកាយ៉ាងច្រើនដោយការផ្តោតគោលដៅបន្ថែមទៀតលើសមធម៌តាមរយៈច្បាប់ស្តីពីការផ្តល់ឱកាសដល់សិស្ស (Student Opportunity Act)។

ញត្តិផ្តួចផ្តើមនេះ លុបបំបាត់លក្ខខណ្ឌបញ្ចប់ការសិក្សារួមតែមួយ ដោយមិនបង្កើតជម្រើសរួមតែមួយនោះឡើយ។ ផ្អែកលើសក្ខីកម្មដែលបានបង្ហាញ មានការព្រួយបារម្ភជាសំខាន់អំពីកង្វះស្តង់ដាមួយដែលជាការវាយតម្លៃទូទាំងរដ្ឋ។ ទាំងអ្នកដឹកនាំផ្នែកអប់រំ និងអ្នកជំទាស់នឹងញត្តិផ្តួចផ្តើម បានទទួលស្គាល់អំពីតម្រូវការក្នុងការធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធបច្ចុប្បន្ន ដើម្បីឱ្យសិស្សដែលមិនសម្រេចបាននូវកម្រិតចំណេះដឹង និងជំនាញអប្បបរមាដែលត្រូវការដើម្បីបញ្ចប់ការសិក្សា ទទួលបានការគាំទ្រដែលពួកគេត្រូវការជាចាំបាច់ ក្នុងការបំពេញតាមតម្រូវការជាមូលដ្ឋានទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ការលុបបំបាត់លក្ខខណ្ឌបញ្ចប់ការសិក្សារួមតែមួយ ដែលនឹងអនុញ្ញាតឱ្យសិស្សបញ្ចប់ការសិក្សាដែលមិនបំពេញតាមស្តង់ដាជាមូលដ្ឋាន ដោយមិនមានចំណុចគោលជាស្តង់ដានិងជាប់លាប់សមស្រប ដើម្បីធានាថា ស្តង់ដាទាំងនោះត្រូវបានបំពេញនឹងមិនធ្វើឱ្យលទ្ធផលសិស្សកាន់តែប្រសើរឡើងនោះទេ និងធ្វើឱ្យមានហានិភ័យប្រឈមនឹងភាពមិនស៊ីចង្វាក់គ្នា និងវិសមភាពក្នុងការបង្រៀននិងរៀននៅទូទាំងមណ្ឌលសិក្សាធិការកាន់តែខ្លាំង។

សម្រាប់ហេតុផលទាំងនេះ យើងខ្ញុំ ដែលជាសមាជិកភាគច្រើននៃគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើម សូមផ្តល់អនុសាសន៍ថា "ច្បាប់ដែលតម្រូវឱ្យមណ្ឌលសិក្សាធិការបញ្ជាក់ថា សិស្សបានទទួលជំនាញ សមត្ថភាព និងចំណេះដឹងតាមស្តង់ដារដ្ឋ ជំនួសឱ្យលក្ខខណ្ឌបញ្ចប់ការសិក្សារបស់ MCAS" (សូមមើលសភាតំណាងរាស្ត្រ លេខ 4252) ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះទេ។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Paul R. Feeney | Michael S. Day |
| Ryan C. Fattman | Kenneth I. Gordon |
| | David T. Vieira |

# 3

## សំណួរទី៣ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# *ការចូលសហជីពសម្រាប់អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន*

*តើលោកអ្នកយល់ស្របតាមច្បាប់ដែលបានសង្ខេបខាងក្រោមទេ ដែលចែងថាគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយសមាជិកព្រឹទ្ធសភា ឬសភាតំណាងរាស្ត្រឡើយ នៅមុនថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៤?*

**សេចក្តីសង្ខេប** ▶
តាមច្បាប់តម្រូវ សេចក្តីសង្ខេបគឺសរសេរឡើងដោយអគ្គរដ្ឋអាជ្ញា។

សេចក្តីស្នើច្បាប់នេះនឹងផ្តល់អោយអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន (ហៅកាត់ថា "អ្នកបើកបរ") នូវសិទ្ធិបង្កើតសហជីព ("សហជីពអ្នកបើកបរ") ដើម្បីចរចារួមគ្នាជាមួយបណ្តាញក្រុមហ៊ុនដឹកជញ្ជូន (ហៅកាត់ថា "ក្រុមហ៊ុន") ដែលជាក្រុមហ៊ុនប្រើបណ្តាញអ៊ីនធឺណិត(ឌីជីថល) ដើម្បីភ្ជាប់អ្នកជិះទៅកាន់អ្នកបើកបរ សម្រាប់ការដឹកជញ្ជូនដែលបានរៀបចំទុកមុន ដើម្បីចងក្រងនូវអនុសាសន៍ដែលបានចរចាហើយទាក់ទងនឹងប្រាក់ឈ្នួល, អត្ថប្រយោជន៍ និង លក្ខខណ្ឌផ្សេងៗនៃការងារ។ គេមិនតម្រូវអោយអ្នកបើកបរចូលរួមក្នុងសកម្មភាពសហជីពណាមួយឡើយ។ គេនឹងអនុញ្ញាតអោយក្រុមហ៊ុនបង្កើតសមាគមដែលមានក្រុមហ៊ុនច្រើនចូលរួម ដើម្បីតំណាងអោយអ្នកបើកបរទាំងនោះ នៅពេលចរចាជាមួយសហជីពអ្នកបើកបរ។ រដ្ឋនឹងពិនិត្យមើលសកម្មភាពការងារ តាមការអនុញ្ញាតនៃសេចក្តីស្នើច្បាប់នេះ និង ទទួលខុសត្រូវក្នុងការសម្រេចយល់ព្រម ឬមិនយល់ព្រមលើអនុសាសន៍ដែលបានចរចាហើយនោះ។

សេចក្តីស្នើច្បាប់នេះនឹងកំណត់សកម្មភាពជាក់លាក់មួយចំនួនរបស់ក្រុមហ៊ុន ឬសហជីពអ្នកបើកបរ ដើម្បីអោយមានយុត្តិធម៌ក្នុងការអនុវត្ត។ សេចក្តីស្នើច្បាប់នេះនឹងបង្កើតអោយមានដំណើរការសវនាការមួយសម្រាប់អោយក្រុមប្រឹក្សាទំនាក់ទំនងការងាររដ្ឋ (ហៅកាត់ថា "ក្រុមប្រឹក្សា") អនុវត្តតាម នៅពេលដែលក្រុមហ៊ុន ឬសហជីពអ្នកបើកបរណាមួយត្រូវបានចោទប្រកាន់ពីបទអនុវត្តន៍ការងារមិនត្រឹមត្រូវ។ សេចក្តីស្នើច្បាប់នេះនឹងអនុញ្ញាតអោយក្រុមប្រឹក្សានេះចាត់វិធានការ រួមទាំងផ្តល់សំណងដល់អ្នកបើកបរដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ បើគេរកឃើញថាបានអនុវត្តការងារមិនត្រឹមត្រូវ។ សេចក្តីស្នើច្បាប់នេះអនុញ្ញាតអោយមានបណ្តឹងឧទ្ធរណ៍ចំពោះការសម្រេចរបស់ក្រុមប្រឹក្សានេះទៅតុលាការឧទ្ធរណ៍ប្រចាំរដ្ឋ។

សេចក្តីស្នើច្បាប់នេះក៏នឹងបង្កើតអោយមាននីតិវិធីមួយដើម្បីកំណត់ថាតើអ្នកបើកបរណាខ្លះជាអ្នកបើកបរសកម្ម មានន័យថាពួកគេបានផ្តល់សេវាជំនិះលើសពីចំនួនមធ្យមនៅក្នុងរយៈពេលប្រាំមួយខែកន្លងទៅ។ សេចក្តីស្នើច្បាប់នេះនឹងបង្កើតអោយមាននីតិវិធីផ្សេងៗសម្រាប់ក្រុមប្រឹក្សានេះប្រើប្រាស់ ដើម្បីកំណត់ថាសហជីពអ្នកបើកបរបានចុះហត្ថលេខាលើលិខិតអនុញ្ញាតពីអ្នកបើកបរសកម្ម យ៉ាងហោចណាស់ចំនួនប្រាំភាគរយ ដើម្បីធ្វើអោយសហជីពអ្នកបើកបរនេះទទួលបានការចុះបញ្ជីថាជាអ្នកបើកបរសកម្ម; ដើម្បីចាត់តាំងសហជីពអ្នកបើកបរជាអ្នកតំណាងចរចាផ្តាច់មុខអោយអ្នកបើកបរទាំងអស់ ដោយផ្អែកលើលិខិតអនុញ្ញាតដែលបានចុះហត្ថលេខាពីអ្នកបើកបរសកម្មយ៉ាងតិចចំនួនម្ភៃប្រាំភាគរយ (២៥%) និង ដើម្បីដោះស្រាយវិវាទទាក់ទងនឹងឋានៈចរចាផ្តាច់មុខ រួមទាំងតាមរយៈការបោះឆ្នោត; ហើយក៏ដើម្បីដកហូតឋានៈរបស់សហជីពអ្នកបើកបរក្នុងការចរចាផ្តាច់មុខ។ សហជីពអ្នកបើកបរដែលត្រូវបានចាត់តាំងជាអ្នកតំណាងចរចាផ្តាច់មុខ នឹងមានសិទ្ធិផ្តាច់មុខក្នុងការធ្វើជាតំណាងអ្នកបើកបរទាំងឡាយ និង ទទួលបានការបញ្ចុះថ្លៃការបង់ប្រាក់ជាសមាជិកភាពដោយស្ម័គ្រចិត្ត។

នៅពេលដែលក្រុមប្រឹក្សាកំណត់ថា សហជីពអ្នកបើកបរណាមួយមានសិទ្ធិធ្វើជាអ្នកតំណាងចរចាផ្តាច់មុខអោយអ្នកបើកបរទាំងអស់ គេនឹងតម្រូវអោយក្រុមហ៊ុនចរចាជាមួយសហជីពអ្នកបើកបរនោះអំពីប្រាក់ឈ្នួល, អត្ថប្រយោជន៍ និង លក្ខខណ្ឌផ្សេងៗនៃការងារ។ នៅពេលដែលសហជីពអ្នកបើកបរ និង ក្រុមហ៊ុន បានព្រមព្រៀងគ្នាលើប្រាក់ឈ្នួល, អត្ថប្រយោជន៍ និង លក្ខខណ្ឌផ្សេងៗនៃការងារហើយ កិច្ចព្រមព្រៀងនោះនឹងត្រូវបោះឆ្នោតដោយអ្នកបើកបរទាំងអស់ដែលបានផ្តល់សេវាដឹកជញ្ជូនយ៉ាងតិចចំនួន១០០ដង ក្នុងរយៈពេលមួយត្រីមាសកន្លងទៅ។ បើទទួលបានការយល់ព្រមសំឡេងភាគច្រើនពីការបោះឆ្នោតនោះ អនុសាសន៍ទាំងនេះនឹងត្រូវគេដាក់ជូនទៅរដ្ឋមន្ត្រីការងារប្រចាំរដ្ឋ ដើម្បីអនុម័ត។ ហើយបើទទួលបានអនុម័ត នោះវានឹងមានសុពលភាពសម្រាប់រយៈពេលបីឆ្នាំ។ សេចក្តីស្នើច្បាប់នេះនឹងបង្កើតអោយមាននីតិវិធីផ្សេងៗសម្រាប់ការសម្រុះសម្រួល និង ការធ្វើជាអាជ្ញាកណ្តាល បើសិនជាសហជីពអ្នកបើកបរ និង ក្រុមហ៊ុន មិនមានការព្រមព្រៀងគ្នាក្នុងរយៈពេលជាក់លាក់ណាមួយ។ អ្នកធ្វើជាអាជ្ញាកណ្តាល (មជ្ឈត្តករ)នឹងពិចារណាលើកត្តាផ្សេងៗដែលមានចែងក្នុងសេចក្តីស្នើច្បាប់នេះ រួមទាំងពិចារណាថាតើប្រាក់ឈ្នួលរបស់អ្នកបើកបរនឹងគ្រប់គ្រាន់ដែរឬទេ ដើម្បីកុំអោយអ្នកបើកបរទាំងនោះចាំបាច់ត្រូវពឹងផ្អែកលើអត្ថប្រយោជន៍សាធារណៈណាមួយ។ សេចក្តីស្នើច្បាប់នេះក៏នឹងដាក់ចេញនូវនីតិវិធីផ្សេងៗ សម្រាប់អោយរដ្ឋមន្ត្រីការងារពិនិត្យ និង ការអនុម័តលើអនុសាសន៍នានាដែលបានចរចាដោយសហជីពអ្នកបើកបរ និង ក្រុមហ៊ុន និង សម្រាប់ការពិនិត្យឡើងវិញតាមផ្លូវតុលាការទៅលើការសម្រេចរបស់រដ្ឋមន្ត្រី។

សេចក្តីស្នើច្បាប់នេះចែងថា ទាំងបទបញ្ញត្តិរបស់ខ្លួន, កិច្ចព្រមព្រៀង ឬ ការកំណត់ដោយរដ្ឋមន្ត្រី សុទ្ធតែមិនអាចកាត់បន្ថយស្តង់ដាការងារដែលបានបង្កើតឡើងដោយច្បាប់ផ្សេងទៀតឡើយ។ បើទោះជាមានទំនាស់ណាមួយរវាងសេចក្តីស្នើច្បាប់នេះ និង ច្បាប់ដែលទាក់ទងនឹងការងារដែលមានស្រាប់នៅរដ្ឋម៉ាសាឈូសិតក៏ដោយ សេចក្តីស្នើច្បាប់នេះនឹងមានសុពលភាពសម្រាប់ប្រើប្រាស់។

ក្រុមប្រឹក្សានឹងបង្កើតអោយមានវិធាន និង បទបញ្ញត្តិនានា ដើម្បីធ្វើអោយសេចក្តីស្នើច្បាប់នេះមានសុពលភាពពេញលេញជាច្បាប់សម្រាប់អនុវត្ត ។

សេចក្តីស្នើច្បាប់នេះចែងថា ទោះជាផ្នែកណាមួយរបស់ខ្លួនត្រូវបានគេប្រកាសថាមិនត្រឹមត្រូវ ផ្នែកផ្សេងទៀតនឹងនៅជាធរមាន។

# សំណួរទី៣ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

**ឥទ្ធិពលពីការបោះឆ្នោតរបស់អ្នក** ▶

តាមច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** នឹងផ្តល់អោយអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូននូវជម្រើសក្នុងការបង្កើតសហជីពដើម្បីចរចារួមគ្នាជាមួយក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន អំពីប្រាក់ឈ្នួល, អត្ថប្រយោជន៍ និង លក្ខខណ្ឌផ្សេងៗនៃការងារ ។

***ការបោះឆ្នោតជំទាស់*** នឹងមិនធ្វើអោយមានការកែប្រែអ្វីឡើយក្នុងច្បាប់ពាក់ព័ន្ធនឹងលទ្ធភាពរបស់អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនដើម្បីបង្កើតសហជីពឡើយ។

---

**របាយការណ៍នៃការប៉ះពាល់លើសារពើពន្ធ** ▶

តាមការតម្រូវដោយច្បាប់ របាយការណ៍ផលប៉ះពាល់លើសារពើពន្ធ ត្រូវសរសេរដោយក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ។

ច្បាប់ដែលបានស្នើ ពុំអាចដឹងពីផលប៉ះពាល់លើសារពើពន្ធជាសារវន្តចំពោះហិរញ្ញវត្ថុរដ្ឋ និងហិរញ្ញវត្ថុរដ្ឋាភិបាលក្រុងឡើយ។

---

**ទឡ្ហីករណ៍** ▶

ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវសរសេរដោយអ្នកគាំទ្រ និង អ្នកបដិសេធលើសំណួរនីមួយៗ និងឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។ **រដ្ឋាភិបាលរដ្ឋម៉ាសាឈូសិត ពុំបានគាំទ្រចំពោះទឡ្ហីករណ៍ទាំងនេះទេ ហើយក៏មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងនៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះរបស់បុគ្គល និងស្ថាប័នដែលបានសរសេរទឡ្ហីករណ៍នីមួយៗ និងមតិយោបល់ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃផ្សេងទៀត ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***បោះឆ្នោតគាំទ្រ៖*** ការបោះឆ្នោត **គាំទ្រ** នឹងផ្តល់ឱ្យអ្នកបើកបររថយន្តជិះរួមគ្នាក្នុងរដ្ឋម៉ាសាឈូសិត ដែលធ្វើការឱ្យក្រុមហ៊ុនដូចជា Uber និង Lyft នូវជម្រើសក្នុងការចូលសហជីព ដែលក្នុងខណៈពេលនោះក៏រក្សាបាននូវភាពបត់បែន និងឯករាជ្យភាពរបស់អ្នកបើកបរផងដែរ។ ជម្រើសដើម្បីចូលសហជីព ត្រូវបានធានាសម្រាប់កម្មករនិយោជិតភាគច្រើន ប៉ុន្តែអ្នកបើកបររថយន្តជិះរួមគ្នា បច្ចុប្បន្នមិនមានជម្រើសបែបនោះទេ។  បោះឆ្នោត **គាំទ្រ** ដើម្បីអនុញ្ញាតឱ្យអ្នកបើកបររថយន្តជិះរួមគ្នា មានជម្រើសក្នុងការជ្រើសរើសសហជីព។

**Roxana Rivera**
**United for Justice**
**26 West Street, 6th Floor**
**Boston, MA 02111**
**401-965-3555**
**www.DriversNeedaUnion.org**

***បោះឆ្នោតជំទាស់៖*** អ្នកបើកបរ និងអ្នកជិះរថយន្តទទូចឱ្យជំទាស់នឹងសំណួរទី 3។

សំណួរទី 3 នឹងដំឡើងថ្លៃសម្រាប់អ្នកជិះរថយន្តទាំងអស់ ដែលជាការផ្តល់មូលនិធិដល់សហជីព មិនមែនដល់អ្នកបើកបរទេ។

ច្បាប់នេះផ្តល់ឱ្យអ្នកនយោបាយនូវសិទ្ធិក្នុងការកំណត់ច្បាប់**ដោយគ្មាន**ទំនួលខុសត្រូវរួម និងបង្កើតប្រភេទការងារផ្លាស់ប្តូរថ្មីទាំងស្រុងដែលមិនស្របតាមច្បាប់ការងារសហព័ន្ធ។

អ្នកបើកបរនៅរដ្ឋម៉ាសាឈូសិត ទទួលបានរួចហើយនូវ៖

- ប្រាក់ម៉ោងគោលចំនួន $32.50 ក្នុងមួយម៉ោងដោយមានការដំឡើងប្រចាំឆ្នាំ
- ការឈប់សម្រាកដោយជំងឺមានប្រាក់ឈ្នួល
- ការឈប់សម្រាកព្យាបាលជំងឺគ្រួសារមានប្រាក់ឈ្នួល
- ប្រាក់ឧបត្ថម្ភថែទាំសុខភាព
- ការធានារ៉ាប់រងរបួសពេលបំពេញការងារ
- ការការពារប្រឆាំងនឹងការរើសអើង
- ការឈប់សម្រាកដោយសារអំពើហិង្សាក្នុងគ្រួសារ
- ការការពារប្រឆាំងនឹងការសងសឹក
- ដំណើរការបណ្តឹងតវ៉ា

សំណួរទី 3 ពិតជាមិនបានបង្កើតការចរចាសម្រាប់កម្មករនិយោជិតឡើយ។ អ្នកបើកបរនឹងមិនមានការគ្រប់គ្រងលើការដឹកនាំរបស់សហជីពទេ ហើយនឹងបង់ថ្លៃចំណាយសំខាន់ៗដោយគ្មានតំណាងពិតប្រាកដ។

សំណើនេះមិនយុត្តិធម៌សម្រាប់អ្នកបើកបរទេ ហើយអនុញ្ញាតឱ្យចំនួន 2.5 នៃអ្នកបើកបរ បង្ខំចិត្តចូលជាសហជីព ហើយទុកឱ្យអ្នកបើកបរជាច្រើនមិនអាចបញ្ចេញសម្លេង ឬសម្តែងមតិបាន។

បោះឆ្នោតជំទាស់ចំពោះសំណួរទី 3។

**សម្ព័ន្ធភាពសារពើពន្ធរដ្ឋម៉ាសាឈូសិត**
**Boston, MA**
**617-553-4115**
**www.massfiscal.org**

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ**

ត្រូវអនុម័តដោយប្រជាជន និងតាមសិទ្ធិអំណាចរបស់ពួកគេ៖

ច្បាប់មួយដែលផ្តល់ឱ្យអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូននូវជម្រើសក្នុងការបង្កើតសហជីពនិងចរចាជាសមូហភាព។

ច្បាប់នេះ ដែលបន្ថែមជំពូក 150F ទៅនឹងច្បាប់ទូទៅ បង្កើតឱកាសសម្រាប់កម្មករនិយោជិតនៅក្នុងឧស្សាហកម្មដឹកជញ្ជូនឌីជីថលដើម្បីបង្កើតសហជីពអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន និងដើម្បីចរចានៅក្នុងឧស្សាហកម្មនេះទាំងមូលជាមួយនឹងក្រុមហ៊ុនក្នុងឧស្សាហកម្មនេះ លើអនុសាសន៍នានាដែលផ្តល់ជូនរដ្ឋម៉ាសាឈូសិត ដែលបង្កើនស្តង់ដាសម្រាប់លក្ខខណ្ឌការងារនៅក្នុងឧស្សាហកម្មនេះ។

ត្រូវមានជំពូក 150F ថ្មីដែលត្រូវចែងដូចខាងក្រោម៖

ផ្នែក 1. លទ្ធផល និងគោលនយោបាយ

A. រដ្ឋម៉ាសាឈូសិតទទួលស្គាល់ថា ភាពជឿនលឿននៃបច្ចេកវិទ្យាបានបង្កើត "ទីផ្សារឌីជីថល" ថ្មីនៅក្នុងវិស័យដឹកជញ្ជូន ដែលក្នុងនោះ ក្រុមហ៊ុនភ្ជាប់ទំនាក់ទំនងអតិថិជនដែលកំពុងស្វែងរកសេវាកម្មដឹកជញ្ជូនអ្នកដំណើរ តាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ជាមួយមនុស្សដែលមានឆន្ទៈក្នុងការផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូននោះ។ មនុស្សទាំងនេះ ជារឿយៗទទួលបានប្រាក់ឈ្នួលទាប ការធានារ៉ាប់រងសុខភាពមិនគ្រប់គ្រាន់ និងម៉ោងការងារមិនគ្រប់គ្រាន់ ឬមិនទៀងទាត់។ តាមរយៈនេះ ត្រូវបានប្រកាសថា ផលប្រយោជន៍ដ៏ល្អបំផុតរបស់រដ្ឋម៉ាសាឈូសិតត្រូវបានបម្រើដោយការផ្តល់ឱ្យអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន នូវឱកាសក្នុងការរៀបចំដោយខ្លួនឯង និងចាត់តាំងអ្នកតំណាងការជ្រើសរើសរបស់ពួកគេផ្ទាល់ និងដើម្បីចរចាជាសមូហភាពដើម្បីទទួលបានប្រាក់ឈ្នួល អត្ថប្រយោជន៍ និងលក្ខខណ្ឌការងារប្រកបដោយនិរន្តរភាព ដែលស្ថិតក្រោមការអនុម័តយល់ព្រម និងការត្រួតពិនិត្យជាបន្តបន្ទាប់ដោយរដ្ឋម៉ាសាឈូសិត។ ក៏មានការប្រកាសបន្ថែមទៀតថា ផលប្រយោជន៍ដ៏ល្អបំផុតរបស់រដ្ឋម៉ាសាឈូសិតត្រូវបានបម្រើដោយការបង្ការ ឬការដោះស្រាយភ្លាមៗនូវវិវាទនានាដែលកើតឡើង រវាងក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូនជិះរួមគ្នា និងមនុស្សដែលផ្គត់ផ្គង់កម្លាំងពលកម្ម ដើម្បីអនុវត្តសេវាកម្មទាំងនោះ។ ជំពូកនេះ ត្រូវបានចាត់ទុកថាជាការប្រើសិទ្ធិអំណាចអនុវត្តច្បាប់របស់រដ្ឋម៉ាសាឈូសិត ហើយត្រូវបានបកស្រាយទូលំទូលាយដើម្បីសម្រេចបាននូវគោលបំណងរបស់វា។

B. ដោយសារហេតុផលដូចមានចែងនៅក្នុងផ្នែករង A គោលនយោបាយសាធារណៈរបស់រដ្ឋម៉ាសាឈូសិតគឺត្រូវដាក់បង្ហាញការប្រកួតប្រជែងនូវបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌការងារសម្រាប់អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនដែលបានកំណត់ក្នុងនេះ ហើយស្របតាមគោលនយោបាយនេះ គឺត្រូវលើកលែងពីច្បាប់ដែលបង្កើតឡើងដើម្បីលើកកម្ពស់ការប្រកួតប្រជែង និងទប់ស្កាត់ការប្រតិបត្តិផ្តាច់មុខនៅក្នុងទីផ្សារ (Antitrust laws) របស់សហព័ន្ធ និងរដ្ឋម៉ាសាឈូសិត ការបង្កើតសហជីពអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន និងសមាគមក្រុមហ៊ុនចម្រុះសម្រាប់គោលបំណងនៃការចរចាជាសមូហភាព រវាងក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន និងអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូននៅក្នុងឧស្សាហកម្មមួយទាំងមូល និងដើម្បីត្រួតពិនិត្យ វាយតម្លៃ ហើយប្រសិនបើមានការអនុម័តយល់ព្រម គឺត្រូវអនុវត្តអនុសាសន៍បានចរចាដែលកើតមានទាក់ទងនឹងលក្ខខណ្ឌការងារសម្រាប់អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនទាំងអស់នៅក្នុងឧស្សាហកម្មមួយ នៅពេលដែលអនុសាសន៍ទាំងនោះត្រូវបានឈ្វេងយល់ដោយរដ្ឋមន្ត្រីការងារ ដើម្បីគាំទ្រដល់គោលបំណងសាធារណៈដែលមានចែងក្នុងផ្នែកនេះ និងបន្ទាប់មក ត្រូវតែអនុវត្តតាមដោយមិនគិតពីផលវិបាកនៃការប្រកួតប្រជែងនៅទីនោះឡើយ។

1. រដ្ឋម៉ាសាឈូសិតមានគោលបំណងឱ្យអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន មានសិទ្ធិបង្កើត ចូលរួម ឬជួយការងារសហជីព ដើម្បីទទួលបានការធ្វើជាតំណាងដោយអ្នកតំណាងដែលពួកគេបានជ្រើសរើសផ្ទាល់ និងដើម្បីចូលរួមក្នុងសកម្មភាពសមូហភាពក្នុងគោលបំណងចរចាជាមួយក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន និងបង្កើតអនុសាសន៍ដែលបានចរចា ដែលត្រូវបង្កើតជាមូលដ្ឋានសម្រាប់បទប្បញ្ញត្តិឧស្សាហកម្ម។

2. រដ្ឋម៉ាសាឈូសិតមានគោលបំណងឱ្យក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន មានសិទ្ធិបង្កើតសមាគមក្រុមហ៊ុនចម្រុះដើម្បីតំណាងឱ្យពួកគេ ក្នុងពេលចរចាជាមួយសហជីពអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន ដើម្បីបង្កើតអនុសាសន៍ដែលបានចរចា ដែលត្រូវបង្កើតជាមូលដ្ឋានសម្រាប់បទប្បញ្ញត្តិឧស្សាហកម្ម។

3. គោលបំណងនិងគោលនយោបាយរបស់រដ្ឋម៉ាសាឈូសិត គឺសម្រាប់ការលើកលែងការងារដែលមានលក្ខន្តិកៈ និងការងារដែលគ្មានលក្ខន្តិកៈ ឱ្យរួចផុតពីច្បាប់ដែលបង្កើតឡើងដើម្បីលើកកម្ពស់ការប្រកួតប្រជែង និងទប់ស្កាត់ការប្រតិបត្តិផ្តាច់មុខនៅក្នុងទីផ្សារ (Antitrust laws) របស់សហព័ន្ធ និងច្បាប់ស្រដៀងគ្នារបស់រដ្ឋម៉ាសាឈូសិតដើម្បីអនុវត្តចំពោះអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន ដែលពួកគេបានជ្រើសរើសបង្កើត ចូលរួម ឬជួយសហជីពការងារក្នុងសកម្មភាពការងារនៅក្នុងរដ្ឋម៉ាសាឈូសិតដែលបានអនុញ្ញាតតាមរយៈច្បាប់នេះ។

4. ក្នុងការអនុញ្ញាតនិងគ្រប់គ្រងក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន និងអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនដែលចូលរួមក្នុងសកម្មភាពការងារដែលច្បាប់នេះអនុញ្ញាត រដ្ឋម៉ាសាឈូសិតមានបំណងចង់ឱ្យមានការផ្តល់អភ័យឯកសិទ្ធិសកម្មភាពរបស់រដ្ឋចំពោះលក្ខន្តិកៈនេះ និងចង់ឱ្យក្រុមហ៊ុននិងអ្នកបើកបរទាំងនោះមានអភ័យឯកសិទ្ធិរួចផុតពីច្បាប់ដែលបង្កើតឡើងដើម្បីលើកកម្ពស់ការប្រកួតប្រជែង និងទប់ស្កាត់ការប្រតិបត្តិផ្តាច់មុខនៅក្នុងទីផ្សាររបស់សហព័ន្ធ និងរដ្ឋម៉ាឈូសិតដល់កម្រិតពេញលេញបំផុតដែលអាចធ្វើទៅបាន ក្នុងការប្រតិបត្តិរបស់ពួកគេ ដោយអនុលោមតាមច្បាប់នេះ។

5. រដ្ឋម៉ាសាឈូសិតនឹងត្រួតពិនិត្យយ៉ាងសកម្មចំពោះសកម្មភាពការងារដែលត្រូវបានអនុញ្ញាតតាមរយៈច្បាប់នេះដែលធ្វើឡើងដោយក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន និងអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន ស្របតាមច្បាប់នេះ ដើម្បីធានាថាការអនុវត្តដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ការពារសិទ្ធិកម្មករនិយោជិតនិងក្រុមហ៊ុន លើកទឹកចិត្តដល់ការចរចាជាសមូហភាព និងសន្តិភាពការងារ ហើយបើមិនដូច្នេះទេ គឺគាំទ្រដល់គោលបំណងនៃច្បាប់នេះ។

ផ្នែក 2. និយមន័យ

A. “អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនសកម្ម” ឬ “TND សកម្ម” មានន័យថាជាអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន ដែលត្រូវបានកំណត់ស្របតាមនីតិវិធីខាងក្រោម៖ តាមការស្នើសុំរបស់ក្រុមប្រឹក្សា ហើយនៅក្រោយពេលបញ្ចប់ត្រីមាសប្រតិទិននីមួយៗនោះ ក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូននីមួយៗ (ហៅកាត់ថា “TNC”) ត្រូវផ្តល់ជូនក្រុមប្រឹក្សានូវព័ត៌មានដែលកំណត់អត្តសញ្ញាណអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន (“TND”) ទាំងអស់ ដែលបានបង្គ្រប់ការផ្តល់សេវាជំនិះចំនួនប្រាំដង ឬច្រើនជាងនេះ នៅតាមចំណតរបស់ TNC ដែលមានប្រភពដើម នៅក្នុងរដ្ឋម៉ាសាឈូសិត

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

ក្នុងរយៈពេលប្រាំមួយខែមុន។ TNC នីមួយៗត្រូវផ្តល់ព័ត៌មាននេះក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីដំណាច់ត្រីមាសប្រតិទិននីមួយៗ (ថ្ងៃទី 31 ខែមីនា ថ្ងៃទី 30 ខែមិថុនា ថ្ងៃទី 30 ខែកញ្ញា និងថ្ងៃទី 31 ខែធ្នូ)។ ព័ត៌មានបែបនេះត្រូវរួមបញ្ចូលតែឈ្មោះរបស់TND លេខបណ្ណបើកបររបស់ TND និងចំនួនជិះរបស់ TND ដែលបានបញ្ចប់តាមចំណតរបស់ TNC ក្នុងរយៈពេលប្រាំមួយខែមុន។ ក្រុមប្រឹក្សាត្រូវរួមបញ្ចូលគ្នានូវទិន្នន័យដែលផ្តល់ដោយ TNCs ទាំងអស់ដើម្បីកំណត់ការបែងចែកចំនួនជិះដែលសម្រេចបានដោយ TNDs ទាំងអស់ដើម្បីបញ្ជូនទិន្នន័យ ហើយបន្ទាប់មកត្រូវកំណត់ចំនួនមធ្យមនៃជិះរបស់ TNDs ដែលទិន្នន័យរបស់ខ្លួនត្រូវបានបញ្ជូនក្នុងរយៈពេលប្រាំមួយខែមុន។ TND ណាក៏ដោយ ដែលសម្រេចបានការផ្តល់សេវាជិះលើសពីចំនួនមធ្យម នឹងត្រូវចាត់ទុកថាជាអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនសកម្មនៅក្នុងឧស្សាហកម្មជិះរថយន្តរួមគ្នា។

B. “ក្រុមប្រឹក្សា” មានន័យថាជាក្រុមប្រឹក្សាទំនាក់ទំនងការងាររដ្ឋម៉ាសាឈូសិត ដែលបង្កើតដោយផ្នែក 9R ក្នុងជំពូកទី 23 នៃច្បាប់ទូទៅ។

C. “សហជីពក្រុមហ៊ុន” មានន័យថាជាគណៈកម្មាធិការ ផែនការតំណាងនិយោជិត ឬសមាគមកម្មករនិយោជិតណាមួយ ឬអ្នកផ្សេងទៀតដែលមានសម្រាប់គោលបំណងទាំងមូល ឬមួយផ្នែក ក្នុងការដោះស្រាយជាមួយ TNCs ទាក់ទងនឹងការតវ៉ា ឬលក្ខខណ្ឌការងារសម្រាប់ TNDs ដែល (1) TNC បានផ្តួចផ្តើម ឬបានបង្កើត ឬការផ្តួចផ្តើម ឬការបង្កើត TNC នោះខ្លួនបានស្នើ បានចូលរួមក្នុង ឬស្ថិតនៅក្នុងការបង្កើតក្រុមហ៊ុនដែលមានច្បាប់ឬគោលនយោបាយគ្រប់គ្រង ឬការអនុវត្តការគ្រប់គ្រង ប្រតិបត្តិការ ឬការបោះឆ្នោតដែល TNC ចូលរួម ឬគ្រប់គ្រង។ ឬ (2) ដែល TNC រក្សាទុក ផ្តល់ហិរញ្ញប្បទាន គ្រប់គ្រង ត្រួតត្រា ឬជួយដល់ការថែរក្សា ឬផ្តល់ហិរញ្ញប្បទាន លុះត្រាតែមានការតម្រូវឱ្យធ្វើដូច្នេះដោយជំពូកនេះ ឬបទប្បញ្ញត្តិណាមួយដែលអនុវត្តជំពូកនេះ ទោះជាដោយការផ្តល់សំណងដល់នរណាម្នាក់សម្រាប់សេវាកម្មដែលធ្វើឡើងក្នុងនាមខ្លួន ឬដោយការបរិច្ចាគដោយឥតគិតថ្លៃនូវសេវាកម្ម បរិក្ខារ សម្ភារ ការិយាល័យ ឬកន្លែងប្រជុំ ឬអ្វីមួយផ្សេងទៀតដែលមានតម្លៃ ឬដោយមធ្យោបាយផ្សេងទៀតណាមួយ។ សហជីព TND មិនត្រូវបានចាត់ទុកថាជាសហជីពរបស់ក្រុមហ៊ុននោះទេ ដោយសារតែខ្លួនបានចរចា ឬត្រូវបានផ្តល់សិទ្ធិក្នុងការចាត់តាំងកម្មករឱ្យឈប់សម្រាកដោយមានប្រាក់ឈ្នួល ក្នុងគោលបំណងផ្តល់សេវាតំណាងក្នុងកិច្ចការគ្រប់គ្រងកម្លាំងការងារក្នុងនាមកម្មករដែលតំណាងដោយសហជីព TND ឬនៅក្នុងដំណើរការផ្តល់សេវាតំណាងដល់កម្មករដែលខ្លួនជាអ្នកតំណាងចរចាផ្តាច់មុខដែល TNC អនុញ្ញាតឱ្យភ្នាក់ងារសហជីព TND ជួបជាមួយកម្មករនៅកន្លែងរបស់ TNC ។

D. “តំណាងចរចាផ្តាច់មុខ” មានន័យថាជាសហជីព TND ដែលបញ្ជាក់ដោយក្រុមប្រឹក្សា ស្របតាមជំពូកនេះ ថាជាតំណាងរបស់ TNDs នៅក្នុងផ្នែកចរចា។

E. “ក្រុមហ៊ុនបណ្តាញ” មានន័យថាជា TNC ។ លើកលែងតែអង្គភាពអាជីវកម្មដែលរក្សាកម្មវិធី ឬវេទិកាកម្មវិធីដែលដំណើរការតាមអនឡាញដែលបំពេញតាមការធ្វើតេស្តទាំងបីខាងក្រោម មិនមែនជាក្រុមហ៊ុនក្នុងបណ្តាញនោះទេៈ (1) ត្រូវបានប្រើប្រាស់ដើម្បីជួយសម្រួលជាចម្បងដល់សេវាកម្មដែលមិនមែនជាការជិះរថយន្តរួមគ្នានៅក្នុងរដ្ឋម៉ាសាឈូសិត (2) តិចជាង 7.5% ភាគរយនៃសំណើសេវាកម្មដែលបានបំពេញតាមរយៈវេទិកាកម្មវិធីប្រចាំឆ្នាំគឺសម្រាប់សេវាជិះរថយន្តរួមគ្នា និង (3) សំណើសេវាកម្មតិចជាងមួយម៉ឺនដែលបានបំពេញតាមរយៈវេទិកាកម្មវិធីក្នុងឆ្នាំណាមួយគឺសម្រាប់សេវាជិះរថយន្តរួមគ្នា។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ កម្មវិធី ឬវេទិកាទាំងអស់ដែលប្រើប្រាស់ដោយអង្គភាពសាជីវកម្មក្រោមការគ្រប់គ្រងរួមត្រូវចាត់ទុកថាជាកម្មវិធី ឬវេទិកាតែមួយ។

F. “អ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន” ឬ “TND” មានន័យថាជាអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូនដែលបានបរិយាយដោយ § 1 ក្នុងជំពូក 159A½ នៃច្បាប់ទូទៅ។ TND មិនត្រូវរាប់បញ្ចូលបុគ្គលណាម្នាក់ដែលទាក់ទងនឹងការផ្តល់សេវាតាមរយៈកម្មវិធី ឬវេទិកាដែលបើកដំណើរការតាមអនឡាញរបស់ TNC គឺជានិយោជិតនៅក្នុងអត្ថន័យនៃផ្នែកទី 29 U.S.C. § 152 (3) ។

G. “សហជីពអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន” ឬ “សហជីព TND” មានន័យថាជាស្ថាប័នណាមួយដែលអ្នកបើកបរក្នុងប្រព័ន្ធចូលរួម ហើយដែលមាន និងត្រូវបានបង្កើតឡើងសម្រាប់គោលបំណងទាំងមូល ឬមួយផ្នែក ក្នុងការចរចាជាសមូហភាព ឬក្នុងការដោះស្រាយជាមួយក្រុមហ៊ុនក្នុងបណ្តាញដែលទាក់ទងនឹងការតវ៉ា ឬលក្ខខណ្ឌការងារ ឬក្នុងការជួយគ្នាទៅវិញទៅមកផ្សេងទៀត ឬក្នុងការការពារ ហើយដែលមិនមែនជាសហជីពក្រុមហ៊ុន ដូចដែលបានឱ្យនិយមន័យនៅក្នុងនេះ។

H. “ក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន” or “TNC” មានន័យថាជាក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន ដូចបានបរិយាយដោយ § 1 ក្នុងជំពូក 159A½ នៃច្បាប់ទូទៅ។

I. “ការប្រតិបត្តិការងារមិនត្រឹមត្រូវ” មានន័យសម្រាប់តែការប្រតិបត្តិការងារមិនត្រឹមត្រូវដូចមានរាយនៅក្នុងផ្នែក 4 ខាងក្រោមតែប៉ុណ្ណោះ។

ផ្នែក 3. សិទ្ធិរបស់ TNDs

TNDs ត្រូវមានសិទ្ធិស្វ័យរៀបចំ បង្កើត ចូលរួម ឬជួយសហជីព TND ក្នុងការចរចាជាសមូហភាព តាមរយៈតំណាងដែលពួកគេជ្រើសរើសផ្ទាល់ និងចូលរួមក្នុងសកម្មភាពសមូហភាព ក្នុងគោលបំណងចរចាជាសមូហភាព ឬក្នុងការជួយគ្នាទៅវិញទៅមកផ្សេងទៀត ឬក្នុងការការពារពីការជ្រៀតជ្រែក រឹតត្បិត ឬបង្ខិតបង្ខំដោយ TNCs ហើយក៏ត្រូវមានសិទ្ធិមិនចូលរួមក្នុងសកម្មភាពទាំងនេះណាមួយដែរ។ ក្នុងជំពូកនេះ គ្មានផ្នែកណាមួយត្រូវបានបកស្រាយដើម្បីហាមឃាត់មិនឱ្យ TNDs អនុវត្តសិទ្ធិក្នុងការពិភាក្សាជាមួយ TNCs នៅពេលណាមួយនោះឡើយ ប្រសិនបើក្នុងអំឡុងពេលពិភាក្សានោះ TNC មិនមានការប៉ុនប៉ងដោយផ្ទាល់ ឬដោយប្រយោលក្នុងការជ្រៀតជ្រែក រារាំង ឬបង្ខិតបង្ខំកម្មករនិយោជិតទាំងនោះឱ្យអនុវត្តសិទ្ធិដែលធានាដោយផ្នែកនេះទេនោះ។

ផ្នែក 4. ការប្រតិបត្តិការងារមិនត្រឹមត្រូវ

A. ជាការប្រតិបត្តិការងារមិនត្រឹមត្រូវសម្រាប់ TNC ក្នុងការៈ

1. ខកខាន ឬបដិសេធមិនផ្តល់ឱ្យក្រុមប្រឹក្សានូវបញ្ជីឈ្មោះ ការធ្វើដំណើរដែលបានធ្វើឡើង និងព័ត៌មានទំនាក់ទំនងត្រឹមត្រូវសម្រាប់ TNDs ដូចដែលបានតម្រូវដោយជំពូកនេះ។

2. បដិសេធមិនចរចាដោយស្មោះត្រង់ជាមួយសហជីព TND ដែលត្រូវបានបញ្ជាក់ ឬទទួលស្គាល់ ដែលតំណាងឱ្យ TNDs ដែលចូលរួមជាមួយ TNC នេះ ទាក់ទងនឹងប្រាក់ឈ្នួល ម៉ោងធ្វើការ ឬលក្ខខណ្ឌការងារផ្សេងៗ។ ដោយហេតុថា

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

កាតព្វកិច្ចក្នុងការចរចាដោយស្មោះត្រង់រួមមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានដែលបានស្នើសុំពាក់ព័ន្ធនឹងដំណើរការចរចា វាក៏ជាការប្រតិបត្តិការងារមិនត្រឹមត្រូវផងដែរសម្រាប់ TNC ក្នុងការបដិសេធមិនផ្តល់ឱ្យសហជីព TND ដែលត្រូវបានបញ្ជាក់ ឬទទួលស្គាល់ នូវព័ត៌មានពាក់ព័ន្ធដែលបានស្នើសុំដោយសហជីព TND ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកតំណាងចរចាររបស់ TND។

3. បដិសេធមិនផ្តល់ឱ្យសហជីព TND នូវបញ្ជីឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់ TNDs ដែលការផ្តល់បញ្ជីបែបនេះត្រូវបានតម្រូវដោយជំពូកនេះ។

4. បដិសេធមិនបន្តគោរពតាមលក្ខខណ្ឌទាំងអស់នៃការកំណត់លក្ខខណ្ឌការងារដែលកំណត់ដោយរដ្ឋមន្ត្រីការងារ ដោយអនុលោមតាមជំពូកនេះ រហូតដល់ត្រូវមានការកំណត់ជាថ្មី។

5. បិទទ្វារមិនឱ្យ TNDs ចូលធ្វើការ។ ពាក្យ “បិទទ្វារមិនឱ្យចូលធ្វើការ” សម្រាប់គោលបំណងនៃផ្នែកនេះ មានន័យថាជាការបដិសេធដោយ TNC ក្នុងការអនុញ្ញាតឱ្យ TND ចូលធ្វើការជាធម្មតាលើមធ្យោបាយតភ្ជាប់ TNDs របស់ TNC ទៅបុគ្គលដែលស្វែងរកសេវាដឹកជញ្ជូនដោយសារតែមានវិវាទជាមួយកម្មករនិយោជិតទាំងនោះ ឬ សហជីព TND ដែលតំណាងឱ្យកម្មករនិយោជិតទាំងនោះ ដែលប៉ះពាល់ដល់ប្រាក់ឈ្នួល ម៉ោងធ្វើការនិងលក្ខខណ្ឌការងារផ្សេងទៀតរបស់កម្មករនិយោជិតទាំងនោះ ដែលទោះជាយ៉ាងនេះក្តី ការបិទទ្វារមិនឱ្យចូលធ្វើការនេះ មិនត្រូវរាប់បញ្ចូលការបញ្ចប់ការចូលរួមរបស់កម្មករនិយោជិត សម្រាប់ហេតុផលត្រឹមត្រូវ ដែលមិនពាក់ព័ន្ធនឹងកម្មករនិយោជិតដែលអនុវត្តសិទ្ធិណាមួយដែលត្រូវបានធានាដោយជំពូកនេះនោះឡើយ។

6. យកការណ៍ ឬរក្សាការឃ្លាំមើល មិនថាដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារ ឬបុគ្គលណាក៏ដោយ ចំពោះសកម្មភាពណាមួយរបស់ TNDs តំណាងកម្មករនិយោជិតទាំងនោះ ឬបុគ្គលណាម្នាក់ផ្សេងទៀត ឬសកម្មភាពណាមួយរបស់កម្មករនិយោជិតទាំងនោះ ឬតំណាងកម្មករនិយោជិតទាំងនោះ ក្នុងការអនុវត្តសិទ្ធិដែលធានាដោយជំពូកនេះ។

7. ត្រួតត្រា ឬជ្រៀតជ្រែកលើការបង្កើត អត្ថិភាព ឬការគ្រប់គ្រងរបស់សហជីព TND ណាមួយ ឬរួមចំណែកផ្នែកហិរញ្ញវត្ថុ ឬជំនួយផ្សេងទៀតដល់សហជីពនោះដោយផ្ទាល់ ឬដោយប្រយោល លុះត្រាតែតម្រូវដោយជំពូកនេះ ឬដោយបទប្បញ្ញត្តិណាមួយដែលអនុវត្តជំពូកនេះ រួមមានជាអាទិ៍៖

(a) ការចូលរួម ឬការជួយ ការគ្រប់គ្រង ឬការពិនិត្យ (i) ការផ្តួចផ្តើម ឬការបង្កើតសហជីពបែបនេះណាមួយ ឬ (ii) ការប្រជុំ ការគ្រប់គ្រង ប្រតិបត្តិការ ការបោះឆ្នោត ការបង្កើត ឬវិសោធនកម្មលក្ខន្តិកៈ ច្បាប់ ឬគោលនយោបាយរបស់សហជីពបែបនេះណាមួយ។

(b) ការផ្តល់គ្រឿងលើកទឹកចិត្តដល់ TNDs ដើម្បីចូលរួមក្នុងសហជីពបែបនេះណាមួយ។

(c) ការបរិច្ចាគសេវា សម្ភារ បរិក្ខារ ការិយាល័យ ឬកន្លែងប្រជុំ ឬអ្វីផ្សេងទៀតដែលមានតម្លៃសម្រាប់ការប្រើប្រាស់របស់សហជីពបែបនេះដោយមិនគិតថ្លៃ ក្នុងលក្ខខណ្ឌដែលថា TNC មិនត្រូវបានហាមឃាត់មិនអនុញ្ញាតឱ្យកម្មករនិយោជិតធ្វើការងារតំណាងដែលត្រូវបានការពារក្រោមជំពូកនេះក្នុងអំឡុងពេលម៉ោងធ្វើការ ដោយមិនបាត់បង់ពេលវេលា ឬប្រាក់ឈ្នួល ឬមិនអនុញ្ញាតឱ្យភ្នាក់ងាររបស់សហជីព TND ដែលជាតំណាងផ្តាច់មុខរបស់កម្មករនិយោជិតបណ្តាញរបស់ខ្លួនពីការជួបជាមួយកម្មករនិយោជិតនៅក្នុងបរិវេណទីធ្លារបស់ខ្លួន។

8. តម្រូវឱ្យ TND ចូលរួមក្នុងសហជីពក្រុមហ៊ុន ឬសហជីព TND ណាមួយ ឬតម្រូវឱ្យ TND មិនត្រូវបង្កើត ឬចូលរួមឬជួយសហជីព TND តាមជម្រើសរបស់ពួកគេផ្ទាល់។

9. លើកទឹកចិត្តសមាជិកភាពក្នុងសហជីពក្រុមហ៊ុនណាមួយ ឬបង្អាក់ទឹកចិត្តសមាជិកភាពក្នុងសហជីព TND ណាមួយ តាមរយៈការរើសអើងទាក់ទងនឹងការជួលការផ្តល់តួនាទី ឬក្នុងលក្ខខណ្ឌ ឬអណត្តិការងារ ឬការចូលរួមណាមួយ។

10. បណ្តេញចេញពីការងារ ឬរើសអើងប្រឆាំងនឹង TND ដោយសារតែពួកគេបានចុះហត្ថលេខា ឬដាក់លិខិតភស្តុតាង ញត្តិ ឬពាក្យបណ្តឹង ឬផ្តល់ព័ត៌មាន ឬសក្ខីកម្មណាមួយនៅក្រោមជំពូកនេះ។

11. ចែកចាយ ឬផ្សព្វផ្សាយបញ្ជីខ្មៅណាមួយរបស់បុគ្គលដែលអនុវត្តសិទ្ធិណាមួយដែលបានបង្កើត ឬបញ្ជាក់ដោយជំពូកនេះ ឬសមាជិករបស់សហជីព TND ឬជូនដំណឹងដល់បុគ្គលណាម្នាក់អំពីការអនុវត្តសិទ្ធិនោះដោយបុគ្គលណាម្នាក់ ឬអំពីសមាជិកភាពរបស់បុគ្គលណាម្នាក់នៅក្នុងសហជីព TND ក្នុងគោលបំណងរារាំងបុគ្គលដែលជាប់ក្នុងបញ្ជីខ្មៅ ឬមានឈ្មោះដូច្នេះ មិនឱ្យទទួលបាន ឬរក្សាបាននូវឱកាសសម្រាប់ប្រាក់សំណង។

12. ធ្វើសកម្មភាពណាមួយ ក្រៅពីអ្វីដែលបានរៀបរាប់រួចហើយនៅក្នុងផ្នែកនេះ ដែលជ្រៀតជ្រែក រារាំង ឬបង្ខិតបង្ខំ TNDs ក្នុងការអនុវត្តសិទ្ធិដែលធានាដោយជំពូកនេះ។

B. ជាការប្រតិបត្តិការងារមិនត្រឹមត្រូវសម្រាប់សហជីព TND ក្នុងការ៖

1. បដិសេធមិនព្រមចរចាជាសមូហភាពដោយស្មោះត្រង់ជាមួយ TNC ប្រសិនបើខ្លួនគឺជាអ្នកតំណាងដែលមានការបញ្ជាក់ ឬទទួលស្គាល់ពីកម្មករនិយោជិតរបស់ក្រុមហ៊ុន។ ដោយសារកាតព្វកិច្ចក្នុងការចរចាដោយស្មោះត្រង់រួមមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានដែលទាក់ទងនឹងដំណើរការចរចាតាមការស្នើសុំ វាក៏ជាការប្រតិបត្តិការងារមិនត្រឹមត្រូវផងដែរសម្រាប់ TND ដែលបានបញ្ជាក់ឬទទួលស្គាល់ ក្នុងការបដិសេធមិនផ្តល់ព័ត៌មានដែលស្នើដោយសហជីព TNC ពាក់ព័ន្ធនឹងដំណើរការចរចា។

2. រារាំង ឬបង្ខិតបង្ខំ TNDs ក្នុងការអនុវត្តសិទ្ធិដែលធានាដោយជំពូកនេះ ដែលទោះជាយ៉ាងណាក៏ដោយ កថាខណ្ឌនេះនឹងមិនរារាំងសិទ្ធិរបស់សហជីព TND ក្នុងការកំណត់ច្បាប់របស់ខ្លួនទាក់ទងនឹងការទទួលបាន ឬរក្សាសមាជិកភាពនៅក្នុងសហជីពនោះទេ។

3. ខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើជាតំណាងដោយយុត្តិធម៌សម្រាប់ TNDs ដែលខ្លួនគឺជាអ្នកតំណាងចរចាផ្តាច់មុខដោយទង្វើ ឬការលុបចោលដែលបំពាន រើសអើង ឬដោយអសុទ្ធចិត្ត។

4. រារាំង ឬបង្ខិតបង្ខំ TNC ក្នុងការជ្រើសរើសអ្នកតំណាងរបស់ខ្លួន ក្នុងគោលបំណងចរចា ឬកែតម្រូវបណ្តឹងសារទុក្ខ។

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

C. ការទប់ស្កាត់ការប្រតិបត្តិការងារមិនត្រឹមត្រូវ

1. ក្រុមប្រឹក្សាត្រូវបានផ្តល់សិទ្ធិអំណាច និងដឹកនាំ ដូចដែលបានចែងនៅខាងក្រោមនេះ ដើម្បីការពារ TNC និងសហជីព TND ណាមួយមិនឱ្យចូលរួមក្នុងការប្រតិបត្តិការងារមិនត្រឹមត្រូវណាមួយ ដែលបានបរិយាយនៅក្នុងជំពូកនេះ។ អំណាចនេះមិនត្រូវប៉ះពាល់ ឬរារាំងដោយមធ្យោបាយណាមួយនៃការកែតម្រូវ ការសម្របសម្រួល ឬការផ្សះផ្សាក្នុងវិវាទការងារដែលក្រោយពីនោះត្រូវបាន ឬអាចនឹងត្រូវបានបង្កើតឡើងដោយច្បាប់ ឬដោយលក្ខខណ្ឌដែលមានចែងក្នុងផ្នែកទី 6 (F) ខាងក្រោមឡើយ។ ទប់ស្កាត់ការប្រតិបត្តិការងារមិនត្រឹមត្រូវ ដែល TNC នីមួយៗត្រូវផ្ញើសារជាអក្សរ និងអ៊ីមែល យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ទៅកាន់ TNDs សកម្មនីមួយៗក្នុងទម្រង់ដែលកំណត់ដោយក្រុមប្រឹក្សា ដោយជូនដំណឹងដល់ TNDs អំពីសិទ្ធិរបស់ពួកគេនៅក្រោមជំពូកនេះ និងនីតិវិធីសម្រាប់ការដាក់ពាក្យចោទប្រកាន់អំពីការប្រតិបត្តិការងារមិនត្រឹមត្រូវ។ ក្រុមប្រឹក្សាក៏ត្រូវផ្សព្វផ្សាយច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះនៅលើគេហទំព័ររបស់ខ្លួនផងដែរ។

2. នៅពេលណាដែលមានការចោទប្រកាន់ថា សហជីព TNC ឬ TND ណាមួយបានចូលរួម ឬកំពុងចូលរួមក្នុងការប្រតិបត្តិការងារមិនត្រឹមត្រូវបែបនេះ ក្រុមប្រឹក្សា ឬភ្នាក់ងារ ឬទីភ្នាក់ងារណាមួយដែលត្រូវបានចាត់តាំងដោយក្រុមប្រឹក្សាសម្រាប់គោលបំណងបែបនេះ នឹងត្រូវមានអំណាចក្នុងការរៀបចំ ឬអនុញ្ញាតឱ្យរៀបចំពាក្យបណ្តឹងប្រឆាំង TNC ឬ TND បែបនេះ ដោយបញ្ជាក់ពីការចោទប្រកាន់ផ្សេងៗទាក់ទងនឹងបញ្ហានោះ និងដោយមានការជូនដំណឹងអំពីសវនាការនៅចំពោះមុខក្រុមប្រឹក្សា ឬសមាជិកម្នាក់ ឬនៅចំពោះមុខភ្នាក់ងារ ឬទីភ្នាក់ងារដែលមានស្រាប់នៅកន្លែងដែលបានកំណត់ ក្នុងរយៈពេលមិនតិចជាងប្រាំថ្ងៃបន្ទាប់ពីការដាក់ពាក្យបណ្តឹង។ បណ្តឹងបែបនេះណាមួយ អាចត្រូវបានកែប្រែដោយសមាជិក ភ្នាក់ងារ ឬទីភ្នាក់ងារដែលធ្វើសវនាការ ឬតាមការសម្រេចរបស់ក្រុមប្រឹក្សាក្នុងពេលណាមួយមុនពេលចេញដីកាដោយផ្អែកលើបណ្តឹងនោះ។ សហជីព TNC ឬ TND ដែលត្រូវបានប្តឹងដូច្នេះ មានសិទ្ធិដាក់ចម្លើយចំពោះបណ្តឹងដើម ឬបណ្តឹងដែលបានធ្វើវិសោធនកម្មរួច ហើយចូលខ្លួនដោយផ្ទាល់ ឬដោយមធ្យោបាយណាមួយផ្សេងទៀត ហើយផ្តល់សក្ខីកម្មនៅកន្លែង និងពេលវេលាដែលបានកំណត់ក្នុងពាក្យបណ្តឹងនោះ។ តាមការសម្រេចរបស់សមាជិក ភ្នាក់ងារ ឬទីភ្នាក់ងារដែលធ្វើសវនាការ ឬក្រុមប្រឹក្សាអ្នកផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យធ្វើបទអន្តរាគមន៍ក្នុងដំណើរការនេះ និងផ្តល់សក្ខីកម្មបាន។ នៅក្នុងដំណើរការបែបនេះណាមួយ វិធាននៃភស្តុតាងដែលមាននៅក្នុងតុលាការច្បាប់ ឬតុលាការសមធម៌ នឹងមិនមានអំណាចឡើយ។

3. ផ្អែកតាមកំណត់ត្រានៅចំពោះមុខពួកគេ ប្រសិនបើសមាជិក ភ្នាក់ងារ ឬទីភ្នាក់ងារកំណត់ថា ការប្រតិបត្តិការងារមិនត្រឹមត្រូវ ត្រូវបានប្រព្រឹត្តដោយសហជីព TNC ឬ TND ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងនោះ ពួកគេត្រូវចេញ ឬអនុញ្ញាតឱ្យចេញដីកាបញ្ជាឱ្យបុគ្គលដែលបានអនុវត្តប្រតិបត្តិការការងារមិនត្រឹមត្រូវនោះ បញ្ឈប់និងបោះបង់ចោលការប្រតិបត្តិការងារមិនត្រឹមត្រូវនោះ ហើយត្រូវចាត់វិធានការវិជ្ជមានបន្ថែមទៀត ដែលនឹងអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ រួមមាន ជាអាទិ៍ (a) ការដកការទទួលស្គាល់ និងការបដិសេធពីការចរចាជាសមូហភាពជាមួយសហជីព ឬសមាគមទីភ្នាក់ងារ ឬផែនការណាមួយដែលត្រូវបានកំណត់នៅក្នុងជំពូកនេះថាជាសហជីពរបស់ក្រុមហ៊ុន ឬត្រូវបានបង្កើតឡើង ឬត្រូវបានរក្សា ឬត្រូវបានជួយដោយសកម្មភាពណាមួយដែលបានកំណត់ក្នុងជំពូកនេះថាជាការប្រតិបត្តិការងារមិនត្រឹមត្រូវ (b) ការផ្តល់ប្រាក់ឈ្នួលត្រឡប់មកវិញ ឬការប្រគល់ត្រឡប់មកវិញនូវសំណងផ្សេងទៀតដោយគ្មានការកាត់បន្ថយណាមួយដោយផ្អែកលើប្រាក់ចំណូលបណ្តោះអាសន្នរបស់ TND ឬការមិនទទួលបានប្រាក់ចំណូលបណ្តោះអាសន្ន សំណងមិនចំពោះ និងចំនួនបន្ថែមជាប្រាក់ប៉ះប៉ូវការខូចខាតកំណត់ជាមុនតាមកិច្ចសន្យា ស្មើនឹង 2 ដងនៃចំនួនការខូចខាតដែលកើតមាន (c) ការតម្រូវឱ្យមានការភ្ជាប់ទំនាក់ទំនងឡើងវិញ ឬការបង្កើតឡើងវិញនូវទំនាក់ទំនងដែលមានស្រាប់ពីមុនរបស់ TNC ជាមួយនឹង TNDs ដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយមិនសមស្រប ដោយមានឬគ្មានសំណង ឬការថែរក្សាបញ្ជីអនុគ្រោះដែលកម្មករនិយោជិតនោះត្រូវបានភ្ជាប់ទំនាក់ទំនងឡើងវិញ ឬទំនាក់ទំនងត្រូវបានបង្កើតឡើងវិញ ហើយដីកាបែបនេះអាចនឹងតម្រូវបន្ថែមទៀតឱ្យជនជាប់ចោទនោះត្រូវធ្វើរបាយការណ៍តាមដំណាក់កាលដែលបង្ហាញពីវិសាលភាពដែលដីកានោះត្រូវបានអនុវត្តតាម។

(d) ការតម្រូវឱ្យជនជាប់ចោទផ្តល់ឱ្យដើមចោទនូវបញ្ជីឈ្មោះ TNDs ទាំងអស់ រួមទាំងអាសយដ្ឋានជាក់ស្តែង និងអ៊ីមែល និងលេខទូរសព្ទស្គាល់ច្បាស់របស់កម្មករនិយោជិតទាំងនោះ និង (e) តម្រូវឱ្យ TNC ត្រូវទទួលស្គាល់ និងចរចាជាមួយសហជីព TND ប្រសិនបើក្រុមប្រឹក្សាសម្រេចថា ការប្រតិបត្តិការងារមិនត្រឹមត្រូវនោះបានរំខានដល់សិទ្ធិរបស់ TND ក្នុងការបង្កើត ឬចូលរួមជាមួយសហជីព TND ។ ប្រសិនបើសមាជិក ភ្នាក់ងារ ឬទីភ្នាក់ងារសម្រេចថា ការប្រតិបត្តិការងារមិនត្រឹមត្រូវនោះមិនត្រូវបានប្រព្រឹត្តនោះទេ ពួកគេនឹងចេញដីកាបដិសេធបណ្តឹងតវ៉ានោះ។ ដីកាដែលចេញដោយអនុលោមតាមផ្នែករងនេះ នឹងក្លាយទៅជាដីកាស្ថាពរ និងភ្ជាប់កាតព្វកិច្ចអនុវត្ត លុះត្រាតែភាគីណាមួយស្នើសុំឱ្យក្រុមប្រឹក្សាធ្វើការពិនិត្យទាំងស្រុងឡើងវិញ ក្នុងរយៈពេលដប់ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីការចេញដីកានោះ ការពិនិត្យឡើងវិញអាចធ្វើឡើងតាមសេចក្តីថ្លែងការណ៍អំពីករណីជាលាយលក្ខណ៍អក្សរដោយសមាជិក ភ្នាក់ងារ ឬទីភ្នាក់ងារដែលយល់ព្រមដោយគូភាគី ឬតាមសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលផ្តល់ដោយគូភាគី ឬប្រសិនបើភាគីណាមួយ ឬក្រុមប្រឹក្សាស្នើសុំ តាមប្រតិចារិកនៃសក្ខីកម្មដែលបានធ្វើឡើងនៅក្នុងសវនាការ (ប្រសិនបើមាន) រួមជាមួយនឹងសក្ខីកម្មបែបនេះផ្សេងទៀត តាមដែលក្រុមប្រឹក្សាអាចនឹងតម្រូវឱ្យមាន។

ផ្អែកតាមកំណត់ត្រានៅចំពោះមុខខ្លួន ប្រសិនបើក្រុមប្រឹក្សាកំណត់ថា ការប្រតិបត្តិការងារមិនត្រឹមត្រូវមួយត្រូវបានប្រព្រឹត្តទេនោះ ខ្លួននឹងបញ្ជាក់ពីសេចក្តីសន្និដ្ឋាននៃអង្គហេតុ ហើយចេញ និងអនុញ្ញាតឱ្យចេញដីកាមួយដែលតម្រូវឱ្យសហជីព TNC ឬ TND នោះត្រូវបញ្ឈប់ និងបោះបង់ចោលនូវការប្រតិបត្តិការងារមិនត្រឹមត្រូវបែបនេះ ហើយត្រូវចាត់វិធានការជាវិជ្ជមានបន្ថែមទៀតដែលនឹងអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ។ ផ្អែកតាមកំណត់ត្រានៅចំពោះមុខ ប្រសិនបើក្រុមប្រឹក្សាកំណត់ថា ការប្រតិបត្តិការងារមិនត្រឹមត្រូវមួយមិនត្រូវបានប្រព្រឹត្តទេនោះ ខ្លួននឹងបញ្ជាក់ពីសេចក្តីសន្និដ្ឋាននៃអង្គហេតុ ហើយចេញដីកាច្រានចោលពាក្យបណ្តឹងនេះ។

4. រហូតទាល់តែកំណត់ត្រាក្នុងសំណុំរឿងមួយត្រូវដាក់នៅតុលាការ ដូចដែលបានចែង ក្រុមប្រឹក្សាអាចកែប្រែ ឬលុបចោលទាំងស្រុង ឬមួយផ្នែក នូវសេចក្តីសន្និដ្ឋាន ឬដីកាដែលខ្លួនបានធ្វើឡើង ឬចេញ នៅពេលណាក៏បាន នៅពេលមានការជូនដំណឹងសមស្រប និងតាមវិធីដែលខ្លួនយល់ឃើញថាត្រឹមត្រូវ។

5. ក្រុមប្រឹក្សាអាចចាប់ផ្តើមដំណើរការសមស្របនៅក្នុងសាលាឧទ្ធរណ៍សម្រាប់ការអនុវត្តដីកាស្ថាពររបស់ខ្លួន។

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

6. ភាគីទាំងឡាយណាដែលប៉ះពាល់ដោយដីកាស្ថាពររបស់ក្រុមប្រឹក្សានោះ អាចដំណើរការសម្រាប់ការសើរើតាមផ្លូវតុលាការនៅសាលាឧទ្ធរណ៍ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលដីកានោះ។ ដំណើរការក្នុងសាលាឧទ្ធរណ៍ ដរាបណាអាចអនុវត្តបាន ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃផ្នែកទីដប់បួននៃជំពូកទីសាមសិប A។

7. ដំណោះស្រាយបែបអធិបញ្ញា

(a) ភាគីដែលដាក់បណ្តឹងចោទប្រកាន់អំពីការប្រតិបត្តិការងារមិនត្រឹមត្រូវ នៅក្រោមផ្នែកនេះ អាចដាក់ញត្តិទៅក្រុមប្រឹក្សា ដើម្បីទទួលបានដំណោះស្រាយបែបអធិបញ្ញា ដោយរង់ចាំការសម្រេចលើទិដ្ឋភាពសំខាន់ៗនៃការចោទប្រកាន់ដោយក្រុមប្រឹក្សា ដោយផ្អែកលើការបង្ហាញថា៖ (i) មានហេតុផលសមស្របនឹងជឿថា ការប្រតិបត្តិការងារមិនត្រឹមត្រូវមួយបានកើតឡើង ហើយ (ii) ព្យសនកម្ម ការបាត់បង់ ឬការខូចខាតភ្លាមៗ និងមិនអាចជួសជុលបាន ទំនងជានឹងកើតមានដោយសារការប្រតិបត្តិការងារមិនត្រឹមត្រូវនោះ ដែលបណ្តាលឱ្យការចេញដីកាស្ថាពរផ្អែកតាមទិដ្ឋភាពនោះមិនមានប្រសិទ្ធភាព ដែលតម្រូវឱ្យមានភាពចាំបាច់ក្នុងការស្តារស្ថានការណ៍ឱ្យដូចមុនពេលកើតមានប្រតិបត្តិការងារមិនត្រឹមត្រូវ ឬរក្សាទុកអ្វីៗនាពេលបច្ចុប្បន្នឱ្យនៅដដែលដើម្បីផ្តល់ដំណោះស្រាយពេញលេញ។ ព្យសនកម្មភ្លាមៗនិងមិនអាចជួសជុលបាននេះ អាចរាប់បញ្ចូលទាំងការភ័យខ្លាចរបស់កម្មករនិយោជិតក្នុងការអនុវត្តសិទ្ធិដែលចែងក្នុងជំពូកនេះ។

(b) ក្នុងរយៈពេលដប់ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាបានទទួលញត្តិនេះ ប្រសិនបើក្រុមប្រឹក្សាកំណត់ថា ភាគីដើមចោទមួយបានបង្ហាញគ្រប់គ្រាន់ថាមានទាំងហេតុផលសមស្របនឹងជឿថាការប្រតិបត្តិការងារមិនត្រឹមត្រូវបានកើតឡើង ហើយព្យសនកម្ម ការបាត់បង់ ឬការខូចខាតភ្លាមៗនិងមិនអាចជួសជុលបាន ទំនងជានឹងកើតឡើងដោយសារការប្រតិបត្តិការងារមិនត្រឹមត្រូវនោះ ដែលបណ្តាលឱ្យការចេញដីកាស្ថាពរផ្អែកលើទិដ្ឋភាពនោះមិនមានប្រសិទ្ធភាព ដែលតម្រូវឱ្យមានភាពចាំបាច់ក្នុងការស្តារស្ថានការណ៍ឱ្យដូចមុនពេលកើតមានប្រតិបត្តិការងារមិនត្រឹមត្រូវ ឬរក្សាទុកអ្វីៗនាពេលបច្ចុប្បន្នឱ្យនៅដដែលដើម្បីផ្តល់ដំណោះស្រាយពេញលេញ ក្នុងករណីនេះ ក្រុមប្រឹក្សាត្រូវដាក់ញត្តិទៅតុលាការជាន់ខ្ពស់នៅក្នុងខោនធីណាមួយដែលការប្រតិបត្តិការងារមិនត្រឹមត្រូវបានកើតឡើង នៅពេលជូនដំណឹងដល់ភាគីទាំងអស់ ដើម្បីឱ្យមានដំណោះស្រាយបែបអធិបញ្ញាចាំបាច់ ឬប្រសិនបើក្រុមប្រឹក្សាកំណត់ថាមិនស្វែងរកដំណោះស្រាយបែបអធិបញ្ញាទេ ភាគីដើមចោទអាចស្វែងរកដំណោះស្រាយបែបអធិបញ្ញាដោយការដាក់ញត្តិទៅតុលាការជាន់ខ្ពស់ ដែលក្នុងករណីនោះក្រុមប្រឹក្សាត្រូវតែចូលរួមជាភាគីចាំបាច់។ ក្នុងករណីដែលអាចអនុវត្តបាន ក្រុមប្រឹក្សា ឬ ភាគីដើមចោទមិនតម្រូវឱ្យផ្តល់កិច្ចសន្យា ឬប្រាក់បង់ធានាណាមួយឡើយ ហើយនឹងមិនទទួលខុសត្រូវចំពោះ ការខូចខាត ឬការចំណាយដែលអាចកើតមានដោយសារដំណោះស្រាយបែបអធិបញ្ញាណាមួយដែលបានចេញនោះឡើយ។ ប្រសិនបើក្រុមប្រឹក្សាមិនមានចំណាត់ការក្នុងរយៈពេលដប់ថ្ងៃដូចដែលបានចែងនេះសម្រាប់គោលបំណងនៃការសើរើឡើងវិញនេះ ក្រុមប្រឹក្សានឹងត្រូវចាត់ទុកថាបានចេញដីកាស្ថាពរដែលកំណត់ថាមិនស្វែងរកដំណោះស្រាយបែបអធិបញ្ញា។ ក្នុងករណីមានការខកខានរបស់ TNC ក្នុងការផ្តល់នូវបញ្ជីឈ្មោះ និងអាសយដ្ឋានត្រឹមត្រូវរបស់ TNDs ព្យសនកម្ម ការបាត់បង់ ឬការខូចខាតភ្លាមៗនិងមិនអាចជួសជុលបាន នឹងត្រូវសន្មតថាកើតមាន។

(C) បន្ទាប់ពីបានស្តាប់ភាគីទាំងអស់ ដំណោះស្រាយបែបអធិបញ្ញាអាចនឹងត្រូវបានចេញដោយតុលាការ ប្រសិនបើតុលាការកំណត់ថាមានហេតុផលសមស្របនឹងជឿថាការប្រតិបត្តិការងារមិនត្រឹមត្រូវបានកើតឡើង ហើយព្យសនកម្ម ការបាត់បង់ ឬការខូចខាតភ្លាមៗនិងមិនអាចជួសជុលបាន ទំនងជានឹងកើតមានដោយសារការប្រតិបត្តិការងារមិនត្រឹមត្រូវនោះ ដែលបណ្តាលឱ្យការចេញដីកាស្ថាពរផ្អែកលើទិដ្ឋភាពនោះមិនមានប្រសិទ្ធភាព ដែលតម្រូវឱ្យមានភាពចាំបាច់ក្នុងការស្តារស្ថានការណ៍ឱ្យដូចមុនពេលកើតមានប្រតិបត្តិការងារមិនត្រឹមត្រូវ ឬរក្សាទុកអ្វីៗនាពេលបច្ចុប្បន្នឱ្យនៅដដែលដើម្បីផ្តល់ដំណោះស្រាយពេញលេញ។ ដំណោះស្រាយបែបនេះត្រូវផុតកំណត់ដោយការសម្រេចចិត្តរបស់ក្រុមប្រឹក្សាដែលរកឃើញថាមិនមានការប្រតិបត្តិការងារមិនត្រឹមត្រូវកើតឡើងឡើយ បណ្តឹងសារទុក្ខដោយជោគជ័យលើការផ្តល់ដំណោះស្រាយបែបអធិបញ្ញា ឬសកម្មភាពជនជាប់ចោទ ក្នុងការដកខ្លួនចេញ ឬកែប្រែអធិបញ្ញាដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នីតិវិធីរដ្ឋប្បវេណី។ ក្រុមប្រឹក្សាត្រូវបញ្ចប់ដំណើរការសវនាការ និងចេញសេចក្តីសម្រេចដោយផ្អែកលើទិដ្ឋភាពជាក់ស្តែងក្នុងរយៈពេលមួយរយប៉ែតសិបថ្ងៃ បន្ទាប់ពីការដាក់ចេញនូវដំណោះស្រាយបែបអធិបញ្ញានេះ ពុំនោះទេ លុះត្រាតែមានការយល់ព្រមទៅវិញទៅមកដោយភាគីចុងចោទ និងភាគីដើមចោទ។

(d) ការសម្រេចដោយផ្អែកលើទិដ្ឋភាពនៃការចោទប្រកាន់ការប្រតិបត្តិការងារមិនត្រឹមត្រូវដែលរកឃើញដោយក្រុមប្រឹក្សា ថាបានកើតឡើង ត្រូវបន្តឱ្យមានដំណោះស្រាយបែបអធិបញ្ញា រហូតទាល់តែ៖ (i) ភាគីចុងចោទធ្វើការកែតម្រូវ ឬ (ii) ភាគីចុងចោទដាក់សំណើដោយជោគជ័យឱ្យតុលាការធ្វើមោឃៈភាពដីការបស់ក្រុមប្រឹក្សា ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូក 30A នៃច្បាប់ទូទៅ។

(E) ដីកាបែបអធិបញ្ញាដែលនៅមានសុពលភាពរហូតដល់មានការសម្រេចរបស់ក្រុមប្រឹក្សា (i) ត្រូវផុតកំណត់នៅពេលដែលការសម្រេចចិត្តរបស់ក្រុមប្រឹក្សាដោយរកឃើញថាមិនមានការប្រតិបត្តិការងារមិនត្រឹមត្រូវបានកើតឡើងឡើយ ដោយក្រុមប្រឹក្សាត្រូវជូនដំណឹងទៅតុលាការក្នុងរយៈពេលពីរថ្ងៃធ្វើការ ឬ (ii) នឹងនៅតែមានសុពលភាពជាធរមានតែក្នុងកម្រិតដែលខ្លួនអនុវត្តដីកាដំណោះស្រាយដែលចេញដោយក្រុមប្រឹក្សាតាមការសម្រេចរបស់ខ្លួន ដែលក្រុមប្រឹក្សាត្រូវជូនដំណឹងដល់តុលាការក្នុងរយៈពេលពីរថ្ងៃធ្វើការ។

(f) ការប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាណាមួយដែលចេញ បដិសេធ កែប្រែ ឬលុបចោលដំណោះស្រាយបែបអធិបញ្ញាដែលតុលាការបានចេញ ដោយអនុលោមតាមផ្នែករងនេះ ត្រូវធ្វើឡើងស្របតាមវិធាននៃនីតិវិធីបណ្តឹងឧទ្ធរណ៍។

(g) លើកលែងតែមានចែងក្នុងផ្នែកនេះ ការសើរើតាមផ្លូវតុលាការចំពោះដីកាដែលចេញដោយក្រុមប្រឹក្សាត្រូវដូចមានចែងសម្រាប់ផ្នែក 9 ខាងក្រោម។

ផ្នែក 5. អ្នកតំណាង

A. បន្ទាប់ពីទទួលបានព័ត៌មានដែលបានកំណត់នៅក្នុងផ្នែកទី 2(A) ពី TNC នីមួយៗ នៅដំណាច់ត្រីមាសប្រតិទិននីមួយៗ (ថ្ងៃទី 31 ខែមីនា ថ្ងៃទី 30 ខែមិថុនា ថ្ងៃទី 30 ខែកញ្ញា ថ្ងៃទី 31 ខែធ្នូ) ក្រុមប្រឹក្សាត្រូវផ្តល់ឱ្យ TNC នីមួយៗនូវឈ្មោះរបស់ TNDs សកម្មដែលមានបើកបរឱ្យ TNC នោះ ហើយ TNC នីមួយៗត្រូវមានពេល 30 ថ្ងៃដើម្បីដាក់ជូនក្រុមប្រឹក្សា ជាទម្រង់អេឡិចត្រូនិកដែលត្រូវកំណត់ដោយក្រុមប្រឹក្សានូវលេខទូរសព្ទ អាសយដ្ឋានផ្ញើសំបុត្រ និងអាសយដ្ឋានអ៊ីមែលសម្រាប់ TND សកម្មនីមួយៗ។ ព័ត៌មានលម្អិតទាំងនេះមិនត្រូវបង្ហាញឱ្យឃើញដោយយោងតាមជំពូកទី 66 នៃច្បាប់ទូទៅឡើយ។

B. អង្គភាពចរចា សម្រាប់គោលបំណងនៃជំពូកនេះ TND នឹងត្រូវបានរាប់បញ្ចូលនៅក្នុងអង្គភាពចរចាទាំងមូលនៃឧស្សាហកម្មរបស់ TNDs ទាំងអស់។

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

C. ការបង្ហាញការចាត់តាំងតំណាង សហជីព TND អាចបង្ហាញថា ខ្លួនត្រូវបានចាត់តាំងជាអ្នកតំណាងចរចាដោយបង្ហាញកាតក្រុមប្រឹក្សា ញត្តិ ឬភស្តុតាងផ្សេងទៀតដែលអាចជាទម្រង់អេឡិចត្រូនិក ដែលគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា TND បានអនុញ្ញាតឱ្យសហជីព TND ដើរតួជាអ្នកតំណាងចរចាផ្តាច់មុខរបស់កម្មករនិយោជិត។ ដើម្បីឱ្យមានសុពលភាព កាត ញត្តិ ឬភស្តុតាងផ្សេងទៀត ត្រូវតែត្រូវបានចុះហត្ថលេខាដោយកម្មករនិយោជិតក្នុងរយៈពេលមួយឆ្នាំនៃកាលបរិច្ឆេទដែលសហជីព TND ដាក់ជូនភស្តុតាងទាំងនោះទៅក្រុមប្រឹក្សា។ ការចុះហត្ថលេខាអាចធ្វើឡើងតាមអេឡិចត្រូនិក។

D. ស្ថានភាពអ្នកតំណាង

1. តាមការស្នើសុំរបស់សហជីព TND ក្រុមប្រឹក្សាត្រូវធ្វើការសម្រេចចិត្តថា សហជីពនោះត្រូវបានចាត់តាំងជាអ្នកតំណាងចរចាយ៉ាងហោចណាស់ចំនួនប្រាំភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចា។

2. នៅពេលដែលក្រុមប្រឹក្សាសម្រេចថា សហជីព TND ត្រូវបានចាត់តាំងជាអ្នកតំណាងចរចាយ៉ាងហោចណាស់ចំនួនប្រាំភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចា ក្រុមប្រឹក្សាត្រូវ (a) តម្រូវឱ្យ TNC នីមួយៗធ្វើការជូនដំណឹងជាទម្រង់ដែលកំណត់ដោយក្រុមប្រឹក្សាថា សហជីព TND កំពុងស្វែងរកតំណាង TNDs ក្នុងគោលបំណងផ្តួចផ្តើមដំណើរការចរចាដើម្បីបង្កើតលក្ខខណ្ឌសម្រាប់ឧស្សាហកម្មនោះ និង (b) ផ្តល់ឱ្យសហជីព TND នូវបញ្ជីឈ្មោះ លេខទូរសព្ទ អាសយដ្ឋានប្រៃសណីយ៍ និងអាសយដ្ឋានអ៊ីមែលសម្រាប់ TND សកម្មទាំងអស់នៅក្នុងអង្គភាពចរចា។ ក្រុមប្រឹក្សានឹងផ្តល់ឱ្យសហជីព TND នូវបញ្ជីឈ្មោះដែលបានធ្វើបច្ចុប្បន្នភាពរួចនៅត្រីមាសនីមួយៗសម្រាប់ឆ្នាំបន្ទាប់។ សម្រាប់រយៈពេលប្រាំមួយខែគិតចាប់ពីកាលបរិច្ឆេទនៃការសម្រេចរបស់ក្រុមប្រឹក្សាដែលថាសហជីព TND បានបំពេញតាមចំនួនកម្រិតប្រាំភាគរយនៅក្នុងអង្គភាពចរចាហើយ គ្មានសហជីព TND ផ្សេងទៀតអាចនឹងត្រូវបានបញ្ជាក់ថាជាអ្នកតំណាងចរចាផ្តាច់មុខរបស់កម្មករនិយោជិតទាំងនោះដោយគ្មានការបោះឆ្នោតនោះឡើយ។

3. ស្ថានភាពអ្នកតំណាងផ្តាច់មុខ សហជីព TND ដែលផ្តល់ភស្តុតាងដល់ក្រុមប្រឹក្សាថាខ្លួនត្រូវបានចាត់តាំងជាអ្នកតំណាងចរចាដោយចំនួនម្ភៃប្រាំភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចា នឹងត្រូវបានបញ្ជាក់ជាអ្នកតំណាងចរចាផ្តាច់មុខរបស់ TNDs ទាំងអស់នៅក្នុងអង្គភាពចរចា។ ផ្ទុយទៅវិញ សហជីព TND ដែលត្រូវបានចាត់តាំងជាអ្នកតំណាងចរចាយ៉ាងហោចណាស់ចំនួនប្រាំភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចា អាចដាក់ញត្តិទៅក្រុមប្រឹក្សាដើម្បីរៀបចំការបោះឆ្នោត។ ការបោះឆ្នោតត្រូវធ្វើឡើងឱ្យបានលឿនតាមដែលអាចទៅធ្វើបាន ហើយប្រសិនបើសហជីព TND ទទួលបានសំឡេងឆ្នោត ភាគច្រើនដែលមានសុពលភាព សហជីពនោះនឹងត្រូវបានបញ្ជាក់ថាជាអ្នកតំណាងចរចាផ្តាច់មុខ។

4. ការសម្រេចចំពោះស្ថានភាពតំណាងផ្តាច់មុខនៅក្នុងព្រឹត្តិការណ៍នៃវិវាទក្នុងចំណោមសហជីព TND ។

(a) ប្រសិនបើសហជីព TND ស្វែងរកការបញ្ជាក់ជាអ្នកតំណាងចរចាផ្តាច់មុខផ្តល់ភស្តុតាងដែលបង្ហាញថា តិចជាងចំនួនភាគច្រើននៃ TNDs សកម្មបានចាត់តាំងសហជីព TND ជាអ្នកតំណាងចរចារបស់ពួកគេ ក្រុមប្រឹក្សាត្រូវរង់ចាំរយៈពេលប្រាំពីរថ្ងៃមុននឹងបញ្ជាក់ថា សហជីព TND នោះជាអ្នកតំណាងចរចាផ្តាច់មុខ។ ក្នុងអំឡុងពេលប្រាំពីរថ្ងៃ ប្រសិនបើសហជីព TND មួយផ្សេងទៀតផ្តល់ភស្តុតាងថា យ៉ាងហោចណាស់ចំនួន 25 ភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចាបានចាត់តាំងខ្លួនជាតំណាងចរចារបស់ពួកគេ ឬ TND មួយផ្តល់ភស្តុតាងថា យ៉ាងហោចណាស់ 25 ភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចា មិនមានបំណងចង់ឱ្យសហជីព TND ណាមួយចាត់តាំងខ្លួនជាតំណាងទេនោះ ក្រុមប្រឹក្សាត្រូវរៀបចំការបោះឆ្នោតក្នុងចំណោម TNDs សកម្មទាំងអស់នៅក្នុងអង្គភាពចរចា។ ការបោះឆ្នោតនេះត្រូវធ្វើឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ សហជីព TND ដែលទទួលបានសំឡេងភាគច្រើនត្រឹមត្រូវនឹងត្រូវបានបញ្ជាក់ជាអ្នកតំណាងចរចាផ្តាច់មុខរបស់ TNDs ទាំងអស់នៅក្នុងអង្គភាពចរចា។ នៅពេលដែលសហជីព TND ពីរ ឬច្រើនមាននៅលើសន្លឹកឆ្នោត ហើយគ្មានជម្រើសណាមួយ (សហជីព TND ឬ "គ្មានសហជីពកម្មករនិយោជិត") ទទួលបានសំឡេងភាគច្រើនដែលមានសុពលភាព នោះនឹងត្រូវមានការបោះឆ្នោតបន្ត (Run-off election) រវាងជម្រើសទាំងពីរដែលទទួលបានចំនួនសន្លឹកឆ្នោតច្រើនជាងគេបំផុត និងចំនួនសន្លឹកឆ្នោតច្រើនជាងគេបំផុតទីពីរ។ សហជីពTND ដែលទទួលបានសន្លឹកឆ្នោតភាគច្រើនដែលមានសុពលភាពក្នុងការបោះឆ្នោតបន្តនឹងត្រូវបានបញ្ជាក់ថាជាអ្នកតំណាងចរចាផ្តាច់មុខរបស់ TNDs ទាំងអស់នៅក្នុងអង្គភាពចរចា ហើយសហជីពនោះនឹងជំពាក់កាតព្វកិច្ចដើម្បីធ្វើជាតំណាងឱ្យកម្មករនិយោជិតទាំងនោះដោយយុត្តិធម៌។ ប្រសិនបើភាគច្រើនសន្លឹកឆ្នោតដែលមានសុពលភាពគឺ បោះឱ្យ "គ្មានអង្គការកម្មករ" នោះក្រុមប្រឹក្សានឹងមិនបញ្ជាក់សហជីពកម្មករនិយោជិតណាមួយ ជាអ្នកតំណាងចរចាផ្តាច់មុខនោះទេ។ សម្រាប់គោលបំណងបទប្បញ្ញត្តិនេះ បញ្ជីប្រតិបត្តិការរបស់ TNDs សកម្មត្រូវផ្អែកលើបញ្ជីប្រចាំត្រីមាសចុងក្រោយបំផុតដែលផ្តល់ដោយ TNCs ស្របតាមផ្នែកទី 5(A)។

(b) សហជីព TND ដែលត្រូវបានបញ្ជាក់ជាអ្នកតំណាងចរចាផ្តាច់មុខ នឹងមានសិទ្ធិអំណាចផ្តាច់មុខដើម្បីតំណាងឱ្យ TNDs នៅក្នុងអង្គភាពចរចា ដោយគ្មានបញ្ហាប្រឈមជាមួយសហជីព TND ផ្សេងទៀត សម្រាប់រយៈពេល (i) វែងជាងមួយឆ្នាំបន្ទាប់ពីការបញ្ជាក់ ឬ (ii) សម្រាប់រយៈពេលដែលសម្រេចចុងក្រោយដោយរដ្ឋមន្ត្រីការងារ ក្រោមផ្នែកទី 6 (F) ចូលជាធរមាន ប្រសិនបើរយៈពេលនោះមិនលើសពីបីឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចចុងក្រោយនេះ។ ក្នុងអំឡុងពេលដែលអ្នកតំណាងចរចាផ្តាច់មុខត្រូវប្រឈមមុខនឹងបញ្ហា TNDs អាចនឹងដាក់ពាក្យសុំធ្វើមោឃៈភាពការបោះឆ្នោត ដោយបង្ហាញថាយ៉ាងហោចណាស់ចំនួនម្ភៃប្រាំភាគរយនៃ TNDs សកម្មនៅក្នុងអង្គភាពចរចាបានបង្ហាញពីការគាំទ្រសម្រាប់ការធ្វើមោឃៈភាពនេះ។ បន្ទាប់មកក្រុមប្រឹក្សានឹងកំណត់ពេលបោះឆ្នោតដើម្បីកំណត់ថាតើសហជីព TND បានរក្សាឋានៈរបស់ខ្លួនជាអ្នកតំណាងចរចាផ្តាច់មុខដែរឬទេ។ សហជីព TND ត្រូវរក្សាឋានៈរបស់ខ្លួនជាអ្នកតំណាងចរចាផ្តាច់មុខ ប្រសិនបើខ្លួនទទួលបានសន្លឹកឆ្នោតភាគច្រើនត្រឹមត្រូវដែលបោះដោយ TNDs សកម្មនៅក្នុងអង្គភាពចរចា។

(C) ប្រសិនបើសហជីព TND ត្រូវបានចាត់តាំងជាអ្នកតំណាងចរចាផ្តាច់មុខទាក់ទងនឹងអង្គភាពចរចា មានតែសហជីព TND ប៉ុណ្ណោះដែលមានសិទ្ធិ (i) ទទួលបានពី TNCs នូវបញ្ជី TNDs ទាំងអស់របស់ពួកគេ រួមជាមួយនឹងលេខទូរសព្ទ អាសយដ្ឋានផ្ញើសំបុត្រ និងអាសយដ្ឋានអ៊ីមែល និង (ii) មានសិទ្ធិចូលរួមក្នុងការចរចាជាមួយ TNCs សម្រាប់ផ្តល់ជាអនុសាសន៍ដល់រដ្ឋមន្ត្រីការងារទាក់ទងនឹងប្រាក់ឈ្នួល អត្ថប្រយោជន៍ និងលក្ខខណ្ឌការងាររបស់ TNDs ។

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

(D) ការកាត់កងប្រាក់ថ្លៃសមាជិកភាព សហជីព TND ដែលត្រូវបានចាត់តាំងជាអ្នកតំណាងចរចាផ្តាច់មុខទាក់ទងនឹងអង្គភាពចរចាត្រូវមានសិទ្ធិក្នុងការកាត់ប្រាក់ថ្លៃសមាជិកភាពដោយស្ម័គ្រចិត្ត នៅពេលបង្ហាញបណ្ណអនុញ្ញាតការកាត់កងដែលចុះហត្ថលេខាដោយ TNDs ផ្ទាល់ ដែលអាចធ្វើឡើងជាទម្រង់អេឡិចត្រូនិក។ TNC នឹងចាប់ផ្តើមធ្វើការកាត់ប្រាក់បែបនេះឱ្យបានឆាប់តាមដែលអាចអនុវត្តបាន ប៉ុន្តែក្នុងករណីណាក៏ដោយមិនត្រូវយូរជាងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីទទួលបានភស្តុតាងបញ្ជាក់បណ្ណអនុញ្ញាតការកាត់ប្រាក់ដែលបានចុះហត្ថលេខា ហើយការបង់ប្រាក់ត្រូវដាក់ជូនទៅសហជីព TND ក្នុងរយៈពេលសាមសិបថ្ងៃពីការកាត់ប្រាក់នេះ។ TNC នឹងទទួលយកការអនុញ្ញាតដែលបានចុះហត្ថលេខាដើម្បីកាត់ប្រាក់បង់ក្នុងទម្រង់ណាមួយដែលត្រូវបានអនុញ្ញាតដោយជំពូកទី 11OG នៃច្បាប់ទូទៅ។ សិទ្ធិក្នុងការកាត់ប្រាក់ថ្លៃសមាជិកភាពនេះ នឹងនៅតែមានជាធរមាន និងមានសុពលភាពរហូតដល់សមាជិក ដកសមាជិកភាពរបស់ខ្លួនពីសហជីព TND ជាលាយលក្ខណ៍អក្សរ ស្របតាមលក្ខខណ្ឌនៃការអនុញ្ញាតដែលបានចុះហត្ថលេខា។

ផ្នែក 6. ការចរចា នីតិវិធីដោះស្រាយភាពជាប់គាំង និងការសម្រេចចុងក្រោយដោយរដ្ឋមន្ត្រីការងារ។

A. នៅពេលដែលក្រុមប្រឹក្សាសម្រេចថា សហជីព TND គឺជាអ្នកតំណាងចរចាផ្តាច់មុខសម្រាប់អង្គភាពចរចា ក្រុមប្រឹក្សាត្រូវជូនដំណឹងដល់ TNCs ទាំងអស់ ហើយ TNCs ទាំងអស់នឹងតម្រូវឱ្យចរចាជាមួយអ្នកតំណាងចរចាផ្តាច់មុខទាក់ទងនឹងប្រាក់ឈ្នួល អត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ។ លក្ខខណ្ឌដែលត្រូវចរចារួមមាន ប៉ុន្តែមិនត្រូវបានកំណត់ត្រឹមតែ លក្ខណៈវិនិច្ឆ័យសម្រាប់ការបញ្ឈប់ TND និងនីតិវិធីដោះស្រាយវិវាទដើម្បីដោះស្រាយបណ្តឹងដែលចោទប្រកាន់អំពីការបញ្ឈប់ដោយអយុត្តិធម៌។ ដើម្បីជួយសម្រួលដល់ការចរចា TNCs អាចបង្កើតសមាគមឧស្សាហកម្មមួយដើម្បីចរចាជំនួសពួកគេបាន។ ប្រសិនបើ TNCs ជ្រើសរើសមិនបង្កើតសមាគមទេ កិច្ចព្រមព្រៀងដែលបានណែនាំណាមួយត្រូវតែបានអនុម័តដោយ (i) TNCs សមាជិកឧស្សាហកម្មយ៉ាងហោចណាស់ចំនួនពីររូប និង (ii) សមាជិក TNCs ដែលតំណាងឱ្យយ៉ាងហោចណាស់ប៉ែតសិបភាគរយនៃភាគហ៊ុនទីផ្សាររបស់ឧស្សាហកម្មនោះនៅក្នុងរដ្ឋម៉ាសាឈូសិត ដោយមានការបោះឆ្នោតកំណត់តាមសមាមាត្រទៅនឹងចំនួននៃការជិះដែលបានសម្រេចដោយ TNDs ដែលចុះកិច្ចសន្យាដោយផ្ទាល់ជាមួយ TNC នៅក្នុងពីរត្រីមាសតាមប្រតិទិន មុនការទទួលស្គាល់ជាអ្នកតំណាងដែលបានបញ្ជាក់។

B. នៅពេលដែលសហជីព TND និង TNCs សម្រេចបានបណ្តុំអនុសាសន៍ដែលបានចរចាសម្រាប់ឧស្សាហកម្មនេះហើយ អនុសាសន៍ដែលបានចរចានោះនឹងត្រូវដាក់ជូនដោយសហជីព TND ដើម្បីទទួលការបោះឆ្នោតដោយ TNDs ទាំងអស់នៅក្នុងឧស្សាហកម្មដែលសម្រេចបានការធ្វើដំណើរយ៉ាងហោចណាស់មួយរយដងនៅក្នុងត្រីមាសមុន។ ប្រសិនបើត្រូវបានអនុម័តដោយសន្លឹកឆ្នោតភាគច្រើនរបស់ TNDs អនុសាសន៍ដែលបានចរចាត្រូវដាក់ជូនទៅរដ្ឋមន្ត្រីការងារដើម្បីអនុម័ត។ ប្រសិនបើភាគច្រើននៃសន្លឹកឆ្នោតត្រឹមត្រូវដែលបោះដោយ TNDs គឺមិនពេញចិត្តនឹងអនុសាសន៍ដែលបានចរចានោះ សហជីពកម្មករនិយោជិតក្នុងបណ្តាញដឹកជញ្ជូន និង TNCs នឹងបន្តការចរចាគ្នាឡើងវិញ។

C. សម្រាប់គោលបំណងនៃផ្នែកនេះ ភាពជាប់គាំងអាចនឹងត្រូវបានចាត់ទុកថាកើតមានប្រសិនបើ TNCs និងអ្នកតំណាងចរចាផ្តាច់មុខមិនអាចសម្រេចបានកិច្ចព្រមព្រៀងមួយនៅត្រឹម ដោយចុងបញ្ចប់នៃរយៈពេលមួយរយប៉ែតសិបថ្ងៃចាប់ពីថ្ងៃដែលសហជីព TND ត្រូវបានចាត់តាំងជាអ្នកតំណាងការចរចាផ្តាច់មុខ ឬចាប់ពីកាលបរិច្ឆេទផុតកំណត់នៃការសម្រេចជាមុនដោយរដ្ឋមន្ត្រីការងារ ដូចមានចែងក្នុងកថាខណ្ឌ F ខាងក្រោម។

D. នៅពេលមានភាពជាប់គាំង TNCs ណាមួយដែលរងផលប៉ះពាល់ ឬអ្នកតំណាងចរចាផ្តាច់មុខអាចស្នើសុំក្រុមប្រឹក្សាដើម្បីផ្តល់ជំនួយដូចមានចែងនៅក្នុងផ្នែកនេះ។

E. នៅពេលទទួលបានសំណើទាន់ពេលវេលាពីអ្នកតំណាងចរចាផ្តាច់មុខសម្រាប់ការចាប់ផ្តើមដំណើរការភាពជាប់គាំង ក្រុមប្រឹក្សាត្រូវជួយភាគីដូចខាងក្រោម៖

1. ដើម្បីជួយភាគីក្នុងការដោះស្រាយវិវាទដោយស្ម័គ្រចិត្តឱ្យមានប្រសិទ្ធភាព ក្រុមប្រឹក្សាត្រូវតែងតាំងអ្នកសម្រុះសម្រួលពីបញ្ជីបុគ្គលដែលមានសមត្ថភាពដែលគ្រប់គ្រងដោយក្រុមប្រឹក្សា ដែលគូភាគីមានសេរីភាពក្នុងការជ្រើសរើសអ្នកសម្រុះសម្រួលតាមការពេញចិត្តរបស់ពួកគេ ឬបដិសេធការជ្រើសរើសនោះ។

2. ប្រសិនបើអ្នកសម្រុះសម្រួលមិនអាចសម្រេចបានកិច្ចព្រមព្រៀងរវាងគូភាគីទាក់ទងនឹងដំណោះស្រាយសមស្របមួយក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីក្រុមប្រឹក្សាបានផ្តល់បញ្ជីអ្នកសម្រុះសម្រួល ភាគីណាមួយអាចដាក់ញត្តិទៅក្រុមប្រឹក្សាដើម្បីបញ្ជូនវិវាទទៅមជ្ឈត្តករមួយរូប។

3. តាមការស្នើសុំទាន់ពេលវេលារបស់ភាគីណាមួយ ក្រុមប្រឹក្សាត្រូវបញ្ជូនវិវាទនេះទៅមជ្ឈត្តករ ដូចដែលបានចែងនៅពេលក្រោយ។

(A) មុនពេលបញ្ជូនវិវាទទៅមជ្ឈត្តករ ក្រុមប្រឹក្សាត្រូវរៀបចំការបោះឆ្នោតក្នុងចំណោម TNDs ទាំងអស់នៅក្នុងឧស្សាហកម្មដែលបានសម្រេចយ៉ាងហោចណាស់មួយរយជើងធ្វើដំណើរក្នុងត្រីមាសមុន។ TNDs នឹងជ្រើសរើសរវាងការដាក់ជូនវិវាទទៅមជ្ឈត្តករ ឬការធ្វើមោឃៈភាពអ្នកតំណាងចរចាផ្តាច់មុខ។ ប្រសិនបើភាគច្រើននៃការបោះឆ្នោតដែលមានសិទ្ធិត្រូវបានបោះឆ្នោតសម្រាប់ការធ្វើមោឃៈភាព អ្នកតំណាងចរចាផ្តាច់មុខនឹងត្រូវបានធ្វើមោឃៈភាព ហើយបទប្បញ្ញត្តិដែលមានស្រាប់ណាមួយនឹងនៅដដែលរហូតដល់ផុតកំណត់ដូចមានចែងក្នុងកថាខណ្ឌ F ខាងក្រោម។

(b). ប្រសិនបើភាគច្រើននៃ TNDs ដែលបោះឆ្នោតជ្រើសរើសមជ្ឈត្តករដែលបានតែងតាំង អ្នកតំណាងចរចាផ្តាច់មុខត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាអំពីតម្រូវការក្នុងការតែងតាំងមជ្ឈត្តករ ហើយក្រុមប្រឹក្សាត្រូវជូនដំណឹងដល់ TNCs អំពីសំណើនេះ។ ក្រុមនីមួយៗរបស់ភាគីដែលរងផលប៉ះពាល់ (TNCs ដែលរងផលប៉ះពាល់គឺជាក្រុមមួយ ហើយអ្នកតំណាងចរចាផ្តាច់មុខគឺជាក្រុមមួយទៀត) នឹងមានឥទ្ធិពលស្មើគ្នាក្នុងការជ្រើសរើសមជ្ឈត្តករ ហើយក្រុមនីមួយៗក្នុងចំណោមក្រុមទាំងពីរត្រូវមានចំណែកស្មើគ្នាសម្រាប់ថ្លៃចំណាយរបស់មជ្ឈត្តករ។ ប្រសិនបើគូភាគីមិនអាចយល់ស្របលើមជ្ឈត្តករក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាបានជូនដំណឹងដល់ TNCs អំពីតម្រូវការក្នុងការតែងតាំងមជ្ឈត្តករ នោះក្រុមប្រឹក្សាត្រូវដាក់ជូនគូភាគីនូវបញ្ជីបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមិនពាក់ព័ន្ធនឹងផលប្រយោជន៍ សម្រាប់ការជ្រើសរើសជាមជ្ឈត្តករ។ តំណាងរបស់ក្រុមនីមួយៗ ក្នុងចំណោមក្រុមទាំងពីរត្រូវ

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

ដកចេញឆ្លាស់គ្នាពីបញ្ជីឈ្មោះទីមួយ តាមលំដាប់នៃការដកចេញដែលកំណត់ដោយចំនួនច្រើន រហូតដល់បុគ្គលម្នាក់ដែលនៅសល់ត្រូវបានចាត់តាំងជាមជ្ឈត្តករ។ ក្រុមនីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនសម្រាប់គោលបំណងនេះ តាមការយល់ឃើញថាសមស្រប។ ការខកខានរបស់ក្រុមមួយក្នុងការយល់ព្រមលើការតែងតាំងតំណាងរបស់ខ្លួន នឹងនាំឱ្យមានការខកខានចំពោះនីតិវិធីដកចេញ ប៉ុន្តែមិនមានឧបសគ្គដល់ការតែងតាំងមជ្ឈត្តកររបស់ក្រុមប្រឹក្សានៅពេលមានការខកខានបែបនេះកើតឡើងឡើយ។ ដំណើរការដកចេញត្រូវបញ្ចប់ក្នុងរយៈពេលប្រាំថ្ងៃបន្ទាប់ពីទទួលបានបញ្ជីឈ្មោះរបស់ក្រុមប្រឹក្សាភិបាល។ អ្នកតំណាងដែលធ្វើការដកចេញត្រូវជូនដំណឹងទៅក្រុមប្រឹក្សាអំពីមជ្ឈត្តករដែលបានចាត់តាំង។ ក្នុងករណីដែលគូភាគីមិនអាចជ្រើសរើសមជ្ឈត្តករក្នុងរយៈពេលប្រាំថ្ងៃបន្ទាប់ពីទទួលបានបញ្ជីឈ្មោះនេះ ក្រុមប្រឹក្សាត្រូវតែងតាំងមជ្ឈត្តករ។

(C) មជ្ឈត្តករត្រូវបើកសវនាការលើគ្រប់បញ្ហាដែលទាក់ទងនឹងវិវាទនោះ។ គូភាគីអាចត្រូវបានធ្វើសវនាការដោយផ្ទាល់ ដោយមេធាវី ឬដោយអ្នកតំណាងផ្សេងទៀត ដូចដែលពួកគេអាចចាត់តាំងរៀងៗខ្លួន។ មជ្ឈត្តករត្រូវកំណត់លំដាប់នៃការធ្វើបទបង្ហាញដោយគូភាគី ហើយត្រូវមានឆន្ទានុសិទ្ធិ និងសិទ្ធិអំណាចក្នុងការសម្រេចរាល់បញ្ហានីតិវិធីដែលអាចនឹងត្រូវបានលើកឡើង។

(d) គូភាគីរួមទាំង TNCs ទាំងអស់ដែលចូលរួមយ៉ាងហោចណាស់ហាសិប TND នៅក្នុងអង្គភាពចរចា និងអ្នកតំណាងចរចាផ្តាច់មុខដែលរងផលប៉ះពាល់ អាចបង្ហាញដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ ឬទាំងពីរ នូវសេចក្តីថ្លែងការណ៍អំពីអង្គហេតុ សាក្សីគាំទ្រ និងភស្តុតាងផ្សេងទៀត និងការជជែកវែកញែកអំពីទស្សនៈឬគោលជំហរខ្លួន ទាក់ទងនឹងករណីនីមួយៗ។ មជ្ឈត្តករត្រូវមានសិទ្ធិអំណាចក្នុងការទាមទារឱ្យមានការបង្ហាញភស្តុតាងបែបនេះបន្ថែម ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ តាមដែលខ្លួនចង់បានពីគូភាគី ហើយត្រូវធានាតាមការស្នើសុំពីក្រុមភាគីណាមួយថា កំណត់ត្រាពេញលេញនិងគ្រប់ជ្រុងជ្រោយអំពីសវនាការណាមួយនោះត្រូវបានរក្សាទុក និងថ្លៃចំណាយលើកំណត់ត្រានោះត្រូវរ៉ាប់រងដោយភាគីស្នើសុំ។ ប្រសិនបើមានបង្កើតកំណត់ត្រានេះ ត្រូវចែករំលែកជាមួយគ្រប់ភាគី ដោយមិនគិតថា ភាគីណាមួយជាអ្នកទទួលខុសត្រូវលើការចំណាយនោះឡើយ។

(e) TNC ណាមួយដែលមាន TNDs ចូលរួមតិចជាងហាសិបនៅក្នុងអង្គភាពចរចាត្រូវមានឱកាសដើម្បីធ្វើការដាក់ស្នើជាលាយលក្ខណ៍អក្សរទៅកាន់មជ្ឈត្តករ។

(f) មជ្ឈត្តករត្រូវធ្វើការសម្រេចដោយយុត្តិធម៌និងសមស្របចំពោះបញ្ហាដែលកំពុងមានវិវាទ ហើយនឹងចេញសេចក្តីសម្រេចដែលនឹងអនុវត្តចំពោះ TNCs ទាំងអស់ និងអ្នកតំណាងចរចាផ្តាច់មុខ។ ក្នុងការឈានដល់ការសម្រេចបែបនេះ មជ្ឈត្តករត្រូវបញ្ជាក់អំពីមូលដ្ឋានសម្រាប់ការរកឃើញរបស់ខ្លួន ដោយពិចារណាល្អិតល្អន់បន្ថែមចំពោះកត្តាណាមួយដែលបានណែនាំដោយគូភាគីថាមជ្ឈត្តករយល់ឃើញស្របគ្នានឹងជំពូកនេះ មានដូចខាងក្រោម៖

i. ថាតើប្រាក់ឈ្នួល អត្ថប្រយោជន៍ ម៉ោងធ្វើការ និងលក្ខខណ្ឌការងាររបស់ TNDs សម្រេចបាននូវគោលដៅគោលនយោបាយដែលបានកំណត់ក្នុងផ្នែករង A នៃផ្នែកទី 1 ដែរឬទេ។ ចំនួននេះត្រូវតែគិតគូរពីតម្លៃរស់នៅពិតប្រាកដ វាអាចលើសច្រើនពីប្រាក់ឈ្នួលអប្បបរមាតាមច្បាប់ណាមួយ ហើយគួរតែជាចំនួនគ្រប់គ្រាន់ដែល TNDs មិនចាំបាច់ពឹងផ្អែកលើអត្ថប្រយោជន៍សាធារណៈណាមួយឡើយ។

ii. ថាតើមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការផ្តល់អត្ថប្រយោជន៍គឺតាមរយៈមូលនិធិអត្ថប្រយោជន៍ដែលមានសិទ្ធិទទួលបានដែរឬទេ ហើយប្រសិនបើដូច្នេះមែន តើត្រូវវាយតម្លៃ TNC នីមួយៗឱ្យល្អបំផុតអំពីចំណែកនៃការចំណាយលើការផ្តល់អត្ថប្រយោជន៍ទាំងនោះយ៉ាងដូចម្តេច។

iii. លទ្ធភាពហិរញ្ញវត្ថុផ្នែករបស់ TNCs ដែលរងផលប៉ះពាល់ក្នុងការទូទាត់សំណង និងអត្ថប្រយោជន៍ដែលកំពុងពិភាក្សា និងផលប៉ះពាល់លើការផ្តល់សេវាដែលផ្តល់ដោយក្រុមហ៊ុន។

iv. ការបង្កើតយន្តការដោះស្រាយវិវាទសមហេតុផលដែលនឹងអនុញ្ញាតឱ្យ TNDs មានការរំពឹងទុកសមស្របអំពីការងារដែលមិនមានការរំខាន ហើយអនុញ្ញាតឱ្យ TNCs ផ្លាស់ប្តូរ ឬបញ្ចប់ទំនាក់ទំនងរបស់ពួកគេជាមួយកម្មករនិយោជិត ប្រសិនបើមានហេតុផលសម្រាប់រឿងនោះ និង

v. ការប្រៀបធៀបលក្ខណៈពិសេសទាក់ទងនឹងពាណិជ្ជកម្ម ឬវិជ្ជាជីវៈផ្សេងទៀត រួមទាំងជាពិសេស (a) គ្រោះថ្នាក់ការងារ (b) លក្ខណសម្បត្តិរូបវន្ត (c) លក្ខណសម្បត្តិផ្នែកអប់រំ (d) លក្ខណសម្បត្តិផ្លូវចិត្ត និង (e) ការបណ្តុះបណ្តាលនិងជំនាញការងារ។

F. អនុសាសន៍ទាំងឡាយដែលបានព្រមព្រៀងរវាង TNCs និងសហជីព TND ដែលដើរតួជាអ្នកតំណាងចរចាផ្តាច់មុខរបស់ TNDs នៅក្នុងអង្គភាពចរចា និង/ឬសេចក្តីសម្រេចណាមួយដែលសម្រេចបានដោយមជ្ឈត្តករនៅក្រោមជំពូកនេះ នឹងត្រូវត្រួតពិនិត្យនិងអនុម័តដោយរដ្ឋមន្ត្រីការងារ។ ក្នុងការសម្រេចចិត្តថាតើត្រូវផ្តល់ការយល់ព្រមចំពោះអនុសាសន៍របស់មជ្ឈត្តករ ការសម្រេចរបស់រដ្ឋមន្ត្រីការងារត្រូវផ្អែកលើកត្តាដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ E(3)(f) ខាងលើ និងគោលនយោបាយដែលមានចែងក្នុងផ្នែកទី 1។ ក្នុងការសម្រេចថាតើត្រូវយល់ព្រមលើកិច្ចព្រមព្រៀង ឬការសម្រេចនោះឬអត់ រដ្ឋមន្ត្រីការងារត្រូវផ្តល់ឱ្យអ្នកតំណាងផ្តាច់មុខ TNCs និង TNDs ទាំងអស់នូវពេលវេលាមិនលើសពីសាមសិបថ្ងៃ ដើម្បីដាក់ជូនមតិយោបល់ និងអំណះអំណាងដែលទាក់ទងនឹងករណីថាតើការអនុម័តយល់ព្រមត្រូវបានធានាដែរឬអត់។ ក្នុងរយៈពេលហុកសិបថ្ងៃបន្ទាប់ពីកាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ជូនមតិយោបល់ រដ្ឋមន្ត្រីការងារត្រូវអនុម័ត ឬមិនអនុម័តលើកិច្ចព្រមព្រៀង ឬការសម្រេចនោះ។ ក្នុងករណីមិនអនុម័ត រដ្ឋមន្ត្រីការងារអាចផ្តល់អនុសាសន៍សម្រាប់ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀង ឬការសម្រេចដែលនឹងធ្វើឱ្យរដ្ឋមន្ត្រីការងារយល់ព្រម និងផ្តល់ឱកាសឱ្យគូភាគីឆ្លើយតបទៅនឹងអនុសាសន៍ទាំងនោះ។ ការសម្រេចចុងក្រោយដោយរដ្ឋមន្ត្រីការងារត្រូវរួមបញ្ចូលកាលបរិច្ឆេទមួយ ដែលបន្ទាប់កាលបរិច្ឆេទនោះ លក្ខខណ្ឌថ្មីៗអាចនឹងត្រូវបានកំណត់សម្រាប់អង្គភាពចរចាដែលកាលបរិច្ឆេទនោះមិនត្រូវលើសពីរយៈពេលបីឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចនេះ។ ក្នុងអំឡុងពេលបីឆ្នាំ (ឬរយៈពេលតិចជាងនេះណាមួយដែលរដ្ឋមន្ត្រីការងារកំណត់ជាថិរវេលាសម្រាប់ការសម្រេចចុងក្រោយ) ប្រសិនបើរដ្ឋមន្ត្រីការងារសម្រេចថាលក្ខខណ្ឌទីផ្សារបានផ្លាស់ប្តូរ រដ្ឋមន្ត្រីការងារនឹងផ្តល់ឱ្យអ្នកតំណាងចរចាផ្តាច់មុខ TNCs និង TNDs ទាំងអស់នូវឱកាសមួយដើម្បីដាក់ជូនមតិយោបល់ និងអំណះអំណាងទាក់ទងនឹងករណីថាតើការសម្រេចចុងក្រោយនោះគួរតែត្រូវបានកែប្រែដែរឬទេ ហើយបន្ទាប់ពីទទួលបានមតិយោបល់ទាំងនោះ រដ្ឋមន្ត្រីការងារអាចនឹងកែប្រែការសម្រេចចុងក្រោយនោះ។

**អត្ថបទទាំងស្រុងនៃសំណើច្បាប់ដែលបានស្នើ (ត)**

ផ្នែក 7. បទដ្ឋានការងារអប្បបរមា គ្មានកិច្ចព្រមព្រៀង ឬការសម្រេចដែលបានធ្វើឡើងដោយស្របតាមជំពូកនេះ នឹងត្រូវកាត់បន្ថយ ឬលុបបំបាត់បទដ្ឋានការងារអប្បបរមាដែលអាចនឹងអនុវត្តចំពោះ TND ផ្សេងទៀតផ្ទុយពីនេះ។

ផ្នែក 8. សិទ្ធិបុព្វក្រ័យ ច្បាប់នេះនឹងមិនលុបចោលការអនុម័តណាមួយរបស់រដ្ឋម៉ាសាឈូសិត ដែលផ្តល់អត្ថប្រយោជន៍ ឬការការពារកាន់តែច្រើនដល់ TND ឡើយ។

ផ្នែក 9. ការសើរើតាមផ្លូវតុលាការ

A. ដីកាស្ថាពររបស់ក្រុមប្រឹក្សាដែលបានចេញដោយស្របតាមជំពូកនេះ ត្រូវបញ្ចប់ដំណើរការនីតិវិធីរបស់ភាគីទាំងអស់ និងបុគ្គលដែលមានឱកាសក្លាយជាភាគីនៃដំណើរការនីតិវិធីរបស់ខ្លួន លើកលែងតែមានការកែប្រែ ឬធ្វើវិសោធនកម្មនៅក្នុងដំណើរការនីតិវិធីសម្រាប់ការអនុវត្តច្បាប់ ឬការសើរើតាមប្រព័ន្ធតុលាការដូចមានចែងនៅទីនេះ។ ដីកាស្ថាពររបស់ក្រុមប្រឹក្សា នឹងត្រូវសើរើដូចមានចែងក្នុងផ្នែកទី 6 ក្នុងជំពូកទី 150A នៃច្បាប់ទូទៅ ប្រសិនបើដីកាស្ថាពររបស់ក្រុមប្រឹក្សា នៅក្រោមផ្នែកទី 5 នៃជំពូកនេះ ទាក់ទងនឹងវិសាលភាពរបស់អង្គភាពចរចា ឬការចាត់តាំងរបស់សហជីព TND ជាអ្នកតំណាងចរចាផ្តាច់មុខ ឬមានសិទ្ធិក្នុងការទទួលបានការបង្ហាញបញ្ជី TNDs នឹងត្រូវបានបដិសេធតែក្នុងករណីដែលរកឃើញថាបានចេញតាមទំនើងចិត្ត និងគ្មានហេតុផលតែប៉ុណ្ណោះ។

B. ដីកាស្ថាពររបស់រដ្ឋមន្ត្រីការងារ ដោយអនុលោមតាមផ្នែកទី 6(F) នៃជំពូកនេះ ត្រូវបញ្ចប់ចំពោះសហជីព TND ដែលរងផលប៉ះពាល់ទាំងអស់ និង TNCs ទាំងអស់នៅក្នុងឧស្សាហកម្មនេះ ពុំនោះទេលុះត្រាតែមានការកែប្រែ ឬធ្វើវិសោធនកម្មនៅក្នុងដំណើរការនីតិវិធីសម្រាប់ការអនុវត្តច្បាប់ ឬការសើរើតាមប្រព័ន្ធតុលាការដូចមានចែងនៅទីនេះ។ ដីកាស្ថាពរនេះនឹងត្រូវត្រួតពិនិត្យដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី 14 ក្នុងជំពូកទី 30A នៃច្បាប់ទូទៅ ដែលបានចែងថា ការសម្រេចរបស់រដ្ឋមន្ត្រីការងារនឹងត្រូវបានបដិសេធតែក្នុងករណីដែលរកឃើញថាបានចេញតាមទំនើងចិត្តនិងគ្មានហេតុផលតែប៉ុណ្ណោះ។

(C) លើកលែងតែនៅក្នុងដំណើរការដែលនាំនូវការជំទាស់ទៅនឹងដីកាស្ថាពររបស់រដ្ឋមន្ត្រីការងារ ពុំនោះទេ ការសម្រេចរបស់មជ្ឈត្តករមិនត្រូវស្ថិតនៅក្រោមការសើរើតាមប្រព័ន្ធផ្លូវតុលាការឡើយ។

ផ្នែក 10. វិធាន និងបទប្បញ្ញត្តិផ្សេងៗ

ក្រុមប្រឹក្សាត្រូវបង្កើតវិធាននិងបទប្បញ្ញត្តិបែបនេះ តាមដែលអាចសមស្រប ដើម្បីអនុវត្តគោលបំណងនិងបទប្បញ្ញត្តិនៃជំពូកនេះ។

ផ្នែក 11. សភាពជាន់គ្នានៃច្បាប់

ក្នុងករណីមានសភាពជាន់គ្នាណាមួយជាមួយជំពូកទី 150A នៃច្បាប់ទូទៅ ត្រូវយកបទប្បញ្ញត្តិនៃជំពូកនេះជាគោល។

ផ្នែក 12. ភាពអាចផ្តាច់ចេញបាន

បទប្បញ្ញត្តិនៃច្បាប់នេះត្រូវអាចផ្តាច់ចេញពីគ្នាបាន ហើយប្រសិនបើឃ្លា អនុប្រយោគ ប្រយោគ ឬបទប្បញ្ញត្តិនៃមាត្រានេះ ឬ សុពលភាពនៃឃ្លា អនុប្រយោគ ប្រយោគ ឬបទប្បញ្ញត្តិនៃមាត្រានេះចំពោះបុគ្គល អង្គភាព ឬកាលៈទេសៈណាមួយ នឹងត្រូវបានចាត់ទុកជាមោឃៈនោះ ផ្នែកដែលនៅសល់នៃច្បាប់នេះ និងសុពលភាពរបស់វានឹងមិនត្រូវបានមានផលប៉ះពាល់ឡើយ។

## របាយការណ៍មតិភាគច្រើន

*របាយការណ៍ខាងក្រោមត្រូវបានរៀបចំឡើងដោយមតិភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា ដែលជាគណៈកម្មាធិការនៃសភារដ្ឋម៉ាសាឈូសិត តាមតម្រូវដោយរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត របាយការណ៍មតិភាគច្រើននេះ ត្រូវបានបោះពុម្ពដូចខាងក្រោម។ សេចក្តីថ្លែងការណ៍នានានៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីមតិយោបល់របស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

មតិភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា (ហៅកាត់ថា "គណៈកម្មាធិការ") ផ្តល់អនុសាសន៍ថា ញត្តិលេខ 23-35 សភាតំណាងរាស្ត្រលេខ 4253 "ច្បាប់មួយដែលផ្តល់ឱ្យអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូននូវជម្រើសក្នុងការចូលសហជីព និងចរចាជាសមូហភាព" ("ញត្តិផ្តួចផ្តើម") ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះ នោះឡើយ។

គោលបំណងនៃរបាយការណ៍នេះគឺដើម្បីផ្តល់ជាអនុសាសន៍ដល់ស្ថាប័ននីតិប្បញ្ញត្តិពេញអង្គ អំពីថាតើត្រូវទទួលយកញត្តិផ្តួចផ្តើមដូចដែលបានព្រាងសម្រាប់ការពិចារណា និងអនុម័តដែរឬទេ។

ញត្តិផ្តួចផ្តើមដែលបានស្នើឡើងនឹងផ្តល់ឱ្យអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន ("អ្នកបើកបរ") នូវសិទ្ធិបង្កើតសហជីព និងចរចាជាសមូហភាពជាមួយក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន ("TNCs") ដើម្បីបង្កើតអនុសាសន៍ដែលបានចរចាទាក់ទងនឹងប្រាក់ឈ្នួល អត្ថប្រយោជន៍ និងលក្ខខណ្ឌការងារ។

***សក្ខីភាព***

គណៈកម្មាធិការនេះបានដឹងព័ត៌មានពីអ្នកជំនាញដែលមានបទពិសោធន៍ អ្នកគាំទ្រញត្តិផ្តួចផ្តើម ក៏ដូចជាសាធារណជនទូទៅផងដែរ។ មិនមានសក្ខីកម្មជំទាស់នឹងញត្តិផ្តួចផ្តើមទេ ហើយអ្នកតំណាងមកពី TNCs បានបញ្ជាក់ច្បាស់ថាពួកគេមិនគាំទ្រ ឬជំទាស់នឹងញត្តិផ្តួចផ្តើមនេះទេ។

លោក Patrick Moore ជាអគ្គរដ្ឋអាជ្ញាអមទីមួយនៃរដ្ឋម៉ាសាឈូសិត បានផ្តល់សក្ខីកម្មថា ភាសារបស់ញត្តិផ្តួចផ្តើមនេះនឹងអនុវត្តចំពោះតែអ្នកបើកបរដែលប្រើចំណតរបស់ TNCs ប៉ុណ្ណោះ ដែលភាគច្រើនជា Uber និង Lyft ហើយមិនមែនក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន ("DNCs") ដូចជា DoorDash ឬ Instacart ជាដើមនោះទេ។ ញត្តិផ្តួចផ្តើមនេះ បង្កើតក្របខណ្ឌមួយដើម្បីអនុញ្ញាតឱ្យអ្នកបើកបរចរចាជាសមូហភាព ប្រសិនបើពួកគេជ្រើសរើសធ្វើដូច្នោះ ក្នុងដំណើរការមួយដែលគ្រប់គ្រងដោយក្រុមប្រឹក្សាទំនាក់ទំនងការងាររដ្ឋម៉ាសាឈូសិត ("CERB") ដែលកំណត់ការប្រតិបត្តិការងារមិនត្រឹមត្រូវនៅក្នុងវិស័យនេះ។ ប្រសិនបើចំនួន 5 ភាគរយនៃអ្នកបើកបរសកម្ម ដែលកំណត់ដោយ TNCs ថាជាអ្នកបើកបរដែលសម្រេចបានចំនួនការជិះច្រើនជាងចំនួនមធ្យមក្នុងរយៈពេលប្រាំមួយខែមុនផ្តល់សិទ្ធិដល់សហជីពនោះសហជីពទទួលបានបញ្ជីអ្នកបើកបរសកម្មទាំងអស់ពី TNCs។ ប្រសិនបើសហជីពទទួលបានការគាំទ្រពីចំនួន 25 ភាគរយនៃអ្នកបើកបរសកម្មទាំងអស់ នោះសហជីពអ្នកបើកបរអាចត្រូវបានទទួលស្គាល់ដោយ CERB ថាជាអ្នកតំណាងផ្តាច់

### របាយការណ៍មតិភាគច្រើន (ត)

មុខរបស់អ្នកបើកបរ។ ប្រសិនបើអ្នកបើកបរផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងចរចានោះ ត្រូវបញ្ជូនកិច្ចព្រមព្រៀងចរចានេះទៅរដ្ឋមន្ត្រីការងារនិងអភិវឌ្ឍន៍កម្លាំងពលកម្ម ដើម្បីឱ្យរដ្ឋម៉ាសាឈូសិតបញ្ជាក់កិច្ចព្រមព្រៀងនោះ។ TNCs ក៏អាចបង្កើតសមាគមដើម្បីតំណាងឱ្យពួកគេក្នុងការចរចាជាមួយសហជីពអ្នកបើកបរបានដែរ។

អគ្គរដ្ឋអាជ្ញាអមទីមួយ លោក Moore បានកត់សម្គាល់ថា TNCs បច្ចុប្បន្នមានការពាក់ព័ន្ធនឹងបណ្តឹងដែលដាក់ដោយអគ្គរដ្ឋអាជ្ញាដើម្បីសម្រេចថាតើអ្នកបើកបរគួរតែត្រូវបានចាត់ថ្នាក់ជានិយោជិតដែរឬទេ បើពិចារណាទៅលើច្បាប់កំណត់ប្រាក់ឈ្នួលរដ្ឋម៉ាសាឈូសិត និង "ការធ្វើតេស្ត ABC" យ៉ាងតឹងរឹងរបស់រដ្ឋនេះអំពីទំនាក់ទំនងរវាងនិយោជិតនិងនិយោជក។ ករណីនេះ ដែលអាចត្រូវបានសម្រេចក្នុងរយៈពេលពីរបីខែខាងមុខ នឹងរក្សាការទទួលស្គាល់អ្នកបើកបរថាជាអ្នកម៉ៅការឯករាជ្យនៅរដ្ឋម៉ាសាឈូសិត ឬក៏ចាត់ថ្នាក់អ្នកបើកបរជានិយោជិត ដោយអនុវត្តទាំងពីចំណុចនោះសម្រាប់ប្រតិបត្តិការនាពេលអនាគតនិងប្រតិបត្តិការនាអតីតកាលរបស់ TNCs នៅរដ្ឋម៉ាសាឈូសិត។ ញត្តិផ្តួចផ្តើមនានារបស់សភាតំណាងរាស្ត្រលេខ 4256 សភាតំណាងរាស្ត្រលេខ 4257 សភាតំណាងរាស្ត្រលេខ 4258 សភាតំណាងរាស្ត្រលេខ 4259 និងសភាតំណាងរាស្ត្រលេខ 4260 ដែលទាក់ទងនឹង TNCs និងអ្នកបើកបរ ហើយក៏ត្រូវបានសង្កេតដោយយកចិត្តទុកដាក់នៅក្នុងរបាយការណ៍ដោយឡែកមួយផងដែរ នឹងចាត់ថ្នាក់អ្នកបើកបរជាអ្នកម៉ៅការឯករាជ្យ សម្រាប់គោលបំណងច្បាប់រដ្ឋម៉ាសាឈូសិត។ ប្រសិនបើគំនិតផ្តួចផ្តើមទាំងនោះនឹងត្រូវបានអនុម័ត អ្នកបើកបរនឹងមិនត្រូវបានចាត់ទុកថាជានិយោជិតចាប់ពីចំណុចនាអនាគតកាលទេ (ប្រសិនបើតុលាការកំពូលកាត់សេចក្តីថា អ្នកបើកបរគឺជា និងធ្លាប់ជានិយោជិតពីមុនមក)។ នៅពេលដែលត្រូវបានចោទសួរអំពីទំនាស់ដែលអាចកើតមានឡើងរវាងញត្តិផ្តួចផ្តើមរបស់សភាតំណាងរាស្ត្រលេខ 4256 សភាតំណាងរាស្ត្រលេខ 4257 សភាតំណាងរាស្ត្រលេខ 4258 សភាតំណាងរាស្ត្រលេខ 4259 និងសភាតំណាងរាស្ត្រលេខ 4260 អគ្គរដ្ឋអាជ្ញាអមទីមួយ លោក Moore បានផ្តល់សក្ខីកម្មថា អាចនឹងមានភាពមិនស៊ីសង្វាក់គ្នាបន្តិចបន្តួច ប៉ុន្តែញត្តិផ្តួចផ្តើមនានាទាំងនេះត្រូវបានតាក់តែងឡើង ដើម្បីកុំឱ្យមានការប៉ះទង្គិច ហើយថាញត្តិផ្តួចផ្តើមនានានេះអាចចូលជាធរមាន ដោយមិនគិតពីលទ្ធផលនៃញត្តិផ្តួចផ្តើមនានាចំនួនប្រាំផ្សេងទៀតឡើយ។

ក្រុមអ្នកគាំទ្រទីមួយចំពោះញត្តិផ្តួចផ្តើមនេះ រួមមាន 32BJ ក្នុងតំបន់របស់សហជីពអន្តរជាតិសម្រាប់និយោជិតផ្តល់សេវាកម្ម ("SEIU") និងអ្នកបើកបរក្រុមហ៊ុន Uber និង Lyft TNCs ។ ក្រុមនោះបានលើកហេតុផលថា សិទ្ធិក្នុងការរួបរួមជាសហជីព នឹងក្លាយជាមធ្យោបាយដ៏ល្អបំផុតក្នុងការធានាសិទ្ធិរបស់អ្នកបើកបរ ដោយមិនគិតពីផលប៉ះពាល់នៃបណ្តឹងរបស់អគ្គរដ្ឋអាជ្ញា ឬញត្តិផ្តួចផ្តើមនានាដែលមានចែងក្នុងកថាខណ្ឌខាងលើនោះទេ។ ក្រុមនេះបានបញ្ជាក់ថា ប្បញ្ញត្តិនៃញត្តិផ្តួចផ្តើមនេះនឹងធានាថា ទោះជាអ្នកបើកបរត្រូវបានចាត់ថ្នាក់ជាអ្នកម៉ៅការឯករាជ្យ ឬជានិយោជិតនៅក្រោមច្បាប់រដ្ឋម៉ាសាឈូសិតក៏ដោយ សិទ្ធិក្នុងការចរចាជាសមូហភាពនឹងផ្តល់ឱ្យអ្នកបើកបរនូវឱកាសដើម្បីធានានូវនិរន្តរភាពយូរអង្វែងនៃវិជ្ជាជីវៈរបស់ពួកគេ ដោយធ្វើការសហការជាមួយ TNCs អំពីសិទ្ធិ និងការការពាររបស់កម្មករនិយោជិត រួមទាំងចំណែកនៃថ្លៃឈ្នួលដឹកជញ្ជូនដែលអ្នកបើកបរទទួលបាន ដំណើរការធ្វើមោឃៈភាពសម្រាប់អ្នកបើកបរ និងប្រាក់ឈ្នួលអប្បបរមា ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ។ ក្រុមនេះក៏បានចង្អុលបង្ហាញពីគំរូអតីតកាល ដោយលើកឡើងពីកិច្ចខិតខំប្រឹងប្រែងពីមុនរបស់រដ្ឋម៉ាសាឈូសិត ក្នុងការអនុញ្ញាតឱ្យការថែទាំតាមផ្ទះ និងអ្នកថែទាំកុមារដែលមិនធ្វើការនៅទីតាំងក្រុមហ៊ុនជាអចិន្ត្រៃយ៍អាចរួបរួមគ្នាជាអ្នកម៉ៅការឯករាជ្យនៅពេលដែលពួកគេពីមុនមិនមានសិទ្ធិដូច្នោះនោះ។

ក្រុមគាំទ្រទីពីរ មានអ្នកតំណាងមកពី SEIU California មជ្ឈមណ្ឌលគម្រោងកម្មករនិយោជិតអាមេរិកដើម្បីវឌ្ឍនភាពអាមេរិក (Center for American Progress American Worker Project) និងសមាគមយន្តការីមណ្ឌល 15 អន្តរជាតិ (International Association of Machinists District 15)។ ពិតមែនតែក្រុមនេះគាំទ្រដល់ញត្តិផ្តួចផ្តើមដើម្បីអនុញ្ញាតឱ្យអ្នកបើកបររួបរួមគ្នាជាអ្នកម៉ៅការឯករាជ្យ ប៉ុន្តែឥរិយាបថរបស់ពួកគេបង្ហាញថា បច្ចុប្បន្ន អ្នកបើកបរត្រូវបានចាត់ថ្នាក់មិនត្រឹមត្រូវថាជាអ្នកម៉ៅការឯករាជ្យ ហើយថាសំណើណាមួយដែលអនុញ្ញាតឱ្យមានសហជីព មិនគួរប្រកាសច្បាស់ថាអ្នកបើកបរជាអ្នកម៉ៅការឯករាជ្យនៅក្រោមច្បាប់រដ្ឋម៉ាសាឈូសិតនោះទេ។

### សន្និដ្ឋាន

ទោះបីជាមតិភាគច្រើនដែលចុះហត្ថលេខាខាងក្រោមគិតថាមានគុណសម្បត្តិចំពោះកម្មវត្ថុនៃញត្តិផ្តួចផ្តើមនេះទាក់ទងនឹងសិទ្ធិរបស់អ្នកបើកបរក្នុងការបង្កើតសហជីព និងការចរចាជាសមូហភាពក៏ដោយ ក៏សំណួរសំខាន់ៗនៅតែមានពាក់ព័ន្ធនឹងអន្តរកម្មរវាងញត្តិផ្តួចផ្តើមនេះ និងញត្តិផ្តួចផ្តើមនានាទាំងប្រាំដែលទាក់ទងនឹងទំនាក់ទំនងរវាងក្រុមហ៊ុនក្នុងបណ្តាញដឹកជញ្ជូន និងកម្លាំងការងាររបស់ពួកគេ ប្រសិនបើញត្តិទាំងពីរប្រភេទនោះត្រូវបានបង្ហាញដល់អ្នកបោះឆ្នោត។

វាបង្ហាញឱ្យឃើញច្បាស់ផងដែរតាមរយៈសក្ខីកម្មដែលទទួលបាននៅក្នុងសវនាការសាធារណៈនោះថា ទោះបីជាមានការគាំទ្រជាមូលដ្ឋានចំពោះសិទ្ធិរបស់កម្មករនិយោជិតក្នុងការបង្កើតសហជីពក៏ដោយ ក៏ក្តីកង្វល់នានាត្រូវបានលើកឡើងដោយសហជីពការងារមួយចំនួនទាក់ទងនឹងដំណើរការ និងសិទ្ធិផ្តាច់មុខផ្នែកយុត្តាធិការនៃកិច្ចសម្របសម្រួលនេះដូចដែលបានដាក់ញត្តិស្នើសុំ។ គណៈកម្មាធិការក៏កត់សម្គាល់ផងដែរថា ញត្តិផ្តួចផ្តើមដូចដែលបានព្រាងគឺផ្តោតលើ TNCs ហើយមិនមានភាសាណាមួយដែលនឹងបង្កើតសិទ្ធិនេះតាមលក្ខន្តិកៈសម្រាប់កម្មករនិយោជិត DNC ដែលមានស្ថានភាពស្រដៀងគ្នានេះឡើយ។

គណៈកម្មាធិការក៏យល់ដឹងផងដែរអំពីបញ្ហាប្រឈមផ្លូវច្បាប់ទាក់ទងនឹងញត្តិផ្តួចផ្តើមនេះ ដែលត្រូវជជែកវែកញែកនៅចំពោះមុខតុលាការកំពូលនៅខែឧសភា ឆ្នាំ 2024 បន្ទាប់ពីកាលបរិច្ឆេទកំណត់រដ្ឋធម្មនុញ្ញ ដែលអង្គនីតិប្បញ្ញត្តិអាចអនុម័តញត្តិផ្តួចផ្តើមនេះបាន។

សម្រាប់ហេតុផលទាំងនេះ យើងខ្ញុំ ជាសមាជិកភាគច្រើននៃគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា សូមផ្តល់អនុសាសន៍ថា "ច្បាប់មួយដែលផ្តល់ឱ្យអ្នកបើកបរក្នុងបណ្តាញដឹកជញ្ជូន នូវជម្រើសក្នុងការចូលសហជីព និងចរចាជាសមូហភាព" (សូមមើលសភាតំណាងរាស្ត្រលេខ 4253 ) ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះ នោះឡើយ។

| **សមាជិកព្រឹទ្ធសភា** | **អ្នកតំណាង** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Paul R. Feeney | Michael S. Day |
| Ryan C. Fattman | Kenneth I. Gordon |
| | David T. Vieira |

# 4

## សំណួរទី៤ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# *នីត្យានុកូលកម្មនិងបទប្បញ្ញត្តិមានដែនកំណត់ស្តីពីសារធាតុវង្វេងវង្វាន់ធម្មជាតិជាក់លាក់មួយចំនួន*

*តើលោកអ្នកយល់ស្របតាមច្បាប់ដែលបានសង្ខេបខាងក្រោមទេ ដែលចែងថាគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយសមាជិកព្រឹទ្ធសភា ឬសភាតំណាងរាស្ត្រឡើយ នៅមុនថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៤?*

**សេចក្តីសង្ខេប ▶**

តាមច្បាប់តម្រូវ សេចក្តីសង្ខេបត្រូវបានសរសេរឡើងដោយអគ្គរដ្ឋអាជ្ញា។

សេចក្តីស្នើច្បាប់នេះនឹងអនុញ្ញាតអោយពលរដ្ឋដែលមានអាយុចាប់ពី២១ឆ្នាំឡើងទៅ អាចធ្វើការដាំដុះ, កាន់កាប់ និង ប្រើប្រាស់សារធាតុធម្មជាតិណាមួយដែលធ្វើអោយវង្វេងវង្វាន់នៅក្នុងស្ថានភាពមួយចំនួន។ សារធាតុវង្វេងវង្វាន់ដែលគេបានអនុញ្ញាតនេះមានពីរយ៉ាង ដែលមាននៅក្នុងរុក្ខជាតិផ្សិត (សារធាតុស៊ីឡូស៊ីប៊ីន psilocybin និង ស៊ីឡូស៊ីន psilocyn) និង សារធាតុបីយ៉ាងដែលមាននៅក្នុងរុក្ខជាតិ (សារធាតុឌីមេទីលទ្រីបតាមីន dimethyltryptamine, មេសាលីន mescaline, និង អ៊ីបូហ្កាអ៊ីន ibogaine)។ គេអាចរកទិញសារធាតុទាំងនេះតាមទីតាំងដែលមានការអនុញ្ញាតសម្រាប់ប្រើប្រាស់ ក្រោមការត្រួតពិនិត្យរបស់អ្នកសម្របសម្រួលដែលមានអាជ្ញាប័ណ្ណ។ សេចក្តីស្នើច្បាប់នេះមិនអនុញ្ញាតអោយមានការលក់រាយណាមួយនៃសារធាតុទាំងនេះឡើយ។ សេចក្តីស្នើច្បាប់នេះក៏នឹងចែងអំពីការគ្រប់គ្រង និង ការយកពន្ធលើសារធាតុវង្វេងវង្វាន់ទាំងនេះដែរ។

សេចក្តីស្នើច្បាប់នេះនឹងផ្តល់អាជ្ញាប័ណ្ណ និង គ្រប់គ្រងកន្លែងផ្តល់ការប្រើប្រាស់សារធាតុវង្វេងវង្វាន់ដែលស្ថិតក្រោមការឃ្លាំមើលទាំងនេះ និង ចែងអំពីការយកពន្ធលើប្រាក់ចំណូលពីការលក់សារធាតុវង្វេងវង្វាន់របស់កន្លែងទាំងនោះ។ សេចក្តីស្នើច្បាប់នេះក៏នឹងអនុញ្ញាតអោយពលរដ្ឋដែលមានអាយុចាប់ពី២១ឆ្នាំឡើងទៅ អាចធ្វើការដាំដុះសារធាតុវង្វេងវង្វាន់ទាំងនេះក្នុងផ្ទៃក្រឡាដីទំហំ១២ហ្វីតគុណនឹង១២ហ្វីត នៅផ្ទះរបស់ពួកគេ ហើយប្រើប្រាស់សារធាតុវង្វេងវង្វាន់ទាំងនេះនៅផ្ទះរបស់ពួកគេ។ សេចក្តីស្នើច្បាប់នេះនឹងអនុញ្ញាតអោយពលរដ្ឋដែលមានអាយុចាប់ពី២១ឆ្នាំឡើងទៅ កាន់កាប់សារធាតុស៊ីឡូស៊ីប៊ីន (psilocybin) រហូតដល់ចំនួនមួយក្រាម, សារធាតុស៊ីឡូស៊ីន (psilocyn) មួយក្រាម, សារធាតុឌីមេទីលទ្រីបតាមីន (dimethyltryptamine) មួយក្រាម, សារធាតុមេសាលីន (mescaline)១៨ក្រាម និង សារធាតុអ៊ីបូហ្កាអ៊ីន (ibogaine) ៣០ក្រាម (ហៅថា "បរិមាណប្រើប្រាស់ផ្ទាល់ខ្លួន") បន្ថែមលើអ្វីៗដែលពួកគេអាចដាំដុះនៅផ្ទះរបស់ពួកគេ និង អាចអោយសារធាតុនេះចំនួនដូចដែលខ្លួនប្រើប្រាស់ផ្ទាល់ទៅដល់មនុស្សម្នាក់ដែលមានអាយុចាប់ពី២១ឆ្នាំឡើងបាន។

សេចក្តីស្នើច្បាប់នេះនឹងបង្កើតអោយមានគណៈកម្មការមួយដើម្បីគ្រប់គ្រងសារធាតុវង្វេងវង្វាន់ធម្មជាតិនេះ ដែលមានសមាជិកចំនួនប្រាំរូប ដែលតែងតាំងដោយអភិបាលរដ្ឋ, អគ្គរដ្ឋអាជ្ញា និង ហិរញ្ញិក ដែលមានបន្ទុកចាត់ចែងធ្វើច្បាប់គ្រប់គ្រងការប្រើប្រាស់ និង ការចែកចាយសារធាតុវង្វេងវង្វាន់ទាំងនេះ។ គណៈកម្មការនេះនឹងអនុម័តបទបញ្ញត្តិដើម្បីត្រួតពិនិត្យមើលលក្ខណសម្បត្តិនៃការផ្តល់អាជ្ញាប័ណ្ណ, សុវត្ថិភាព, ការរក្សាកំណត់ត្រា, ការអប់រំ និង ការបណ្តុះបណ្តាល, លក្ខខណ្ឌដែលគេតម្រូវអោយមានផ្នែកសុខភាព និង សុវត្ថិភាព, ការធ្វើតេស្ត និង ការផ្ទៀងផ្ទាត់អាយុ។

សេចក្តីស្នើច្បាប់នេះក៏នឹងបង្កើតអោយមានក្រុមប្រឹក្សាពិគ្រោះយោបល់លើសារធាតុវង្វេងវង្វាន់ធម្មជាតិ ដែលមានសមាជិកចំនួន២០រូបតែងតាំងដោយអភិបាលរដ្ឋ, អគ្គរដ្ឋអាជ្ញា និង ហិរញ្ញិក ដែលមានតួនាទីធ្វើការសិក្សា និងផ្តល់អនុសាសន៍ដល់គណៈកម្មការអំពីការគ្រប់គ្រង និង ការយកពន្ធលើសារធាតុវង្វេងវង្វាន់ទាំងនេះ។

សេចក្តីស្នើច្បាប់នេះនឹងអនុញ្ញាតអោយក្រុងទាំងឡាយកំណត់ពេល, ទីកន្លែង និង របៀបសមស្របនៃដំណើរការរបស់កន្លែងដែលមានអាជ្ញាប័ណ្ណផ្តល់ជូនសារធាតុវង្វេងវង្វាន់ទាំងនេះ ប៉ុន្តែក្រុងទាំងឡាយមិនអាចហាមឃាត់ទីកន្លែងទាំងនោះ ឬហាមមិនអោយទីកន្លែងទាំងនោះផ្តល់សារធាតុទាំងអស់នេះបានទេ។

ប្រាក់ចំណូលពីការលក់សារធាតុវង្វេងវង្វាន់នៅតាមកន្លែងដែលមានអាជ្ញាប័ណ្ណ នឹងត្រូវបង់ពន្ធជូនរដ្ឋលើការលក់ និង ពន្ធរដ្ឋាករបន្ថែមចំនួន១៥ភាគរយ។ លើសពីនេះ ក្រុងអាចកំណត់ពន្ធដាច់ដោយឡែកមួយផ្សេងទៀតរហូតដល់ពីរភាគរយ។ ប្រាក់ចំណូលដែលទទួលបានពីការបង់ពន្ធរដ្ឋាករបន្ថែម, ថ្លៃស្នើសុំអាជ្ញាប័ណ្ណ និង ការពិន័យរដ្ឋប្បវេណីសម្រាប់ការរំលោភលើសេចក្តីស្នើច្បាប់នេះ នឹងត្រូវដាក់ចូលក្នុងមូលនិធិគ្រប់គ្រងសារធាតុវង្វេងវង្វាន់ធម្មជាតិ ហើយនឹងត្រូវបានប្រើប្រាស់ ក្រោមការបែងចែកមូលនិធិសម្រាប់គ្រប់គ្រងដំណើរអនុវត្តន៍សេចក្តីស្នើច្បាប់នេះ ។

ការប្រើប្រាស់សារធាតុវង្វេងវង្វាន់ដែលត្រូវបានអនុញ្ញាតដោយច្បាប់ដែលបានស្នើនេះ មិនអាចជាមូលដ្ឋានដើម្បីបដិសេធមិនអោយបុគ្គលណាម្នាក់ទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ ឬជំនួយសាធារណៈ, ដាក់វិន័យដោយក្រុមប្រឹក្សាផ្តល់អាជ្ញាប័ណ្ណវិជ្ជាជីវៈ ឬចេញដីកាបង្គាប់បដិសេធលើករណីសិទ្ធិគ្រប់គ្រងកូន ដោយគ្មានភស្តុតាងច្បាស់លាស់ និង អាចជឿងទុកចិត្តបានដែលជាសកម្មភាពបង្កើតអោយមានគ្រោះថ្នាក់មិនសមស្របដល់សុវត្ថិភាពរបស់កុមារ។

សេចក្តីស្នើច្បាប់នេះនឹងមិនប៉ះពាល់ឡើយដល់ច្បាប់ដែលមានស្រាប់ទាក់ទងនឹងការបញ្ជាយានជំនិះក្នុងពេលកំពុងស្ថិតក្រោមឥទ្ធិពលថ្នាំ ឬសមត្ថភាពរបស់និយោជកក្នុងការអនុវត្តគោលនយោបាយនៅកន្លែងធ្វើការដែលដាក់កម្រិតនិយោជិតចំពោះការប្រើប្រាស់សារធាតុវង្វេងវង្វាន់ទាំងនេះ។

សេចក្តីស្នើច្បាប់នេះនឹងអនុញ្ញាតអោយម្ចាស់អចលនទ្រព្យហាមឃាត់ការប្រើប្រាស់, ការតាំងបង្ហាញ, ការដាំដុះ, ការកែច្នៃ ឬការលក់សារធាតុវង្វេងវង្វាន់ទាំងនេះ នៅក្នុងបរិវេណទីតាំងរបស់ពួកគេ។ រដ្ឋាភិបាលប្រចាំរដ្ឋ និង មូលដ្ឋានទាំងឡាយអាចបន្តដាក់កម្រិតលើការកាន់កាប់ និង ការប្រើប្រាស់សារធាតុវង្វេងវង្វាន់ទាំងនេះនៅក្នុងអគារសាធារណៈ ឬ នៅតាមសាលារៀន។

សេចក្តីស្នើច្បាប់នេះនឹងចូលជាធរមាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២៤។

# សំណួរទី៤ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

**ការចូលរួមចំណែកពីការបោះឆ្នោតរបស់អ្នក** ▶

តាមច្បាប់កំណត់ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** អាចនឹងអនុញ្ញាតអោយពលរដ្ឋដែលមានអាយុចាប់ពី២១ឡើងទៅ ប្រើប្រាស់សារធាតុរវើរវាយធម្មជាតិក្រោមការគ្រប់គ្រងដែលមានអាជ្ញាប័ណ្ណ និង ធ្វើការដាំដុះ និង កាន់កាប់សារធាតុទាំងនោះក្នុងបរិមាណតិចតួចនៅក្នុងផ្ទះរបស់ពួកគេ ហើយការបង្កើតគណៈកម្មការដើម្បីគ្រប់គ្រងការប្រើប្រាស់សារធាតុទាំងនោះ។

***ការបោះឆ្នោតជំទាស់*** នឹងមិនធ្វើអោយមានការកែប្រែអ្វីឡើយក្នុងច្បាប់ពាក់ព័ន្ធនឹងសារធាតុរវើរវាយធម្មជាតិ។

---

**របាយការណ៍អំពីការប៉ះពាល់លើសារពើពន្ធ** ▶

តាមច្បាប់កំណត់ របាយការណ៍ផលប៉ះពាល់លើសារពើពន្ធ ត្រូវសរសេរដោយក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ។

វិធានការនេះនឹងបង្កើតពន្ធរដ្ឋាករ 15% សម្រាប់ការលក់សារធាតុរវើរវាយធម្មជាតិ ដែលនឹងអាចមានសម្រាប់ការចំណាយពីមូលនិធិដែលបានកំណត់។ ទោះយ៉ាងណាក៏ដោយ គេមិនដឹងអំពីផលប៉ះពាល់ដែលកើតឡើងពីចំណូលនេះនោះទេ ដោយសារតែកង្វះទិន្នន័យសម្រាប់ទីផ្សារថ្មីដែលបានស្នើឡើង។ វិធានការនេះក៏នឹងអនុញ្ញាតឱ្យមានជម្រើសពន្ធក្នុងស្រុកដែលអាចបង្កើតប្រាក់ចំណូលពន្ធលើការលក់ក្នុងស្រុក។

វិធានការនេះក៏នឹងបង្កើតគណៈកម្មការត្រួតពិនិត្យ ដែលអាចនឹងតម្រូវឱ្យធនធានកំណត់ជាក់លាក់ ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន។ ការចំណាយលើការបង្កើតនិងដំណើរការគណៈកម្មការនេះ អាចនឹងចាំបាច់ត្រូវបង្កើតឡើង ហើយអាចនឹងស្ថិតនៅក្រោមការបែងចែកមូលនិធិ។

---

**ទឡ្ហីករណ៍** ▶

ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យត្រូវសរសេរដោយអ្នកគាំទ្រ និងអ្នកបដិសេធលើសំណួរនីមួយៗ និងឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។ **រដ្ឋាភិបាលរដ្ឋម៉ាសាឈូសិតពុំបានគាំទ្រចំពោះទឡ្ហីករណ៍ទាំងនេះទេ ហើយក៏មិនបញ្ជាក់ពីការពិត ឬភាពត្រឹមត្រូវច្បាស់លាស់នៃសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងនៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះរបស់បុគ្គល និងស្ថាប័នដែលបានសរសេរទឡ្ហីករណ៍នីមួយៗ និងមតិយោបល់ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃផ្សេងទៀត ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***បោះឆ្នោតគាំទ្រ៖*** បោះឆ្នោតគាំទ្រលេខ 4 ដើម្បីផ្តល់លទ្ធភាពប្រើប្រាស់ដោយសុវត្ថិភាព និងដោយមានការគ្រប់គ្រងចំពោះថ្នាំរវើរវាយធម្មជាតិដ៏មានប្រសិទ្ធភាពសម្រាប់ជំងឺបាក់ស្បាត (PTSD) ដែលស៊ាំនឹងការព្យាបាល ការថប់បារម្ភ និងជំងឺធ្លាក់ទឹកចិត្ត។ ថ្នាំរវើរវាយ នឹងមានផ្តល់ជូននៅក្នុងទីតាំងព្យាបាលដែលបានអនុញ្ញាត ក្រោមការត្រួតពិនិត្យរបស់អ្នកសម្របសម្រួលដែលទទួលបានការបណ្តុះបណ្តាលនិងមានអាជ្ញាប័ណ្ណ មិនមែនលក់នៅក្នុងហាងដើម្បីយកទៅផ្ទះនោះទេ។

ការស្រាវជ្រាវពីស្ថាប័នវេជ្ជសាស្ត្រឈានមុខគេ រួមមាន Mass General Brigham វិទ្យាស្ថាន Dana Farber Cancer Institute និង Johns Hopkins បង្ហាញថា ថ្នាំរវើរវាយអាចជាការព្យាបាលដ៏មានប្រសិទ្ធភាពសម្រាប់បញ្ហាធ្លាក់ទឹកចិត្ត និងការថប់បារម្ភ ។ តាមពិត ស្ថាប័នរដ្ឋបាលចំណីអាហារនិងឱសថ (FDA) ថ្មីៗនេះបានទទួលស្គាល់ការប្រើសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) ថាជា "ការព្យាបាលដ៏សំខាន់ដែលបានរកឃើញ"។

សម្រាប់មនុស្សជាច្រើនដែលកំពុងរងគ្រោះ ការប្រើថ្នាំប្រចាំថ្ងៃ និងការព្យាបាលតាមស្តង់ដាផ្សេងទៀត មិនមានប្រសិទ្ធភាពទេ។ អតីតយុទ្ធជនជាង 6,000 នាក់បានស្លាប់ដោយសារការធ្វើអត្តឃាតជារៀងរាល់ឆ្នាំ ហើយជាច្រើននាក់ទៀតប្រឈមនឹងការលំបាកពីការប៉ះទង្គិចផ្លូវចិត្តទាក់ទងនឹងកាតព្វកិច្ចយោធា។ ថ្នាំរវើរវាយធម្មជាតិ ក៏អាចផ្តល់ជូនអ្នកជំងឺដែលមានរោគវិនិច្ឆ័យជំងឺដំណាក់កាលចុងក្រោយ នូវការបន្ថយការឈឺចាប់បណ្តាលមកពីការថប់បារម្ភដំណាក់កាលចុងក្រោយនៃជីវិត និងជួយពួកគេឱ្យស្ងប់ក្នុងចិត្ត។

នោះហើយជាមូលហេតុដែលសំណួរទី 4 ត្រូវបានគាំទ្រដោយវេជ្ជបណ្ឌិត អ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត និងអ្នកតស៊ូមតិអតីតយុទ្ធជន។

បោះឆ្នោតគាំទ្រដើម្បីពង្រីកជម្រើសសុខភាពផ្លូវចិត្ត។

**លោកអភិបាលរង Sarko Gergerian ជាអ្នកពិគ្រោះយោបល់ផ្នែកសុខភាពផ្លូវចិត្ត (MHC)**
**Massachusetts for Mental Health Options**
**14 Sullivan Street**
**Boston, MA 02129**
**781-205-9737**
**https://maformentalhealth.org**

***បោះឆ្នោតជំទាស់៖* អ្នកឯកទេសវិជ្ជាជីវៈសុខាភិបាលនិងសុខភាពផ្លូវចិត្ត អតីតយុទ្ធជន និងក្រុមអ្នកជួយព្យាបាល ទទូចសុំឱ្យបដិសេធទៅលើសំណួរទី 4**

- សំណួរទី 4 អាចនឹងលុបចោលទោសទណ្ឌចំពោះការប្រើថ្នាំរវើរវាយ បើកដំណើរការមជ្ឈមណ្ឌលលក់រកប្រាក់កម្រៃ អនុញ្ញាតឱ្យមានការដាំដុះក្នុងតំបន់ដែលមានទំហំ 12 ហ្វីតគុណនឹង 12 ហ្វីតនៅក្នុងផ្ទះ និងការចែកចាយថ្នាំនៅទូទាំងរដ្ឋ។ **ទីផ្សារងងឹតនឹងកើតមានជៀសមិនរួចឡើយតាមរយៈបរិមាណនៃការដាំដុះតាមផ្ទះបែបនេះ។**
- ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការដកហូតប័ណ្ណបើកបរដោយសារការបើកបរក្រោមឥទ្ធិពលថ្នាំ បានកើនឡើង 65% ហើយគ្រោះថ្នាក់នៃការបើកបរក្រោមឥទ្ធិពលថ្នាំ (DUI) ធ្ងន់ធ្ងរបានកើនឡើងជាង 50% ។ **ដោយសារតែអ្នកប្រើប្រាស់ថ្នាំរវើរវាយញឹកញាប់ម្នាក់ក្នុងចំណោម 3 នាក់បានរាយការណ៍អំពីការបើកបរក្រោមឥទ្ធិពលនៃថ្នាំរវើរវាយ**ក្នុងឆ្នាំកន្លងទៅ ដូច្នេះ តួលេខនេះនឹងកើនឡើងបន្ថែមទៀត។
- **សារធាតុអ៊ីបូហ្គាអ៊ីន (ibogaine) នៅក្នុងថ្នាំរវើរវាយ បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់មុខងារបេះដូង ដែលគម្រាមកំហែងដល់អាយុជីវិត** អាចកើតមានជំងឺខ្សោយបេះដូងក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីប្រើថ្នាំមួយដូស។
- ការទទួលទានដោយចៃដន្យនូវអាហារដែលមានសារធាតុនេះ មានគ្រោះថ្នាក់ជាពិសេស**ចំពោះកុមារនិងសត្វចិញ្ចឹម។**
- មជ្ឈមណ្ឌលមិនត្រូវបានតម្រូវឱ្យគ្រប់គ្រងដោយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាល មិនអាចផ្តល់ការថែទាំឯកទេសនៅអំឡុងពេលមានប្រតិកម្មទាស់ និងមិនត្រូវបានហាមឃាត់ **មិនឱ្យផ្តល់ថ្នាំរវើរវាយដល់អ្នកជំងឺដែលមានហានិភ័យខ្ពស់** ដូចជាអ្នកដែលមាន**ជំងឺវិកលចរិត ជំងឺបាយប៉ូឡា និងស្ត្រីមានផ្ទៃពោះ ឬបំបៅដោះកូននោះទេ។**

**វេជ្ជបណ្ឌិត Anahita Dua**
**គ្រូពេទ្យវះកាត់ នៅមន្ទីរពេទ្យទូទៅនៃរដ្ឋម៉ាសាឈូសិត**
**សាស្ត្រាចារ្យរងផ្នែកវះកាត់ សាលា Harvard Medical School**
**សម្ព័ន្ធដើម្បីសហគមន៍មានសុវត្ថិភាព (Coalition For Safe Communities)**
**11 Beacon Street, Suite 1125**
**Boston, MA 02108**
**www.SafeCommunitiesMA.com**

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ**

ត្រូវអនុម័តដោយប្រជាជន និងតាមសិទ្ធិអំណាចរបស់ពួកគេ ដូចខាងក្រោម៖

ច្បាប់ស្តីពីសារធាតុរវើរវាយធម្មជាតិ

ផ្នែកទី 1. គោលបំណងនៃច្បាប់នេះគឺដើម្បីបង្កើតអភិក្រមថ្មី ប្រកបដោយមេត្តាធម៌ មានទំនួលខុសត្រូវផ្នែកវប្បធម៌ និងមានប្រសិទ្ធភាពចំពោះការប្រើសារធាតុរវើរវាយធម្មជាតិតាមរយៈ៖ (a) ការបង្កើតលទ្ធភាពទទួលបានសារធាតុរវើរវាយធម្មជាតិតាមការកំណត់សម្រាប់មនុស្សពេញវ័យដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ ដែលបង្ហាញពីសក្តានុពលព្យាបាលក្នុងការបង្កើនសុខុមាលភាព និងការពេញចិត្តក្នុងជីវិត និងការកែលម្អសុខភាពផ្លូវចិត្ត។ និង (b) ការទទួលយកអភិក្រមសុខភាពសាធារណៈចំពោះសារធាតុរវើរវាយធម្មជាតិ តាមរយៈការលុបចោលការដាក់ទោសព្រហ្មទណ្ឌសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនតិចតួចរបស់មនុស្សពេញវ័យដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ។ គោលបំណងរបស់ច្បាប់នេះគឺដើម្បីលុបចោលការប្រើប្រាស់ផ្ទាល់ខ្លួននូវសារធាតុរវើរវាយធម្មជាតិពីក្នុងទីផ្សារខុសច្បាប់ និងដើម្បីផ្តល់លទ្ធភាពទទួលបានថ្នាំដោយមានការត្រួតពិនិត្យ និងដោយសុវត្ថិភាពនៅក្នុងការទីតាំងព្យាបាលតាមរយៈប្រព័ន្ធដែលបានគ្រប់គ្រងនិងជាប់ពន្ធ។ តាមលទ្ធភាពដែលអាចធ្វើបាន លក្ខខណ្ឌរបស់ច្បាប់នេះត្រូវបានបកស្រាយស្របតាមគោលបំណងនិងឆន្ទៈដែលមានចែងក្នុងផ្នែកនេះ។

ផ្នែកទី 2. ច្បាប់នេះត្រូវបានហៅថា "ច្បាប់ស្តីពីសារធាតុរវើរវាយធម្មជាតិ"។

ផ្នែកទី 3. ជំពូក 10 នៃច្បាប់ទូទៅត្រូវបានធ្វើវិសោធនកម្មដោយការដាក់បញ្ចូលបន្ទាប់ពីផ្នែក 78 នូវផ្នែកបន្តបន្ទាប់ដូចខាងក្រោម៖

ផ្នែក 79. គណៈកម្មការសារធាតុរវើរវាយធម្មជាតិ

(a) នឹងត្រូវមានគណៈកម្មការសារធាតុរវើរវាយធម្មជាតិរបស់រដ្ឋម៉ាសាឈូសិត ដែលមានសមាសភាពសមាជិកគណៈកម្មការចំនួន 5 រូប៖ ម្នាក់ក្នុងចំណោមពួកគេទាំងនោះ ត្រូវបានតែងតាំងដោយអភិបាល និងត្រូវមានបទពិសោធន៍ខាងផ្នែកស្រាវជ្រាវនិងវិទ្យាសាស្ត្រលើថ្នាំរវើរវាយ។ ម្នាក់ក្នុងចំណោមពួកគេទាំងនោះ ត្រូវបានតែងតាំងដោយអគ្គរដ្ឋអាជ្ញា ហើយត្រូវមានបទពិសោធន៍ខាងផ្នែកសុវត្ថិភាពសាធារណៈ។ ម្នាក់ក្នុងចំណោមពួកគេទាំងនោះ នឹងត្រូវបានតែងតាំងដោយអគ្គហិរញ្ញិកនិងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ហើយត្រូវមានបទពិសោធន៍ក្នុងការគ្រប់គ្រងសាជីវកម្ម ហិរញ្ញវត្ថុ ឬមូលបត្រ។ ហើយ 2 នាក់ក្នុងចំណោមពួកគេទាំងនោះ នឹងត្រូវបានតែងតាំងដោយការបោះឆ្នោតសំឡេងភាគច្រើនរបស់អភិបាល អគ្គរដ្ឋអាជ្ញា ហិរញ្ញិក និងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ ដែលពួកគេម្នាក់ៗត្រូវមានបទពិសោធន៍វិជ្ជាជីវៈក្នុងការត្រួតពិនិត្យ ឬការគ្រប់គ្រងឧស្សាហកម្ម រួមទាំងការផ្តល់សេវាផងដែរ នៅក្នុងឧស្សាហកម្មដែលបានគ្រប់គ្រង ហើយម្នាក់ក្នុងចំណោមពួកគេទាំងនោះត្រូវមានបទពិសោធន៍ទាក់ទងនឹងការប្រើប្រាស់សារធាតុរវើរវាយធម្មជាតិរបស់ជនជាតិដើមភាគតិច ឬតាមបែបប្រពៃណី។ អគ្គហិរញ្ញិក និងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែងតាំងប្រធានគណៈកម្មការ។ ប្រធានត្រូវបម្រើការក្នុងសមាសភាពនោះពេញមួយអាណត្តិនៃការតែងតាំង និងរហូតដល់អ្នកស្នងតំណែងម្នាក់ត្រូវបានតែងតាំង។ មុនពេលតែងតាំងគណៈកម្មការ ការស៊ើបអង្កេតពីប្រវត្តិសាវតារត្រូវធ្វើឡើងទៅលើស្ថិរភាពហិរញ្ញវត្ថុ សុចរិតភាព និងការទទួលខុសត្រូវរបស់បេក្ខជន រួមទាំងកេរ្តិ៍ឈ្មោះរបស់បេក្ខជនចំពោះចរិតលក្ខណៈល្អ និងភាពស្មោះត្រង់។ គ្មានជនណាដែលធ្លាប់បានជាប់ទោសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិចូលបម្រើការងារក្នុងគណៈកម្មការនេះឡើយ។

(b) សមាជិកគណៈកម្មការនីមួយៗ ត្រូវតែជាអ្នករស់នៅក្នុងរដ្ឋម៉ាសាឈូសិត ក្នុងរយៈពេល 90 ថ្ងៃបន្ទាប់ពីការតែងតាំង ហើយក្នុងពេលបំពេញការងារក្នុងគណៈកម្មការ មិនត្រូវ៖ (i) កាន់មុខតំណែង ឬជាបេក្ខជនសម្រាប់មុខតំណែងថ្នាក់សហព័ន្ធ ថ្នាក់រដ្ឋ ឬថ្នាក់មូលដ្ឋាន (ii) កាន់តំណែងដែលបានតែងតាំងនៅក្នុងរដ្ឋាភិបាលសហព័ន្ធ រដ្ឋ ឬមូលដ្ឋាន ឬ (iii) បម្រើការជាមន្ត្រីនៅក្នុងគណបក្សនយោបាយឡើយ។ មិនត្រូវមានសមាជិកគណៈកម្មការមិនលើសពី 3 រូបមកពីគណបក្សនយោបាយតែមួយឡើយ។

(c) សមាជិកគណៈកម្មការនីមួយៗ ត្រូវបម្រើការងាររយៈពេល 5 ឆ្នាំ ឬរហូតដល់អ្នកស្នងតំណែងត្រូវបានតែងតាំង ហើយមានសិទ្ធិក្នុងការតែងតាំងសាជាថ្មី។ តែទោះយ៉ាងណាក៏ដោយ គ្មានសមាជិកគណៈកម្មការណាម្នាក់ត្រូវបំពេញតួនាទីលើសពី 10 ឆ្នាំឡើយ។ បុគ្គលដែលត្រូវបានតែងតាំងឱ្យចូលកាន់តួនាទីទំនេរក្នុងតំណែងរបស់សមាជិកគណៈកម្មការ ត្រូវបានតែងតាំងក្នុងលក្ខណៈដូចគ្នា ហើយត្រូវបំពេញតួនាទីតែក្នុងអាណត្តិដែលមិនទាន់ផុតសុពលភាពរបស់សមាជិកគណៈកម្មការនោះតែប៉ុណ្ណោះ។

(d) អភិបាល អគ្គរដ្ឋអាជ្ញា ឬហិរញ្ញិក និងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ អាចដកសមាជិកគណៈកម្មការមួយរូបដែលបានតែងតាំងដោយសិទ្ធិអំណាចតែងតាំងនោះបាន ប្រសិនបើសមាជិកគណៈកម្មការ៖ (i) មានពិរុទ្ធពីបទប្រព្រឹត្តអំពើខុសច្បាប់នៅក្នុងមុខតំណែង (ii) ធ្វេសប្រហែសយ៉ាងខ្លាំងចំពោះភារកិច្ចរបស់គណៈកម្មការ (iii) មិនអាចប្រើប្រាស់សិទ្ធិអំណាច និងភារកិច្ចនោះបាន (iv) ប្រព្រឹត្តិខុសធ្ងន់ធ្ងរ ឬ (v) ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ។ មុននឹងដកតំណែង សមាជិកគណៈកម្មការត្រូវទទួលបានសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការដកតំណែង និងទទួលបានឱកាសដើម្បីយល់ពីហេតុផល និងតវ៉ាប្រសិនបើការដកតំណែងនេះមិនត្រឹមត្រូវ។

(e) អភិបាល អគ្គរដ្ឋអាជ្ញា និងអគ្គហិរញ្ញិកនិងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ អាចដកតំណែងតាមការបោះឆ្នោតសំឡេងភាគច្រើន នូវសមាជិកគណៈកម្មការដែលបានទទួលការតែងតាំងដោយការបោះឆ្នោតសំឡេងភាគច្រើននៃអភិបាល អគ្គរដ្ឋអាជ្ញា និងហិរញ្ញិកនិងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ ប្រសិនបើសមាជិកគណៈកម្មការ៖ (i) មានពិរុទ្ធពីបទប្រព្រឹត្តអំពើខុសច្បាប់នៅក្នុងមុខតំណែង (ii) ធ្វេសប្រហែសយ៉ាងខ្លាំងចំពោះភារកិច្ចរបស់គណៈកម្មការ (iii) មិនអាចប្រើប្រាស់សិទ្ធិអំណាច និងភារកិច្ចនៃមុខតំណែងរបស់សមាជិកគណៈកម្មការនោះបាន (iv) ប្រព្រឹត្តិខុសធ្ងន់ធ្ងរ ឬ (v) ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ។ មុននឹងដកតំណែង សមាជិកគណៈកម្មការត្រូវទទួលបានសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការដកតំណែង និងទទួលបានឱកាសដើម្បីយល់ពីហេតុផល និងតវ៉ាប្រសិនបើការដកតំណែងនេះមិនត្រឹមត្រូវ។

(f) សមាជិកគណៈកម្មការបីរូប ត្រូវបង្កើតបានជាមួយកូរ៉ុម ហើយត្រូវតម្រូវឱ្យមានការបោះឆ្នោតគាំទ្ររបស់សមាជិកគណៈកម្មាការចំនួន 3 រូប សម្រាប់វិធានការរបស់គណៈកម្មការ។ ប្រធាន ឬសមាជិក 3 រូបនៃគណៈកម្មការអាចកោះហៅការប្រជុំមួយ តែយ៉ាងណាក៏ដោយ ការជូនដំណឹងអំពីការប្រជុំទាំងអស់ត្រូវផ្តល់ជូនដល់សមាជិកគណៈកម្មការនីមួយៗ និងអ្នកផ្សេងទៀតដែលស្នើសុំការជូនដំណឹងនោះ។ គណៈកម្មការត្រូវបង្កើតបទប្បញ្ញត្តិកំណត់នីតិវិធី ដែលអាចរាប់បញ្ចូលទាំងទំនាក់ទំនងតាម

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

ប្រព័ន្ធអេឡិចត្រូនិកផងដែរ សម្រាប់ការប្រគល់សំណើសុំទទួលការជូនដំណឹង និង សម្រាប់វិធីក្នុងការទទួលបានការជូនដំណឹងទាន់ពេលវេលា។

(g) សមាជិកគណៈកម្មការ ត្រូវទទួលបានប្រាក់ខែមិនលើសពី .75 នៃប្រាក់បៀវត្សរ៍របស់រដ្ឋមន្ត្រីក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ អនុលោមតាមផ្នែកទី 4 នៃជំពូកទី 7។ តែទោះយ៉ាងណាក៏ដោយ ប្រធានត្រូវទទួលបានប្រាក់ខែស្មើនឹងប្រាក់ខែរបស់រដ្ឋមន្ត្រីក្រសួងរដ្ឋបាលនិងហិរញ្ញវត្ថុ។ សមាជិកគណៈកម្មការត្រូវលះបង់ពេលវេលា និងយកចិត្តទុកដាក់ពេញទំហឹងក្នុងតួនាទីភារកិច្ចរបស់ខ្លួន។

(h) គណៈកម្មការត្រូវជ្រើសរើសសមាជិក 1 រូបជារៀងរាល់ឆ្នាំឱ្យធ្វើជាលេខា និងជ្រើសរើសសមាជិក 1 រូបឱ្យធ្វើជាហិរញ្ញិក។ លេខាត្រូវរក្សាកំណត់ត្រាដំណើរការរបស់គណៈកម្មការ ហើយត្រូវធ្វើជាអ្នកមើលថែ និងរក្សាកំណត់ត្រាសៀវភៅ ឯកសារ និងលិខិតស្នាមទាំងអស់ដែលប្រគល់ជូនដោយគណៈកម្មការ និងកំណត់ត្រាកំណត់ហេតុប្រជុំរបស់គណៈកម្មការ។ លេខាធិការត្រូវថតចម្លងសំណៅឯកសារកំណត់ហេតុប្រជុំទាំងអស់ និងកំណត់ត្រានិងឯកសារផ្សេងទៀតរបស់គណៈកម្មការ ហើយត្រូវបញ្ជាក់ថាសំណៅថតចម្លងទាំងនោះជាច្បាប់ចម្លងត្រឹមត្រូវពិតប្រាកដ ហើយបុគ្គលគ្រប់រូបដែលទាក់ទងជាមួយគណៈកម្មការអាចពឹងផ្អែកលើការបញ្ជាក់នេះបាន។

(i) ប្រធានត្រូវមាន និងអនុវត្តការត្រួតពិនិត្យនិងគ្រប់គ្រងលើកិច្ចការទាំងអស់របស់គណៈកម្មការ។ ប្រធានត្រូវធ្វើជាអធិបតីភាពក្នុងសវនាការទាំងអស់ដែលប្រធានមានវត្តមាន ហើយត្រូវចាត់តាំងសមាជិកគណៈកម្មការមួយរូបឱ្យធ្វើជាប្រធានក្នុងពេលអវត្តមានប្រធាន។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង ប្រធានត្រូវធ្វើការបែងចែក ឬបន្តបែងចែកការងាររបស់គណៈកម្មការក្នុងចំណោមសមាជិកគណៈកម្មការតាមដែលប្រធានយល់ឃើញថាសមស្រប។

(j) សមាជិកគណៈកម្មការត្រូវចូលរួម តាមការដឹកនាំរបស់ប្រធាន នៅក្នុងសវនាការនិងការសម្រេចចិត្តលើបញ្ហាណាមួយនៅចំពោះមុខគណៈកម្មការ។ តែទោះយ៉ាងណាក៏ដោយ យ៉ាងហោចណាស់សមាជិកគណៈកម្មការ 2 រូប ត្រូវចូលរួមក្នុងសវនាការនិងការសម្រេចចិត្តលើបញ្ហាផ្សេងទៀត ក្រៅពីបញ្ហាដែលមានលក្ខណៈផ្លូវការឬតាមបែបបទរដ្ឋបាល នៅចំពោះមុខគណៈកម្មការ។ លើសពីនេះទៀត រាល់បញ្ហាទាំងអស់នោះអាចនឹងត្រូវបានធ្វើសវនការ ត្រួតពិនិត្យ និងស៊ើបអង្កេតដោយនិយោជិតរបស់គណៈកម្មការដែលបានចាត់តាំង និងប្រគល់សិទ្ធិដោយប្រធាន ដោយមានការឯកភាពពីសមាជិកគណៈកម្មការម្នាក់ទៀត។ និយោជិតនោះត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទាក់ទងនឹងសវនាការ ការពិនិត្យ និងការស៊ើបអង្កេតរាល់បញ្ហាទាំងនោះ ជូនដល់គណៈកម្មការដើម្បីធ្វើការការសម្រេច។ សម្រាប់គោលបំណងនៃសវនាការ ការពិនិត្យ និងការស៊ើបអង្កេតលើបញ្ហាណាមួយ និយោជិតនោះត្រូវមានសិទ្ធិអំណាចគ្រប់យ៉ាងដែលទទួលបានក្នុងនាមជាសមាជិកគណៈកម្មការ អនុលោមតាមផ្នែកនេះ។ សម្រាប់សវនាការនីមួយៗ ការឯកភាពគ្នារបស់សមាជិកគណៈកម្មការភាគច្រើនដែលចូលរួមក្នុងការសម្រេចនោះ គឺជាការចាំបាច់។

(k) គណៈកម្មការត្រូវតែងតាំងនាយកប្រតិបត្តិម្នាក់។ នាយកប្រតិបត្តិត្រូវបំពេញមុខងារតាមការចង់បានរបស់គណៈកម្មការ ត្រូវទទួលបានប្រាក់បៀវត្សរ៍តាមការកំណត់ដោយគណៈកម្មការ ហើយត្រូវលះបង់ពេលវេលា និងយកចិត្តទុកដាក់ពេញទំហឹងលើភារកិច្ចក្នុងមុខតំណែង។ នាយកប្រតិបត្តិត្រូវតែជាបុគ្គលដែលមានជំនាញ និងបទពិសោធន៍ក្នុងការគ្រប់គ្រង ត្រូវធ្វើជានាយកប្រតិបត្តិ និងជាប្រធានរដ្ឋបាលនៃគណៈកម្មការ ហើយត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងនិងអនុវត្តច្បាប់ទាក់ទងនឹងគណៈកម្មការ និងអង្គភាពរដ្ឋបាលនីមួយៗ។ នាយកប្រតិបត្តិត្រូវតែងតាំងនិងជួលប្រធានផ្នែកហិរញ្ញវត្ថុនិងគណនេយ្យ និងអាចជួលបុគ្គលិកផ្សេងទៀត ទីប្រឹក្សាភ្នាក់ងារ និងទីប្រឹក្សា ព្រមទាំងទីប្រឹក្សាច្បាប់ ស្ថិតក្រោមការយល់ព្រមពីគណៈកម្មការ ហើយត្រូវចូលរួមកិច្ចប្រជុំរបស់គណៈកម្មការ។ ប្រធានផ្នែកហិរញ្ញវត្ថុនិងគណនេយ្យនៃគណៈកម្មការ ត្រូវទទួលបន្ទុកលើថវិកា សៀវភៅគណនេយ្យ និងកំណត់ត្រាគណនេយ្យរបស់ខ្លួន។ គ្មានមូលនិធិណាមួយត្រូវបានផ្ទេរដោយគណៈកម្មការដោយគ្មានការយល់ព្រមពីគណៈកម្មការ និងហត្ថលេខារបស់ប្រធានហិរញ្ញវត្ថុនិងគណនេយ្យនិងហិរញ្ញិករបស់គណៈកម្មការនោះទេ។ ក្នុងករណីអវត្តមាន ឬគ្មានអ្នកកាន់មុខតំណែងនាយកប្រតិបត្តិ ឬករណីពិការភាពដែលកំណត់ដោយគណៈកម្មការនោះ គណៈកម្មការអាចចាត់តាំងនាយកប្រតិបត្តិស្តីទីម្នាក់ឱ្យបម្រើការជានាយកប្រតិបត្តិរហូតដល់មានអ្នកចូលកាន់មុខតំណែងនោះ ឬលែងមានអវត្តមាន ឬពិការភាពតទៅទៀត។ នាយកប្រតិបត្តិស្តីទីត្រូវមានសិទ្ធិអំណាចនិងភារកិច្ចគ្រប់យ៉ាងក្នុងនាមជានាយកប្រតិបត្តិ ហើយមានលក្ខណៈសម្បត្តិប្រហាក់ប្រហែលនឹងនាយកប្រតិបត្តិដែរ។

(l) ជំពូក 268A និង 268B ត្រូវអនុវត្តចំពោះសមាជិកគណៈកម្មការ និងនិយោជិតនៃគណៈកម្មការ។ តែទោះយ៉ាងណាក៏ដោយ គណៈកម្មការត្រូវបង្កើតក្រមសីលធម៌សម្រាប់សមាជិក និងនិយោជិតទាំងអស់ ដែលត្រូវមានលក្ខណៈតឹងរ៉ឹងជាងជំពូក 268A និង 268B។ ច្បាប់ចម្លងនៃក្រមសីលធម៌នេះ ត្រូវដាក់ជូនទៅគណៈកម្មការសីលធម៌របស់រដ្ឋ។ ក្រមនេះនឹងរួមបញ្ចូលនូវបទប្បញ្ញត្តិដែលចាំបាច់ក្នុងការអនុវត្តគោលបំណងនៃផ្នែកនេះ និងច្បាប់ផ្សេងទៀតដែលស្ថិតក្រោមយុត្តាធិការរបស់គណៈកម្មការ រួមមានជាអាទិ៍៖ (i) ការហាមប្រាមការទទួលអំណោយដោយសមាជិកគណៈកម្មការនិងនិយោជិត ពីអ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ អ្នកស្នើសុំ សហការីជិតស្និទ្ធ សាខា ឬបុគ្គលផ្សេងទៀត ឬអង្គភាពដែលស្ថិតនៅក្រោមយុត្តាធិការនៃគណៈកម្មការ។ (ii) ការហាមប្រាមការចូលរួមដោយសមាជិកគណៈកម្មការនិងនិយោជិត នៅក្នុងបញ្ហាជាក់លាក់មួយ ដូចដែលបានកំណត់ក្នុងផ្នែកទី 1 នៃជំពូកទី 268A ដែលប៉ះពាល់ដល់ផលប្រយោជន៍ហិរញ្ញវត្ថុរបស់សាច់ញាតិជិតស្និទ្ធបីជំនាន់ ឬបុគ្គលដែលសមាជិកគណៈកម្មការឬនិយោជិតនោះមានទំនាក់ទំនងសំខាន់ៗជាមួយ ដូចបានកំណត់និយមន័យនៅក្នុងច្បាប់នេះ។ និង (iii) ការផ្តល់សម្រាប់ការដកខ្លួនចេញរបស់សមាជិកគណៈកម្មការក្នុងការសម្រេចចិត្តផ្តល់អាជ្ញាប័ណ្ណដោយសារទំនាស់ផលប្រយោជន៍ដែលអាចកើតមាន។

(m) គណៈកម្មការសារធាតុរវើរវាយធម្មជាតិនៃរដ្ឋម៉ាសាឈូសេត ត្រូវតែជាគណៈកម្មការសម្រាប់គោលបំណងនៃផ្នែកទី 3 នៃជំពូក 12 ។

(n) សម្រាប់គោលបំណងនៃការអនុលោមតាមច្បាប់ហិរញ្ញវត្ថុរបស់រដ្ឋ គណៈកម្មការត្រូវដំណើរការជាទីភ្នាក់ងាររដ្ឋ ដូចបានកំណត់ក្នុងផ្នែកទី 1 នៃជំពូកទី 29 ហើយត្រូវអនុលោមតាមច្បាប់ជាធរមានសម្រាប់ទីភ្នាក់ងារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាល។ តែទោះជាយ៉ាងណាក៏ដោយ ត្រូវអនុវត្តតាមការណែនាំឬសកម្មភាពចាំបាច់សម្រាប់នាយកដ្ឋានក្នុងការគ្រប់គ្រងប្រតិបត្តិការសារពើពន្ធនៅក្នុងប្រព័ន្ធគណនេយ្យ

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

របស់រដ្ឋ និងក្នុងការបំពេញតាមស្តង់ដាគណនេយ្យនិងសវនកម្មរបស់រដ្ឋ និងស្តង់ដាផ្សេងទៀតរបស់រដ្ឋាភិបាល។ គណៈកម្មការត្រូវចាត់ថ្នាក់ឱ្យបានត្រឹមត្រូវនូវការចំណាយលើប្រតិបត្តិការនិងមូលធនរបស់ខ្លួន ហើយមិនត្រូវរាប់បញ្ចូលប្រាក់បៀវត្សរ៍របស់និយោជិតទៅក្នុងការចំណាយមូលធនរបស់គណៈកម្មការនោះទេ។ លុះត្រាតែច្បាប់ឬទីភ្នាក់ងារសេវាកណ្តាលជាធរមានផ្តល់ការអនុគ្រោះ ពុំនោះទេ គណៈកម្មការនឹងចូលរួមនៅក្នុងសេវាកម្មថ្នាក់កណ្តាលរបស់រដ្ឋម៉ាសាឈូសិតដែលមានផ្តល់ជូនផ្សេៗ រួមមានជាអាទិ៍ ប្រព័ន្ធបើកប្រាក់បៀវត្សរ៍របស់រដ្ឋ អនុលោមតាមផ្នែកទី 31 នៃជំពូកទី 29 ដែលបានពោលនោះ ហើយអាចទិញទំនិញនិងសេវាផ្សេងទៀតដែលផ្តល់ដោយទីភ្នាក់ងាររដ្ឋ ស្របតាមបទប្បញ្ញត្តិអ្នកគ្រប់គ្រង។ អ្នកគ្រប់គ្រងអាចគិតថ្លៃពីគណៈកម្មការមកវិញ សម្រាប់ការផ្លាស់ប្តូរនិងការចំណាយបន្តបន្ទាប់លើការចូលរួមក្នុងប្រព័ន្ធគណនេយ្យ និងប្រព័ន្ធបើកប្រាក់បៀវត្សរ៍របស់រដ្ឋ ហើយអាចរក្សាទុក និងធ្វើការចំណាយថ្លៃទាំងនោះដោយមិនមានការបែងចែកមូលនិធិបន្ថែមទៀតសម្រាប់គោលបំណងនៃផ្នែកនេះនោះទេ។ គណៈកម្មការត្រូវស្ថិតនៅក្រោមផ្នែកទី 5D និងផ្នែករង (f) នៃផ្នែកទី 6B នៃជំពូកទី 29 ។

ផ្នែក 80. ក្រុមប្រឹក្សាពិគ្រោះសារធាតុវើរវាយធម្មជាតិ

(a) ត្រូវមានក្រុមប្រឹក្សាពិគ្រោះសារធាតុវើរវាយធម្មជាតិ ដើម្បីសិក្សានិងផ្តល់អនុសាសន៍ដល់គណៈកម្មការសារធាតុវើរវាយធម្មជាតិនៃរដ្ឋម៉ាសាឈូសិតស្តីពីការគ្រប់គ្រងនិងការយកពន្ធសារធាតុវើរវាយធម្មជាតិ។ ក្រុមប្រឹក្សាមានសមាសភាព៖ នាយកប្រតិបត្តិគណៈកម្មការសារធាតុវើរវាយធម្មជាតិនៃរដ្ឋម៉ាសាឈូសិត ដែលនឹងធ្វើជាប្រធាន រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងសេវាមនុស្សជាតិ ឬអ្នកទទួលបានការជ្រើសតាំង, រដ្ឋមន្ត្រីទទួលបន្ទុកចំណូល ឬអ្នកទទួលបានការជ្រើសតាំង រដ្ឋមន្ត្រីទទួលបន្ទុកសុខភាពសាធារណៈ ឬអ្នកទទួលបានការជ្រើសតាំង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬអ្នកទទួលបានការជ្រើសតាំង។ បុគ្គល 5 រូបដែលតែងតាំងដោយអភិបាលក្រុង៖ 1 រូបជាអ្នកជំនាញផ្នែក សុខភាពផ្លូវចិត្តឬអាកប្បកិរិយា 1 រូបជាអ្នកជំនាញព្យាបាលដោយប្រើសារធាតុវើរវាយធម្មជាតិ 1 រូបជាអ្នកមានជំនាញលើបញ្ហាដែលអតីតយុទ្ធជនជួបប្រទះ 1 រូបជាអ្នកមានជំនាញក្នុងការបង្កើតនិងអនុវត្តវិធីសាស្ត្រវាយតម្លៃដើម្បីវាយតម្លៃលទ្ធផលនៃកម្មវិធី រួមទាំងសមិទ្ធផល សុវត្ថិភាព គុណភាព និងផលប៉ះពាល់លើបុគ្គល និង 1 រូបទៀតជាអ្នកមានជំនាញក្នុងការប្រើសារធាតុវើរវាយធម្មជាតិរបស់ជនជាតិដើមភាគតិច។ បុគ្គល 5 រូបដែលបានតែងតាំងដោយអគ្គរដ្ឋអាជ្ញា៖ 1 រូបជាអ្នកមានជំនាញផ្នែកធានារ៉ាប់រងការថែទាំសុខភាព ឬឧបសគ្គក្នុងការទទួលបានសេវាថែទាំសុខភាព 1 រូបជាអ្នកមានជំនាញផ្នែកសេវាវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ឬអ្នកសង្គ្រោះបន្ទាន់ 1 រូបជាអ្នកមានជំនាញខាងផ្នែកសិក្សាអំពីផ្សិតនិងការដាំដុះសារធាតុវើរវាយធម្មជាតិ 1 រូបជាអ្នកមានជំនាញខាងបទពិសោធន៍ក្នុងការបណ្តុះបណ្តាលអ្នកសម្របសម្រួលជំនួយផ្លូវចិត្ត និង 1 រូបទៀតមានជំនាញក្នុងការប្រើប្រាស់សារធាតុវើរវាយធម្មជាតិរបស់ជនជាតិដើមភាគតិច។ និងបុគ្គល 5 រូបដែលចាត់តាំងដោយអគ្គហិរញ្ញិកនិងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ៖ 1 រូបជាអ្នកមានជំនាញផ្នែកកាត់បន្ថយគ្រោះថ្នាក់ 1 រូបជាអ្នកមានជំនាញផ្នែកគោលនយោបាយសារធាតុវើរវាយធម្មជាតិ 1 រូបជាអ្នកមានជំនាញផ្នែកស្រាវជ្រាវសារធាតុវើរវាយធម្មជាតិ 1 រូបជាគ្រូណែនាំស្តារនីតិសម្បទាមិត្តរួមក្រុម ឬអ្នកឯកទេសមានការបញ្ជាក់ដែលមានបទពិសោធន៍ក្នុងការបណ្តុះបណ្តាល និងវិញ្ញាបនប័ត្រជំនួយមិត្តរួមក្រុមនៅរដ្ឋម៉ាសាឈូសិត, និង 1 រូបទៀតជាអ្នកមានជំនាញក្នុងការប្រើប្រាស់សារធាតុវើរវាយធម្មជាតិរបស់ជនជាតិដើមភាគតិច។ សមាជិកនៃក្រុមប្រឹក្សា ត្រូវបំពេញតួនាទីសម្រាប់អាណត្តិរយៈពេល 2 ឆ្នាំ ឬរហូតដល់អ្នកស្នងតំណែងម្នាក់ត្រូវបានតែងតាំង និងត្រូវមានសិទ្ធិទទួលបានការតែងតាំងសាជាថ្មី។ សមាជិកក្រុមប្រឹក្សា ត្រូវបំពេញមុខងារដោយគ្មានផលតបស្នង ប៉ុន្តែត្រូវទទួលបានការទូទាត់សងមកវិញនូវការចំណាយរបស់ពួកគេដែលកើតមានជាក់ស្តែងនិងចាំបាច់នៅក្នុងការអនុវត្តភារកិច្ចផ្លូវការរបស់ពួកគេ។ សមាជិកក្រុមប្រឹក្សាគប្បីមិនមែនជាបុគ្គលិករដ្ឋក្រោមជំពូក 268A ដោយសារតែការងាររបស់ពួកគេនៅលើក្រុមប្រឹក្សានោះទេ។ ដើម្បីអនុវត្តសកម្មភាពនៅក្នុងកិច្ចប្រជុំមួយ សមាជិកភាគច្រើននៃក្រុមប្រឹក្សាដែលមានវត្តមាននិងបោះឆ្នោត ត្រូវបង្កើតបានជាមួយកូរ៉ុម។

(b) ក្រុមប្រឹក្សាភិបាលត្រូវ៖

(i) ពិចារណាលើបញ្ហាទាំងអស់ដែលបានប្រគល់ជូនខ្លួនដោយគណៈកម្មការ។

(ii) ប្រឹក្សាយោបល់ជូនគណៈកម្មការលើគោលការណ៍ណែនាំ វិធាន និងបទប្បញ្ញត្តិនានា រួមមាន៖

(A) វិធីសាស្ត្រសុខភាពសាធារណៈដែលត្រឹមត្រូវនិងសមស្របតាមវប្បធម៌ ទាក់ទងនឹងការប្រើប្រាស់ ប្រសិទ្ធភាព និងការកាត់បន្ថយហានិភ័យសម្រាប់សារធាតុវើរវាយធម្មជាតិ និងខ្លឹមសារនិងវិសាលភាពនៃយុទ្ធនាការអប់រំទាក់ទងនឹងសារធាតុវើរវាយធម្មជាតិ។

(B) ការស្រាវជ្រាវទាក់ទងនឹងប្រសិទ្ធភាព និងបទប្បញ្ញត្តិនៃសារធាតុវើរវាយធម្មជាតិ រួមទាំងអនុសាសន៍ទាក់ទងនឹងសុវត្ថិភាពផលិតផល ការកាត់បន្ថយគ្រោះថ្នាក់ និងទំនួលខុសត្រូវវប្បធម៌។

(C) កម្មវិធីបណ្តុះបណ្តាល លក្ខខណ្ឌតម្រូវខាងអប់រំនិងពិសោធន៍ កម្រិតផ្សេងៗនៃការចេញអាជ្ញាប័ណ្ណ វិសាលភាពនៃការអនុវត្ត និងលក្ខណសម្បត្តិសម្រាប់អ្នកសម្របសម្រួលដែលការពារសុវត្ថិភាពអ្នកចូលរួម បង្កើនលទ្ធភាពទទួលបានសេវា និងកាត់បន្ថយឧបសគ្គចំពោះការផ្តល់អាជ្ញាប័ណ្ណ ដោយគិតគូរដល់គំរូនៃការអប់រំនិងការបញ្ជាក់ដែលមានស្រាប់នៅក្នុងរដ្ឋម៉ាសាឈូសិត រួមទាំងគំរូការបញ្ជាក់ការគាំទ្រមិត្តរួមក្រុម និងរបៀបល្អបំផុតក្នុងការការពារក្រុមអតីតយុទ្ធជនចាស់ៗដែលប្រើសារធាតុវើរវាយធម្មជាតិ និងសមាជិកនៃសហគមន៍ស្វ័យគ្រប់គ្រងផ្សេងទៀត។

(D) លទ្ធភាពសមរម្យ សមធម៌ សីលធម៌ បរិយាបន្ន និងទំនួលខុសត្រូវផ្នែកវប្បធម៌ក្នុងការទទួលបានសេវាសារធាតុវើរវាយធម្មជាតិ និងលក្ខខណ្ឌតម្រូវដើម្បីធានាថា ការទទួលបានសារធាតុវើរវាយធម្មជាតិគឺមានតម្លៃសមរម្យ សមធម៌ សីលធម៌ បរិយាបន្ន និងទំនួលខុសត្រូវខាងវប្បធម៌។

(E) ការការពារការប្រើប្រាស់និងអនុវត្តបែបប្រពៃណីទាក់ទងនឹងសារធាតុវើរវាយធម្មជាតិ និងទទួលបានការបណ្តុះបណ្តាលដោយស្ម័គ្រចិត្ត និងឧត្តមានុវត្តដែលលើកកម្ពស់សុវត្ថិភាព និងកាត់បន្ថយគ្រោះថ្នាក់នៃការប្រើប្រាស់ដែលស្ថិតនៅក្រៅប្រព័ន្ធគ្រប់គ្រង។

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

(F) លក្ខខណ្ឌតម្រូវ វិធីសាស្ត្រ ការរាយការណ៍ និងការបោះពុម្ពផ្សាយព័ត៌មានទាក់ទងនឹងការអនុវត្ត និងលទ្ធផលនៃច្បាប់នេះ ដើម្បីវាស់វែងយ៉ាងទូលំទូលាយអំពីភាពជោគជ័យ សុវត្ថិភាព គុណភាព ផលប៉ះពាល់លើសុខុមាលភាពរបស់បុគ្គល និងសុខភាពសាធារណៈ។

(G) បញ្ហានិរន្តរភាពដែលទាក់ទងនឹងសារធាតុវេវរាយធម្មជាតិ និងផលប៉ះពាល់លើវប្បធម៌ជនជាតិដើមភាគតិច និងចងក្រងឯកសារកិច្ចខិតខំទទួលស្គាល់គ្នានាពេលនេះ និងវិធានការគាំទ្របន្តដែលត្រូវការចាំបាច់។

(H) សក្តានុពលនៃការគ្រប់គ្រងពេលអនាគត និងការប្រើប្រាស់សារធាតុវេវរាយបន្ថែមទៀតជាមួយនឹងសក្តានុពលព្យាបាល លើសពីអ្វីដែលបានរួមបញ្ចូលនៅក្នុងជំពូកនេះ និង

(I) បរិមាណសមស្របនៃរុក្ខជាតិ ឬផ្សិតដែលមានសារធាតុវេវរាយធម្មជាតិ ដែលស្មើនឹងបរិមាណប្រើប្រាស់ផ្ទាល់ខ្លួនដែលមានចែងក្នុងផ្នែកទី 5(b) នៃជំពូក 94J ។

(c) ប្រធានអាចតែងតាំងអនុគណៈកម្មការដើម្បីពន្លឿនការងាររបស់ក្រុមប្រឹក្សា។ តែទោះយ៉ាងណាក៏ដោយ ប្រធានត្រូវតែងតាំងយ៉ាងហោចណាស់នូវ៖

(i) អនុគណៈកម្មាធិការសុខភាពសាធារណៈ ដើម្បីបង្កើតអនុសាសន៍ស្តីពីបញ្ហាសុខភាពសាធារណៈ។

(ii) អនុគណៈកម្មាធិការសុវត្ថិភាពសាធារណៈ ដើម្បីបង្កើតអនុសាសន៍ស្តីពីការអនុវត្តច្បាប់ និងការបណ្តុះបណ្តាលអ្នកសង្គ្រោះបន្ទាន់។

(iii) អនុគណៈកម្មាធិការផ្នែកការដាំដុះ ការចែកចាយ និងការគ្រប់គ្រងសារធាតុវេវរាយធម្មជាតិ ដើម្បីបង្កើតអនុសាសន៍ស្តីពីការធ្វើតេស្ត និងការផ្តល់អាជ្ញាប័ណ្ណ។

(iv) អនុគណៈកម្មាធិការផ្នែកផ្តល់អាជ្ញាប័ណ្ណអ្នកសម្របសម្រួល វិសាលភាពនៃការអនុវត្ត និងការបណ្តុះបណ្តាល។

(v) អនុគណៈកម្មការស្រាវជ្រាវសារធាតុវេវរាយធម្មជាតិ។

(vi) អនុគណៈកម្មាធិការផ្នែកការអនុវត្តនិងលទ្ធផល ដើម្បីបង្កើតអនុសាសន៍លើលក្ខខណ្ឌតម្រូវ វិធីសាស្ត្រ និងការរាយការណ៍ព័ត៌មាន ដើម្បីវាស់ស្ទង់ភាពជោគជ័យ សុវត្ថិភាព គុណភាព និងផលប៉ះពាល់លើសុខុមាលភាពរបស់បុគ្គល។

(vii) អនុគណៈកម្មាធិការផ្នែកចូលរួមកម្មវិធី និងសមធម៌ ដើម្បីបង្កើតអនុសាសន៍ស្តីពីការគាំទ្រស្ត្រី ជនជាតិភាគតិច និងអាជីវកម្មដែលគ្រប់គ្រងដោយអតីតយុទ្ធជន បុគ្គលដែលមានបទពិសោធន៍ក្នុងការប្រើប្រាស់សារធាតុវេវរាយធម្មជាតិតាមបែបប្រពៃណី និងគំរូនៃភាពជាម្ចាស់កម្មសិទ្ធិរួមគ្នា។ និង

(viii) អនុគណៈកម្មាធិការផ្នែកប្រើប្រាស់សារធាតុវេវរាយធម្មជាតិរបស់ជនជាតិដើម និងតាមបែបប្រពៃណី។

ផ្នែកទី 4. ច្បាប់ទូទៅត្រូវបានកែប្រែដោយដាក់បញ្ចូលបន្ទាប់ពីជំពូក 64N នូវជំពូកបន្ទាប់៖

ជំពូក 64O

ពន្ធលើសារធាតុវេវរាយធម្មជាតិ

ផ្នែកទី 1. និយមន័យ ដូចប្រើប្រាស់នៅក្នុងជំពូកនេះ ពាក្យខាងក្រោម ត្រូវមានអត្ថន័យដូចតទៅ លើកលែងតែមានបរិបទកំណត់ជាក់ច្បាស់ផ្សេងពីនេះ៖

(a) “ប្រធាននាយកដ្ឋាន” គឺប្រធាននាយកដ្ឋានចំណូល។

(b) “សារធាតុវេវរាយធម្មជាតិ” ដូចបានកំណត់និយមន័យនៅក្នុងជំពូក 94J នៃច្បាប់ទូទៅ។

ផ្នែកទី 2. ការដាក់កម្រិតឱ្យបង់ពន្ធរដ្ឋាករ អត្រា ការទូទាត់។ ពន្ធអាករនេះត្រូវបានដាក់កម្រិតឱ្យបង់លើការលក់សារធាតុវេវរាយធម្មជាតិទៅឱ្យអ្នកផ្សេងក្រៅពីអ្នកទទួលអាជ្ញាប័ណ្ណសារធាតុវេវរាយធម្មជាតិ ក្នុងអត្រា 15 ភាគរយនៃតម្លៃលក់សរុបដែលអ្នកលក់ទទួលបានជាថ្នូរទៅនឹងការលក់នោះ។ ពន្ធអាករនឹងត្រូវកាត់បន្ថែមលើពន្ធរដ្ឋដែលដាក់កម្រិតឱ្យបង់លើការលក់អចលនទ្រព្យ ឬសេវាកម្មដូចមានចែងក្នុងផ្នែកទី 2 ជំពូកទី 64H នៃច្បាប់ទូទៅ ហើយត្រូវបានអ្នកលក់បង់ឱ្យទៅរដ្ឋមន្ត្រីទទួលបន្ទុកនៅពេលវេលាកំណត់សម្រាប់ការដាក់ឯកសារប្រកាសពន្ធដែលបានកំណត់ដោយផ្នែកទី 16 ជំពូក 62C នៃច្បាប់ទូទៅ។

ផ្នែកទី 3. ជម្រើសពន្ធក្នុងស្រុក

(a) ទីក្រុងឬទីប្រជុំជនណាដែលទទួលយកផ្នែកនេះក្នុងលក្ខណៈដូចមានចែងក្នុងផ្នែកទី 4 ជំពូកទី 4 នៃច្បាប់ទូទៅ អាចដាក់កម្រិតឱ្យបង់ពន្ធលក់ក្នុងស្រុកទៅលើការលក់ ឬការផ្ទេរសារធាតុវេវរាយធម្មជាតិដោយអ្នកទទួលអាជ្ញាប័ណ្ណដែលប្រតិបត្តិការនៅក្នុងទីក្រុងឬទីប្រជុំ ទៅឱ្យនរណាម្នាក់ក្រៅពីអ្នកទទួលអាជ្ញាប័ណ្ណសារធាតុវេវរាយធម្មជាតិក្នុងអត្រាមិនលើសពី 2 ភាគរយនៃតម្លៃលក់សរុបដែលទទួលបានដោយអ្នកលក់សម្រាប់ការលក់សារធាតុវេវរាយធម្មជាតិណាមួយ។ អ្នកលក់ត្រូវបង់ពន្ធលក់ក្នុងស្រុកដែលបានកំណត់ឱ្យបង់ស្របតាមផ្នែកនេះ ទៅឱ្យប្រធាននាយកដ្ឋានក្នុងពេលដំណាលគ្នានោះ និងក្នុងលក្ខណៈដូចគ្នាទៅនឹងពន្ធលក់ដែលត្រូវបង់ទៅឱ្យរដ្ឋម៉ាសាឈូសិត។

(b) ទឹកប្រាក់សរុបទាំងអស់ដែលប្រធាននាយកដ្ឋានទទួលបានក្នុងផ្នែកនេះ ត្រូវបានបែងចែក បញ្ចូល និងបង់ដោយមន្ត្រីហិរញ្ញវត្ថុរដ្ឋ យ៉ាងហោចណាស់មួយត្រីមាសម្តងនៅពេលមានការបញ្ជាក់ពីប្រធាននាយកដ្ឋានដល់ទីក្រុងឬទីប្រជុំជននីមួយៗដែលបានទទួលយកផ្នែកនេះ តាមសមាមាត្រនៃចំនួនសរុបដែលទទួលបាននៅក្នុងទីក្រុងឬទីប្រជុំជន។ ទីក្រុងឬទីប្រជុំជនណាដែលស្វែងរកការជំទាស់នឹងការគណនារបស់រដ្ឋមន្ត្រីទៅលើការបែងចែកទឹកប្រាក់ដល់ខ្លួនអនុលោមតាមផ្នែករងនេះ ត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីជាលាយលក្ខណ៍អក្សរ មិនលើសពី 1 ឆ្នាំគិតចាប់ពីថ្ងៃដែលពន្ធត្រូវបានប្រធាននាយកដ្ឋានបែងចែកទៅឱ្យទីក្រុងឬទីប្រជុំជននោះ។

(c) ផ្នែកនេះត្រូវចូលជាធរមាននៅក្នុងទីក្រុងឬទីប្រជុំជននៅថ្ងៃទីមួយនៃត្រីមាសតាមប្រតិទិន បន្ទាប់ពី 30 ថ្ងៃក្រោយពីការយល់ព្រមទទួលយកដោយទីក្រុងឬទីប្រជុំជន ឬនៅថ្ងៃទីមួយនៃត្រីមាសប្រតិទិនបន្ទាប់ដែលទីក្រុងឬទីប្រជុំជនកំណត់យក។

ផ្នែកទី 4. ការអនុវត្តចំណូលពន្ធ ប្រធាននាយកដ្ឋានត្រូវតម្កល់ចំណូលដែលប្រមូលបានតាមជំពូកនេះ ក្រៅពីចំណូលដែលប្រមូលបានដោយអនុលោមតាមផ្នែកទី 2 ជំពូក 64H នៃច្បាប់ទូទៅ នៅក្នុងមូលនិធិគ្រប់គ្រងសារធាតុវេវរាយធម្មជាតិ ដែលបង្កើតឡើងដោយផ្នែកទី 12 ជំពូកទី 94J នៃច្បាប់ទូទៅ ហើយចំណូលនោះតែស្ថិតក្រោមការបែងចែកមូលនិធិ។

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

ផ្នែកទី 5. ច្បាប់ទូទៅត្រូវបានកែប្រែដោយដាក់បញ្ចូលបន្ទាប់ពីជំពូក 94I នូវជំពូកបន្ទាប់៖

ជំពូក 94J.

គ្រប់គ្រងការទទួលបានសារធាតុរវើរវាយធម្មជាតិដែលគ្មានវេជ្ជបញ្ជា

ផ្នែកទី 1. និយមន័យ ដូចប្រើប្រាស់នៅក្នុងជំពូកនេះ ពាក្យខាងក្រោម ត្រូវមានអត្ថន័យដូចតទៅ លើកលែងតែមានបរិបទកំណត់ជាក់ច្បាស់ផ្សេងពីនេះ៖

(a) "ម៉ោងផ្តល់ថ្នាំ" មានន័យថា រយៈពេលដែលប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយ ឬទីតាំងផ្សេងទៀតដែលបានអនុញ្ញាតដោយបទប្បញ្ញត្តិដែលអនុម័តដោយគណៈកម្មការ នៅពេលដែលអ្នកចូលរួមប្រើប្រាស់ និងទទួលរងឥទ្ធិពលនៃសារធាតុរវើរវាយធម្មជាតិ ក្រោមការត្រួតពិនិត្យរបស់អ្នកសម្របសម្រួលម្នាក់ឬច្រើននាក់។

(b) "ក្រុមប្រឹក្សាពិគ្រោះ" មានន័យថាជាក្រុមប្រឹក្សាពិគ្រោះសារធាតុរវើរវាយធម្មជាតិ ដែលបានបង្កើតឡើងក្នុងផ្នែកទី 80 ជំពូកទី 10 នៃច្បាប់ទូទៅ។

(c) "គណៈកម្មការ" មានន័យថា គណៈកម្មការសារធាតុរវើរវាយធម្មជាតិ ដែលត្រូវបានបង្កើតឡើងនៅក្នុងផ្នែកទី 79 ជំពូកទី 10 នៃច្បាប់ទូទៅ។

(d) "ដាំដុះ" មានន័យថា ការបង្កបង្កើនផល និងការដាំដុះសារធាតុរវើរវាយធម្មជាតិ។

(e) "អ្នកសម្របសម្រួល" មានន័យថា អ្នកដែលបានទទួលអាជ្ញាប័ណ្ណពីគណៈកម្មការដែល៖

(1) មានអាយុ 21 ឆ្នាំឡើងទៅ

(2) បានយល់ព្រមផ្តល់សេវាសារធាតុរវើរវាយធម្មជាតិជូនដល់អ្នកចូលរួម និង

(3) បានបំពេញតាមលក្ខខណ្ឌតម្រូវដែលបង្កើតឡើងដោយគណៈកម្មការ។

អ្នកសម្របសម្រួល អាចនឹងទទួលបានផលតបស្នងសម្រាប់សេវាថ្នាំរវើរវាយធម្មជាតិ ឬសម្រាប់សារធាតុរវើរវាយធម្មជាតិ ហើយអាចផ្តល់សេវាថ្នាំរវើរវាយធម្មជាតិដល់អ្នកចូលរួមច្រើនជាងម្នាក់ ក្នុងពេលតែមួយ នៅក្នុងម៉ោងផ្តល់ថ្នាំជាក្រុម។ អ្នកសម្របសម្រួលមិនមែនចាំបាច់ត្រូវតែផ្តល់សារធាតុរវើរវាយធម្មជាតិនោះទេ។

(f) "ម៉ោងសមាហរណកម្ម" មានន័យថា កិច្ចប្រជុំមួយរវាងអ្នកចូលរួមនិងអ្នកសម្របសម្រួល ឬអ្នកដែលមានការអនុញ្ញាតផ្សេងទៀត ដែលប្រព្រឹត្តទៅបន្ទាប់ពីអ្នកចូលរួមបានបញ្ចប់ម៉ោងផ្តល់ថ្នាំ។

(g) "សារធាតុរវើរវាយធម្មជាតិ" មានន័យថា សារធាតុដូចខាងក្រោម ដែលបានមកពីរុក្ខជាតិឬផ្សិត និងរុក្ខជាតិ ផ្សិត ឬការរៀបចំផ្សំថ្នាំដែលមានសារធាតុទាំងនោះ៖

(1) ឌីមេទីលទ្រីបតាមីន (dimethyltryptamine)

(2) មេសាលីន (mescaline)

(3) អ៊ីបូហ្គាអ៊ីន (ibogaine)

(4) ស៊ីឡូស៊ីប៊ីន (psilocybin) ឬ

(5) ស៊ីឡូស៊ីន (psilocyn)។

"សារធាតុរវើរវាយធម្មជាតិ" មិនមានន័យថាជាសារធាតុសំយោគ ឬអាណាឡូកសំយោគនៃសារធាតុណាមួយក្នុងចំណោមសារធាតុទាំងនេះទេ ហើយក៏មិនមានន័យថាជាកូនរុក្ខជាតិដំបងយក្ស (peyote) នោះដែរ រួមទាំងអំបូររុក្ខជាតិដែលត្រូវបានចាត់ថ្នាក់ជារុក្ខជាតិ Lophophora williamsii (មិនថាលូតលាស់ឬអត់) គ្រប់របស់រុក្ខជាតិ សារធាតុចម្រាញ់ចេញពីផ្នែកណាមួយនៃរុក្ខជាតិ និងរាល់សមាសធាតុ អំបិល សារធាតុស្រឡាយ ល្បាយ ឬការផ្សំរូបមន្តរុក្ខជាតិ ឬគ្រាប់ពូជ ឬសារធាតុចម្រាញ់របស់រុក្ខជាតិនោះ។

(h) "អ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ" មានន័យថា បុគ្គល ឬអង្គភាពដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការ ដោយអនុលោមតាមជំពូកនេះ។

(i) "សេវាថ្នាំរវើរវាយធម្មជាតិ" មានន័យថា សេវាកម្មដែលផ្តល់ដោយអ្នកសម្របសម្រួល ឬអ្នកសម្របសម្រួល ឬអ្នកដែលមានសិទ្ធិផ្សេងទៀត ទៅដល់អ្នកចូលរួមនៅមុនពេល អំឡុងពេល និងក្រោយពេលដែលអ្នកចូលរួមប្រើប្រាស់សារធាតុរវើរវាយធម្មជាតិ ដែលរួមមានយ៉ាងហោចណាស់៖

(1) ម៉ោងរៀបចំថ្នាំ

(2) ម៉ោងផ្តល់ថ្នាំ និង

(3) ម៉ោងសមាហរណកម្ម។

(j) "អ្នកចូលរួម" មានន័យថា បុគ្គលដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ ដែលទិញ ឬទទួលបានសារធាតុរវើរវាយធម្មជាតិពីអ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ សម្រាប់ប្រើប្រាស់រួមជាមួយនឹងសេវាថ្នាំរវើរវាយធម្មជាតិនៅតាមទីតាំងដែលបានអនុញ្ញាត និងស្ថិតក្រោមការត្រួតពិនិត្យរបស់អ្នកសម្របសម្រួល។

(k) "ម៉ោងរៀបចំថ្នាំ" មានន័យថា ការប្រជុំរវាងអ្នកចូលរួមនិងអ្នកសម្របសម្រួល ឬអ្នកដែលមានការអនុញ្ញាតផ្សេងទៀត ដែលប្រព្រឹត្តទៅនៅមុនពេលអ្នកចូលរួមចូលរួមទៅក្នុងម៉ោងផ្តល់ថ្នាំ។

(l) "ការរៀបចំថ្នាំ" មានន័យថា ការផ្សំបញ្ចូលគ្នានៃសារធាតុពីរុក្ខជាតិ ឬផ្សិត និងគ្រឿងផ្សំផ្សេងទៀត ដែលមានបំណងប្រើប្រាស់ ឬទទួលទាន។

(m) "ការកែច្នៃ" មានន័យថា ការបំបែកសារធាតុចេញពីរុក្ខជាតិ ឬផ្សិត ដោយប្រើការបំបែកលក្ខណៈរូប ឬធាតុរំលាយ ហើយរួមបញ្ចូលការផ្សំសារធាតុជាមួយនឹងសារធាតុផ្សំផ្សេងទៀត ដើម្បីបង្កើតការរៀបចំផ្សំថ្នាំ។

(n) "មជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយ" មានន័យថា អង្គភាពដែលទទួលបានអាជ្ញាប័ណ្ណពីគណៈកម្មការ៖

(1) ដែលទិញ ទទួល ដាំដុះ កែច្នៃ ដឹកជញ្ជូន ធ្វើតេស្ត ឬលក់សារធាតុធម្មជាតិរវើរវាយមួយមុខឬច្រើនមុខ ឬការផ្គត់ផ្គង់ពាក់ព័ន្ធ ដែលបានអនុញ្ញាតស្របតាមអាជ្ញាប័ណ្ណរបស់ខ្លួន ឬផ្តល់សារធាតុរវើរវាយធម្មជាតិសម្រាប់សេវាថ្នាំរវើរវាយធម្មជាតិនៅទីតាំងដែលអនុញ្ញាតដោយគណៈកម្មការ ឬចូលរួមក្នុងសកម្មភាពទាំងនេះមួយលើកឬច្រើនលើក។

(2) ដែលម៉ោងផ្តល់ថ្នាំត្រូវបានធ្វើឡើង ឬ

(3) ដែលសេវាថ្នាំរវើរវាយធម្មជាតិត្រូវបានផ្តល់ជូនដោយអ្នកសម្របសម្រួល។

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

មជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយ អាចទទួលបានការទូទាត់សម្រាប់សេវាថ្នាំរវើរវាយធម្មជាតិ សារធាតុរវើរវាយធម្មជាតិ ឬសេវាកម្មនិងផលិតផលពាក់ព័ន្ធផ្សេងទៀត។

ផ្នែកទី 2. ដែនកំណត់

(a) ការបញ្ជាយានយន្តក្រោមឥទ្ធិពលថ្នាំ ជំពូកនេះមិនធ្វើវិសោធនកម្មលើការពិន័យដែលមានស្រាប់សម្រាប់ប្រតិបត្តិការ ការស្ទង់មើលទិស ឬការគ្រប់គ្រងជាក់ស្តែងផ្ទាល់លើយានយន្ត រថភ្លើង យន្តហោះ ទូកអ៊ូប័រ ឬទម្រង់ដឹកជញ្ជូនប្រើដោយកម្លាំងម៉ាស៊ីន ឬគ្រឿងចក្រផ្សេងទៀត ខណៈពេលទទួលរងឥទ្ធិពលថ្នាំរវើរវាយធម្មជាតិ ឬសម្រាប់ការប្រើប្រាស់សារធាតុរវើរវាយធម្មជាតិ ខណៈពេលកំពុងប្រតិបត្តិការ ស្ទង់មើលទិស ឬគ្រប់គ្រងជាក់ស្តែងផ្ទាល់លើយានយន្ត រថភ្លើង យន្តហោះ ទូកអ៊ូប័រ ឬទម្រង់ដឹកជញ្ជូនប្រើដោយកម្លាំងម៉ាស៊ីន ឬគ្រឿងចក្រផ្សេងទៀត។

(b) ការផ្ទេរទៅឱ្យ ឬការកាន់កាប់ដោយមនុស្សដែលមានអាយុក្រោម 21 ឆ្នាំ។ ជំពូកនេះមិនត្រូវបកស្រាយដើម្បីអនុញ្ញាតឱ្យមានការផ្ទេរសារធាតុធម្មជាតិរវើរវាយធម្មជាតិណាមួយ ដោយមានឬគ្មានប្រាក់កម្រៃ ទៅឱ្យជនអាយុក្រោម 21 ឆ្នាំ ឬអនុញ្ញាតឱ្យជនអាយុក្រោម 21 ឆ្នាំកាន់កាប់ ប្រើប្រាស់ ទិញ ទទួលបាន ដាំដុះ កែច្នៃ រៀបចំផ្សំថ្នាំ ចែកចាយ ឬលក់ ឬផ្ទេរសារធាតុរវើរវាយធម្មជាតិណាមួយផ្សេងទៀត។

(c) ការលក់រាយនូវសារធាតុរវើរវាយធម្មជាតិ។ ជំពូកនេះមិនត្រូវបកស្រាយដើម្បីអនុញ្ញាតឱ្យមានការលក់សារធាតុរវើរវាយធម្មជាតិ ដល់បុគ្គលណាម្នាក់សម្រាប់ប្រើប្រាស់នៅទីតាំងដែលមិនបានអនុញ្ញាតដោយគណៈកម្មការ ឬសម្រាប់គោលបំណងនៃការប្រើប្រាស់ ក្រៅពីអំឡុងម៉ោងផ្តល់ថ្នាំនោះទេ។

(d) ទីតាំងទ្រព្យសម្បត្តិ ជំពូកនេះមិនត្រូវបានបកស្រាយដើម្បី៖

(1) រារាំងបុគ្គលម្នាក់មិនឱ្យហាមឃាត់ ឬគ្រប់គ្រងការប្រើប្រាស់ ការតាំងបង្ហាញ ការដាំដុះ ការកែច្នៃ ឬការលក់សារធាតុរវើរវាយធម្មជាតិនៅលើ ឬនៅក្នុងទីតាំងទ្រព្យសម្បត្តិដែលបុគ្គលនោះមានកម្មសិទ្ធិ កាន់កាប់ ឬគ្រប់គ្រង។

(2) រារាំងរដ្ឋម៉ាសាឈូសិត ផ្នែករងណាមួយនៃរដ្ឋម៉ាសាឈូសិត ឬទីភ្នាក់ងាររដ្ឋាភិបាលក្នុងតំបន់ មិនឱ្យហាមឃាត់ ឬគ្រប់គ្រងការកាន់កាប់ ឬប្រើប្រាស់សារធាតុរវើរវាយធម្មជាតិនៅក្នុងអគារដែលបានគ្រប់គ្រង ដាក់ជួល ឬកាន់កាប់ដោយរដ្ឋម៉ាសាឈូសិត ផ្នែករងនយោបាយនៃរដ្ឋម៉ាសាឈូសិត ឬទីភ្នាក់ងារនៃរដ្ឋម៉ាសាឈូសិត ឬផ្នែករងនយោបាយនៃរដ្ឋម៉ាសាឈូសិត ឬ

(3) អនុញ្ញាតឱ្យមានការកាន់កាប់ ឬការប្រើប្រាស់សារធាតុរវើរវាយធម្មជាតិនៅក្នុងបរិវេណ ឬនៅក្នុងសាលារដ្ឋឬឯកជនដែលកុមារចូលរៀននៅក្នុងកម្មវិធីក្រោមមត្តេយ្យសិក្សា កម្មវិធីមត្តេយ្យសិក្សា ឬថ្នាក់ទី 1 ដល់ 12 ទាំងអស់ ឬនៅក្នុងបរិវេណ ឬនៅក្នុងមណ្ឌលកែប្រែណាមួយ។

(e) ការងារ ជំពូកនេះមិនតម្រូវឱ្យនិយោជកអនុញ្ញាត ឬបណ្តោយឱ្យមានការប្រព្រឹត្តណាមួយដែលបានអនុញ្ញាតដោយជំពូកនេះនៅកន្លែងធ្វើការឡើយ ហើយមិនត្រូវកែប្រែសិទ្ធិអំណាចរបស់និយោជកក្នុងការបង្កើតនិងអនុវត្តគោលនយោបាយកន្លែងធ្វើការដែលរឹតត្បិតការប្រើប្រាស់សារធាតុរវើរវាយធម្មជាតិរបស់និយោជិតឡើយ។

(f) ការប្រព្រឹត្តធ្វេសប្រហែស ជំពូកនេះមិនត្រូវធ្វើវិសោធនកម្មលើការពិន័យដែលមានស្រាប់សម្រាប់ការប្រព្រឹត្តពាក់ព័ន្ធនឹងការបំពេញការងារណាមួយ ខណៈពេលទទួលរងឥទ្ធិពលសារធាតុរវើរវាយធម្មជាតិដែលអាចនឹងបង្កើតជាការធ្វេសប្រហែស ឬការប្រព្រឹត្តមិនត្រឹមត្រូវតាមវិជ្ជាជីវៈ ហើយមិនត្រូវរារាំងដល់ការដាក់ពិន័យផ្នែករដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬទោសទណ្ឌផ្សេងទៀតសម្រាប់ការប្រព្រឹត្តបែបនេះឡើយ។

(g) ការក្លែងបន្លំ និងការបន្លំស្លាកយីហោ ជំពូកនេះមិនត្រូវលើកលែងសារធាតុរវើរវាយធម្មជាតិពីផ្នែកទី 186 ដល់ 195 រួមទាំងជំពូកទី 94 នៃច្បាប់ទូទៅ ទាក់ទងនឹងការក្លែងបន្លំ និងការបន្លំស្លាកយីហោទៅលើចំណីអាហារ ឱសថ និងវត្ថុផ្សេងៗ។ សារធាតុរវើរវាយធម្មជាតិដែលរៀបចំឡើងដោយអនុលោមតាមបទប្បញ្ញត្តិក្រោមជំពូកនេះ មិនត្រូវចាត់ទុកថាជាសារធាតុក្លែងបន្លំ ឬបន្លំស្លាកយីហោឡើយ។

(h) ច្បាប់សហព័ន្ធ ជំពូកនេះមិនត្រូវបានបកស្រាយដើម្បី៖

(l) តម្រូវឱ្យបុគ្គលម្នាក់បំពានច្បាប់សហព័ន្ធ ឬ

(2) លើកលែងបុគ្គលម្នាក់ឱ្យរួចផុតពីច្បាប់សហព័ន្ធ ឬរារាំងការអនុវត្តច្បាប់សហព័ន្ធនោះឡើយ។

ផ្នែកទី 3. ការគ្រប់គ្រងតាមមូលដ្ឋាន

(a) ទីក្រុងឬទីប្រជុំជន អាចគ្រប់គ្រងពេលវេលា ទីកន្លែង និងរបៀបនៃប្រតិបត្តិការរបស់អ្នកផ្តល់អាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ស្របតាមជំពូកនេះនៅក្នុងព្រំប្រទល់ដែនដីរបស់ខ្លួន។

(b) ទីក្រុងឬទីប្រជុំជន មិនអាចហាមប្រាម ឬហាមឃាត់ទាំងស្រុងចំពោះការបង្កើត ឬប្រតិបត្តិការរបស់អ្នកផ្តល់អាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ដែលដំណើរការដោយអនុលោមតាមជំពូកនេះ និងវិធានរបស់គណៈកម្មការ នៅក្នុងព្រំប្រទល់ដែនដីរបស់ខ្លួន។

(c) ទីក្រុងឬទីប្រជុំជន មិនអាចហាមប្រាម ឬហាមឃាត់ទាំងស្រុងលើការផ្តល់សេវាថ្នាំរវើរវាយធម្មជាតិដែលផ្តល់ជូនដោយអនុលោមតាមជំពូកនេះ និងវិធានរបស់គណៈកម្មការ។

(d) ទីក្រុងឬទីប្រជុំជន មិនអាចហាមឃាត់ការដឹកជញ្ជូនសារធាតុរវើរវាយធម្មជាតិតាមរយៈយុត្តាធិការរបស់ខ្លួននៅលើផ្លូវសាធារណៈដែលធ្វើឡើងដោយអ្នកទទួលអាជ្ញាប័ណ្ណ ឬដែលបានអនុញ្ញាតផ្សេងទៀតតាមជំពូកនេះ។

(e) គ្មានការព្រមព្រៀងរវាងទីក្រុងឬទីប្រជុំជន និងអ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ តម្រូវឱ្យបង់ថ្លៃសេវាទៅទីក្រុងឬទីប្រជុំជននោះ ដែលមិនមានសមាមាត្រដោយផ្ទាល់ និងទាក់ទងសមស្របទៅនឹងថ្លៃចំណាយដែលកំណត់លើទីក្រុងឬទីប្រជុំតាមប្រតិបត្តិការអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ។ រាល់ការចំណាយសម្រាប់ទីក្រុងឬទីប្រជុំជនតាមរយៈប្រតិបត្តិការរបស់អ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ត្រូវបានកត់ត្រា និងចាត់ទុកជាឯកសារសាធារណៈ ដូចបានកំណត់ដោយប្រការទីម្ភៃប្រាំមួយ នៃផ្នែកទី 7 ក្នុងជំពូកទី 4 នៃច្បាប់ទូទៅ។

(f) ទីក្រុងឬទីប្រជុំជនមិនអាចអនុម័តបទប្បញ្ញត្តិ ឬដីកាដែលមិនអាចអនុវត្តបានសមស្រប ឬផ្ទុយនឹងច្បាប់នេះទេ ប៉ុន្តែអាចអនុម័តបទប្បញ្ញត្តិ ឬដីកាដែលដាក់ទោស

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ** (ត)

ទណ្ឌព្រហ្មទណ្ឌឬរដ្ឋប្បវេណីទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិ ក្នុងកម្រិតតិចតួចជាងការទោសទណ្ឌដែលចែងដោយក្រមច្បាប់នេះ ឬច្បាប់រដ្ឋផ្សេងទៀត។

ផ្នែកទី 4. អាជ្ញាប័ណ្ណនៃសារធាតុធម្មជាតិរវើរវាយធម្មជាតិ និងសេវាកម្ម

(a) ដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាពិគ្រោះសារធាតុរវើរវាយធម្មជាតិ និងដោយអនុលោមតាមជំពូក 30A នៃច្បាប់ទូទៅ គណៈកម្មការសារធាតុរវើរវាយធម្មជាតិអនុម័តបទប្បញ្ញត្តិស្របតាមជំពូកនេះសម្រាប់ការគ្រប់គ្រង ការបំភ្លឺ និងការអនុវត្តច្បាប់ដែលគ្រប់គ្រងនិងផ្តល់អាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិនិងសេវាកម្ម។ បទប្បញ្ញត្តិត្រូវរួមបញ្ចូលទាំងវិធានដើម្បី៖

(1) ផ្តល់អាជ្ញាប័ណ្ណដល់បុគ្គលឬអង្គភាពដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់សកម្មភាពខាងក្រោមដែលទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិមួយមុខឬច្រើនមុខ៖ ការដាំដុះ ការកែច្នៃ ការដឹកជញ្ជូន ការធ្វើតេស្ត ការលក់ ការដំណើរការកន្លែងដែលសេវាថ្នាំរវើរវាយធម្មជាតិអនុវត្ត និងការសម្របសម្រួលសេវាសារធាតុរវើរវាយធម្មជាតិ ដែលរួមមាន៖

(a) ការបង្កើតប្រភេទអាជ្ញាប័ណ្ណ និងការចុះឈ្មោះដែលរួមមានយ៉ាងហោចណាស់៖

(i) អាជ្ញាប័ណ្ណមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយ

(ii) អាជ្ញាប័ណ្ណអ្នកសម្របសម្រួល

(iii) អាជ្ញាប័ណ្ណដាំដុះ កែច្នៃ ឬការលក់តែមួយគត់ ដែលនឹងអនុញ្ញាតឱ្យមានការផ្តល់និងលក់សារធាតុរវើរវាយធម្មជាតិទៅឱ្យអ្នកចូលរួមនៅក្នុងបរិវេណនៃមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយធម្មជាតិដែលទទួលបានអាជ្ញាប័ណ្ណដាច់ដោយឡែក ឬទីតាំងដែលត្រូវបានអនុញ្ញាតសម្រាប់ប្រើប្រាស់ក្នុងអំឡុងម៉ោងផ្តល់ថ្នាំនៅមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយ ឬទីតាំងដែលបានអនុញ្ញាតនោះ និង

(iv) អាជ្ញាប័ណ្ណសាកល្បងសម្រាប់ការធ្វើតេស្តសារធាតុរវើរវាយធម្មជាតិ រកមើលកំហាប់និងធាតុកខ្វក់នានា។

(B) ការបង្កើតនីតិវិធីពាក្យសុំអាជ្ញាប័ណ្ណ ការចេញ ការបដិសេធ ការបន្តសុពលភាព ការព្យួរ និងដកហូតអាជ្ញាប័ណ្ណ និង

(C) ការបង្កើតពាក្យសុំអាជ្ញាប័ណ្ណ និងថ្លៃបន្តសុពលភាពដែលត្រូវ៖

(i) មានភាពគ្រប់គ្រាន់ ប៉ុន្តែមិនត្រូវច្រើនលើសពីបរិមាណចាំបាច់នោះទេ ដើម្បីរ៉ាប់រងថ្លៃចំណាយលើការអនុវត្តជំពូកនេះ និង

(ii) កែសម្រួលសម្រាប់ថ្លៃអាជ្ញាប័ណ្ណនិងបន្តសុពលភាព ផ្អែកលើបរិមាណអាជីវកម្មរបស់អ្នកទទួលអាជ្ញាប័ណ្ណ ឬចំណូលសរុបប្រចាំឆ្នាំរបស់អ្នកទទួលអាជ្ញាប័ណ្ណ។

(2) បង្កើតលក្ខខណ្ឌតម្រូវដែលគ្រប់គ្រងលើការផ្តល់សេវាថ្នាំរវើរវាយធម្មជាតិប្រកបដោយសុវត្ថិភាពដល់អ្នកចូលរួម ដែលរួមមាន៖

(A) រៀបចំ និងផ្ទៀងផ្ទាត់ការបញ្ចប់ម៉ោងរៀបចំថ្នាំ ម៉ោងផ្តល់ថ្នាំ និងម៉ោងសមាហរណកម្ម។

(B) ការព្រមានអំពីសុខភាពនិងសុវត្ថិភាព ដែលត្រូវតែផ្តល់ជូនដល់អ្នកចូលរួម មុនពេលសេវាផ្លូវថ្នាំរវើរវាយចាប់ផ្តើម។

(C) ឯកសារអប់រំដែលត្រូវតែផ្តល់ជូនអ្នកចូលរួម មុនពេលសេវាថ្នាំរវើរវាយចាប់ផ្តើម។

(C) ការពិនិត្យវាយតម្លៃសុវត្ថិភាពដែលផ្តល់ដោយអ្នកសម្របសម្រួល ដែលអ្នកចូលរួមត្រូវតែបំពេញមុនម៉ោងផ្តល់ថ្នាំ។

(E) ទម្រង់បែបបទដែលអ្នកសម្របសម្រួល និងអ្នកចូលរួមម្នាក់ៗត្រូវតែចុះហត្ថលេខា មុនពេលផ្តល់ ឬទទួលសេវាថ្នាំរវើរវាយ ដោយផ្ទៀងផ្ទាត់ថាអ្នកចូលរួមត្រូវបានផ្តល់ព័ត៌មានសុខភាពត្រឹមត្រូវនិងពេញលេញស្របតាមវិធានរបស់គណៈកម្មការ បានទទួលដំណឹងអំពីកត្តាហានិភ័យ និងលក្ខណៈប្រឆាំងនឹងការប្រើថ្នាំដែលបានកំណត់ ហើយបានផ្តល់ការយល់ព្រមដោយមានព័ត៌មានពេញលេញ ដើម្បីទទួលបានសេវាថ្នាំរវើរវាយធម្មជាតិ។

(F) ការត្រួតពិនិត្យត្រឹមត្រូវក្នុងអំឡុងម៉ោងផ្តល់ថ្នាំ និងការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពសម្រាប់អ្នកចូលរួម នៅពេលម៉ោងនោះត្រូវបញ្ចប់។

(G) ការផ្តល់ម៉ោងផ្តល់ថ្នាំជាក្រុមដែលអ្នកសម្របសម្រួលម្នាក់ ឬច្រើននាក់ ផ្តល់សេវាថ្នាំរវើរវាយធម្មជាតិដល់អ្នកចូលរួមច្រើនជាងម្នាក់ ជាផ្នែកមួយនៃម៉ោងផ្តល់ថ្នាំនោះ។

(H) បទប្បញ្ញត្តិដើម្បីអនុញ្ញាតឱ្យអ្នកសម្របសម្រួល ឬមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំរវើរវាយ បដិសេធមិនផ្តល់សេវាថ្នាំរវើរវាយធម្មជាតិដល់អ្នកចូលរួម។

(I) តម្រូវការ និងស្តង់ដាសម្រាប់ការធ្វើតេស្តសារធាតុរវើរវាយធម្មជាតិរកមើលកំហាប់សារធាតុនិងធាតុកខ្វក់ ក្នុងកម្រិតអាចអនុវត្តបានដែលបច្ចេកវិទ្យាអនុញ្ញាតតាមសមស្រប។

(J) ស្តង់ដាសម្រាប់ការផ្សាយពាណិជ្ជកម្ម និងការធ្វើទីផ្សារសារធាតុរវើរវាយធម្មជាតិ និងសេវាថ្នាំរវើរវាយធម្មជាតិ។

(K) លក្ខខណ្ឌតម្រូវធានារ៉ាប់រងចំពោះវិសាលភាពដែលគោលនយោបាយទាំងនោះមានផ្តល់ជូនតាមបែបពាណិជ្ជកម្ម និងមិនមានថ្លៃចំណាយខ្ពស់ហួសហេតុពេក។ និង

(L) នីតិវិធីផ្ទៀងផ្ទាត់អាយុដើម្បីធានាថា អ្នកចូលរួមមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ។

(3) បង្កើតលក្ខខណ្ឌតម្រូវដែលគ្រប់គ្រងអាជ្ញាប័ណ្ណ និងការប្រតិបត្តិរបស់អ្នកសម្របសម្រួល ដែលរួមមាន៖

(a) វិសាលភាពនៃការប្រតិបត្តិសម្រាប់អ្នកសម្របសម្រួល

(B) លក្ខខណ្ឌតម្រូវសម្រាប់លក្ខណសម្បត្តិ ការអប់រំ និងការបណ្តុះបណ្តាល ដែលអ្នកសម្របសម្រួលត្រូវតែបំពេញ មុននឹងផ្តល់សេវាថ្នាំរវើរវាយធម្មជាតិ ដែលត្រូវ៖

(i) ចាត់ថ្នាក់ដើម្បីកំណត់ឱ្យមានកម្រិតផ្សេងៗគ្នានៃការអប់រំនិងបណ្តុះបណ្តាលអាស្រ័យលើអ្នកចូលរួមដែលអ្នកសម្របសម្រួលនឹងសហការជាមួយ និងសេវាកម្មដែលអ្នកសម្របសម្រួលនឹងផ្តល់ជូន។

(ii) រួមបញ្ចូលការអប់រំនិងបណ្តុះបណ្តាលស្តីពីសុវត្ថិភាពអ្នកចូលរួម លក្ខណៈប្រឆាំងនឹងថ្នាំ សុខភាពផ្លូវចិត្ត ស្ថានភាពផ្លូវចិត្ត សុខភាពរាងកាយ ស្ថានភាពរាងកាយ ការពិចារណាផ្នែកសង្គមនិងវប្បធម៌ មជ្ឈដ្ឋានខាងក្រៅ ការរៀបចំថ្នាំ ការរួមបញ្ចូលគ្នា និងសីលធម៌។

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

(iii) អនុញ្ញាតឱ្យមានការលើកលែងកម្រិតតិចតួចលើលក្ខខណ្ឌតម្រូវការនៃការអប់រំ និងបណ្តុះបណ្តាល ផ្អែកលើបទពិសោធន៍ ការបណ្តុះបណ្តាល ឬជំនាញពីមុនរបស់អ្នកដាក់ពាក្យសុំពាក់ព័ន្ធនឹងសារធាតុវើរវាយធម្មជាតិជាដើម។

(iv) មិនដាក់ឱ្យមានឧបសគ្គផ្នែកហិរញ្ញវត្ថុ ឬផ្នែកឡូជីស្ទិកមិនសមស្រប ដែលធ្វើឱ្យការទទួលបានអាជ្ញាប័ណ្ណអ្នកសម្របសម្រួលតាមបែបពាណិជ្ជកម្ម មានភាពមិនសមស្របសម្រាប់អ្នកដែលមានចំណូលទាប។ និង

(v) មិនតម្រូវឱ្យអាជ្ញាប័ណ្ណវិជ្ជាជីវៈ ឬសញ្ញាបត្រវិជ្ជាជីវៈ ក្រៅពីអាជ្ញាបណ្ណអ្នកសម្របសម្រួលដែលត្រូវបានផ្តល់ជូនដោយអនុលោមតាមផ្នែកនេះ សម្រាប់កម្រិតទីមួយនៃអាជ្ញាប័ណ្ណ។

(C) នីតិវិធីនិងគោលនយោបាយដែលអនុញ្ញាតឱ្យមានសំណងទូទាត់សម្រាប់សេវាថ្នាំវើរវាយធម្មជាតិ និងសារធាតុវើរវាយធម្មជាតិ

(D) នីតិវិធីនិងគោលនយោបាយដែលអនុញ្ញាតឱ្យមានការផ្តល់សេវាថ្នាំវើរវាយធម្មជាតិដល់អ្នកចូលរួមច្រើនលើសពីម្នាក់ក្នុងពេលតែមួយនៅក្នុងម៉ោងផ្តល់ថ្នាំជាក្រុម។

(E) លក្ខខណ្ឌតម្រូវការត្រួតពិនិត្យនិងគ្រប់គ្រងសម្រាប់អ្នកសម្របសម្រួល រួមទាំងស្តង់ដាទំនួលខុសត្រូវវិជ្ជាជីវៈ និងលក្ខខណ្ឌតម្រូវផ្នែកការអប់រំបន្ត។

(F) បណ្តឹងតវ៉ា ការស៊ើបអង្កេត និងដំណើរការដាក់វិន័យសម្រាប់អ្នកសម្របសម្រួលដែលចូលរួមក្នុងការប្រព្រឹត្តខុស និង

(G) ការរក្សាកំណត់ត្រា ឯកជនភាព និងលក្ខខណ្ឌតម្រូវរក្សាការសម្ងាត់សម្រាប់អ្នកសម្របសម្រួល ដរាបណាការរក្សាកំណត់ត្រាបែបនេះមិនបណ្តាលឱ្យមានការលាតត្រដាងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកចូលរួមបាន ទៅដល់សាធារណៈជន ឬទីភ្នាក់ងាររដ្ឋាភិបាលណាមួយ។

(4) បង្កើតលក្ខខណ្ឌតម្រូវការគ្រប់គ្រងអាជ្ញាប័ណ្ណ និងប្រតិបត្តិការនៃមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយ និងអ្នកទទួលអាជ្ញាប័ណ្ណផ្សេងទៀត ដែលរួមមាន៖

(A) លក្ខខណ្ឌតម្រូវការត្រួតពិនិត្យសម្រាប់អ្នកទទួលអាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ។

(B) ការរក្សាកំណត់ត្រា ឯកជនភាព និងលក្ខខណ្ឌរក្សាការសម្ងាត់សម្រាប់អ្នកទទួលអាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ ដរាបណាការរក្សាកំណត់ត្រាបែបនេះមិនបណ្តាលឱ្យមានការលាតត្រដាងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកចូលរួមបាន ទៅដល់សាធារណៈជន ឬទីភ្នាក់ងាររដ្ឋាភិបាលណាមួយ។

(C) លក្ខខណ្ឌសុវត្ថិភាពសម្រាប់អ្នកទទួលអាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ រួមទាំងលក្ខខណ្ឌតម្រូវសម្រាប់ការការពារទីតាំងមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយដែលមានអាជ្ញាប័ណ្ណនីមួយៗ តាមរយៈប្រព័ន្ធផ្តល់សញ្ញាព្រមានសុវត្ថិភាពដែលដំណើរការពេញលេញ។

(D) នីតិវិធីនិងគោលនយោបាយដែលអនុញ្ញាតឱ្យអ្នកផ្តល់អាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ ទទួលបានការទូទាត់សម្រាប់សេវាកម្ម និងសារធាតុវើរវាយធម្មជាតិដែលបានផ្តល់ជូន។

(E) នីតិវិធីនិងគោលនយោបាយដើម្បីធានាបាននូវលទ្ធភាពទូទាំងរដ្ឋក្នុងការចូលទៅកាន់មជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយ និងសេវាថ្នាំវើរវាយធម្មជាតិ។

(F) វិធានដែលហាមឃាត់បុគ្គលម្នាក់មិនឱ្យទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយលើសពី 5 កន្លែង។

(E) វិធានដែលអនុញ្ញាតឱ្យអ្នកទទួលអាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ ប្រើប្រាស់ទីតាំងតែមួយរួមគ្នាជាមួយអ្នកទទួលអាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិផ្សេងទៀត ឬប្រើប្រាស់ទីតាំងតែមួយរួមគ្នាជាមួយកន្លែងថែទាំសុខភាព ដើម្បីឱ្យអ្នកចូលរួមអាចទទួលបានសារធាតុវើរវាយធម្មជាតិពីអ្នកទទួលអាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ និងបញ្ចប់ម៉ោងផ្តល់ថ្នាំនៅទីតាំងដែលគ្រប់គ្រងនិងអនុញ្ញាតដាច់ដោយឡែក។

(H) វិធានដែលអនុញ្ញាតឱ្យមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយ ផ្តល់សេវាថ្នាំវើរវាយធម្មជាតិដល់អ្នកចូលរួមនៅក្នុងបរិវេណនៃមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយដាច់ដោយឡែក កន្លែងថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ លំនៅឋានឯកជន ឬទីតាំងផ្សេងទៀតដែលបានអនុញ្ញាតដោយគណៈកម្មការ។ និង

(I) វិធានដែលអនុញ្ញាតឱ្យមានការយល់ព្រមលើទីតាំងដែលមិនគ្រប់គ្រងដោយមជ្ឈមណ្ឌលព្យាបាលដោយប្រើថ្នាំវើរវាយ ដែលសេវាថ្នាំវើរវាយធម្មជាតិអាចនឹងផ្តល់ជូនដោយអ្នកសម្របសម្រួលដែលមានអាជ្ញាប័ណ្ណ រួមមានជាអាទិ៍ កន្លែងថែទាំសុខភាព និងលំនៅឋានឯកជន។

(5) បង្កើតនីតិវិធី គោលនយោបាយ និងកម្មវិធីដើម្បីធានាថា ការផ្តល់អាជ្ញាប័ណ្ណសារធាតុវើរវាយធម្មជាតិ និងការផ្តល់សេវាថ្នាំវើរវាយធម្មជាតិ ប្រព្រឹត្តទៅដោយសមធម៌ និងបរិយាបន្ន និងដើម្បីលើកកម្ពស់ការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់សេវាថ្នាំវើរវាយធម្មជាតិដល់មនុស្សមកពីសហគមន៍ដែលមានប្រាក់ចំណូលទាប ដល់អ្នកដែលប្រឈមនឹងឧបសគ្គក្នុងការទទួលបានការថែទាំសុខភាព ដល់អ្នកដែលមានប្រវត្តិធ្លាប់ប្រើប្រាស់សារធាតុវើរវាយធម្មជាតិរបស់ជនជាតិដើមភាគតិច និងដល់អ្នកដែលជាអតីតយុទ្ធជន រួមមានជាអាទិ៍៖

(A) ថ្លៃសេវាបញ្ចុះតម្លៃសម្រាប់កម្មវិធីបណ្តុះបណ្តាលអំពីការចេញអាជ្ញាប័ណ្ណនិងអ្នកសម្របសម្រួល និងសេវាកម្មគាំទ្រផ្សេងទៀតសម្រាប់អ្នកដាក់ពាក្យសុំ ដែលអាចរួមបញ្ចូលប្រាក់កម្ចី និងមូលនិធិជំនួយផងដែរ។

(B) ការលើកទឹកចិត្តដល់ការផ្តល់សេវាថ្នាំវើរវាយធម្មជាតិ ស្ថិតក្រោមការបញ្ចុះតម្លៃសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប។

(C) ការលើកទឹកចិត្តដល់ភាពចម្រុះខាងផ្នែកភូមិសាស្ត្រនិងវប្បធម៌ក្នុងការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់និងទទួលសេវាថ្នាំវើរវាយធម្មជាតិ។ និង

(D) ដំណើរការសម្រាប់ពិនិត្យឡើងវិញជារៀងរាល់ឆ្នាំនូវប្រសិទ្ធភាពនៃគោលនយោបាយនិងកម្មវិធីដែលប្រកាសឱ្យប្រើប្រាស់អនុលោមតាមផ្នែករងនេះ។

(6) ប្រមូលផ្តុំនិងបោះពុម្ពផ្សាយប្រចាំឆ្នាំនូវព័ត៌មានគ្រប់គ្រាន់ ដើម្បីជួយសម្រួលដល់ការស្រាវជ្រាវទាក់ទងនឹងការអនុវត្ត សុវត្ថិភាព សមធម៌ គុណភាព និងលទ្ធផលនៃជំពូកនេះ ដោយធ្វើតាមទិន្នន័យសំឡេងនិងពិធីការឯកជនភាព ដោយមិនបង្ហាញព័ត៌មានលម្អិតដែលអាចកំណត់អត្តសញ្ញាណបានពាក់ព័ន្ធនឹងអ្នកចូលរួមម្នាក់ៗ។

(7) អនុម័ត កែប្រែ និងលុបចោលវិធានតាមការចាំបាច់ ដើម្បីអនុវត្តជំពូកនេះ និងដើម្បីការពារសុខភាពនិងសុវត្ថិភាពសាធារណៈ។

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

(b) គណៈកម្មការត្រូវចាត់ចែងច្បាប់និងបទប្បញ្ញត្តិទាក់ទងនឹងអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិនៅក្នុងជំពូកនេះ។

(c) នៅពេលទទួលបានពាក្យសុំពេញលេញសម្រាប់អាជ្ញាប័ណ្ណក្រោមជំពូកនេះ គណៈកម្មការត្រូវមានពេល 120 ថ្ងៃដើម្បី ចេញសេចក្តីសម្រេចរបស់ខ្លួនលើពាក្យសុំនោះ។

(d) គណៈកម្មការអាចផ្អាក ឬដកហូតអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ក្រោមបទប្បញ្ញត្តិដែលធ្វើឡើងដោយយោងតាមជំពូកនេះ នៅពេលមានការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការរំលោភបំពាន និងឱកាសដើម្បីដោះស្រាយបញ្ហាការរំលោភបំពានណាមួយក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការជូនដំណឹងនោះ ប្រសិនបើអាចធ្វើបាន។ អ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិទាំងអស់ មានសិទ្ធិទទួលបានសវនាការកាត់សេចក្តីដោយអនុលោមតាមជំពូកទី 30A នៃច្បាប់ទូទៅ មុនពេលការផ្អាកអាជ្ញាប័ណ្ណលើសពី 5 ថ្ងៃ ឬការដកហូតអាជ្ញាប័ណ្ណ។

(e) គណៈកម្មការត្រូវអនុវត្តច្បាប់និងបទប្បញ្ញត្តិទាក់ទងនឹងការដាំដុះ កែច្នៃ ការរៀបចំថ្នាំ ការដឹកជញ្ជូន ការផ្ទុក ការលក់ ការសម្របសម្រួល និងការធ្វើតេស្តសារធាតុរវើរវាយធម្មជាតិ និងការផ្តល់សេវាថ្នាំរវើរវាយធម្មជាតិ។ គណៈកម្មការត្រូវធ្វើការស៊ើបអង្កេតលើការអនុលោមតាមជំពូកនេះ ហើយនឹងធ្វើការត្រួតពិនិត្យជាប្រចាំនូវអ្នកទទួលអាជ្ញាប័ណ្ណ និងសៀវភៅបញ្ជីនិងកំណត់ត្រារបស់អ្នកទទួលអាជ្ញាប័ណ្ណតាមការចាំបាច់ ដើម្បីអនុវត្តជំពូកនេះ។ គណៈកម្មការត្រូវសហការជាមួយស្ថាប័នរដ្ឋនិងមូលដ្ឋានសមស្រប ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់របស់រដ្ឋម៉ាសាឈូសិត និងផ្នែករងនយោបាយរបស់ខ្លួន។

(f) គណៈកម្មការត្រូវបើកសវនាការជាសាធារណៈមុនការអនុម័ត ការធ្វើវិសោធនកម្ម ឬការលុបចោលបទប្បញ្ញត្តិណាមួយ។ ដំណើរការកាត់សេចក្តី ត្រូវធ្វើឡើងដោយអនុលោមតាមជំពូកទី 30A នៃច្បាប់ទូទៅ និងតាមវិធានស្តង់ដានៃនីតិវិធីកាត់សេចក្តីដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមផ្នែកទី 9 ជំពូកទី 30A នៃច្បាប់ទូទៅ។

(g) គណៈកម្មការត្រូវបោះពុម្ពជារៀងរាល់ឆ្នាំនូវរបាយការណ៍ទាំងស្រុងនៃសកម្មភាពរបស់ខ្លួនក្នុងអំឡុងឆ្នាំនីមួយៗ ដែលមានការពិពណ៌នាដោយទូលំទូលាយអំពីសកម្មភាពរបស់ខ្លួន និងរបាយការណ៍ចំណូលនិងចំណាយរបស់គណៈកម្មការ។

(h) គណៈកម្មការត្រូវតម្កល់អាជ្ញាប័ណ្ណ ការចុះឈ្មោះ និងការពិន័យជាប្រាក់ទាំងអស់ដែលប្រមូលបាន ដោយយោងតាមជំពូកនេះ នៅក្នុងមូលនិធិគ្រប់គ្រងសារធាតុរវើរវាយធម្មជាតិ ដែលបង្កើតឡើងដោយផ្នែកទី 12 នៃជំពូកនេះ។

(i) ក្នុងការអនុវត្តការកិច្ចរបស់ខ្លួនក្រោមជំពូកនេះ គណៈកម្មការត្រូវពិគ្រោះជាមួយក្រុមប្រឹក្សាពិគ្រោះសារធាតុរវើរវាយធម្មជាតិ ហើយក៏អាចពិគ្រោះជាមួយភ្នាក់ងាររដ្ឋផ្សេងទៀត ឬបុគ្គលឬអង្គភាពផ្សេងទៀតដែលគណៈកម្មការគិតថាចាំបាច់។

ផ្នែកទី 5. ការប្រើប្រាស់ផ្ទាល់ខ្លួននូវសារធាតុរវើរវាយធម្មជាតិ

(a) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសផ្សេងទៀតណាមួយផ្ទុយពីនេះក៏ដោយ លើកលែងតែមានចែងផ្សេងទៀតក្នុងជំពូកនេះ ពុំនោះទេ បុគ្គលដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ មិនត្រូវបានចាប់ខ្លួន កាត់ទោស ពិន័យ ទទួលទណ្ឌកម្ម ឬដកហូតសិទ្ធិក្រោមច្បាប់នៃរដ្ឋម៉ាសាឈូសិតដោយប្រការណាមួយ ឬបដិសេធសិទ្ធិឬឯកសិទ្ធិណាមួយឡើយ ហើយមិនត្រូវទទួលរងនូវការរឹបអូស ឬដកហូតយកទ្រព្យសម្បត្តិសម្រាប់៖

(1) ការកាន់កាប់ ការប្រើប្រាស់ ការកែច្នៃ ឬការធ្វើតេស្តមិនលើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួននៃសារធាតុរវើរវាយធម្មជាតិ។

(2) ការកាន់កាប់ ការដាំដុះ ឬការកែច្នៃរុក្ខជាតិ ឬផ្សិតដែលមានសមត្ថភាពផលិតសារធាតុរវើរវាយធម្មជាតិ និងការកាន់កាប់សារធាតុរវើរវាយធម្មជាតិដែលផលិតចេញពីរុក្ខជាតិឬផ្សិតទាំងនោះ ដរាបណា៖

(A) រុក្ខជាតិឬផ្សិតដែលកំពុងដាំដុះ មិនមានបរិមាណសរុបលើសពីផ្ទៃដីទទឹងជាង 12 ហ្វីតគុណនឹងបណ្តោយ 12 ហ្វីត នៅក្នុងតំបន់ដាំដុះមួយឬច្រើនកន្លែង នៅក្នុង ឬនៅលើដីលំនៅឋានរបស់បុគ្គលដែលដាំដុះសារធាតុរវើរវាយធម្មជាតិ និងត្រូវបានធានាសុវត្ថិភាពមិនឱ្យមានការចូលប្រើប្រាស់ដោយមនុស្សដែលមានអាយុក្រោម 21 ឆ្នាំឡើយ និង

(B) សារធាតុរវើរវាយធម្មជាតិដែលផលិតលើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវបានរក្សាទុកនៅក្នុង ឬនៅលើបរិវេណលំនៅឋានរបស់មនុស្សដែលដាំដុះសារធាតុរវើរវាយធម្មជាតិ ហើយត្រូវបានធានាមិនឱ្យមានការចូលប្រើប្រាស់ដោយមនុស្សដែលមានអាយុក្រោម 21 ឆ្នាំ។

(3) ការជួយមនុស្សម្នាក់ទៀតដែលមានអាយុ 21 ឆ្នាំឡើងទៅ ក្នុងសកម្មភាពណាមួយដែលបានពិពណ៌នានៅក្នុងផ្នែកនេះ និង

(4) ការឱ្យទទេ ឬផ្ទេរដោយគ្មានប្រាក់កម្រៃ លើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួននៃសារធាតុរវើរវាយធម្មជាតិ ទៅឱ្យបុគ្គលដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ ដរាបណាការផ្ទេរនេះមិនត្រូវបានផ្សព្វផ្សាយពាណិជ្ជកម្ម ឬធ្វើប្រូម៉ូសិនជាសាធារណៈ និងមិនមែនជាផ្នែកមួយនៃការធ្វើប្រូម៉ូសិនពាណិជ្ជកម្ម ឬសកម្មភាពពាណិជ្ជកម្មផ្សេងទៀត។

(b) សម្រាប់គោលបំណងនៃជំពូកនេះ "បរិមាណប្រើប្រាស់ផ្ទាល់ខ្លួន" មានន័យថាបរិមាណសារធាតុរវើរវាយធម្មជាតិដូចខាងក្រោមក្នុងមនុស្សម្នាក់៖

(1) ឌីមេទីលទ្រីបតាមីន (dimethyltryptamine) មួយ (1) ក្រាម

(2) មេសាលីន (mescaline) ដប់ប្រាំបី (18) ក្រាម

(3) អ៊ីបូហ្គាអ៊ីន (ibogaine) សាមសិប (30) ក្រាម

(4) ស៊ីឡូស៊ីប៊ីន (psilocybin) មួយ (1) ក្រាម និង

(5) ស៊ីឡូស៊ីន (psilocyn) មួយ (1) ក្រាម។

"បរិមាណប្រើប្រាស់ផ្ទាល់ខ្លួន" មិនរាប់បញ្ចូលទម្ងន់នៃវត្ថុធាតុណាមួយដែលសារធាតុនេះគឺជាផ្នែកមួយនៃទម្ងន់នោះ ឬដែលសារធាតុនេះត្រូវបានបន្ថែម រំលាយ រក្សាទុកក្នុងសូលុយស្យុង ឬអណ្តែត ឬធាតុផ្សំ ឬវត្ថុធាតុដែលផ្សំជាមួយសារធាតុដែលបានបញ្ជាក់នៅក្នុងផ្នែករងនេះដែលបានមកពីរុក្ខជាតិឬផ្សិតថាជាផ្នែកមួយនៃការរៀបចំផ្សំថ្នាំ។

(c) ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ លើកលែងតែមានចែងផ្សេងទៀតក្នុងជំពូកនេះ ពុំនោះទេ បុគ្គលមិនត្រូវបានចាប់ខ្លួន កាត់ទោស

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

ផ្តន្ទាទោស ដាក់ទណ្ឌកម្ម ឬបដិសេធផលប្រយោជន៍ណាមួយផ្សេងទៀតឡើយ ហើយមិនត្រូវទទួលរងនូវការរឹបអូស ឬដកហូតទ្រព្យសម្បត្តិ សម្រាប់ការអនុញ្ញាតឱ្យយកទ្រព្យសម្បត្តិដែលបុគ្គលនោះមានកម្មសិទ្ធិ កាន់កាប់ ឬគ្រប់គ្រង ទៅប្រើប្រាស់សម្រាប់សកម្មភាពណាមួយដែលធ្វើឡើងស្របច្បាប់ក្នុងជំពូកនេះ ឬសម្រាប់ការចុះឈ្មោះ ឬជួលបុគ្គលដែលចូលរួមក្នុងសកម្មភាពទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិស្របតាមច្បាប់នៅក្រោមជំពូកនេះ។

(d) បើគ្មានភស្តុតាងច្បាស់លាស់ អាចជឿជាក់បាន និងអាចបញ្ជាក់បានថា សកម្មភាពរបស់បុគ្គលពាក់ព័ន្ធនឹងសារធាតុរវើរវាយធម្មជាតិណាមួយបានបង្កើតនូវគ្រោះថ្នាក់មិនសមស្របដល់សុវត្ថិភាពរបស់កុមារអនីតិជនទេនោះ ពុំមានវត្តមានសមាសធាតុផ្សំនៃសារធាតុរវើរវាយធម្មជាតិឬមេតាបូលីតនៅក្នុងសារធាតុរាវរាងកាយ ឬការប្រព្រឹត្តណាមួយដែលបានអនុញ្ញាតនៅក្រោមជំពូកនេះទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិដោយបុគ្គលដែលទទួលបន្ទុកសុខុមាលភាពរបស់កុមារ ត្រូវបង្កើតជាមូលដ្ឋានតែមួយគត់ ឬជាមូលដ្ឋានសម្រាប់ការបញ្ជាក់ផែនការសេវាកម្ម ការដកចេញ ឬការបញ្ចប់ ឬសម្រាប់ការបដិសេធចំពោះការឃុំឃាំង ការទៅសួរសុខទុក្ខ ឬសិទ្ធិមាតាបិតាផ្សេងទៀត ឬការទទួលខុសត្រូវនោះឡើយ។

(e) ការប្រើប្រាស់សារធាតុរវើរវាយធម្មជាតិ មិនត្រូវដកសិទ្ធិបុគ្គលណាមួយចេញពីនីតិវិធីវេជ្ជសាស្ត្រដែលត្រូវការ ឬការព្យាបាលវេជ្ជសាស្ត្រ ឬសេវាដែលទាក់ទងនឹងសុខភាពស្របច្បាប់ផ្សេងទៀតឡើយ។

(f) គ្មានចំណុចណាមួយនៅក្នុងជំពូកនេះ ត្រូវដាក់កម្រិតលើការលក់ ការកាន់កាប់ ការតាំងបង្ហាញ ឬការដាំដុះរុក្ខជាតិមានជីវិតដែលស្របតាមច្បាប់ នៅមុនការអនុម័តនៃផ្នែកនេះទេ។

(g) ការចូលរួមក្នុងសកម្មភាពទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិដូចបានអនុញ្ញាតក្នុងជំពូកនេះ មិនមែនជាមូលដ្ឋានដើម្បីបដិសេធសិទ្ធិទទួលបានកម្មវិធីជំនួយសាធារណៈណាមួយឡើយ លុះត្រាតែកំណត់ដោយច្បាប់សហព័ន្ធ។

(h) គ្មានចំណុចណាមួយនៅក្នុងផ្នែកនេះ ត្រូវបានបកស្រាយដើម្បីអនុញ្ញាតឱ្យបុគ្គលដាំដុះ កែច្នៃ ឬរៀបចំផ្សំសារធាតុរវើរវាយធម្មជាតិក្នុងលក្ខណៈដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរឡើយ។

(i) គ្មានចំណុចណាមួយក្នុងផ្នែកនេះ នឹងត្រូវបានបកស្រាយដើម្បីរារាំងសកម្មភាពណាមួយដោយអ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ស្របតាមវិធានរបស់គណៈកម្មការឡើយ។

ផ្នែកទី 6. គ្រឿងបរិក្ខារដែលបានអនុញ្ញាឱ្យប្រើសម្រាប់សារធាតុរវើរវាយធម្មជាតិ

ទោះបីជាមានច្បាប់ទូទៅឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ លើកលែងតែមានចែងផ្សេងទៀតក្នុងជំពូកនេះ ពុំនោះទេ បុគ្គលដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ មិនត្រូវចាប់ខ្លួន កាត់ទោស ពិន័យ ដាក់ទោស ឬដកហូតសិទ្ធិ ហើយមិនត្រូវទទួលរងនូវការរឹបអូស ឬដកហូតទ្រព្យសម្បត្តិសម្រាប់ការកាន់កាប់ ការទិញ ឬការទទួលបានឬផលិតគ្រឿងបរិក្ខារប្រើប្រាស់ផ្សេងទៀតសម្រាប់សកម្មភាពដែលទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិ ឬសម្រាប់លក់ ឬផ្ទេរគ្រឿងបរិក្ខារប្រើប្រាស់សម្រាប់សកម្មភាពទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិទៅឱ្យមនុស្សដែលមានអាយុ 21 ឆ្នាំឡើងទៅ។

ផ្នែកទី 7. ប្រតិបត្តិការស្របច្បាប់របស់អ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ

(a) ទោះបីមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ លើកលែងតែមានចែងផ្សេងទៀតក្នុងជំពូកនេះ ពុំនោះទេ សកម្មភាពនិងការប្រព្រឹត្តដែលបានអនុញ្ញាតដោយអនុលោមតាមអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិដែលចេញដោយគណៈកម្មការ ឬដែលបានអនុញ្ញាតផ្សេងទៀតដោយវិធានគណៈកម្មការ ឬដោយអ្នកដែលអនុញ្ញាតឱ្យគេប្រើប្រាស់ទ្រព្យសម្បត្តិអនុលោមតាមអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិដែលចេញដោយគណៈកម្មការ ឬតាមការអនុញ្ញាតផ្សេងទៀតដោយច្បាប់របស់គណៈកម្មការ គឺពុំខុសច្បាប់ឡើយ និងមិនមែនជាបទល្មើសនៅក្រោមច្បាប់រដ្ឋ ឬច្បាប់តាមមូលដ្ឋានណាមួយក្នុងរដ្ឋ ឬជាកម្មវត្ថុនៃការផាកពិន័យរដ្ឋប្បវេណី ទោសទណ្ឌ ឬការដាក់ទណ្ឌកម្ម ឬជាមូលដ្ឋានសម្រាប់ការឃុំខ្លួន ការឆែកឆេរ ឬការចាប់ខ្លួន ឬបដិសេធសិទ្ធិឬឯកសិទ្ធិណាមួយ ឬដកហូត ឬរឹបអូសទ្រព្យសម្បត្តិក្រោមច្បាប់រដ្ឋ ឬច្បាប់តាមមូលដ្ឋានណាមួយនៅក្នុងរដ្ឋ។

(b) គ្មានចំណុចណាមួយនៅក្នុងផ្នែកនេះ នឹងត្រូវបានវែកញែក ឬបកស្រាយដើម្បីរារាំងគណៈកម្មការពីការអនុវត្តវិធានរបស់ខ្លួនប្រឆាំងនឹងអ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ឬកំណត់សមត្ថភាពរបស់ភ្នាក់ងារអនុវត្តច្បាប់របស់រដ្ឋឬមូលដ្ឋាន ក្នុងការស៊ើបអង្កេតសកម្មភាពខុសច្បាប់ទាក់ទងនឹងអ្នកទទួលអាជ្ញាប័ណ្ណ។

ផ្នែកទី 8. កិច្ចសន្យាអាចអនុវត្តបានទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិ

ជាគោលការណ៍សាធារណៈនៃរដ្ឋម៉ាសាឈូសិត កិច្ចសន្យាទាក់ទងនឹងសារធាតុរវើរវាយធម្មជាតិនៅក្រោមជំពូកនេះ គប្បី អាចអនុវត្តបាន។ កិច្ចសន្យាដែលបានចុះដោយអ្នកទទួលអាជ្ញាប័ណ្ណសារធាតុរវើរវាយធម្មជាតិ ឬភ្នាក់ងាររបស់ខ្លួនដែលបានអនុញ្ញាតដោយអនុលោមតាមអាជ្ញាប័ណ្ណមានសុពលភាពដែលចេញដោយគណៈកម្មការ ឬដោយអ្នកដែលអនុញ្ញាតឱ្យអ្នកទទួលអាជ្ញាប័ណ្ណសារធាតុសារធាតុរវើរវាយធម្មជាតិ ឬភ្នាក់ងាររបស់ខ្លួន ប្រើប្រាស់ទ្រព្យសម្បត្តិដែលបានអនុញ្ញាតដោយអនុលោមតាមអាជ្ញាប័ណ្ណមានសុពលភាពដែលបានចេញដោយគណៈកម្មការ ឬដែលអនុញ្ញាតតាមវិធានរបស់គណៈកម្មការ គឺមិនអាចអនុវត្ត ឬចាត់ទុកជាមោឃៈទាំងស្រុងបានឡើយ ពីព្រោះសកម្មភាព ឬការប្រព្រឹត្តដែលបានអនុញ្ញាតដោយអនុលោមតាមអាជ្ញាប័ណ្ណត្រូវបានហាមឃាត់ដោយច្បាប់សហព័ន្ធ។

ផ្នែកទី 9. ការផ្តល់សេវាវិជ្ជាជីវៈ

បុគ្គលដែលប្រកបវិជ្ជាជីវៈ ឬមុខរបរស្ថិតក្រោមការទទួលបានអាជ្ញាប័ណ្ណ មិនត្រូវទទួលរងវិធានការវិន័យដោយក្រុមប្រឹក្សាអាជ្ញាប័ណ្ណវិជ្ជាជីវៈសម្រាប់តែការផ្តល់សេវាវិជ្ជាជីវៈទាក់ទងនឹងសកម្មភាពដែលត្រូវបានអនុញ្ញាតក្នុងជំពូកនេះ ដែលមិនមែនជាកម្មវត្ថុនៃទោសព្រហ្មទណ្ឌក្រោមច្បាប់នៃរដ្ឋម៉ាសាឈូសិតនោះទេ។ ផ្នែកនេះមិនអនុញ្ញាតឱ្យបុគ្គលម្នាក់ចូលរួមក្នុងការប្រព្រឹត្តមិនត្រឹមត្រូវ ឬបំពានលើស្តង់ដានៃការប្រកបរបរវិជ្ជាជីវៈដែលបុគ្គលម្នាក់បានទទួលអាជ្ញាប័ណ្ណសម្រាប់ប្រកបវិជ្ជាជីវៈនោះទេ។

ផ្នែកទី 10. ធានារ៉ាប់រង

លុះត្រាតែតម្រូវដោយច្បាប់សហព័ន្ធ ពុំនោះទេ សុខភាពផ្លូវចិត្ត វិបត្តិនៃការសេពសារធាតុញៀន ឬសេវាសុខភាពអាកប្បកិរិយាដែលស្ថិតក្រោមការធានារបស់កម្មវិធី MassHealth មិនត្រូវបានបដិសេធដោយផ្អែកលើមូលដ្ឋានដែលពួកវាត្រូវបានរ៉ាប់រង រួមជាមួយនឹងសេវាថ្នាំរវើរវាយធម្មជាតិ ឬផ្អែកលើមូលដ្ឋានដែលសារធាតុរវើរវាយធម្មជាតិត្រូវបានហាមឃាត់ដោយច្បាប់សហព័ន្ធនោះឡើយ។ គ្មានការធានារ៉ាប់រង ឬអ្នកផ្តល់សេវាធានារ៉ាប់រងណាមួយ តម្រូវឱ្យរ៉ាប់រងថ្លៃសារធាតុរវើរវាយ

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

ធម្មជាតិដោយខ្លួនឯងឡើយ។

ផ្នែកទី 11. **ទោសទណ្ឌ**

(a) ការរឹតបន្តឹងលើការចូលប្រើប្រាស់ដោយមនុស្សអាយុក្រោម 21 ឆ្នាំ។ ជនណាម្នាក់ដែលបំពានលើផ្នែកទី 5(a)(2) នៃជំពូកនេះ ដោយមិនបានការពារមិនឱ្យបុគ្គលអាយុក្រោម 21 ឆ្នាំទទួលបាន នូវរុក្ខជាតិ ផ្សិត ឬសារធាតុវរើរវាយធម្មជាតិ នឹងត្រូវផ្តន្ទាទោសដោយការពិន័យរដ្ឋប្បវេណី មិនលើសពី $100 ឡើយ និងការរឹបអូសសារធាតុវរើរវាយធម្មជាតិនោះ។

(b) ការរឹតបន្តឹងលើការកាន់កាប់លើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួន។ បុគ្គលដែលមានអាយុយ៉ាងតិច 21 ឆ្នាំ និងដែលមានបរិមាណសារធាតុវរើរវាយធម្មជាតិលើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួន ប៉ុន្តែមិនលើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួនពីរដងឡើយ លើកលែងបានអនុញ្ញាតដោយផ្នែកទី 5(a)(2) នៃជំពូកនេះ ពុំនោះទេ នឹងត្រូវប្រឈមមុខនឹងការពិន័យរដ្ឋប្បវេណីមិនលើសពី $100 ឡើយ និងការរឹបអូសសារធាតុវរើរវាយធម្មជាតិ ប៉ុន្តែមិនត្រូវទទួលរងនូវទម្រង់ផ្សេងទៀតនៃការផ្តន្ទាទោសព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ឬការដកសិទ្ធិដោយសារការប្រព្រឹត្តនេះតែមួយមុខនោះទេ។

(c) រឹតបន្តឹងលើការប្រើប្រាស់ជាសាធារណៈនូវសារធាតុវរើរវាយធម្មជាតិ។ គ្មានបុគ្គលណាម្នាក់ ប្រើសារធាតុវរើរវាយធម្មជាតិនៅទីសាធារណៈឡើយ។ បុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រានេះ ត្រូវផ្តន្ទាទោសដោយការផាកពិន័យផ្នែករដ្ឋប្បវេណីមិនលើសពី 100 ដុល្លារឡើយ។ ផ្នែករងនេះមិនត្រូវអនុវត្តចំពោះបុគ្គលដែលប្រើសារធាតុវរើរវាយធម្មជាតិនៅទីតាំងដែលមានអាជ្ញាប័ណ្ណ ឬត្រូវបានអនុម័តដោយគណៈកម្មការដើម្បីផ្តល់សេវាថ្នាំវរើរវាយធម្មជាតិនោះទេ។

(b) ផ្ទេរទៅឱ្យ ឬកាន់កាប់ដោយមនុស្សអាយុក្រោម 21 ឆ្នាំ។ បុគ្គលមានអាយុក្រោម 21 ឆ្នាំដែលមានសារធាតុវរើរវាយធម្មជាតិមិនលើសពីបរិមាណប្រើប្រាស់ផ្ទាល់ខ្លួន នឹងត្រូវផ្តន្ទាទោសដោយការពិន័យរដ្ឋប្បវេណីមិនលើសពី $100 ឡើយ ហើយត្រូវបញ្ចប់កម្មវិធីការយល់ដឹងអំពីគ្រឿងញៀនដែលបានបង្កើតឡើងស្របតាមផ្នែកទី 32M ជំពូក 94C នៃច្បាប់ទូទៅ។ ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ជនល្មើសមានអាយុក្រោម 18 ឆ្នាំ ត្រូវទទួលបានការជូនដំណឹងដោយអនុលោមតាមផ្នែកទី 32N ជំពូក 94C នៃច្បាប់ទូទៅ ហើយការមិនបានបញ្ចប់កម្មវិធីយល់ដឹងអំពីគ្រឿងញៀនក្នុងរយៈពេល 1 ឆ្នាំបន្ទាប់ពីបទល្មើសរបស់ជនល្មើស អាចនឹងក្លាយជាមូលដ្ឋានសម្រាប់នីតិវិធីប្រព្រឹត្តបទល្មើសចំពោះជនដែលមានអាយុក្រោម 17 ឆ្នាំ នៅពេលមានការប្រព្រឹត្តល្មើសរបស់បុគ្គលនោះ។

(e) ការអនុវត្តច្បាប់ ការផ្តន្ទាទោសរដ្ឋប្បវេណីដែលដាក់អនុលោមតាមផ្នែកនេះ នឹងត្រូវបានអនុវត្តដោយប្រើប្រាស់នីតិវិធីសម្រេចទោសមិនមែនព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងផ្នែកទី 32N ជំពូក 94C នៃច្បាប់ទូទៅ។

ផ្នែកទី 12. មូលនិធិគ្រប់គ្រងសារធាតុវរើរវាយធម្មជាតិ

(a) ត្រូវតែបានបង្កើតនិងរៀបចំមូលនិធិដាច់ដោយឡែកមួយនៅលើសៀវភៅបញ្ជីរបស់រដ្ឋម៉ាសាឈូសិត ដែលត្រូវបានស្គាល់ ថាជាមូលនិធិគ្រប់គ្រងសារធាតុវរើរវាយធម្មជាតិ។ អាស្រ័យការបែងចែក មូលនិធិនេះត្រូវមានប្រាក់ទាំងអស់ដែលទទួលបានក្នុងគណនីរដ្ឋម៉ាសាឈូសិត ដោយសារតែការស្នើសុំ និងការផ្តល់អាជ្ញាប័ណ្ណក្រោមជំពូកនេះ ការពិន័យរដ្ឋប្បវេណីទាំងអស់ដែលបានទទួលសម្រាប់ការរំលោភបំពានលើជំពូកនេះ ប្រាក់ចំណូលដែលរកបានដោយពន្ធរដ្ឋដែលកំណត់ឱ្យបង់ក្រោមផ្នែកទី 2 ជំពូកទី 64O នៃច្បាប់ទូទៅ និងការប្រាក់ដែលទទួលបាន ឬប្រាក់ចំណូលផ្សេងទៀតនៅលើសមតុល្យនៅក្នុងមូលនិធិ។

(b) អាស្រ័យទៅលើការបែងចែក មូលនិធិនេះត្រូវបានគណៈកម្មការចំណាយជាលើកដំបូងសម្រាប់ការអនុវត្ត ការគ្រប់គ្រង និងការពង្រឹងការអនុវត្តជំពូកនេះ។

ផ្នែកទី 6. ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ ក្នុងការតែងតាំងដំបូងនូវសមាជិកដែលបានតែងតាំងដោយការព្រមព្រៀងសំឡេងភាគច្រើននៃអភិបាល អគ្គរដ្ឋអាជ្ញា និងអគ្គហិរញ្ញវត្ថុនិងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងគណៈកម្មការសារធាតុវរើរវាយធម្មជាតិដែលបានបង្កើតឡើងនៅក្នុងផ្នែកទី 79 ជំពូកទី 10 នៃច្បាប់ទូទៅ សមាជិកគណៈកម្មការ 1 រូបត្រូវបានតែងតាំងសម្រាប់មួយអាណត្តិរយៈពេល 3 ឆ្នាំ និង 1 រូបទៀតត្រូវបានតែងតាំងសម្រាប់មួយអាណត្តិរយៈពេល 4 ឆ្នាំ។ សមាជិកគណៈកម្មការដែលត្រូវបានតែងតាំងដោយអគ្គហិរញ្ញិកនិងអ្នកគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបំពេញតួនាទីមួយអាណត្តិរយៈពេល 5 ឆ្នាំ, សមាជិកគណៈកម្មការដែលត្រូវបានតែងតាំងដោយអគ្គរដ្ឋអាជ្ញា ត្រូវបំពេញតួនាទីមួយអាណត្តិដែលមានរយៈពេល 6 ឆ្នាំ, ហើយសមាជិកគណៈកម្មការដែលត្រូវបានតែងតាំងដោយអភិបាល ត្រូវបំពេញតួនាទីក្នុងមួយអាណត្តិរយៈពេល 7 ឆ្នាំ។ សមាជិកគណៈកម្មការ ត្រូវបានតែងតាំងនៅត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2025។ តែទោះជាយ៉ាងក៏ដោយ គ្មានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាតឱ្យបម្រើការក្នុងគណៈកម្មការ មុនពេលបញ្ចប់ការស៊ើបអង្កេតសាវតារ អនុលោមតាមផ្នែកទី 79 នៃជំពូកទី 10 នេះទេ។

ផ្នែកទី 7. ទោះបីជាមានច្បាប់ទូទៅ ឬច្បាប់ពិសេសណាមួយផ្ទុយពីនេះក៏ដោយ ការតែងតាំងដំបូងទៅក្នុងក្រុមប្រឹក្សាប្រឹក្សាសារធាតុធម្មជាតិវរើរវាយដែលបានបង្កើតឡើងក្នុងផ្នែកទី 80 ជំពូកទី 10 នៃច្បាប់ទូទៅ នឹងត្រូវធ្វើឡើងត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2025។

ក្រុមប្រឹក្សាប្រឹក្សាត្រូវជួបប្រជុំយ៉ាងហោចណាស់រៀងរាល់ត្រីមាស រហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 2028 ហើយបន្ទាប់ពីនោះមក ការជួបប្រជុំនោះនឹងប្រព្រឹត្តញឹកញាប់ទៅតាមការជ្រើសរើសរបស់ក្រុមប្រឹក្សា ។

ផ្នែកទី 8. គណៈកម្មការសារធាតុវរើរវាយធម្មជាតិ ត្រូវប្រកាសឱ្យប្រើប្រាស់បទប្បញ្ញត្តិនៅក្រោមផ្នែកទី 4 ជំពូក 94J នៃច្បាប់ទូទៅទាក់ទងនឹងសារធាតុវរើរវាយធម្មជាតិយ៉ាងតិចមួយមុខ មិនលើសពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2026 ឡើយ ដរាបណាបទប្បញ្ញត្តិទាក់ទងនឹងសារធាតុវរើរវាយធម្មជាតិទាំងអស់ត្រូវបានប្រកាសឱ្យប្រើមិនលើសពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2028។

ផ្នែកទី 9. គណៈកម្មការសារធាតុវរើរវាយធម្មជាតិ នឹងចាប់ផ្តើមទទួលយកពាក្យសុំអាជ្ញាប័ណ្ណក្រោមផ្នែកទី 4 ជំពូក 94J នៃច្បាប់ទូទៅ មិនឱ្យលើសពីថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2026 ឡើយ។

ផ្នែកទី 10. ច្បាប់នេះត្រូវចូលជាធរមាននៅថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2024។

**របាយការណ៍មតិភាគច្រើន**

*របាយការណ៍ខាងក្រោម ត្រូវបានរៀបចំឡើងដោយមតិភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា ដែលជាគណៈកម្មាធិការនៃសភារដ្ឋម៉ាសាឈូសិត តាមតម្រូវដោយរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិត របាយការណ៍មតិភាគច្រើននេះ ត្រូវបានបោះពុម្ពដូចខាងក្រោម។ សេចក្តីថ្លែងការណ៍នានានៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីមតិយោបល់របស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា (ហៅកាត់ថា "គណៈកម្មាធិការ") ផ្តល់អនុសាសន៍ថា ញត្តិលេខ 23-13 សេចក្តីព្រាងច្បាប់សភាតំណាងរាស្ត្រលេខ 4255 "ញត្តិផ្តួចផ្តើមសម្រាប់ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការយកពន្ធលើសារធាតុរវើរវាយធម្មជាតិ" (ហៅកាត់ថា "ញត្តិផ្តួចផ្តើម") ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះទេ។

គោលបំណងនៃរបាយការណ៍នេះគឺដើម្បីផ្តល់អនុសាសន៍មួយដល់ស្ថាប័ននីតិប្បញ្ញត្តិពេញអង្គថាតើត្រូវទទួលយកញត្តិផ្តួចផ្តើមដូចដែលបានសរសេរសម្រាប់ការពិចារណា និងអនុម័តនោះដែរឬទេ។

សំណើញត្តិផ្តួចផ្តើមនេះ នឹងអនុញ្ញាតឱ្យមនុស្សដែលមានអាយុចាប់ពី 21 ឆ្នាំឡើងទៅ អាចដាំដុះ កាន់កាប់ និងប្រើប្រាស់សារធាតុរវើរវាយធម្មជាតិជាក់លាក់នៅក្នុងរដ្ឋម៉ាសាឈូសិត ក្នុងស្ថានភាពមួយចំនួនបាន។ ញាតិនេះនឹងអនុញ្ញាតឱ្យមានការលក់សារធាតុទាំងនេះផងដែរនៅទីតាំងដែលបានយល់ព្រមសម្រាប់ប្រើប្រាស់ក្រោមការត្រួតពិនិត្យរបស់អ្នកសម្របសម្រួលដែលមានអាជ្ញាប័ណ្ណ និងជាកម្មវត្ថុនៃបទប្បញ្ញត្តិដែលត្រូវប្រកាសឱ្យប្រើប្រាស់ដោយគណៈកម្មការសារធាតុរវើរវាយធម្មជាតិដែលទើបបានបង្កើតឡើង ដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាពិគ្រោះសារធាតុរវើរវាយធម្មជាតិដែលទើបបានបង្កើតឡើង។ "សារធាតុរវើរវាយដែលបានអនុញ្ញាត" រួមមានសារធាតុពីរយ៉ាងដែលមាននៅក្នុងផ្សិត (សារធាតុស៊ីឡូស៊ីប៊ីន (psilocybin) និងស៊ីឡូស៊ីន (psilocyn)) និងសារធាតុបីយ៉ាងដែលមាននៅក្នុងរុក្ខជាតិ (សារធាតុឌីមេទីលទ្រីបតាមីន (dimethyltryptamine) មេសាលីន (mescaline) និងអ៊ីបូហ្គាអ៊ីន (ibogaine)) ។ ញត្តិផ្តួចផ្តើមគំនិតក៏នឹងបង្កើតអត្រាពន្ធសម្រាប់ការលក់សារធាតុទាំងនេះដោយអ្នកសម្របសម្រួលដែលមានអាជ្ញាប័ណ្ណ។ ការផលិត ការចែកចាយ ការផ្គត់ផ្គង់ និងការកាន់កាប់សារធាតុទាំងនេះនៅតែបន្ត (ហើយអាចនឹងនៅតែបន្ត) ខុសច្បាប់ សហព័ន្ធដដែល។

***សក្ខីភាព***

គណៈកម្មាធិការនេះបានឮពីអ្នកជំនាញដែលមានបទពិសោធន៍ អ្នកគាំទ្រ និងអ្នកជំទាស់ចំពោះញត្តិផ្តួចផ្តើម ក៏ដូចជាសមាជិកសាធារណជនទូទៅផងដែរ។

អ្នកជំនាញលើប្រធានបទ បានរួមបញ្ចូលវេជ្ជបណ្ឌិតនានាដែលកំពុងសិក្សាពីផលប៉ះពាល់នៃការព្យាបាលដោយប្រើថ្នាំរវើរវាយលើអ្នកជំងឺ មានដូចជាលោកវេជ្ជបណ្ឌិត Jerrold Rosenbaum ជាប្រធានពេទ្យផ្នែកវិកលចរិកកិត្តិយសដែលបានចូលនិវត្ត, នាយកមជ្ឈមណ្ឌលវិទ្យាសាស្ត្រសិក្សាអំពីផលប៉ះពាល់នៃថ្នាំរវើរវាយទៅលើសរសៃប្រសាទនៅមន្ទីរពេទ្យ Massachusetts General Hospital, លោកវេជ្ជបណ្ឌិត Franklin King នៃសាកលវិទ្យាល័យ Harvard និងជានាយកផ្នែកបណ្តុះបណ្តាលនិងអប់រំនៅមជ្ឈមណ្ឌលវិទ្យាសាស្ត្រសិក្សាអំពីផលប៉ះពាល់នៃថ្នាំរវើរវាយទៅលើសរសៃប្រសាទនៅមន្ទីរពេទ្យ Massachusetts General Hospital, និងលោកវេជ្ជបណ្ឌិត Yvan Gersaint នៃវិទ្យាស្ថានមហារីក Dana Farber Cancer Institute។ វេជ្ជបណ្ឌិតនីមួយៗបានលើកឡើងពីអត្ថប្រយោជន៍ដែលអាចកើតមានចំពោះការប្រើប្រាស់ភ្នាក់ងារសារធាតុរវើរវាយ ដូចបានបង្ហាញយ៉ាងច្បាស់នៅក្នុងការសិក្សាបែបគ្លីនិករបស់ពួកគេ ដោយបង្ហាញពីអត្ថប្រយោជន៍ផ្លូវចិត្តដែលមានប្រសិទ្ធភាព ឬថែមទាំងអាចមានប្រសិទ្ធភាពខ្លាំងជាងវិធីព្យាបាលរោគដែលអាចស្វែងរកបាន ដោយអាចមានកម្រិតជាតិពុលនិងហានិភ័យតិចតួចបំផុត ធៀបទៅនឹងឱសថដែលអាចស្វែងរកបាន។ ពិតមែនតែការញៀននឹងថ្នាំរវើរវាយទំនងជាមិនអាចទៅរួចក្តី ក៏វេជ្ជបណ្ឌិតបានផ្តល់សក្ខីកម្មថាមានការប្រឈមផ្នែកបទប្បញ្ញត្តិ និងផ្នែកឡូជីស្ទិកក្នុងការធ្វើឱ្យប្រសើរឡើងនូវការសិក្សាបែបគ្លីនិកជុំវិញថ្នាំរវើរវាយ។ វេជ្ជបណ្ឌិតក៏បានចង្អុលបង្ហាញអំពីបញ្ហានៃការប្រើប្រាស់ថ្នាំរវើរវាយដែលធ្វើឱ្យជំងឺវិកលចរិកកាន់តែធ្ងន់ធ្ងរចំពោះបុគ្គលដែលមានស្ថានភាពបង្កឱ្យមានជំងឺវិកលចរិក។

Angie Allbee អ្នកគ្រប់គ្រងផ្នែកសេវាសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) ក្នុងរដ្ឋ Oregon នៃអាជ្ញាធរសុខាភិបាលរដ្ឋ Oregon បានផ្តល់សក្ខីកម្មលើក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) នៅក្នុងរដ្ឋ Oregon បន្ទាប់ពីការអនុម័តរបស់ខ្លួននៅក្នុងការបោះឆ្នោតនាខែវិច្ឆិកា ឆ្នាំ 2020 ហើយបានលើកឡើងថា រូបគាត់មិនគាំទ្រដល់សេចក្តីព្រៀងច្បាប់របស់សភាតំណាងរាស្ត្រ 4255 ទេ។ នៅរដ្ឋ Oregon មិនមានលក្ខខណ្ឌតម្រូវការស្នាក់នៅក្នុងរដ្ឋទេ ហើយអ្នកណាម្នាក់ដែលមានអាយុលើសពី 21 ឆ្នាំ អាចទទួលបានសារធាតុស៊ីឡូស៊ីប៊ីន បន្ទាប់ពីបញ្ចប់ម៉ោងរៀបចំផ្សំថ្នាំ។ មានអាជ្ញាប័ណ្ណបួនប្រភេទ៖ ក្រុមហ៊ុនផលិត មន្ទីរពិសោធន៍ មជ្ឈមណ្ឌលសេវា (កន្លែងដែលម៉ោងជួបប្រជុំប្រព្រឹត្តទៅ) និងអ្នកសម្របសម្រួល (អ្នកដែលគាំទ្រអតិថិជនតាមរយៈវិធីសាស្ត្រព្យាបាលដោយគ្មានការដឹកនាំក្នុងការប្រើសារធាតុស៊ីឡូស៊ីប៊ីន (psilocybin))។ គិតត្រឹមកាលបរិច្ឆេទនៃសវនាការ រដ្ឋ Oregon បានផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនផលិតចំនួន 9 មន្ទីរពិសោធន៍ចំនួន 2 មជ្ឈមណ្ឌលសេវាចំនួន 23 និងអាជ្ញាប័ណ្ណអ្នកសម្របសម្រួលចំនួន 276 ដោយមានផលិតផលចំនួន 5,697 បានលក់ទៅឱ្យអតិថិជនចាប់ពីខែមករា ឆ្នាំ 2023 ដល់ខែមីនា ឆ្នាំ 2024 ។ នៅពេលស្នើសុំឱ្យប្រៀបធៀបក្របខណ្ឌរបស់រដ្ឋ Oregon និងក្របខណ្ឌរដ្ឋម៉ាសាឈូសិតដែលបានស្នើឡើង ដូចមានចែងនៅក្នុងញត្តិផ្តួចផ្តើមនេះ អ្នកនាង Allbee បាននិយាយថា ការលុបចោលចោលទោសទណ្ឌរបស់រដ្ឋ Oregon ត្រូវបានកាត់បន្ថយ និងមិនអនុញ្ញាតឱ្យការដាំដុះសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនណាមួយក្នុងរដ្ឋ Oregon នោះទេ។

វេជ្ជបណ្ឌិត Matthew Johnson ជាសាស្ត្រាចារ្យទទួលបានមូលនិធិពី Susan Hill Ward ផ្នែកថ្នាំរវើរវាយនិងសតិដឹង (Psychedelics and Consciousness) នៅសាកលវិទ្យាល័យ Johns Hopkins ក៏បានបង្ហាញសក្ខីកម្មក្នុងនាមជាអ្នកជំនាញលើប្រធានបទផងដែរ។ គាត់បានផ្តល់សក្ខីកម្មថាគាត់បានបោះពុម្ពផ្សាយការស្រាវជ្រាវដែលអ្នកសិក្សាជាច្រើនបានដកស្រង់សម្តីអំពីហានិភ័យនៃថ្នាំរវើរវាយ និងគោលការណ៍ណែនាំសុវត្ថិភាព។ វេជ្ជបណ្ឌិត Johnson បានរកឃើញថា មនុស្សដែលប្រើប្រាស់ថ្នាំរវើរវាយ អាចមានប្រតិកម្មខ្លាំងនិងធ្ងន់ធ្ងរ ប៉ុន្តែជាទូទៅ អាចមានអារម្មណ៍ស្ងប់ស្ងាត់តាមរយៈមនុស្សដែលពួកគេទុកចិត្ត។ បណ្ឌិត Johnson បានគូសបញ្ជាក់ពីស្ថិតិជុំវិញផលប៉ះពាល់នៃថ្នាំរវើរវាយ ដោយបង្ហាញពីការកាត់បន្ថយគ្រោះថ្នាក់ ការចូលបន្ទប់សង្គ្រោះបន្ទាន់ ការហៅទូរសព្ទសុំជំនួយកម្លាត់ជាតិធាតុពុល និងការញៀន បើប្រៀបធៀបទៅនឹងការប្រើប្រាស់

**របាយការណ៍មតិភាគច្រើន** (ត)

ថ្នាំអូភីអយដ៍ (opioid) គ្រឿងស្រវឹង និងកូកាអ៊ីន ប៉ុន្តែបានកត់សម្គាល់ថា គ្រោះថ្នាក់ភាគច្រើនកើតឡើងជុំវិញបញ្ហាសរសៃឈាមបេះដូង។ វេជ្ជបណ្ឌិត Johnson បានផ្តល់សក្ខីកម្មបន្ថែមទៀតថា ពិតមែនគេមិនគួរលើកទឹកចិត្តឱ្យប្រើប្រាស់ថ្នាំវង្វេងវង្វាន់យ៉ាងណាក្តី ប៉ុន្តែការដាក់ទោសព្រហ្មទណ្ឌគឺមិនស្របទៅនឹងនឹងគ្រោះថ្នាក់នៃសារធាតុទាំងនេះទេ ហើយបានស្នើថា ការប្រើប្រាស់ដែលមានការគ្រប់គ្រងគួរតែភ្ជាប់មកជាមួយនូវការព្រមានពីសុខភាពសាធារណៈច្បាស់លាស់ពាក់ព័ន្ធនឹងការញែកការប្រើប្រាស់ដែលហានិភ័យខ្ពស់ ចេញឱ្យដាច់ពីការប្រើប្រាស់ដែលហានិភ័យទាបៈ កម្រិតដូសថ្នាំ ការត្រួតពិនិត្យ លក្ខណៈប្រឆាំងទាស់ខាងផ្នែកសុខាភិបាលនិងសុខភាពផ្លូវចិត្ត គ្រោះថ្នាក់នៃការស្រវឹងជាសាធារណៈ និងគ្រោះថ្នាក់នៃអ្នកប្រកបវិជ្ជាជីវៈដែលគ្មានសីលធម៌។ វេជ្ជបណ្ឌិត Johnson ក៏បានបន្ថែមថា អត្ថប្រយោជន៍នៃការព្យាបាលដ៏មានសក្តានុពលគឺទំនងជាមានតិចតួច ប្រសិនបើមិនបានផ្តល់ឱ្យនៅចំពោះមុខអ្នកជំនាញសុខភាពផ្លូវចិត្ត ហើយថាចាំបាច់ត្រូវប្រមូលទិន្នន័យអំពីការប្រើប្រាស់ថ្នាំវង្វេងវង្វាន់ប្រសិនបើឱ្យថ្នាំនេះមានភាពស្របច្បាប់។

ក្រុមអ្នកគាំទ្រញត្តិផ្តួចផ្តើមបានពិពណ៌នាអំពីរបៀបដែលសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) បានអនុញ្ញាតឱ្យពួកគេយល់ដឹងដោយខ្លួនឯងអំពីការប៉ះទង្គិចផ្លូវចិត្តតាមរយៈបទពិសោធន៍របស់ពួកគេនៅក្នុងកងកម្លាំងយោធានិងប៉ូលីស ដោយលើកឡើងពីរឿងរ៉ាវផ្ទាល់ខ្លួនជាច្រើនរបស់អតីតយុទ្ធជននិងមន្ត្រីប៉ូលីស។

សមាជិកនៃការផ្តល់សក្ខីកម្មជាសាធារណៈក្នុងនាមក្រុមសហគមន៍ Bay Staters for Natural Medicine បានបង្ហាញពីការគាំទ្ររបស់ពួកគេចំពោះការធ្វើឱ្យថ្នាំវង្វេងវង្វាន់មានភាពស្របច្បាប់ ប៉ុន្តែបានសំណូមពរឱ្យស្ថាប័ននីតិប្បញ្ញត្តិស្នើសុំឱ្យមានការដាក់ជំនួសញត្តិផ្តួចផ្តើមសម្រាប់ការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ 2024 ។ ការជំនួសដែលបានស្នើឡើង ដែលមានវិសាលភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីញត្តិគំនិតផ្តួចផ្តើម ទំនងជានឹងអាចផ្ទុយទៅនឹងគំរូពីមុនមកដែលបានកំណត់ដោយតុលាការកំពូលក្នុងសំណុំរឿងឆ្នាំ 1976 រវាងលោក Buckley ជាមួយនឹងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ ដែលបានកត់សម្គាល់ថា គោលបំណងរបស់អ្នកតាក់តែងមាត្រា XLVIII ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញគឺចង់ឱ្យផ្នែកនីតិប្បញ្ញត្តិផ្តល់ជូននូវការផ្លាស់ប្តូរបច្ចេកទេសបន្តិចបន្តួចចំពោះញត្តិផ្តួចផ្តើម។

អ្នកប្រឆាំងទៅនឹងញត្តិផ្តួចផ្តើម រួមមានលោកបណ្ឌិត John A. Fromson ចិត្តវិទូនៅមន្ទីរពេទ្យ Brigham and Women's Hospital និងបណ្ឌិត Nassir Ghaemi សាស្ត្រាចារ្យផ្នែកចិត្តសាស្ត្រនៅសាលាសុខាភិបាលនៃសាកលវិទ្យាល័យ Tufts University ដែលបម្រើការជាប្រធាន និងជាប្រធានជាប់ឆ្នោតជ្រើសតាំងនៃសមាគមជំងឺផ្លូវចិត្តរដ្ឋម៉ាសាឈូសិត (Massachusetts Psychiatric Society)។ វេជ្ជបណ្ឌិតបានពិពណ៌នាអំពីកង្វល់ផ្នែកពិនិត្យព្យាបាល ដំណើរការ និងសុវត្ថិភាពនៃញត្តិផ្តួចផ្តើមនេះ ព្រមទាំងរៀបរាប់ថា រដ្ឋបាលឱសថសហព័ន្ធ (FDA) មិនបានយល់ព្រមលើថ្នាំណាមួយដែលមានផ្ទុកសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) និងមិនមានក្របខណ្ឌរឹងមាំគ្រប់គ្រាន់ដើម្បីធានាសុវត្ថិភាពសម្រាប់អ្នកជំងឺ ឬអ្នកផ្តល់សេវានោះទេ។ ក្រុមវេជ្ជបណ្ឌិតបានផ្តល់សក្ខីកម្មបន្ថែមទៀតថា ញត្តិផ្តួចផ្តើមនេះ ពិចារណារួមបញ្ចូលបញ្ហាចំនួនបីគឺ សុខុមាលភាពទូទៅរបស់សាធារណជនទូទៅ ការព្យាបាលជំងឺវិកលចរិក និងការប្រើប្រាស់សារធាតុស៊ីឡូស៊ីប៊ីន (psilocybin) សម្រាប់ការប្រើប្រាស់ ជំនួយស្មារតី ចូលទៅក្នុងគំនិតផ្តួចផ្តើមតែមួយ ដែលតាមគំនិតរបស់ពួកគេយល់ថា គំនិតផ្តួចផ្តើមនេះគឺគ្មានការប្រុងប្រយ័ត្ន គ្មានការទទួលខុសត្រូវ និងមានគ្រោះថ្នាក់ដល់សាធារណៈជន។ ពិតមែនតែក្រុមវេជ្ជបណ្ឌិតបានទទួលស្គាល់ថាបច្ចុប្បន្នមានការស្រាវជ្រាវដ៏ជោគជ័យទាក់ទងនឹងការប្រើប្រាស់សារធាតុស៊ីឡូស៊ីប៊ីន (psilocybin) ដោយអតីតយុទ្ធជនដែលកំពុងទទួលការព្យាបាលដោយរដ្ឋបាលអតីតយុទ្ធជន ប៉ុន្តែការស្រាវជ្រាវនោះនៅតែស្ថិតក្នុងដំណាក់កាលសិក្សានៅឡើយ។ ពួកគេក៏បានកត់សម្គាល់ផងដែរថា សមាគមសមាគមជំងឺផ្លូវចិត្តរដ្ឋម៉ាសាឈូសិត មានសំណួរសំខាន់ៗជាច្រើនទាក់ទងនឹងផលប៉ះពាល់ដែលញត្តិផ្តួចផ្តើមនេះនឹងមានចំពោះអ្នកផ្តល់សេវា រួមទាំងការធានារ៉ាប់រងផងដែរ និងផលប៉ះពាល់ដល់ក្រុមរងនៃប្រជាជនជាក់លាក់ ដូចជាសុខភាពមាតា ឬទារកជាដើម។ ក្រុមវេជ្ជបណ្ឌិតបានពន្យល់បន្ថែមពីការជំទាស់របស់ពួកគេ ដោយកត់សម្គាល់ពីលក្ខណៈទូលំទូលាយនៃញត្តិផ្តួចផ្តើមនេះ កង្វះការស្រាវជ្រាវជាក់ស្តែង ឬលទ្ធផលពីបណ្តារដ្ឋនានាដែលបានឱ្យសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) មានភាពស្របច្បាប់ និងអន្តរកម្មនៃសារធាតុស៊ីឡូស៊ីប៊ីន (psilocybin) (សារធាតុហាលូស៊ីណូសែន (hallucinogen)) ជាមួយនឹងជំងឺផ្លូវចិត្ត សម្រាប់អ្នកដែលមានជំងឺវិកលចរិក ជំងឺបាយប៉ូឡា និងជំងឺយូនីប៉ូឡា។

***សន្និដ្ឋាន***

ពិតមែនតែរុក្ខជាតិថ្នាំវង្វេងវង្វាន់ត្រូវបានប្រើប្រាស់នៅជុំវិញពិភពលោក និងតាំងពីដើមរៀងមកនៅក្នុងការប្រតិបត្តិខាងវិញ្ញាណនិងសាសនា ប៉ុន្តែការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់ពួកគេនៅក្នុងសហរដ្ឋអាមេរិកបានចាប់ផ្តើមជាចម្បងនៅក្នុងសតវត្សទី 20 ហើយរដ្ឋាភិបាលសហព័ន្ធបានចេញវេជ្ជបញ្ជាភាគច្រើននូវការប្រើប្រាស់សារធាតុវង្វេងវង្វាន់ក្នុងឆ្នាំ 1968។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់សារធាតុទាំងនេះបានបន្តអនុវត្តក្នុងទសវត្សរ៍បន្តបន្ទាប់មកទៀត ហើយភ្នាក់ងារអនុវត្តច្បាប់នៅទូទាំងប្រទេសបានរាយការណ៍ពីការកើនឡើងជិតបួនដងនៃទម្ងន់សរុបនៃផ្សិតហាលូស៊ីណូសែន (hallucinogenic) ដែលបានរឹបអូសនៅចន្លោះឆ្នាំ 2017-2022។ ការកើនឡើងនៃការប្រើប្រាស់នេះបាននាំឱ្យមានដំណាក់កាលការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រថ្មីៗខ្លាំងជាងមុន ដែលកំពុងតែបន្តអភិវឌ្ឍ។

ការសិក្សាដែលបានបោះពុម្ពផ្សាយបានបង្ហាញថា នៅពេលដែលអ្នកប្រើប្រាស់លេបថ្នាំតាមកម្រិតដូសថ្នាំនៅក្រោមការត្រួតពិនិត្យព្យាបាល ការប្រើប្រាស់សារធាតុវង្វេងវង្វាន់អាចនឹងមានប្រសិទ្ធភាពខ្ពស់ក្នុងការដោះស្រាយស្ថានភាពសុខភាពផ្លូវចិត្តមិនល្អជាច្រើន។ គណៈកម្មាធិការទទួលស្គាល់ជាពិសេសពីសារៈសំខាន់នៃសក្តានុពលនៃលទ្ធផលព្យាបាលជាវិជ្ជមានចំពោះប្រជាជនដែលកំពុងស្វែងរកជំនួយសម្រាប់ជំងឺបាក់ស្បាតជំងឺធ្លាក់ទឹកចិត្ត ការថប់បារម្ភ និងបញ្ហាសុខភាពផ្លូវចិត្តផ្សេងទៀត ហើយទទួលស្គាល់សក្ខីកម្មដែលខ្លួនបានទទួលពីបុគ្គលនានាដែលមកពីក្រុមអតីតយុទ្ធជននិងអ្នកសង្គ្រោះបន្ទាន់របស់យើង។ ទោះជាយ៉ាងណាក៏ដោយ ការរកឃើញដ៏ជោគជ័យទាំងនេះមិនបានផ្តល់នូវភស្តុតាងបញ្ជាក់ថា ការអនុញ្ញាតឱ្យមានការប្រើប្រាស់ស្របច្បាប់និងទូលំទូលាយនូវសារធាតុសម្រាប់ការកម្សាន្ត នឹងមានប្រយោជន៍នោះទេ កុំថាឡើយមានសុវត្ថិភាពនោះ។

គណៈកម្មាធិការរកឃើញថា គោលដៅសំខាន់ៗរបស់ញត្តិ - ការផ្តល់អាជ្ញាប័ណ្ណ និងការលុបចោលទោសទណ្ឌ - ទំនងជាកាត់បន្ថយឥទ្ធិពលលើគ្នាទៅវិញទៅមក ដោយការបង្កើតប្រព័ន្ធពីរដាច់ដោយឡែកសម្រាប់ការប្រើប្រាស់សារធាតុវង្វេងវង្វាន់។ ញត្តិទាំងពីរនឹងបង្កើតប្រព័ន្ធនៃមជ្ឈមណ្ឌលព្យាបាលដែលមានអាជ្ញាប័ណ្ណនិងជាប់ពន្ធរដ្ឋ ហើយម្យ៉ាងវិញទៀត ការលុបចោលទោសទណ្ឌលើការដាំដុះ ការកាន់កាប់ និងការចែកចាយសារធាតុហាលូស៊ីណូសែន (hallucinogenic) និងសារធាតុដែល

### របាយការណ៍មតិភាគច្រើន (ត)

មានឥទ្ធិពលលើផ្លូវចិត្តសកម្មជាច្រើនប្រភេទ។ ដូច្នេះ អ្នកបោះឆ្នោតត្រូវបានស្នើឱ្យបង្កើតប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណដែលមានតម្លៃថ្លៃដែលដាក់ចេញនូវការគ្រប់គ្រងលើវិធីសាស្ត្រដាំដុះ គុណភាពនៃផលិតផល និងមធ្យោបាយដែលអាចអនុញ្ញាតបានក្នុងការទាក់ទាញអ្នកប្រើប្រាស់មួយចំនួន ដោយក្នុងពេលជាមួយគ្នានេះ ផ្តល់លទ្ធភាពទូលំទូលាយក្នុងការដាំដុះ និងការប្រើប្រាស់លក្ខណៈបុគ្គលនៅទូទាំងរដ្ឋម៉ាសាឈូសិតដោយមិនចាំបាច់មានអាជ្ញាប័ណ្ណ។

ញត្តិនេះនឹងអនុញ្ញាតឱ្យអ្នករស់នៅរដ្ឋម៉ាសាឈូសិត យកផ្សិតដែលមានឥទ្ធិពលលើផ្លូវចិត្តក្នុងបរិមាណច្រើនតាមខ្លួន ឬទុកនៅក្នុងផ្ទះរបស់ពួកគេក្នុងពេលតែមួយបាន។ ដូច្នេះ ជាការសន្និដ្ឋាន ញត្តិនេះអនុញ្ញាតឱ្យអ្នកដាំដុះដែលគ្មានអាជ្ញាប័ណ្ណ “ផ្តល់” ដូសថ្នាំជាក់លាក់ជូនដល់បុគ្គលមួយចំនួន និងមិនបានចែងអំពីលទ្ធភាពរបស់អ្នកដាំដុះក្នុងការគិតប្រាក់សម្រាប់ការត្រួតពិនិត្យការប្រើប្រាស់នោះ ឬការណែនាំអ្នកប្រើប្រាស់តាមរយៈបទពិសោធន៍នៃការប្រើថ្នាំនោះទេ។ គណៈកម្មាធិការរកឃើញថាចន្លោះប្រហោងនេះទំនងជានឹងកាត់បន្ថយប្រសិទ្ធភាពនៃបទប្បញ្ញត្តិសុវត្ថិភាពដែលកំណត់ទៅលើអ្នកសម្របសម្រួលដែលមានអាជ្ញាប័ណ្ណ ដោយបណ្តោយឱ្យមានការរីកដុះដាលនៃទីផ្សារដែលគ្មានការគ្រប់គ្រង និងគ្មានអាជ្ញាប័ណ្ណ។

ស្រដៀងទៅនឹងគំរូដែលរដ្ឋម៉ាសាឈូសិតប្រើប្រាស់ដើម្បីគ្រប់គ្រងការលក់កញ្ឆាដែរ ញត្តិនេះអាចនឹងតម្រូវឱ្យអ្នកផ្តល់សេវាដែលមានអាជ្ញាប័ណ្ណ ពឹងផ្អែកលើប្រព័ន្ធជាសាច់ប្រាក់ ដោយសារភាពខុសច្បាប់របស់វានៅកម្រិតសហព័ន្ធ។ ញត្តិនេះក៏នឹងតម្រូវឱ្យសាលាក្រុងកំណត់ទីតាំង និងអនុញ្ញាតឱ្យមជ្ឈមណ្ឌលដែលមានអាជ្ញាប័ណ្ណទាំងនេះ ដោយកំណត់សមត្ថភាពរបស់សាលាក្រុងក្នុងការកំណត់អត្រាពន្ធដែលខ្លួនគិតថាសមស្របក្នុងការគ្រប់គ្រងចរាចរណ៍ បទបញ្ជាមូលដ្ឋាន ការត្រួតពិនិត្យ និងកំណើននៃការហៅទូរសព្ទសុំជំនួយពីផ្នែកអនុវត្តច្បាប់ ឬអ្នកជំនាញវេជ្ជសាស្ត្រ។

ដោយសារហេតុផលទាំងនេះ យើងខ្ញុំ ជាសមាជិកភាគច្រើននៃគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា សូមផ្តល់អនុសាសន៍ថា “ញត្តិផ្តួចផ្តើមសម្រាប់ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការយកពន្ធលើសារធាតុរវើរវាយធម្មជាតិ” (សូមមើលសេចក្តីព្រាងច្បាប់សភាតំណាងរាស្ត្រលេខ 4255) ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះទេ។

| **សមាជិកព្រឹទ្ធសភា** | **តំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Paul R. Feeney | Michael S. Day |
| Jason M. Lewis | Kenneth I. Gordon |
| Ryan C. Fattman | David T. Vieira |

# 5

## សំណួរទី៥ ច្បាប់ដែលបានស្នើដោយញត្តិផ្តួចផ្តើម

# *ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ*

*តើលោកអ្នកយល់ស្របនឹងច្បាប់ដែលបានសង្ខេបខាងក្រោមទេ ដែលចែងថាគ្មានការបោះឆ្នោតណាមួយត្រូវបានធ្វើឡើងដោយសមាជិកព្រឹទ្ធសភា ឬសភាតំណាងរាស្ត្រឡើយ នៅមុនថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៤?*

---

**សេចក្តីសង្ខេប ▶**
តាមច្បាប់កំណត់ សេចក្តីសង្ខេបផ្សេងៗ ត្រូវបានសរសេរដោយ អគ្គរដ្ឋអាជ្ញា។

សេចក្តីស្នើច្បាប់នេះនឹងបង្កើនប្រាក់ម៉ោងអប្បបរមាជាបណ្តើរៗសម្រាប់ការងារ ដែលនិយោជកត្រូវបង់អោយកម្មករនិយោជិតដែលទទួលបានប្រាក់កម្រៃបន្ថែមពីរដ្ឋ(ប្រាក់ធនានុគ្រោះ)ក្នុងរយៈពេលប្រាំឆ្នាំ តាមកាលវិភាគដូចខាងក្រោម៖

- ដល់ចំនួន ៦៤% នៃប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៥
- ដល់ចំនួន ៧៣% នៃប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៦
- ដល់ចំនួន ៨២% នៃប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៧
- ដល់ចំនួន ៩១% នៃប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៨ និង
- ដល់ចំនួន ១០០% នៃប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ នៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៩។

សេចក្តីស្នើច្បាប់នេះនឹងតម្រូវអោយនិយោជកបន្តផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលទទួលបានប្រាក់ ធនានុគ្រោះ នូវចំនួនខុសគ្នារវាងប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ និង ចំនួនប្រាក់សរុបដែលកម្មករនិយោជិតមានប្រាក់ធនានុគ្រោះទទួលបានជាប្រាក់ម៉ោង បូកនឹងប្រាក់ធនានុគ្រោះរហូតដល់ដំណាច់ឆ្នាំ ២០២៨ ។ សេចក្តីស្នើច្បាប់នេះក៏នឹងអនុញ្ញាតអោយនិយោជកធ្វើការគណនាចំនួនខុសគ្នានេះសម្រាប់រយៈពេលទាំងមូល នៃប្រាក់ឈ្នួលប្រចាំសប្តាហ៍ ឬពីរសប្តាហ៍ម្តង។ លក្ខខណ្ឌតម្រូវអោយទូទាត់ចំនួនខុសគ្នានេះ នឹងបញ្ឈប់នៅពេលប្រាក់ម៉ោងដែលគេតម្រូវអោយមានសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះឡើងដល់១០០% នៃប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋនៅថ្ងៃទី០១ខែមករា ឆ្នាំ២០២៩ ។

ស្ថិតក្រោមសេចក្តីស្នើច្បាប់នេះ បើនិយោជកបើកប្រាក់ម៉ោងដល់កម្មករនិយោជិតរបស់ខ្លួន ដែលយ៉ាងហោចណាស់ស្មើនឹងប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ និយោជកនោះនឹងត្រូវបានអនុញ្ញាតអោយចាត់ចែង "ការប្រមូលប្រាក់ធនានុគ្រោះ" ដែលរួមបញ្ចូលប្រាក់កម្រៃបន្ថែម (ប្រាក់ធនានុគ្រោ) ដែលផ្តល់អោយដោយអតិថិជនដល់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ ហើយបែកចែងប្រាក់ធនានុគ្រោះទាំងនោះក្នុងចំណោមកម្មករនិយោជិតទាំងអស់ រួមទាំងកម្មករនិយោជិតទាំងអស់ដែលមិនទទួលបានប្រាក់ធនានុគ្រោះ។

---

**ឥទ្ធិពល ពីការបោះឆ្នោតរបស់អ្នក ▶**
តាមច្បាប់កំណត់ សេចក្តីថ្លែងការណ៍ដែលបានរៀបរាប់ពីឥទ្ធិពលនៃការបោះឆ្នោត "គាំទ្រ" និងការបោះឆ្នោត "ជំទាស់" ត្រូវបានសរសេររួមគ្នាដោយអគ្គរដ្ឋអាជ្ញា និងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***ការបោះឆ្នោតគាំទ្រ*** *នឹងដំឡើងប្រាក់ម៉ោងអប្បបរមា ដែលនិយោជកត្រូវបង់អោយកម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ រហូតបានប្រាក់ឈ្នួលអប្បបរមាពេញលេញពីរដ្ឋ ដែលត្រូវអនុវត្តក្នុងរយៈពេល៥ឆ្នាំ ដែលពេលនោះ និយោជកអាចប្រមូលប្រាក់ធនានុគ្រោះទាំងអស់ ហើយបែងចែកដល់កម្មករនិយោជិតទាំងអស់ដែលមិនមែនជាអ្នកគ្រប់គ្រង ។*

***ការបោះឆ្នោតជំទាស់*** *នឹងមិនធ្វើអោយមានការកែប្រែអ្វីឡើយក្នុងច្បាប់គ្រប់គ្រងការប្រមូលប្រាក់ធនានុគ្រោះ ឬប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ។*

---

**របាយការណ៍ អំពីផលប៉ះពាល់ ផ្នែកសារពើពន្ធ ▶**
តាមច្បាប់កំណត់ របាយការណ៍អំពីផលប៉ះពាល់ផ្នែកសារពើពន្ធ ត្រូវរៀបចំដោយការិយាល័យប្រតិបត្តិរដ្ឋបាលនិងហិរញ្ញវត្ថុ។

មិនមានផលប៉ះពាល់ផ្នែកសារពើពន្ធដល់រដ្ឋាភិបាលរដ្ឋម៉ាសាឈូសិត ឬក្រុងនានាឡើយ ព្រោះជាទូទៅពួកគេមិនជួលកម្មករនិយោជិតដែលមានប្រាក់ធនានុគ្រោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ វិធានការនេះនឹងប៉ះពាល់ដល់ចំណូលនិងចំណាយរបស់រដ្ឋ និងក្រុងដែលបានស្នើឡើង ដោយសារផលប៉ះពាល់លើប្រាក់ចំណូលនិងចំណូលរបស់កម្មករនិយោជិតនិងអាជីវកម្ម។ ពិតមែនតែផលប៉ះពាល់ទាំងនោះមានការលំបាកក្នុងការប៉ាន់ស្មានទុកជាមុនដោយសារកង្វះទិន្នន័យដែលអាចទុកចិត្តបានយ៉ាងណាក្តី ក៏ការបង្កើនប្រាក់ម៉ោងអប្បបរមារបស់កម្មករនិយោជិតដែលមានប្រាក់ធនានុគ្រោះ ទំនងជានឹងបង្កើនការប្រមូលពន្ធលើប្រាក់ចំណូលរបស់រដ្ឋ ពីព្រោះនិយោជិតនឹងទទួលបានប្រាក់ម៉ោងច្រើនពីពន្ធលើប្រាក់ចំណូលរដ្ឋដែលត្រូវបានកាត់ទុក។ គេមិនដឹងពីផលប៉ះពាល់ចំពោះចំណូលធនានុគ្រោះនិងរបាយការណ៍អំពីពន្ធធនានុគ្រោះនេះឡើយ។

**ទឡ្ហីករណ៍ ▶**

ដូចបានចែងដោយច្បាប់ ទឡ្ហីករណ៍ 150 ពាក្យ ត្រូវសរសេរដោយអ្នកគាំទ្រ និង អ្នកបដិសេធលើសំណួរនីមួយៗ ហើយឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេ។ **រដ្ឋាភិបាលរដ្ឋម៉ាសាឈូសិត មិនគាំទ្រចំពោះទឡ្ហីករណ៍ទាំងនេះទេ ហើយក៏មិនបញ្ជាក់ពីការពិត ឬ ភាពត្រឹមត្រូវច្បាស់លាស់នៃសេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងនៅក្នុងទឡ្ហីករណ៍ទាំងនេះដែរ។** ឈ្មោះរបស់បុគ្គល និងស្ថាប័នដែលបានសរសេរសេចក្តីថ្លែងការណ៍នីមួយៗ និងមតិយោបល់ជាលាយលក្ខណ៍អក្សរណាមួយពីអ្នកដទៃទៀតអំពីទឡ្ហីករណ៍នីមួយៗ ត្រូវបានរក្សាទុកនៅការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

***បោះឆ្នោតគាំទ្រ*** **បោះឆ្នោតគាំទ្រភាពយុត្តិធម៌ -**

**វាត្រឹមត្រូវយុត្តិធម៌សម្រាប់កម្មករនិយោជិត៖**

ជំនួសឱ្យការទទួលបានប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះបច្ចុប្បន្នត្រឹមតែ $6.75 ក្នុងមួយម៉ោង កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះរបស់រដ្ឋម៉ាសាឈូសិតសមនឹងទទួលបាន**ប្រាក់ឈ្នួលអប្បបរមាពេញលេញ រួមជាមួយនិងប្រាក់ធនានុគ្រោះបន្ថែម**។ កម្មករនៅក្នុងរដ្ឋចំនួន 7 ផ្សេងទៀតទទួលបានប្រាក់ឈ្នួលពេញលេញបូកនឹងប្រាក់ធនានុគ្រោះ ហើយពួកគេរីករាយនឹងប្រាក់ធនានុគ្រោះដែលកើនឡើង និងកំណើនភោជនីយដ្ឋានដែលតម្លៃមុខម្ហូបអាចប្រៀបធៀបបានទៅនឹងរដ្ឋម៉ាសាឈូសិត។ ច្បាប់នេះនឹងបង្កើតស្ថិរភាពនិងភាពអាចព្យាករណ៍ជាមុនបានកាន់តែខ្លាំងផ្នែកហិរញ្ញវត្ថុ ដោយទទួលស្គាល់ជំនាញ និង វិជ្ជាជីវៈរបស់កម្មករនិយោជិត។

**វាត្រឹមត្រូវយុត្តិធម៌សម្រាប់និយោជក៖**

អាជីវកម្មខ្នាតតូចនៅរដ្ឋម៉ាសាឈូសិតជាច្រើនកំពុងបង់ប្រាក់ឈ្នួលអប្បបរមាពេញលេញ បូករួមទាំងប្រាក់ធនានុគ្រោះរួចហើយ។ សាជីវកម្មភោជនីយដ្ឋានធំៗ គួរតែធ្វើដូចគ្នា។ ការណ៍នេះនឹងកាត់បន្ថយការផ្លាស់ប្តូរកម្មករនិយោជិត ហើយបង្កើនគុណភាពសេវាកម្ម។

**វាត្រឹមត្រូវយុត្តិធម៌សម្រាប់អតិថិជន៖**

សាជីវកម្មភោជនីយដ្ឋានធំៗមិនបានបង់ប្រាក់ចំណែកសមរម្យរបស់ពួកគេទេ ហើយកំពុងបង្ខំអតិថិជនឱ្យទទួលខុសត្រូវលើប្រាក់ឈ្នួលកម្មករនិយោជិតរបស់ខ្លួន តាមរយៈប្រាក់ធនានុគ្រោះ។ ប្រាក់ធនានុគ្រោះគួរតែជារង្វាន់សម្រាប់សេវាកម្មល្អ មិនមែនជាប្រាក់ឧបត្ថម្ភសម្រាប់ប្រាក់ឈ្នួលទាបដែលបង់ដោយសាជីវកម្មធំៗនោះទេ។


**Estefania Galvis**
**One Fair Wage**
**11 College Ave**
**Dorchester, MA 02148**
**813-898-9136**
**www.yeson5ma.com**


***បោះឆ្នោតជំទាស់៖*** សំណួរនេះត្រូវបានផ្តល់មូលនិធិគាំទ្រដោយក្រុមរ៉ាឌីកាល់មកពីរដ្ឋកាលីហ្វ័រញ៉ា។

និយោជិតដែលមានប្រាក់ធនានុគ្រោះបានបង្ហាញយ៉ាងច្បាស់ថា ពួកគេមិនបានផ្លាស់ប្តូរវិធីដែលពួកគេរកប្រាក់នោះទេ។ ច្បាប់សហព័ន្ធនិងរដ្ឋធានាឱ្យពួកគេទទួលបានប្រាក់ឈ្នួលអប្បបរមា $15 ក្នុងមួយម៉ោង ដែលមនុស្សជាច្រើនរកបានចំនួន $40/ម៉ោង ហើយចំនួន 90% រាយការណ៍ថារកបានយ៉ាងហោចណាស់ចំនួន $20/ម៉ោង។ ការស្ទង់មតិថ្មីៗនេះក៏បានបង្ហាញផងដែរថា 88% ជំទាស់នឹង 'ការប្រមូលប្រាក់ធនានុគ្រោះ' ដែលប្រាក់ធនានុគ្រោះបានចែករំលែកដល់និយោជិតមិនមែនសេវាកម្ម ហើយ 90% ជឿថាប្រសិនបើប្រាក់ឈ្នួលដែលមានប្រាក់ធនានុគ្រោះត្រូវបានលុបចោល ពួកគេនឹងរកប្រាក់បានតិចជាងនេះ។

ការប៉ុនប៉ងផ្សេងទៀតដើម្បីអនុវត្តបែបនេះ បាននាំមកនូវលទ្ធផលធ្ងន់ធ្ងរ។ នៅរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី ជិត 10% នៃនិយោជិតដែលមានប្រាក់ធនានុគ្រោះ បានបាត់បង់ ឬលាឈប់ពីការងាររបស់ពួកគេ។ ការណ៍នេះកើតឡើងបន្ទាប់ពីការដំឡើងថ្លៃមុខម្ហូប ការអនុវត្តការគិត 'ថ្លៃសេវា' 20% និងរលកនៃការបិទអាជីវកម្ម។

ការណ៍នេះនឹងកាត់បន្ថយប្រាក់ឈ្នួលសរុបសម្រាប់អ្នកបម្រើសេវា បង្កើនថ្លៃដើមសម្រាប់ភោជនីយដ្ឋាន និងធ្វើឱ្យតម្លៃនៃការញ៉ាំអាហារនៅក្រៅផ្ទះកើនឡើងឥតឈប់ឈរ។ វានឹងមានសភាពធ្ងន់ធ្ងរដែលភោជនីយដ្ឋានតាមសង្កាត់ជាច្រើនត្រូវបានបង្ខំឱ្យបិទទ្វារ។


**Doug Bacon**
**អតីតអ្នកបម្រើនិងចាក់ស្រា បច្ចុប្បន្នជាម្ចាស់ភោជនីយដ្ឋាន**
**គណៈកម្មាធិការការពារប្រាក់ធនានុគ្រោះ**
**160 E Main St # 2**
**Westborough, MA 01581**
**www.ProtectTips.org**


## អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ

ត្រូវយល់ព្រមដោយប្រជាជន និងតាមសិទ្ធិអំណាចរបស់ពួកគេ៖

ច្បាប់មួយដែលតម្រូវឱ្យបង់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះបន្ថែមលើប្រាក់ធនានុគ្រោះ។

ផ្នែកទី 1

ផ្នែកទី 7 នៃជំពូកទី 151 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវកថាខណ្ឌទី 3 ដូចដែលបានធ្វើវិសោធនកម្មដោយជំពូកទី 121 នៃច្បាប់ឆ្នាំ 2018 ហើយបញ្ចូលជំនួសដោយកថាខណ្ឌខាងក្រោម៖ -

ក្នុងការកំណត់ប្រាក់ឈ្នួលដែលនិយោជកត្រូវបានតម្រូវឱ្យបង់ប្រាក់ឈ្នួលឱ្យនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ ចំនួនទឹកប្រាក់ដែលនិយោជកបានបង់ទៅឱ្យនិយោជិតនោះត្រូវមានចំនួនស្មើនឹង៖ (1) ប្រាក់ឈ្នួលជាសាច់ប្រាក់ដែលបានបង់ដល់និយោជិតនោះ ដែលសម្រាប់គោលបំណងនៃការកំណត់នេះ មិនត្រូវមានចំនួនតិចជាងហុកសិបបួនភាគរយនៃប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី l នោះទេ និង (2) ចំនួនទឹកប្រាក់បន្ថែមលើគណនីប្រាក់ធនានុគ្រោះដែលទទួលបានដោយនិយោជិតនោះ ដែលចំនួននេះយ៉ាងហោចណាស់ស្មើនឹងចំនួនខុសគ្នារវាងប្រាក់ឈ្នួលដែលបានចែងក្នុងប្រការ (1) និងប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី 1 ដែលការទូទាត់ទៅឱ្យនិយោជិតត្រូវស្របគ្នាជាមួយនឹងផ្នែកទី 148 នៃជំពូក 149 ។ កថាខណ្ឌនេះមិនត្រូវអនុវត្តចំពោះនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ឡើយ លុះត្រាតែនិយោជិតនោះត្រូវបានជូនដំណឹងដោយនិយោជកអំពីបទប្បញ្ញត្តិនៃកថាខណ្ឌនេះ ហើយប្រាក់ធនានុគ្រោះទាំងអស់ដែលទទួលបានដោយនិយោជិតនោះត្រូវបានរក្សាទុកដោយនិយោជិត លើកលែងតែកថាខណ្ឌនេះមិនបានបកស្រាយថាហាមមិនឱ្យមានការប្រមូលប្រាក់ធនានុគ្រោះក្នុងចំណោមនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះតាមទម្លាប់និងជាប្រចាំ។

ផ្នែកទី 2

ផ្នែកទី 7 នៃជំពូកទី 151 ដែលបានចែងនេះត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវកថាខណ្ឌទីបី ហើយបញ្ចូលជំនួស ដោយកថាខណ្ឌខាងក្រោម៖-

ក្នុងការកំណត់ប្រាក់ឈ្នួលដែលនិយោជកត្រូវបានតម្រូវឱ្យបង់ប្រាក់ឈ្នួលឱ្យនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ ចំនួនទឹកប្រាក់ដែលនិយោជកបានបង់ទៅឱ្យ

**អត្ថបទទាំងស្រុងនៃច្បាប់ដែលបានស្នើ (ត)**

និយោជិតនោះត្រូវមានចំនួនស្មើនឹង៖ (1) ប្រាក់ឈ្នួលជាសាច់ប្រាក់ដែលបានបង់ដល់និយោជិតនោះ ដែលសម្រាប់គោលបំណងនៃការកំណត់នេះ មិនត្រូវមានចំនួនតិចជាងចិតសិបបីភាគរយនៃប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី I និង (2) ចំនួនទឹកប្រាក់បន្ថែមលើគណនីប្រាក់ធនានុគ្រោះដែលទទួលបានដោយនិយោជិតនោះ ដែលចំនួននេះយ៉ាងហោចណាស់ស្មើនឹងចំនួនខុសគ្នារវាងប្រាក់ឈ្នួលដែលបានចែងក្នុងប្រការ (1) និងប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី 1 ដែលការទូទាត់ទៅនិយោជិតត្រូវស្របគ្នាជាមួយនឹងផ្នែកទី 148 នៃជំពូក 149 ។ កថាខណ្ឌនេះមិនត្រូវអនុវត្តចំពោះនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ឡើយ លុះត្រាតែនិយោជិតនោះត្រូវបានជូនដំណឹងដោយនិយោជកអំពីបទប្បញ្ញត្តិនៃកថាខណ្ឌនេះ ហើយប្រាក់ធនានុគ្រោះទាំងអស់ដែលទទួលបានដោយនិយោជិតនោះត្រូវបានរក្សាទុកដោយនិយោជិត លើកលែងតែកថាខណ្ឌនេះមិនត្រូវបកស្រាយថាហាមមិនឱ្យមានការប្រមូលប្រាក់ធនានុគ្រោះក្នុងចំណោមនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះតាមទម្លាប់និងជាប្រចាំ។

ផ្នែកទី 3

ផ្នែកទី 7 នៃជំពូកទី 151 ដែលបានចែងនេះត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវកថាខណ្ឌទីបី ហើយបញ្ចូលជំនួស ដោយកថាខណ្ឌខាងក្រោម៖-

ក្នុងការកំណត់ប្រាក់ឈ្នួលដែលនិយោជកត្រូវបានតម្រូវឱ្យបង់ប្រាក់ឈ្នួលឱ្យនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ ចំនួនទឹកប្រាក់ដែលនិយោជកបានបង់ទៅឱ្យនិយោជិតនោះត្រូវមានចំនួនស្មើនឹង៖ (1) ប្រាក់ឈ្នួលជាសាច់ប្រាក់ដែលបានបង់ដល់និយោជិតនោះ ដែលសម្រាប់គោលបំណងនៃការកំណត់នេះ មិនត្រូវមានចំនួនតិចជាងប៉ែតសិបពីរភាគរយនៃប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី I និង (2) ចំនួនទឹកប្រាក់បន្ថែមលើគណនីប្រាក់ធនានុគ្រោះដែលទទួលបានដោយនិយោជិតនោះ ដែលចំនួននេះយ៉ាងហោចណាស់ស្មើនឹងចំនួនខុសគ្នារវាងប្រាក់ឈ្នួលដែលបានចែងក្នុងប្រការ (1) និងប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី 1 ដែលការទូទាត់ទៅឱ្យ និយោជិតត្រូវស្របគ្នាជាមួយនឹងផ្នែកទី 148 នៃជំពូក 149 ។ កថាខណ្ឌនេះមិនត្រូវអនុវត្តចំពោះនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ឡើយ លុះត្រាតែនិយោជិតនោះត្រូវបានជូនដំណឹងដោយនិយោជកអំពីបទប្បញ្ញត្តិនៃកថាខណ្ឌនេះ ហើយប្រាក់ធនានុគ្រោះទាំងអស់ដែលទទួលបានដោយនិយោជិតនោះត្រូវបានរក្សាទុកដោយនិយោជិត លើកលែងតែកថាខណ្ឌនេះមិនបានបកស្រាយថាហាមមិនឱ្យមានការប្រមូលប្រាក់ធនានុគ្រោះក្នុងចំណោមនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះតាមទម្លាប់និងជាប្រចាំ។

ផ្នែកទី 4

ផ្នែកទី 7 នៃជំពូកទី 151 ដែលបានចែងនេះត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវកថាខណ្ឌទីបី ហើយបញ្ចូលជំនួស ដោយកថាខណ្ឌខាងក្រោម៖ -

ក្នុងការកំណត់ប្រាក់ឈ្នួលដែលនិយោជកត្រូវបានតម្រូវឱ្យបង់ប្រាក់ឈ្នួលឱ្យនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ ចំនួនទឹកប្រាក់ដែលនិយោជកបានបង់ទៅឱ្យនិយោជិតនោះត្រូវមានចំនួនស្មើនឹង៖ (1) ប្រាក់ឈ្នួលជាសាច់ប្រាក់ដែលបានបង់ដល់និយោជិតនោះ ដែលសម្រាប់គោលបំណងនៃការកំណត់នេះ មិនត្រូវមានចំនួនតិចជាងកៅសិបមួយភាគរយនៃប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី I និង (2) ចំនួនទឹកប្រាក់បន្ថែមលើគណនីប្រាក់ធនានុគ្រោះដែលទទួលបានដោយនិយោជិតនោះ ដែលចំនួននេះយ៉ាងហោចណាស់ស្មើនឹងចំនួនខុសគ្នារវាងប្រាក់ឈ្នួលដែលបានចែងក្នុងប្រការ (1) និងប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី 1 ដែលការទូទាត់ទៅនិយោជិតត្រូវស្របគ្នាជាមួយនឹងផ្នែកទី 148 នៃជំពូក 149 ។ កថាខណ្ឌនេះមិនត្រូវអនុវត្តចំពោះនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ឡើយ លុះត្រាតែនិយោជិតនោះត្រូវបានជូនដំណឹងដោយនិយោជកអំពីបទប្បញ្ញត្តិនៃកថាខណ្ឌនេះ ហើយប្រាក់ធនានុគ្រោះទាំងអស់ដែលទទួលបានដោយនិយោជិតនោះត្រូវបានរក្សាទុកដោយនិយោជិត លើកលែងតែកថាខណ្ឌនេះមិនបានបកស្រាយថាហាមមិនឱ្យមានការប្រមូលប្រាក់ធនានុគ្រោះក្នុងចំណោមនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះតាមទម្លាប់និងជាប្រចាំ។

ផ្នែកទី 5

ផ្នែកទី 7 នៃជំពូកទី 151 ដែលបានចែងនេះត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវកថាខណ្ឌទីបី ហើយបញ្ចូលជំនួស ដោយកថាខណ្ឌខាងក្រោម៖ -

ក្នុងការកំណត់ប្រាក់ឈ្នួលដែលនិយោជកត្រូវបានតម្រូវឱ្យបង់ប្រាក់ឈ្នួលឱ្យនិយោជិតដែលមានប្រាក់ធនានុគ្រោះណាម្នាក់ ចំនួនទឹកប្រាក់ដែលនិយោជកបានបង់ទៅឱ្យនិយោជិតនោះត្រូវមានចំនួនស្មើនឹង៖ (1) ប្រាក់ឈ្នួលជាសាច់ប្រាក់ដែលបានបង់ដល់និយោជិតនោះ ដែលសម្រាប់គោលបំណងនៃការកំណត់នេះ មិនត្រូវមានចំនួនតិចជាងមួយរយភាគរយនៃប្រាក់ឈ្នួលជាធរមានក្រោមផ្នែកទី I និង (2) ចំនួនទឹកប្រាក់បន្ថែមលើគណនីប្រាក់ធនានុគ្រោះដែលទទួលបានដោយនិយោជិតនោះ ដែលការទូទាត់ទៅនិយោជិតត្រូវស្របគ្នាជាមួយនឹងផ្នែកទី 148 នៃជំពូក 149 ។ កថាខណ្ឌនេះមិនត្រូវបានបកស្រាយថាហាមមិនឱ្យមានការប្រមូលប្រាក់ធនានុគ្រោះក្នុងចំណោមនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះតាមទម្លាប់និងជាប្រចាំនោះទេ។

ផ្នែកទី 6

ផ្នែកទី 152A នៃជំពូកទី 149 នៃច្បាប់ទូទៅត្រូវបានធ្វើវិសោធនកម្មដោយការដកចេញនូវកថាខណ្ឌ (c) ហើយបញ្ចូលជំនួសដោយកថាខណ្ឌខាងក្រោម៖ -

(c) ប្រសិនបើបាននិយោជកកំពុងបើកប្រាក់ឈ្នួលដល់និយោជិតទាំងអស់ដែលមានចំនួនមិនតិចជាងប្រាក់ឈ្នួលអប្បបរមាពេញលេញដូចដែលមានចែងក្នុងផ្នែកទី 1 នៃជំពូកទី 151 និយោជកអាចតម្រូវឱ្យនិយោជិតដែលជាបុគ្គលិកបម្រើចំណីអាហារ បុគ្គលិកសេវាកម្ម ឬបុគ្គលិកចាក់ស្រា លាយស្រា ចូលរួមក្នុងការប្រមូលប្រាក់ធនានុគ្រោះ ដែលតាមរយៈនោះ និយោជិតទាំងនោះនឹងប្រគល់ប្រាក់ឈ្នួល ប្រាក់ធនានុគ្រោះ ឬប្រាក់ថ្លៃសេវា ឬចំណែកណាមួយនៃប្រាក់ទាំងនោះ សម្រាប់ចែកចាយដល់និយោជិតដែលមិនមែនជាបុគ្គលិកបម្រើចំណីអាហារ បុគ្គលិកសេវាកម្ម ឬបុគ្គលិកចាក់ស្រា លាយស្រា។ និយោជកអាចចាត់ចែងការប្រមូលប្រាក់ធនានុគ្រោះមានសុពលភាព ហើយអាចរក្សាទុកកំណត់ត្រានៃចំនួនទឹកប្រាក់ដែលបានទទួលសម្រាប់គោលបំណងធ្វើរបាយការណ៍គណនេយ្យឬរបាយការណ៍ពន្ធ។

ផ្នែកទី 7

ផ្នែកទី 1 និងទី 6 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2025។

ផ្នែកទី 8

ផ្នែកទី 2 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2026។

ផ្នែកទី 9

ផ្នែក 3 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2027។

ផ្នែកទី 10

ផ្នែកទី 4 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2028។

ផ្នែកទី 11

ផ្នែកទី 5 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2029។

### របាយការណ៍មតិភាគច្រើន

*របាយការណ៍ខាងក្រោមត្រូវបានរៀបចំឡើងដោយចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា ដែលជាគណៈកម្មាធិការសភានៃរដ្ឋម៉ាសាឈូសិត តាមរដ្ឋធម្មនុញ្ញរដ្ឋម៉ាសាឈូសិតបានកំណត់ របាយការណ៍មតិភាគច្រើននេះ ត្រូវបានបោះពុម្ពដូចខាងក្រោម។ សេចក្តីថ្លែងការណ៍នានានៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងពីមតិយោបល់របស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋឡើយ។*

ចំនួនភាគច្រើននៃសមាជិកគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា (ហៅកាត់ថា “គណៈកម្មាធិការ”) ផ្តល់អនុសាសន៍ថា ញត្តិលេខ 23-12 សភាតំណាងរាស្ត្រលេខ 4254 “ច្បាប់មួយដែលតម្រូវឱ្យបង់ប្រាក់ឈ្នួលអប្បបរមាពេញលេញសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះបន្ថែមលើប្រាក់ធនានុគ្រោះ” (ញត្តិផ្តួចផ្តើម”) ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិប្បញ្ញត្តិនៅពេលនេះទេ។

គោលបំណងនៃរបាយការណ៍នេះគឺដើម្បីផ្តល់ជាអនុសាសន៍ដល់ស្ថាប័ននីតិប្បញ្ញត្តិពេញអង្គអំពីថាតើត្រូវទទួលយកញត្តិផ្តួចផ្តើមដូចដែលបានព្រាងសម្រាប់ការពិចារណា និងអនុម័តដែរឬទេ។

ញត្តិផ្តួចផ្តើមដែលបានស្នើឡើងនឹងដកចេញនូវបទប្បញ្ញត្តិនៅក្នុងច្បាប់របស់រដ្ឋដែលអនុញ្ញាតឱ្យនិយោជកផ្តល់សំណងដល់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះរបស់ពួកគេ ក្នុងអត្រាអប្បបរមាទាបជាងមុន ប្រសិនបើ "ប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះ" រួមជាមួយនឹងតម្លៃប្រាក់ធនានុគ្រោះបន្ថែមរបស់កម្មករ យ៉ាងហោចណាស់ស្មើនឹង ប្រាក់ម៉ោងអប្បបរមាដែលមិនប្រាក់ធនានុគ្រោះរបស់រដ្ឋ ក្នុងអំឡុងពេលនៃវេនដែលបានធ្វើការនីមួយៗ។ ជាងនេះទៀត ញត្តិផ្តួចផ្តើមនេះនឹងអនុញ្ញាតឱ្យម្ចាស់ភោជនីយដ្ឋានតម្រូវឱ្យនិយោជិតដែលមានប្រាក់ធនានុគ្រោះត្រូវចែករំលែកប្រាក់ធនានុគ្រោះរបស់ខ្លួនជាមួយនិយោជិតដែលមិនទទួលបានប្រាក់ធនានុគ្រោះនៅភោជនីយដ្ឋាននោះ។

#### *សក្ខីភាព*

គណៈកម្មាធិការនេះបានឮពីអ្នកជំនាញដែលមានបទពិសោធន៍អ្នកគាំទ្រ និងអ្នកជំទាស់ចំពោះញត្តិផ្តួចផ្តើម ក៏ដូចជាសមាជិកសាធារណជនទូទៅផងដែរ។

Lauren Moran ប្រធានផ្នែកការងារដោយយុត្តិធម៌នៃការិយាល័យអគ្គរដ្ឋអាជ្ញា បានផ្តល់សក្ខីកម្មជាអ្នកជំនាញ ហើយបានជជែកអំពីច្បាប់ “ចរចាដ៏ទូលំទូលាយ (Grand Bargain)” ឆ្នាំ 2018។ ច្បាប់ចរចាដ៏ទូលំទូលាយនេះ បានកែប្រែប្រាក់ឈ្នួលអប្បបរមារបស់កម្មករពី $3.75 ក្នុងមួយម៉ោង បូករួមទាំងប្រាក់ធនានុគ្រោះតាមម៉ោងជាមធ្យមក្នុងសប្តាហ៍ រហូតដល់ប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋខុសគ្នា ដែលនិយោជកបានបង់ដល់ចំនួន $6.75 ក្នុងមួយម៉ោង បូករួមទាំងប្រាក់ធនានុគ្រោះតាមម៉ោងជាមធ្យមក្នុងមួយម៉ោងក្នុងវេនធ្វើការ ដែលនិយោជកបានបង់ទឹកប្រាក់ខុសគ្នាឱ្យ និងអត្រាកើនឡើងជាលំដាប់ក្នុងរយៈពេលប្រាំឆ្នាំដែលចាប់ផ្តើមនៅឆ្នាំ 2019។ ផ្នែកការងារដោយយុត្តិធម៌ បច្ចុប្បន្នមានសមត្ថកិច្ចអនុវត្តយ៉ាងទូលំទូលាយលើសិទ្ធិទទួលបានប្រាក់ឈ្នួលសម្រាប់កម្មករ និយោជិត និងប្រមូលទិន្នន័យស្តីពីបណ្តឹងទាមទារចំពោះការបំពានប្រាក់ធនានុគ្រោះ។ ទិន្នន័យដែលបានបង្ហាញ ចាប់ពីខែមីនា ឆ្នាំ 2021 រហូតដល់ថ្ងៃសវនាការបច្ចុប្បន្ន បណ្តឹងទាមទារចំនួន 15 ភាគរយបានមកពីឧស្សាហកម្មភោជនីយដ្ឋាន និងហាងកែសម្ផស្ស ពីឧស្សាហកម្មដែលធម្មតាផ្តល់ការងារដល់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះខ្ពស់ ដោយចំនួន 30 ភាគរយនៃបណ្តឹងទាមទារបើកចំហសកម្មបានមកពីឧស្សាហកម្មទាំងនេះ។ ដើមបណ្តឹងជិត 700 នាក់ បានអះអាងពីការបំពានប្រាក់ធនានុគ្រោះពីកម្មករនិយោជិត ហើយឧស្សាហកម្មទាំងនេះមានចំនួន 35 ភាគរយនៃការអនុវត្តច្បាប់ពលរដ្ឋសរុប ដែលត្រូវបានវាយតម្លៃថាមានប្រាក់សំណងជិត $2,000,000 ដុល្លារ និងប្រាក់ពិន័យចំនួន $3,400,000 ។

បន្ថែមចំពោះការិយាល័យអគ្គរដ្ឋអាជ្ញា សេដ្ឋកិច្ចវិទូនៅតាមសាកលវិទ្យាល័យក៏បានចែករំលែកទស្សនៈ និងរបកគំហើញរបស់ពួកគេផងដែរ។ បណ្ឌិត Jeannette Wicks-Lim ដែលជាសាស្ត្រាចារ្យស្រាវជ្រាវរងនៃវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចនយោបាយ នៅសាកលវិទ្យាល័យ Massachusetts Amherst បានដកស្រង់អត្ថបទដែលបានត្រួតពិនិត្យពីមិត្តភក្តិចំនួនពីរ ដែលបានស្ទង់មតិលើការស្រាវជ្រាវសហសម័យទាំងអស់អំពីទិន្នន័យប្រាក់ឈ្នួលអប្បបរមា ហើយបានស្នើថា មានភស្តុតាងតិចតួច រហូតដល់គ្មានភស្តុតាង ដែលបង្ហាញពីលទ្ធផលការងារអវិជ្ជមានពីការបង្កើនប្រាក់ឈ្នួលអប្បបរមា។ បណ្ឌិត Wicks-Lim បញ្ជាក់ថា មានចំនួនទិន្នន័យកំណត់ដែលអាចរកបាន ទាក់ទងនឹងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងការងារពីវិធានការស្រដៀងគ្នាមួយដែលត្រូវបានអនុម័តនៅក្នុងរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី ដែលចាប់តាំងពីឆ្នាំ 2023 មក បាននឹងកំពុងលុបបំបាត់ប្រាក់ឈ្នួលអប្បបរមាមានប្រាក់ធនានុគ្រោះបន្តិចម្តងៗ រហូតដល់ត្រូវបានដកចេញទាំងស្រុងនៅឆ្នាំ 2027 ។ បណ្ឌិត Wicks-Lim បាននិយាយថា ភោជនីយដ្ឋាននឹងមិនចាំបាច់មើលឃើញថាការចំណាយសរុបរបស់ពួកគេកើនឡើងតាមសមាមាត្រដូចគ្នានឹងការបង្កើនប្រាក់ឈ្នួលដល់និយោជិតនោះទេ ហើយថា ភោជនីយដ្ឋានមានវិធីដែលអាចបត់បែនបានក្នុងការកែតម្រូវទៅនឹងកំណើនឡើងថ្លៃដើម ដូចជាការឡើងថ្លៃដែលបានកែប្រែជាដើម។ ជាងនេះទៀត បណ្ឌិត Wicks-Lim សង្កេតឃើញថា ការដំឡើងប្រាក់ឈ្នួលនឹងនាំឱ្យតម្លៃរដ្ឋបាល និងវគ្គបណ្តុះបណ្តាលទាប ដោយសារបម្លាស់ប្តូរកម្មករនិយោជិតត្រូវបានកាត់បន្ថយ។ បណ្ឌិត Wicks-Lim ក៏បានលើកឡើងផងដែរថា អត្រាភាពក្រីក្រសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ គឺខ្ពស់ជាងកម្មករនិយោជិតដែលមិនទទួលបានប្រាក់ធនានុគ្រោះ — គឺជាស្ថិតិដែលគួរឱ្យកត់សម្គាល់ជាពិសេសនៅក្នុងរដ្ឋដែលមានប្រាក់ឈ្នួលអប្បបរមាមានប្រាក់ធនានុគ្រោះទាប — ហើយថាឧស្សាហកម្មនេះត្រូវបានបង្កើតឡើងដោយភាគច្រើនជាស្ត្រីដែលចំនួនមួយភាគបួននៃពួកគេត្រូវចិញ្ចឹមកូន។ បណ្ឌិត Sean Jung ជាសាស្ត្រាចារ្យអមនៅសាលារដ្ឋបាលបដិសណ្ឋារកិច្ចនៃសាកលវិទ្យាល័យ Boston បានជំទាស់នឹងការផ្តល់សក្ខីកម្មរបស់បណ្ឌិត Wick-Lim ដោយចង្អុលទៅភស្តុតាងដែលបង្ហាញថាការដកចេញនូវប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះទំនងជានឹងនាំឱ្យភោជនីយដ្ឋានដែលផ្តល់សេវាកម្មពេញលេញបំលែងខ្លួនទៅជាសេវាកម្មមានកំណត់ ឬសេវាកម្មដោយផ្ទាល់វិញ ដោយសារតម្លៃពលកម្ម។ បណ្ឌិត Jung ក៏បានរំលេចផងដែរថា ការដកឥណទានប្រាក់ធនានុគ្រោះអាចនាំឱ្យតម្លៃលើបញ្ជីមុខម្ហូប និងថ្លៃសេវាកើនឡើង ហើយភោជនីយដ្ឋានជាច្រើនទៀតនឹងឈប់ដំណើរការដោយសារប្រាក់ចំណេញទាប។ បណ្ឌិត Jung បានព្យាករណ៍ថា ការណ៍នេះនឹងមានលក្ខណៈធ្ងន់ធ្ងរជាពិសេសនៅតំបន់ជនបទ ដែលអត្រាប្រាក់ចំណេញ និងតម្រូវការអតិថិជនទាប ប៉ុន្តែតម្លៃពលកម្មនឹងកើនឡើងក្នុងអត្រាដូចគ្នានឹងតំបន់ជាយក្រុង ឬទីក្រុង។ បណ្ឌិត Jung បានផ្តល់សក្ខីកម្មផងដែរថា ជាប្រវត្តិសាស្ត្រ នៅពេលដែលតម្លៃពលកម្មកើនឡើង ភោជនីយដ្ឋាននានាបានងាកទៅរកវិធីសាស្ត្រដែលអនុញ្ញាតឱ្យមានការកាត់បន្ថយបុគ្គលិកផ្នែកសេវាកម្ម ដូចជាការប្រើប្រាស់ថេប្លេតសម្រាប់ការបញ្ជាទិញជាដើម។

ក្រុមអ្នកគាំទ្រញត្តិផ្តួចផ្តើមពីយុទ្ធនាការថ្នាក់ជាតិស្តីពីប្រាក់ឈ្នួលសមរម្យមួយ មានអ្នកជំនាញផ្នែកសិក្សាធិការ ម្ចាស់ភោជនីយដ្ឋាន និងបុគ្គលិកភោជនីយដ្ឋានដែលទទួលបានប្រាក់ធនានុគ្រោះ។ ក្រុមនេះបានពណ៌នាអំពីការអនុវត្តប្រាក់ឈ្នួលអប្បបរមាមានប្រាក់ធនានុគ្រោះបច្ចុប្បន្នថាជា "ប្រាក់ឈ្នួលរងអប្បបរមា" ដែលជាបញ្ហាសេដ្ឋកិច្ចយេនឌ័រ និងសមភាពជាតិសាសន៍ យុត្តិធម៌យេនឌ័រ និងបញ្ហាប្រាក់បៀវត្សរ៍សមធម៌យេនឌ័រ។ ក្រុមនេះបានអះអាងថា អតុល្យភាពសិទ្ធិអំណាចកើតមាននៅកន្លែងដែលកម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ ជាពិសេសស្ត្រី និងក្រុមស្ត្រីមិនមែនជាជនស្បែកស ត្រូវបង្ខំចិត្តមិនអើពើនឹងអំពើហិង្សាយេនឌ័រ ការបៀតបៀនផ្លូវភេទ និងការលួចប្រាក់ឈ្នួល ដោយសារពួកគេពឹងផ្អែកលើប្រាក់ធនានុគ្រោះជាផ្នែកនៃសំណង

**របាយការណ៍មតិភាគច្រើន** (ត)

ពេញលេញរបស់ពួកគេ។ អ្នកគាំទ្របានបង្ហាញរដ្ឋចំនួន 7 ដែលបច្ចុប្បន្នមិនមានប្រាក់ឈ្នួលអប្បបរមាទាបសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះគឺ៖ រដ្ឋ Alaska រដ្ឋ California រដ្ឋ Minnesota រដ្ឋ Montana រដ្ឋ Nevada រដ្ឋ Oregon និងរដ្ឋ Washington ។ អ្នកគាំទ្របានលើកឡើងពីភស្តុតាងដែលថា កំណើននៃចំនួនភោជនីយដ្ឋានសុទ្ធក្នុងរដ្ឋកាលីហ្វ័រញ៉ាបានកើនឡើងលើសកំណើនជាមធ្យមក្នុងរដ្ឋដែលត្រូវបង់ប្រាក់ឈ្នួលអប្បបរមាមានប្រាក់ធនានុគ្រោះ រួមទាំងរដ្ឋម៉ាសាឈូសិតផងដែរ។ ពួកគេក៏បានរំលេចផងដែរនូវទិន្នន័យដែលបង្ហាញពីបុគ្គលិកដែលទទួលបានប្រាក់ធនានុគ្រោះជាមធ្យមនៅក្នុងរដ្ឋទាំង 7 ជាប្រាក់សុទ្ធ ចន្លោះពី 10 ទៅ 18 ភាគរយច្រើនជាងបុគ្គលិកដែលទទួលបានប្រាក់ធនានុគ្រោះជាមធ្យមនៅក្នុងរដ្ឋដទៃទៀតនៃប្រទេស។ អ្នកគាំទ្រក៏រក្សាជំហរថា មានកម្រិតភាពក្រីក្រកាន់តែខ្ពស់ ការរំលោភលើប្រាក់ឈ្នួលដែលមិនអាចអនុវត្តបាន និងអត្រាខ្ពស់បំផុតនៃការបៀតបៀនផ្លូវភេទក្នុងឧស្សាហកម្មណាមួយដែលបានសិក្សាដោយសាស្ត្រាចារ្យ Catharine A. MacKinnon ។

អ្នកជំទាស់នឹងញត្តិផ្តួចផ្តើម រួមមាន តំណាងឧស្សាហកម្មភោជនីយដ្ឋាន ម្ចាស់ភោជនីយដ្ឋាន និងបុគ្គលិកភោជនីយដ្ឋានដែលទទួលបានប្រាក់ធនានុគ្រោះ។ ក្រុមជំទាស់ទីមួយបានបង្ហាញពីការចំណាយដែលទាក់ទងនឹងការលុបបំបាត់ប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះ ដែលនឹងបង្កើននូវអ្វីដែលភោជនីយដ្ឋានមួយ ត្រូវបង់ឱ្យនិយោជិតចេញពីប្រាក់ឈ្នួលចន្លោះពី $6.75 ទៅ $15 ក្នុងមួយម៉ោងទៅតម្លៃថេរ $15 ក្នុងមួយម៉ោង។ ពួកគេបានពិពណ៌នាអំពីបច្ចេកវិទ្យាកន្លែងលក់ (Point of Sale) ផ្នែកភោជនីយដ្ឋានថ្មី ដែលផ្តល់នូវការតាមដានទិន្នន័យបែបជឿនលឿនដែលត្រូវបានរចនាឡើងដើម្បីកាត់បន្ថយភាពខុសគ្នាទាក់ទងនឹងប្រាក់ឈ្នួល និងប្រាក់ធនានុគ្រោះដែលទទួលបានក្នុងមួយវេនធ្វើការ។ អ្នកជំទាស់ទៅនឹងញត្តិផ្តួចផ្តើមក៏បានសន្មតថា ករណីនៃការបៀតបៀនផ្លូវភេទ និងការរំលោភបំពានផ្លូវភេទចំពោះសកម្មភាពមិនល្អរបស់ម្ចាស់អាជីវកម្ម និងកំសោយក្នុងការគ្រប់គ្រងរបស់និយោជកជាជាងការកើតមានចំពោះប្រព័ន្ធសំណងប្រាក់ឈ្នួលដែលមានប្រាក់ធនានុគ្រោះ។ អ្នកជំទាស់បានអះអាងបន្ថែមទៀតថា ការដកឥណទានប្រាក់ធនានុគ្រោះនឹងធ្វើឱ្យប៉ះពាល់ដល់ភោជនីយដ្ឋានដែលមានតម្លៃសមរម្យ ដែលដំណើរការក្នុងកម្រិតទាបជាងភោជនីយដ្ឋានលំដាប់ខ្ពស់ ហើយបច្ចុប្បន្នកំពុងប្រកួតប្រជែងជាមួយហាងលក់គ្រឿងទេស គ្រឹះស្ថានលក់អាហារឬរបស់របរកញ្ចប់និងសេវាកម្មរហ័ស ព្រមទាំងអាហារស្រាប់។ អ្នកជំទាស់ភ័យខ្លាចថា ការចំណាយកើនឡើងដែលទាក់ទងនឹងការប្រតិបត្តិនេះ នឹងបំផ្លាញឧស្សាហកម្មភោជនីយដ្ឋានដែលមានតម្លៃសមរម្យ ហើយទទួលយកកម្លាំងការងារដែលមានប្រាក់ធនានុគ្រោះ ដែលជាមធ្យមរកបាន $35-40 ក្នុងមួយម៉ោងជាមួយនឹងប្រាក់ឈ្នួលធម្មតាខ្ពស់រហូតដល់ $70 ដុល្លារក្នុងមួយម៉ោង ដែលបញ្ចប់ការផ្តល់សក្ខីកម្មដោយសង្កត់ធ្ងន់ថា ការប្រតិបត្តិប្រាក់ធនានុគ្រោះជាការលើកទឹកចិត្តសម្រាប់សេវាកម្មល្អ គឺជាផលប៉ះពាល់មួយ មិនមែនជាវិការៈនៃឧស្សាហកម្មភោជនីយដ្ឋាននោះទេ។

ក្រុមជំទាស់ទីពីរ ដែលមានបុគ្គលិកភោជនីយដ្ឋាន បានផ្តល់ភស្តុតាងអត្តនោម័ត និងជំនឿផ្ទាល់ខ្លួនរបស់ពួកគេថា ការដកប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះនឹងនាំឱ្យមានការថយចុះភាគរយនៃប្រាក់ធនានុគ្រោះ និងសំណងជារួមជាយថាហេតុបើប្រៀបធៀបទៅនឹងគំរូបច្ចុប្បន្ន ដោយសមាជិកក្រុមជំទាស់ម្នាក់បានលើកឡើងថា ការពិតដែលថាមានតែរដ្ឋចំនួនប្រាំពីរប៉ុណ្ណោះដែលមិនមានប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះ គឺជាភស្តុតាងដែលបង្ហាញថាប្រព័ន្ធបច្ចុប្បន្នដំណើរការបានល្អ។

គណៈកម្មាធិការមិនទទួលបានទិន្នន័យដែលបង្ហាញពីផលប៉ះពាល់ដល់ឧស្សាហកម្មភោជនីយដ្ឋានរដ្ឋ ម៉ាសាឈូសិត ដោយផ្អែកលើប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះ និងការដំឡើងប្រាក់ឈ្នួលអប្បបរមានៃច្បាប់ "ចរចាដ៏ទូលំទូលាយ" ដែលបានអនុម័តក្នុងឆ្នាំ 2018 ឡើយ។ យោងតាមក្រសួងការងាររបស់សហរដ្ឋអាមេរិកក្នុងឆ្នាំ 2024 ដោយសារតែការដំឡើងប្រាក់ឈ្នួលទាំងនេះ រដ្ឋម៉ាសាឈូសិត ជាប់ចំណាត់ថ្នាក់ទីប្រាំមួយដែលមានប្រាក់ឈ្នួលអប្បបរមាមានប្រសិទ្ធភាពខ្ពស់បំផុតសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ ក្នុងចំណោមរដ្ឋទាំង 50 និង District of Columbia សូម្បីតែនៅពេលគិតពីប្រាក់ឈ្នួលអប្បបរមាខ្ពស់បំផុតនៅក្នុងរដ្ឋដែលមានអត្រាខុសគ្នាសម្រាប់និយោជកនៅក្នុងទីក្រុង ខោនធី ឬតាមទំហំ និងតាមស្ថានភាពរបស់និយោជកក៏ដោយ។ រដ្ឋម៉ាសាឈូសិត ក៏មានប្រាក់ឈ្នួលអប្បបរមាដែលមានប្រសិទ្ធភាពខ្ពស់សម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះ ជាងរដ្ឋទាំងអស់ ប៉ុន្តែមិនមានប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះទេ៖ រដ្ឋកាលីហ្វ័រញ៉ា និងរដ្ឋវ៉ាស៊ីនតោន។ ក៏មានសំណួរមួយអំពីផលប៉ះពាល់នៃគោលនយោបាយលុបបំបាត់នាពេលថ្មីៗនេះស្រដៀងគ្នានៅក្នុងរដ្ឋ Maine ដែលត្រូវតែកែប្រែនូវបញ្ញត្តិស្រដៀងគ្នាទៅនឹងញត្តិផ្តួចផ្តើមនៅចំពោះមុខគណៈកម្មាធិការ ដោយសារតែការកើនឡើងនៃការមិនអនុវត្តតាមកាតព្វកិច្ចប្រាក់កម្ចីរបស់ភោជនីយដ្ឋាន ប៉ុន្តែមិនមានភស្តុតាងណាមួយដែលអាចរកបានពីអ្នកជំនាញអំពីស្ថានភាពនោះនៅរដ្ឋ Maine ឡើយ។

ធាតុផ្សំមួយទៀតនៃសវនាការសាធារណៈ បានផ្តោតលើបញ្ញត្តិនៃញត្តិផ្តួចផ្តើមទាក់ទងនឹងការប្រមូលប្រាក់ធនានុគ្រោះ។ ការប្រតិបត្តិការប្រមូលប្រាក់ធនានុគ្រោះពីបុគ្គលិកដែលធ្វើការជាមួយអតិថិជនផ្ទាល់ រួមជាមួយនិងបុគ្គលិកគាំទ្របច្ចុប្បន្នត្រូវបានដាក់ឱ្យនៅក្រៅច្បាប់ នៅក្នុងរដ្ឋាភិបាលខំមិនវេលរបស់រដ្ឋម៉ាសាឈូសិត ក្រោមច្បាប់ទូទៅរដ្ឋ M.G.L. c 149, s 152A(c) ។ បន្ថែមទៅនឹងការដកប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះនៅក្នុងរដ្ឋាភិបាលរដ្ឋម៉ាសាឈូសិត ញត្តិផ្តួចផ្តើមនេះក៏នឹងផ្លាស់ប្តូរច្បាប់ដាច់ដោយឡែកនេះផងដែរ ដើម្បីអនុញ្ញាតឱ្យភោជនីយដ្ឋានតម្រូវឱ្យមានការប្រមូលប្រាកធនានុគ្រោះទាំងអស់ជាមួយបុគ្គលិកដែលមិនមែនជាអ្នកផ្តល់សេវាកម្មប្រសិនបើបុគ្គលិកបម្រើចំណីអាហារទទួលបានប្រាក់ឈ្នួលអប្បបរមាពេញលេញ។

អ្នកជំនាញបានផ្តល់សក្ខីកម្មថា មានច្បាប់តឹងរ៉ឹងជាច្រើនទាក់ទងនឹងការប្រមូលប្រាក់ធនានុគ្រោះ ជាពិសេសថានិយោជក អ្នកគ្រប់គ្រង ឬប្រធានក្រុមណាម្នាក់មិនអាចទទួលបានប្រាក់ធនានុគ្រោះនៅថ្ងៃដែលពួកគេមានទំនួលខុសត្រូវគ្រប់គ្រង ឬចាត់ចែងទោះបីជាពួកគេបម្រើអតិថិជននៅថ្ងៃនោះក៏ដោយ។ បច្ចុប្បន្នមានភាពខុសប្លែកគ្នាតិចតួចរវាងប្រាក់ឈ្នួលរបស់ “បុគ្គលិកធ្វើការផ្ទាល់ជាមួយអតិថិជន” និង “បុគ្គលិកគាំទ្រ” ប៉ុន្តែបញ្ញត្តិនេះនឹងកាត់បន្ថយភាពខុសគ្នាដែលអាចកើតឡើងពីការដកប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះចេញ។

ក្រុមអ្នកគាំទ្របានអះអាងថា ការប្រមូលប្រាក់ធនានុគ្រោះ នឹងនៅតែត្រូវបានគ្រប់គ្រងដោយច្បាប់សហព័ន្ធដែលរារាំងអ្នកគ្រប់គ្រងឬនិយោជកមិនឱ្យទទួលបានប្រាក់ធនានុគ្រោះពីការប្រមូលប្រាក់នោះឡើយ ហើយនឹងជំរុញឱ្យមានការធ្វើការជាក្រុមបន្ថែមទៀតរវាង “បុគ្គលិកធ្វើការផ្ទាល់ជាមួយអតិថិជន” និង “បុគ្គលិកគាំទ្រ” ដោយសារពួកគេទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍ក្នុងលក្ខណៈចែករំលែកពីប្រាក់ធនានុគ្រោះដែលទទួលបាន។ អ្នកគាំទ្រក៏បានលើកឡើងពីករណីដែលបុគ្គលិក "គាំទ្រ" ប្រើការផ្តល់ប្រាក់ធនានុគ្រោះជាមធ្យោបាយគ្រប់គ្រង ដោយការការបៀតបៀនផ្លូវភេទបុគ្គលិកអ្នកបម្រើចំណីអាហារ ដើម្បីធានាថាអាហារចេញមកភ្លាមៗ ឬដោយត្រឹមត្រូវ។

ក្រុមអ្នកជំទាស់បានចាត់ទុកបញ្ញត្តិប្រមូលប្រាក់ធនានុគ្រោះជាការបង្កគ្រោះថ្នាក់ដល់បុគ្គលិក "ធ្វើការផ្ទាល់ជាមួយអតិថិជន" ដែលទទួលបានប្រាក់ធនានុគ្រោះសម្រាប់សេវាកម្មល្អរបស់ពួកគេក្នុងតួនាទីប្រឈមមុខនឹងអតិថិជន។ បច្ចុប្បន្ននេះ និយោជិត “ធ្វើការផ្ទាល់ជាមួយអតិថិជន” អាច “ចែករំលែកប្រាក់ធនានុគ្រោះ” របស់ខ្លួនដល់បុគ្គលិក “គាំទ្រ” តាមការសម្រេចចិត្តរបស់ពួកគេ ដោយមានឧទាហរណ៍មួយបង្ហាញថា ប្រាក់ធនានុគ្រោះត្រូវបានចែករំលែកជាមួយ “បុគ្គលិកគាំទ្រ” ដើម្បីជួយបុគ្គលិកនិយោជិត ប៉ុន្តែបុគ្គលិក “ធ្វើការផ្ទាល់ជាមួយអតិថិជន” មិនចង់បាត់បង់ផលប្រយោជន៍សំខាន់ពីការងាររបស់ពួកគេនោះទេ។ ក្រុមអ្នកជំទាស់ជាច្រើនដែលជានិយោជិត

**របាយការណ៍មតិភាគច្រើន (ត)**

ភោជនីយដ្ឋានបានបញ្ជាក់ថា ការជំទាស់របស់ពួកគេចំពោះញត្តិផ្តួចផ្តើមនេះភាគច្រើន គឺដោយសារតែបញ្ញត្តិនៃការប្រមូលប្រាក់ធនានុគ្រោះ ប៉ុន្តែពួកគេទំនងជានៅតែជំទាស់នឹងញត្តិផ្តួចផ្តើមប្រសិនបើវាគ្រាន់តែជាការដកប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះចេញនោះ។

***សន្និដ្ឋាន***

នៅពេលនេះ មានភស្តុតាងមិនគ្រប់គ្រាន់ដែលបានផ្តល់ឱ្យ អំពីផលប៉ះពាល់រួមដែលញត្តិផ្តួចផ្តើមផ្តើមនេះនឹងមានចំពោះឧស្សាហកម្មភោជនីយដ្ឋាន និងកម្លាំងពលកម្មភោជនីយដ្ឋានក្នុងរដ្ឋម៉ាសាឈូសិត។ នៅតែមានសំណួរអំពីលទ្ធភាពជោគជ័យនៃភោជនីយដ្ឋាន និងឧស្សាហកម្មដែលបង់ប្រាក់ឈ្នួលមានប្រាក់ធនានុគ្រោះផ្សេងទៀត ដើម្បីស្រូបយកការចំណាយដែលមានការកើនឡើងច្រើនជាង 100 ភាគរយពីប្រាក់ឈ្នួលអប្បបរមាមានប្រាក់ធនានុគ្រោះបច្ចុប្បន្នដែលនិយោជកត្រូវទទួលខុសត្រូវលើការបង់ប្រាក់ ហើយការប្រៀបធៀបទៅនឹងយុត្តាធិការផ្សេងទៀតមានការប្រកួតប្រជែងដោយសាររដ្ឋទាំងប្រាំពីរដែលប្រើច្បាប់នេះ បានអនុវត្តតាមគោលនយោបាយនេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ គណៈកម្មាធិការនេះមិនជឿថា ខ្លួនបានទទួលភស្តុតាងគ្រប់គ្រាន់អំពីបទពិសោធន៍នៅរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី (បច្ចុប្បន្នកំពុងដកប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះចេញ) ឬរដ្ឋ Maine (កំពុងកែប្រែការដំឡើងប្រាក់ឈ្នួលអប្បបរមាដែលមានប្រាក់ធនានុគ្រោះ) ឬផលប៉ះពាល់ដែលការដំឡើងប្រាក់ឈ្នួលអប្បបរមាមានប្រាក់ធនានុគ្រោះតាមច្បាប់ចរចាដ៏ទូលំទូលាយ ដែលត្រូវបានបញ្ចប់នៅឆ្នាំ 2023 ដើម្បីធ្វើការសន្និដ្ឋានអំពីអ្វីដែលញត្តិផ្តួចផ្តើមនេះទំនងជានឹងមានផលប៉ះពាល់ចំពោះភោជនីយដ្ឋានក្នុងរដ្ឋម៉ាសាឈូសិត។ ផ្អែកលើសក្ខីកម្មដែលបានទទួល គណៈកម្មាធិការជឿនេះជាក់ថា អង្គនីតិបញ្ញត្តិនឹងត្រូវបានបម្រើយ៉ាងល្អក្នុងការធ្វើការជាមួយអគ្គរដ្ឋអាជ្ញាដើម្បីជួយពង្រឹងការការពារការលួចប្រាក់ឈ្នួល ការបៀតបៀនផ្លូវភេទ និងការរំលោភបំពាននៅក្នុងឧស្សាហកម្មប្រាក់ឈ្នួលដែលមានប្រាក់ធនានុគ្រោះ។ គួរបញ្ជាក់ថា ញត្តិផ្តួចផ្តើមនេះក៏ជាកម្មវត្ថុនៃបញ្ហាប្រឈមផ្លូវច្បាប់ដែលប្រព្រឹត្តទៅនៅចំពោះមុខតុលាការកំពូលនៅខែឧសភា ឆ្នាំ 2024 បន្ទាប់ពីកាលបរិច្ឆេទចុងក្រោយ ដែលសភានឹងត្រូវអនុម័តលើញត្តិផ្តួចផ្តើមនេះ។

សម្រាប់ហេតុផលទាំងនេះ យើងខ្ញុំ ដែលជាសមាជិកភាគច្រើននៃគណៈកម្មាធិការរួមពិសេសទទួលបន្ទុកញត្តិផ្តួចផ្តើមនានា សូមផ្តល់អនុសាសន៍ថា "ច្បាប់មួយដែលតម្រូវឱ្យបង់ប្រាក់ឈ្នួលអប្បបរមាពេញលេញសម្រាប់កម្មករនិយោជិតដែលទទួលបានប្រាក់ធនានុគ្រោះបន្ថែមលើប្រាក់ធនានុគ្រោះ" (សូមមើលសភាតំណាងរាស្ត្រលេខ 4254) ដែលបច្ចុប្បន្នត្រូវបានព្រាងនិងបង្ហាញជូនគណៈកម្មាធិការនេះ មិនគួរត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិនៅពេលនេះទេ។

| **សមាជិកព្រឹទ្ធសភា** | **សភាតំណាងរាស្ត្រ** |
|---|---|
| Cindy F. Friedman | Alice Hanlon Peisch |
| Paul R. Feeney | Michael S. Day |
| Jason M. Lewis | Kenneth I. Gordon |
| Ryan C. Fattman | David T. Vieira |

# *ចុះឈ្មោះបោះឆ្នោត*



មិនថាអ្នកមានផែនការបោះឆ្នោតដោយផ្ទាល់ ឬតាមសំបុត្រទេ អ្នកនឹងត្រូវធ្វើឱ្យប្រាកដថា អ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ។ អ្នកអាចត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោតរបស់អ្នកតាមអនឡាញ នៅ **www.VoteInMA.com**។

កាលបរិច្ឆេទផុតកំណត់សម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោត គឺមានរយៈពេល **10 ថ្ងៃ** មុនថ្ងៃបោះឆ្នោត។

ដើម្បីអាចបោះឆ្នោតក្នុងការបោះឆ្នោតរបស់រដ្ឋនៅថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ2024 អ្នកត្រូវតែចុះឈ្មោះបោះឆ្នោតត្រឹម**ថ្ងៃទី 26 ខែតុលា ឆ្នាំ2024**។

ថ្ងៃទី26 ខែតុលា ក៏ជាកាលបរិច្ឆេទផុតកំណត់ ដើម្បីផ្លាស់ប្តូរការចុះឈ្មោះបោះឆ្នោតរបស់អ្នកផងដែរ ដូចជាការផ្លាស់ប្តូរអាសយដ្ឋានជាដើម។

## របៀបចុះឈ្មោះបោះឆ្នោត

**តាមអនឡាញ** – ប្រសិនបើអ្នកមានប័ណ្ណបើកបររដ្ឋម៉ាសាឈូសិត ឬអត្តសញ្ញាណប័ណ្ណរដ្ឋម៉ាសាឈូសិត អ្នកអាចចុះឈ្មោះតាមអនឡាញបាននៅ **www.RegisterToVoteMA.com**។ អ្នកក៏អាចប្រើប្រាស់ប្រព័ន្ធចុះឈ្មោះបោះឆ្នោតតាមអនឡាញ ដើម្បីធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នក ឬផ្លាស់ប្តូរគណបក្សនយោបាយរបស់អ្នកផងដែរ។ ការចុះឈ្មោះតាមអនឡាញត្រូវប្រគល់ជូនមិនឱ្យលើសពីម៉ោង 11:59 យប់ នៅថ្ងៃទី26 ខែតុលា ឡើយ។

**តាមសំបុត្រ** – ប្រសិនបើអ្នកមិនអាចចុះឈ្មោះតាមអនឡាញបាន អ្នកក៏មានជម្រើសក្នុងការចុះឈ្មោះបោះឆ្នោតតាមសំបុត្រផងដែរ។ ទម្រង់នៃការចុះឈ្មោះតាមសំបុត្រអាចស្នើសុំបានដោយទូរស័ព្ទទៅលេខ 1-800-462-VOTE (8683)។ រាល់ការចុះឈ្មោះបោះឆ្នោតតាមសំបុត្រទាំងអស់ ត្រូវតែវាយត្រាប្រៃសណីយ៍ ឬប្រគល់ជូនទៅសាលាក្រុង ឬសាលាសង្កាត់ នៅត្រឹមថ្ងៃទី26 ខែតុលា។

**ដោយផ្ទាល់** – អាចចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាននីមួយៗ ដែលជាទូទៅមានទីតាំងនៅក្នុងសាលាក្រុង ឬសាលាសង្កាត់របស់អ្នក។ អ្នកអាចស្វែងរកការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកនៅ **www.VoteInMA.com**។ រាល់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានទាំងអស់ត្រូវផ្តល់ការចុះឈ្មោះអ្នកបោះឆ្នោតដោយផ្ទាល់នៅថ្ងៃទី26 ខែតុលា រហូតដល់ម៉ោង 5 ល្ងាច។

# ការបោះឆ្នោតក្នុងឆ្នាំ 2024

អ្នកបោះឆ្នោតក្នុងរដ្ឋម៉ាសាឈូសិត មានជម្រើសផ្សេងគ្នាច្រើននៅពេលបោះឆ្នោត៖ អ្នកអាចបោះឆ្នោត៖

- នៅថ្ងៃបោះឆ្នោត នៅមណ្ឌលបោះឆ្នោតរបស់អ្នក ឬ
- ក្នុងអំឡុងពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬ
- តាមសំបុត្រ ពីលំនៅដ្ឋានផ្ទាល់ខ្លួនរបស់អ្នក។

អ្នកបោះឆ្នោតគ្រប់រូបអាចជ្រើសយកជម្រើសណាមួយក្នុងចំណោមជម្រើសទាំង 3 ខាងលើ។ ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬការបោះឆ្នោតតាមសំបុត្រ ពុំចាំបាច់មានហេតុផលអ្វីនោះទេ។

សូមអានបន្ត ដើម្បីស្វែងយល់បន្ថែមអំពីការបោះឆ្នោតក្នុងឆ្នាំ 2024។

# ការបោះឆ្នោតតាមសំបុត្រ

រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងរដ្ឋម៉ាសាឈូសិត អាចបោះឆ្នោតតាមសំបុត្របាន ដោយពុំចាំបាច់ត្រូវមានមូលហេតុនៅក្នុងការបោះឆ្នោតនោះឡើយ។ ដើម្បីបោះឆ្នោតតាមសំបុត្រ អ្នកនឹងត្រូវការដាក់សំណើទៅកាន់មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋាន។ ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ ត្រូវបានផ្ញើទៅកាន់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនៅក្នុងរដ្ឋម៉ាសាឈូសិតក្នុងពេលថ្មីៗនេះ។

ប្រសិនបើអ្នកបានដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្រ សន្លឹកឆ្នោតរបស់អ្នកគួរតែត្រូវបានផ្ញើមកអ្នកក្នុងពេលឆាប់ៗនេះមិនខាន។ អ្នកអាចតាមដានសន្លឹកឆ្នោតរបស់អ្នកតាមអនឡាញនៅលើ **www.VoteInMA.com**

ប្រសិនបើអ្នកចង់បោះឆ្នោតតាមសំបុត្រ និងបានដាក់ពាក្យរួចហើយ សូមអនុវត្តតាមជំហានខាងក្រោម ដើម្បីស្នើសុំសន្លឹកឆ្នោតរបស់អ្នក។

## របៀបបោះឆ្នោតតាមសំបុត្រ

1. **ពិនិត្យមើលការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកនៅ www.VoteInMA.com។**

   ប្រសិនបើអ្នកមិនបានចុះឈ្មោះបោះឆ្នោតដោយប្រើអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកទេ អ្នកត្រូវធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នក មុនពេលដាក់ពាក្យសុំការបោះឆ្នោតតាមសំបុត្រ។ កាលបរិច្ឆេទផុតកំណត់ដើម្បីផ្លាស់ប្តូរការចុះឈ្មោះបោះឆ្នោតរបស់អ្នកគឺនៅ**ថ្ងៃទី26 ខែតុលា**។

2. **ដាក់ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្រ។**

   អ្នកអាចបំពេញពាក្យស្នើសុំដោយផ្ទាល់ដៃ ឬតាមប្រព័ន្ធអេឡិចត្រូនិក។ ពាក្យសុំតាមអនឡាញ មាននៅ **www.VoteInMA.com**. ត្រូវប្រាកដថា អ្នកបានបញ្ចូលអាសយដ្ឋានដែលអ្នកចង់ឱ្យគេផ្ញើសន្លឹកឆ្នោតទៅអ្នក ប្រសិនបើអាសយដ្ឋាននោះខុសពីអាសយដ្ឋានដែលអ្នកបានចុះឈ្មោះបោះឆ្នោត។

   ប្រសិនបើអ្នកចង់ឱ្យគេផ្ញើសន្លឹកពាក្យសុំទៅអ្នក សូមទូរសព្ទទៅនាយកដ្ឋានបោះឆ្នោត តាមរយៈលេខ 1-800-462-VOTE (8683) ដើម្បីស្នើសុំ។ ក្នុងជម្រើសនេះ អ្នកគ្រាន់តែដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរតាមលិខិតមួយច្បាប់ ទៅកាន់មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋាន។ លិខិតនោះត្រូវមានឈ្មោះរបស់អ្នក អាសយដ្ឋានអ្នកបានចុះឈ្មោះបោះឆ្នោត អាសយដ្ឋានដែលអ្នកចង់ឱ្យគេផ្ញើសន្លឹកឆ្នោតមក និងហត្ថលេខារបស់អ្នក។

3. **ប្រគល់ពាក្យស្នើសុំរបស់អ្នក** ទៅកាន់ការិយាល័យបោះឆ្នោតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

   ការបោះឆ្នោតតាមសំបុត្ររបស់អ្នក ត្រូវទៅដល់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក មិនយូរជាង**ថ្ងៃទី 29 ខែតុលា** ឡើយ។ សូមណែនាំឱ្យប្រគល់ពាក្យស្នើសុំបោះឆ្នោតតាមសំបុត្រយ៉ាងតិច 2 សប្តាហ៍មុនថ្ងៃបោះឆ្នោត។

   ពាក្យស្នើសុំអាចប្រគល់តាមអនឡាញ តាមសំបុត្រ តាមអ៊ីម៉ែល តាមទូរសារ ឬដោយផ្ទាល់ក៏បាន។ អ្នកអាចស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកបាននៅលើ **www.VoteInMA.com**។

4. **រង់ចាំឱ្យសន្លឹកឆ្នោតរបស់អ្នកមកដល់។**

   មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋាន នឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតនៅត្រឹមដើមខែតុលា ហើយនឹងបន្តផ្ញើសន្លឹកឆ្នោតនៅពេលពាក្យសុំមកដល់ រហូតដល់កាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី 29 ខែតុលា។

5. **ប្រគល់សន្លឹកឆ្នោតត្រឡប់ទៅវិញ។**

   សន្លឹកឆ្នោតទាំងអស់ដែលត្រូវប្រគល់ត្រឡប់ទៅវិញតាមសំបុត្រ ត្រូវមាន**វាយត្រាប្រៃសណីយ៍ត្រឹមថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ2024** ហើយត្រូវ**មកដល់មន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកត្រឹមថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ 2024 ដើម្បីឱ្យមន្ត្រីរាប់ចំនួន។**

   នៅក្នុងគ្រប់កញ្ចប់នៃការបោះឆ្នោតតាមសំបុត្រប្រចាំឆ្នាំ 2024 ទាំងអស់នឹងរួមបញ្ចូលស្រោមសំបុត្រមានចុះអាសយដ្ឋានជាមុន ដែលបានបង់ថ្លៃប្រៃសណីយ៍សម្រាប់ការប្រគល់ត្រឡប់មកវិញ ដើម្បីឱ្យអ្នកប្រើប្រាស់ប្រគល់សន្លឹកឆ្នោតត្រឡប់មកកាន់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកវិញ។ អ្នកក៏អាចប្រគល់សន្លឹកឆ្នោតរបស់អ្នកដោយផ្ទាល់ទៅកាន់ការិយាល័យបោះឆ្នោត ប្រអប់សំបុត្រក្នុងទីក្រុង ឬសង្កាត់របស់អ្នក ឬទៅកាន់ទីតាំងបោះឆ្នោតក្នុងសហគមន៍របស់អ្នក។

ប្រសិនបើអ្នកសម្រេចចិត្តមិនបោះឆ្នោតតាមសំបុត្រទេ អ្នកអាចបោះឆ្នោតដោយផ្ទាល់បាន ឱ្យតែសន្លឹកឆ្នោតរបស់អ្នក មិនទាន់ទទួលបាននៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។ **នៅពេលមន្ត្រីបោះឆ្នោតទទួលសន្លឹកឆ្នោតរបស់អ្នកហើយ អ្នកមិនអាចយកសន្លឹកឆ្នោតនោះមកវិញ ឬបោះឆ្នោតសាជាថ្មីបានទេ។**



# ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត៖

## ថ្ងៃទី 19 ខែតុលា ទៅដល់ ថ្ងៃទី 1 ខែវិច្ឆិកា



ការបោះឆ្នោតមុន សម្រាប់ការបោះឆ្នោតថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024 នឹងប្រព្រឹត្តទៅក្នុងរយៈពេល 15 ថ្ងៃ ដោយធានាថានឹងមានម៉ោងសម្រាប់បោះឆ្នោតនៅថ្ងៃចុងសប្តាហ៍ផង។

### នរណា?

អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ដែលមិនទាន់បានបោះឆ្នោតតាមសំបុត្រ អាចបោះឆ្នោតមុនថ្ងៃបោះឆ្នោតដោយផ្ទាល់បាន។ ការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ពុំចាំបាច់មានហេតុផលអ្វីទេ។

### នៅពេលណា?

រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងចាប់ផ្តើមនៅថ្ងៃសៅរ៍ ទី 19 ខែតុលា ហើយបញ្ចប់ទៅវិញនៅថ្ងៃសុក្រ ទី 1 ខែវិច្ឆិកា។ ក្រុងនិងសង្កាត់នីមួយៗ ត្រូវផ្តល់ជូនការបោះឆ្នោតមុនថ្ងៃបោះឆ្នោតយ៉ាងតិចមួយទីតាំង។ នៅចុងសប្តាហ៍ថ្ងៃទី 19 - 20 ខែតុលា និងថ្ងៃទី 26 - 27 ខែតុលា គ្រប់សហគមន៍ទាំងអស់ ត្រូវផ្តល់ការបោះឆ្នោតនៅថ្ងៃចុងសប្តាហ៍ខ្លះ។ ចំនួនម៉ោងដែលសហគមន៍នីមួយៗត្រូវបើកការិយាល័យ អាស្រ័យលើទំហំទីក្រុង ឬសង្កាត់។

**កំណត់ចំណាំ៖** ទីក្រុងនិងសង្កាត់ជាច្រើនមានម៉ោងធ្វើការមានកំណត់នៅថ្ងៃសុក្រ។ សូមកុំភ្លេចពិនិត្យមើលតារាងពេលវេលាសហគមន៍របស់អ្នកនៅ **www.VoteInMA.com** ហើយរៀបគម្រោងការបោះឆ្នោត។

### ទីណា?

អ្នកអាចបោះឆ្នោតមុនថ្ងៃបោះឆ្នោត នៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោតក្នុងទីក្រុង ឬសង្កាត់ ដែលអ្នកបានចុះឈ្មោះបោះឆ្នោត។ គ្រប់ទីក្រុងនិងសង្កាត់ទាំងអស់ ត្រូវមានទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោតយ៉ាងតិចមួយ ប៉ុន្តែពួកគេអាចជ្រើសរើសឱ្យច្រើនជាងនេះក៏បាន។ ទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត ត្រូវបានជ្រើសរើស ដោយទីក្រុង និងសង្កាត់នីមួយៗ ហើយនឹងត្រូវចុះផ្សាយនៅ **www.VoteInMA.com** ថ្ងៃទី 11 ខែតុលា ឆ្នាំ 2024។

### របៀបណា?

អ្នកពុំចាំបាច់ណាត់ជួប ឬដាក់ពាក្យសុំបោះឆ្នោតដោយផ្ទាល់មុនថ្ងៃបោះឆ្នោតនោះទេ។ អ្នកគ្រាន់តែទៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោតណាមួយនៅក្នុងទីក្រុង ឬសង្កាត់របស់អ្នក រួចបោះឆ្នោតដោយផ្ទាល់ជាការស្រេច ដូចអ្នកធ្វើនៅថ្ងៃបោះឆ្នោតដែរ។ បន្ទាប់ពីអ្នកបោះឆ្នោតរួច អ្នកនឹងត្រូវបិទស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នក ចុះហត្ថលេខាបញ្ជាក់នៅលើស្រោមសំបុត្រនោះ ហើយប្រគល់វាទៅមន្ត្រីបោះឆ្នោត។ នៅពេលដែលអ្នកប្រគល់ស្រោមសំបុត្រសន្លឹកឆ្នោតរួច ហើយស្មៀនបានទទួលយកសន្លឹកឆ្នោត ការបោះឆ្នោតរបស់អ្នក**សម្រេចរួចរាល់ ហើយអ្នកមិនអាចយកសន្លឹកឆ្នោតនោះមកវិញ ឬបោះឆ្នោតម្តងទៀតបានទេ។**

### ចូរចងចាំ៖

ជាទូទៅតែងមានមនុស្សតម្រង់ជួរវែងនៅទីតាំងបោះឆ្នោតនៅថ្ងៃដំបូង និងថ្ងៃចុងក្រោយនៃរយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត។ នៅថ្ងៃចុងសប្តាហ៍ ក៏អាចមានមនុស្សតម្រង់ជួរគ្នាច្រើនដែរ។ សូមលើកទឹកចិត្តឱ្យអ្នកបោះឆ្នោតដែលអាចបោះឆ្នោតក្នុងអំឡុងពេលមនុស្សតិច បានមកបោះឆ្នោតនៅពេលនេះ។

ករណីភាគច្រើន មានទីតាំងបោះឆ្នោតច្រើននៅទូទាំងក្រុងនិងសង្កាត់នីមួយៗនៅថ្ងៃបោះឆ្នោត ច្រើនជាងទីតាំងដែលមានអំឡុងការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ដែលមានន័យថា ក្នុងពេលនោះអាចចំណាយពេលរង់ចាំតិចជាងនៅមណ្ឌលបោះឆ្នោតនៅទីតាំងបោះឆ្នោតមុនថ្ងៃបោះឆ្នោត។

# ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត

អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចទាំងអស់ ដែលមិនបានបោះឆ្នោតតាមសំបុត្រ ឬបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងអាចបោះឆ្នោតដោយផ្ទាល់បាននៅថ្ងៃបោះឆ្នោតនាថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024។ ទីតាំងបោះឆ្នោតនៅទូទាំងរដ្ឋម៉ាសាឈូសិត នឹងចាប់បើកពីម៉ោង **7 ព្រឹក ដល់ម៉ោង 8 យប់**។

### កន្លែងត្រូវបោះឆ្នោត

នៅថ្ងៃបោះឆ្នោត អ្នកអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលបានកំណត់សម្រាប់មណ្ឌលរបស់អ្នក។

ចូលទៅកាន់ **www.VoteInMA.com** ដើម្បីត្រួតពិនិត្យមណ្ឌល និងមណ្ឌលបោះឆ្នោតរបស់អ្នកម្តងទៀត នៅមុនពេលអ្នកទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

### ការត្រៀមលក្ខណៈដើម្បីបោះឆ្នោត

នៅដើមខែតុលា អ្នកក៏នឹងអាចចូលទៅមើល **www.VoteInMA.com** ដើម្បីពិនិត្យសន្លឹកឆ្នោតគំរូ ដើម្បីឱ្យអ្នកអាចសម្រេចចិត្តបាន។

អ្នកមានសិទ្ធិក្នុងការយកកំណត់ចំណាំទៅតាមខ្លួន ទៅកាន់មណ្ឌលបោះឆ្នោត ដើម្បីជួយអ្នកក្នុងការបំពេញសន្លឹកឆ្នោត។ អ្នកមិនត្រូវភ្លេចយកកំណត់ចំណាំ ឬឯកសារណាមួយមកជាមួយអ្នកទេ នៅពេលអ្នកចាកចេញពីមណ្ឌលបោះឆ្នោត។

### ការត្រួតពិនិត្យមុនចូល

នៅពេលអ្នកទៅដល់មណ្ឌលបោះឆ្នោតរបស់អ្នក អ្នកនឹងត្រូវបុគ្គលិករៀបចំការបោះឆ្នោតត្រួតពិនិត្យមុនចូល។ ប្រសិនបើមានមនុស្សតម្រង់ជួររង់ចាំនៅតាមមណ្ឌលច្រើនលើសពីមួយនៅមណ្ឌលបោះឆ្នោតរបស់អ្នក ត្រូវប្រាកដថាអ្នកចូលតម្រង់ជួរនៅតាមមណ្ឌលរបស់អ្នក។ អ្នកអាចសុំបុគ្គលិករៀបចំការបោះឆ្នោតឱ្យជួយបាន ប្រសិនបើអ្នកមិនដឹងច្បាស់ពីមណ្ឌលរបស់អ្នក ឬអ្នកអាចចូលទៅកាន់គេហទំព័រ **www.VoteInMA.com** ដើម្បីស្វែងរកមើលមណ្ឌលបោះឆ្នោតរបស់អ្នក ដែលនឹងបង្ហាញអ្នកពីលេខបន្ទប់ ឬលេខមណ្ឌលផងដែរ។

នៅពេលអ្នកត្រួតពិនិត្យចូល អ្នកនឹងត្រូវប្រាប់បុគ្គលិករៀបចំការបោះឆ្នោតពីអាសយដ្ឋាននិងឈ្មោះរបស់អ្នក ដើម្បីឱ្យគេអាចរកឈ្មោះអ្នកឃើញនៅលើបញ្ជី។ បុគ្គលិករៀបចំការបោះឆ្នោត ត្រូវបានតម្រូវឱ្យបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកម្តងទៀត មុនពេលគូសឈ្មោះអ្នកនៅលើបញ្ជី និងប្រគល់សន្លឹកឆ្នោតជូនអ្នក។

ប្រសិនបើរកមិនឃើញឈ្មោះរបស់អ្នកនៅលើបញ្ជីទេ អ្នកអាចសុំបុគ្គលិករៀបចំការបោះឆ្នោតឱ្យទាក់ទងទៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន ដើម្បីបញ្ជាក់ពីការចុះឈ្មោះរបស់អ្នក។ ប្រសិនបើការចុះឈ្មោះរបស់អ្នកមិនអាចរកឃើញទេ អ្នកមានសិទ្ធិគូសសន្លឹកឆ្នោតបណ្តោះអាសន្នបាន ដែលនឹងត្រូវរាប់ថាបានការ ប្រសិនបើសិទ្ធិរបស់អ្នកអាចបញ្ជាក់ត្រូវបាន។

ប្រសិនបើអ្នកត្រូវបានតម្រូវឱ្យបង្ហាញឯកសារអត្តសញ្ញាណ គេនឹងសាកសួរអ្នកនៅតុត្រួតពិនិត្យចូល។

### ឯកសារអត្តសញ្ញាណ

គេអាចសុំឱ្យអ្នកបង្ហាញឯកសារអត្តសញ្ញាណ ប្រសិនបើអ្នកជាអ្នកបោះឆ្នោតលើកដំបូងក្នុងរដ្ឋម៉ាសាឈូសិត អ្នកជាអ្នកបោះឆ្នោតអសកម្ម ឬមន្ត្រីបោះឆ្នោតមានហេតុផលដទៃទៀតដើម្បីស្នើសុំឯកសារអត្តសញ្ញាណពីអ្នក។

គេពុំបានតម្រូវឱ្យអ្នកបង្ហាញឯកសារអត្តសញ្ញាណមានបិទរូបថត ដើម្បីបោះឆ្នោតឡើយ។ ឯកសារអត្តសញ្ញាណដែលអាចទទួលយកបាន រួមមាន៖

- ប័ណ្ណបើកបរ
- អត្តសញ្ញាណប័ណ្ណរដ្ឋ
- វិក្កយបត្រទឹកភ្លើង
- របាយការណ៍ធនាគារ
- ប័ណ្ណបើកប្រាក់ខែ
- មូលប្បទានបត្ររដ្ឋាភិបាល
- បង្កាន់ដៃជួលនៅលើក្បាលលិខិតរបស់ម្ចាស់ផ្ទះ
- លិខិតពីអន្តេវាសិកដ្ឋាន ឬការិយាល័យលំនៅឋាននៅលើក្បាលលិខិតរបស់សាលារៀន
- ឯកសារផ្លូវការដទៃផ្សេងទៀតដែលបង្ហាញពីឈ្មោះ និងអាសយដ្ឋានរបស់អ្នក។

ទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ត្រូវបង្ហាញពីឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។

ប្រសិនបើអ្នកជាអ្នកបោះឆ្នោតអសកម្ម ហើយអ្នកមិនអាចបង្ហាញឯកសារអត្តសញ្ញាណបាន នោះអ្នកនៅតែត្រូវបានគេអនុញ្ញាតឱ្យធ្វើការបោះឆ្នោត ដោយគូសលើសន្លឹកឆ្នោតដែលបានតវ៉ា។ សន្លឹកឆ្នោតទាំងនេះត្រូវរាប់ថាបានការនៅថ្ងៃបោះឆ្នោត ហើយត្រូវធ្វើការត្រួតពិនិត្យឡើងវិញ តែក្នុងករណីរាប់សន្លឹកឆ្នោតជាថ្មីប៉ុណ្ណោះ។

ប្រសិនបើអ្នកជាអ្នកបោះឆ្នោតលើកដំបូងក្នុងរដ្ឋម៉ាសាឈូសិត ដែលតម្រូវឱ្យបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណតាមច្បាប់ នោះអ្នកនឹងត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតលើសន្លឹកឆ្នោតបណ្តោះអាសន្ន។ អ្នកនឹងត្រូវត្រឡប់មកវិញនៅពេលក្រោយដោយមានយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណរបស់អ្នក ដើម្បីឱ្យសន្លឹកឆ្នោតរបស់អ្នករាប់ថាបានការ។

### ការបោះឆ្នោត

នៅពេលអ្នកមានសន្លឹកឆ្នោតរបស់អ្នក អ្នកអាចទៅកាន់បន្ទប់សម្ងាត់ដើម្បីគូសសន្លឹកឆ្នោតតែម្នាក់ឯង។ ប្រសិនបើអ្នកយកកូនមកជាមួយ គេអនុញ្ញាតឱ្យអ្នកយកកូនៗរបស់អ្នកចូលក្នុងបន្ទប់សម្ងាត់ជាមួយអ្នកបាន។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការគូសសន្លឹកឆ្នោត ដោយសារបញ្ហាពិការភាព ឬដោយសារអសមត្ថភាពក្នុងការអានសន្លឹកឆ្នោតរបស់អ្នក អ្នកអាចជ្រើសរើសមនុស្សណាម្នាក់ឱ្យអមដំណើរអ្នកចូលក្នុងបន្ទប់សម្ងាត់ដើម្បីជួយអ្នកបាន។

ប្រសិនបើចង់គូសសន្លឹកឆ្នោតដោយខ្លួនឯង អ្នកអាចប្រើម៉ាស៊ីនជំនួយអ្នកបោះឆ្នោត ដែលគូសសន្លឹកឆ្នោតដោយស្វ័យប្រវត្តិ ដែលមានផ្តល់ជូននៅគ្រប់មណ្ឌលបោះឆ្នោតទាំងអស់។ ម៉ាស៊ីននេះនឹងអានសន្លឹកឆ្នោតឱ្យអ្នកស្តាប់ ពង្រីកសន្លឹកឆ្នោត និងជួយអ្នកក្នុងការគូសសន្លឹកឆ្នោត។

ប្រសិនបើអ្នកពុំចង់ប្រើការគូសសន្លឹកឆ្នោតដោយស្វ័យប្រវត្តិ ហើយអ្នកពុំបាននាំនរណាម្នាក់ទៅជាមួយដើម្បីជួយអ្នក អ្នកក៏អាចស្នើសុំជំនួយពីបុគ្គលិករៀបចំការបោះឆ្នោតពីរនាក់ក្នុងការគូសសន្លឹកឆ្នោតរបស់អ្នកបានផងដែរ។

### ការគូសសន្លឹកឆ្នោតរបស់អ្នក

បន្ទាប់ពីអ្នកបានជ្រើសរើសរួច អ្នកអាចបន្តដំណើរទៅកាន់តុត្រួតពិនិត្យចេញ។ ប្រសិនបើមណ្ឌលបោះឆ្នោតរបស់អ្នកពុំមានតុត្រួតពិនិត្យចេញទេ អ្នកនឹងត្រូវបន្តដំណើរដោយផ្ទាល់ទៅកាន់ហិបឆ្នោតតែម្តង។

មណ្ឌលបោះឆ្នោតរបស់អ្នកអាចប្រើម៉ាស៊ីនតម្រៀបសន្លឹកឆ្នោតអេឡិចត្រូនិកដើម្បីរាប់សន្លឹកឆ្នោត ឬប្រើហិបឆ្នោតស៊កសន្លឹកឆ្នោតដោយផ្ទាល់ដៃ។

# សំណួរដែលត្រូវបានសាកសួរជាញឹកញាប់

## ការបោះឆ្នោតតាមសំបុត្រ

**តើខ្ញុំត្រូវតែបោះឆ្នោតតាមសំបុត្រមែនទេ?**

អត់ទេ។ ការបោះឆ្នោតដោយផ្ទាល់ គឺនៅតែមានសម្រាប់អ្នកដែលពុំចង់បោះឆ្នោតតាមសំបុត្រ។

**តើខ្ញុំត្រូវដាក់ពាក្យស្នើសុំឆាប់ប៉ុណ្ណា?**

បានឆាប់តាមដែលអាចធ្វើទៅបាន! ពាក្យស្នើសុំរបស់អ្នកត្រូវទៅដល់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន ត្រឹមថ្ងៃទី **29 ខែតុលា** ប៉ុន្តែសំបុត្រអាចចំណាយពេលរហូតដល់ 1 សប្តាហ៍ដើម្បីប្រគល់ជូន ដូច្នេះ កាលណាអ្នកដាក់ពាក្យកាន់តែឆាប់ អ្នកកាន់តែមានពេលវេលាច្រើនក្នុងការប្រគល់សន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ និងប្រាកដថាសន្លឹកឆ្នោតនោះត្រូវបានរាប់។

**ប្រសិនបើខ្ញុំបានស្នើសុំការបោះឆ្នោតតាមសំបុត្រ តើខ្ញុំអាចផ្លាស់ប្តូរទៅបោះឆ្នោតដោយផ្ទាល់វិញបានដែរឬទេ?**

នៅពេលដែលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកបានទទួលសន្លឹកឆ្នោតរបស់អ្នករួចហើយ អ្នកមិនអាចដកយកសន្លឹកឆ្នោតនោះមកវិញ ឬបោះឆ្នោតសាជាថ្មីបានទេ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបោះឆ្នោតតាមសំបុត្រ ប៉ុន្តែពុំបានប្រគល់សន្លឹកឆ្នោតនោះត្រឡប់ទៅឱ្យមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកវិញទេ អ្នកអាចបោះឆ្នោតដោយផ្ទាល់បានក្នុងអំឡុងពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោតបាន។

**តើការបោះឆ្នោតតាមសំបុត្រមានសុវត្ថិភាពដែរឬទេ?**

មាន។ មុនពេលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកអាចផ្ញើសន្លឹកឆ្នោតទៅអ្នកបាន ពួកគេត្រូវតែបញ្ជាក់ថា អ្នកជាអ្នកបោះឆ្នោត ហើយបានកត់ត្រាពាក្យស្នើសុំរបស់អ្នកទុក។ នៅពេលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកទទួលបានសន្លឹកឆ្នោត ពួកគេនឹងគូសសញ្ញាធីកដើម្បីប្រាកដថា អ្នកបានចុះហត្ថលេខាលើស្រោមសំបុត្រ និងបានប្រៀបធៀបហត្ថលេខានោះជាមួយនឹងហត្ថលេខាដែលអ្នកមាននៅលើឯកសារ។ ចំណុចនេះសំខាន់ណាស់ ដោយសារសន្លឹកឆ្នោតនឹងត្រូវបានបដិសេធ ប្រសិនបើពុំបានចុះហត្ថលេខាលើសន្លឹកឆ្នោតទេ។ ប្រសិនបើគេបានទទួលយកសន្លឹកឆ្នោតរបស់អ្នករួចហើយ អ្នកនឹងត្រូវគូសចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ហើយសន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នករក្សាទុកយ៉ាងមានសុវត្ថិភាព រហូតដល់អាចរាប់សន្លឹកឆ្នោតនោះបាន។

**តើកាលបរិច្ឆេទផុតកំណត់នៃការប្រគល់សន្លឹកឆ្នោតរបស់ខ្ញុំត្រឡប់ទៅវិញចំថ្ងៃណា?**

ដើម្បីអាចរាប់សន្លឹកឆ្នោតរបស់អ្នកបាន សន្លឹកឆ្នោតនោះត្រូវមានវាយត្រាប្រៃសណីយ៍ **ត្រឹមថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ2024** ហើយទទួលបានមិនលើសពី**ថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ2024** ឡើយ។ សេវាប្រៃសណីយ៍ សូមណែនាំឱ្យផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញយ៉ាងហោចណាស់មួយសប្តាហ៍ មុនថ្ងៃបោះឆ្នោត។

**តើខ្ញុំអាចរកមើលថាតើគេបានទទួលសន្លឹកឆ្នោតរបស់ខ្ញុំដោយវិធីណា?**

អ្នកអាចរកមើលស្ថានភាពសន្លឹកឆ្នោតរបស់អ្នកតាមអនឡាញ នៅ **www.VoteInMA.com**។ វានឹងបង្ហាញថាតើពាក្យស្នើសុំរបស់អ្នកបានទទួលហើយឬនៅ បង្ហាញពីកាលបរិច្ឆេទដែលមន្ត្រីបោះឆ្នោតក្នុងមូលដ្ឋានបានផ្ញើសន្លឹកឆ្នោតទៅអ្នក និងកាលបរិច្ឆេទដែលសន្លឹកឆ្នោតរបស់អ្នកបានមកដល់ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន។

**តើការបោះឆ្នោតតាមសំបុត្រទាំងអស់ សុទ្ធតែត្រូវរាប់ចំនួនមែនទេ?**

រាល់សន្លឹកឆ្នោតដែលបានទទួលទាន់ពេលវេលា នឹងត្រូវរាប់ចំនួនប្រសិនបើសន្លឹកឆ្នោតនោះបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ។ សូមកុំភ្លេចចុះហត្ថលេខាលើស្រោមសន្លឹកឆ្នោតរបស់អ្នក ដើម្បីឱ្យសន្លឹកឆ្នោតរបស់អ្នកអាចរាប់ជាបានការ! ការរាប់សន្លឹកឆ្នោតគឺមានតម្លាភាព និងបើកទូលាយសម្រាប់ការអង្កេតពីសាធារណជន។

---

## ការបោះឆ្នោតដោយផ្ទាល់

**តើពេលណាទើបខ្ញុំអាចបោះឆ្នោតដោយផ្ទាល់បាន?**

អ្នកអាចបោះឆ្នោតដោយផ្ទាល់បានក្នុងអំឡុងពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត។ រយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត នឹងចាប់ផ្តើមនៅ**ថ្ងៃទី 19 ខែតុលា** ហើយបញ្ចប់ទៅវិញនៅ**ថ្ងៃទី 1 ខែវិច្ឆិកា**។ អ្នកអាចពិនិត្យមើលកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង នៅ **www.VoteInMA.com**។

**នៅថ្ងៃបោះឆ្នោតនាថ្ងៃទី 5 ខែវិច្ឆិកា** មណ្ឌលបោះឆ្នោតនឹងត្រូវបើកចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់។ សូមចូលទៅកាន់ **www.VoteInMA.com** ដើម្បីរកមើលកន្លែងបោះឆ្នោតរបស់អ្នក។ អ្នកក៏អាចទូរសព្ទទៅនាយកដ្ឋានបោះឆ្នោត តាមរយៈលេខ 1-800-462- VOTE (8683) ដើម្បីជួយរកមណ្ឌលបោះឆ្នោតរបស់អ្នក។

**តើខ្ញុំអាចស្វែងយល់ពីមុខតំណែង និងបេក្ខជនណាខ្លះដែលមាននៅលើសន្លឹកឆ្នោតបានដោយរបៀបណា?**

សន្លឹកឆ្នោតគំរូ ក៏ដូចជាប័ណ្ណណែនាំ ត្រូវបានផ្សព្វផ្សាយនៅតាមកន្លែងបោះឆ្នោត នៅថ្ងៃបោះឆ្នោត។ អ្នកក៏នឹងអាចពិនិត្យមើលសន្លឹកឆ្នោតគំរូបានផងដែរនៅ **www.VoteInMA.com** ក្នុងខែតុលា។

**ខ្ញុំបានចុះឈ្មោះបោះឆ្នោតហើយ ប៉ុន្តែខ្ញុំគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត តើខ្ញុំត្រូវធ្វើអ្វីខ្លះ?**

ប្រសិនអ្នកចុះឈ្មោះបោះឆ្នោត ប៉ុន្តែឈ្មោះរបស់អ្នកមិនមាននៅលើបញ្ជីបោះឆ្នោត ចូរសុំមន្ត្រីបោះឆ្នោតដែលទទួលខុសត្រូវនៅមណ្ឌលបោះឆ្នោត ឱ្យជួយរកមើលការបោះឆ្នោតរបស់អ្នកជាមួយស្មៀនក្រុង ឬសង្កាត់ ដើម្បីចង់ដឹងថាតើអ្នកបានចុះឈ្មោះក្នុងមណ្ឌលផ្សេងនៅក្នុងក្រុងនោះឬអត់។ ប្រសិនបើពួកគេនៅតែពុំអាចរកឈ្មោះអ្នកឃើញទៀត អ្នកអាចបោះឆ្នោតលើសន្លឹកឆ្នោតបណ្តោះអាសន្នបាននៅមណ្ឌលបោះឆ្នោត។ បន្ទាប់ពីការបោះឆ្នោត មន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន នឹងស្វែងរកកំណត់ត្រាដើម្បីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតរបស់អ្នក។ ប្រសិនបើគេបានបញ្ជាក់ពីការចុះឈ្មោះរបស់អ្នករួចហើយ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវរាប់ថាបានការ។ ប្រសិនបើសិទ្ធិរបស់អ្នកមិនអាចបញ្ជាក់បានទេ សន្លឹកឆ្នោតរបស់អ្នកនឹងនៅបន្តបិទនៅក្នុងស្រោមសំបុត្រដដែល។

**ចុះបើខ្ញុំធ្វើខុសនៅលើសន្លឹកឆ្នោតវិញ តើខ្ញុំត្រូវធ្វើដូចម្តេច?**

ប្រសិនបើអ្នកធ្វើខុសនៅលើសន្លឹកឆ្នោត អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីបាន។ អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីបានរហូតដល់ទៅពីរ។

**តើខ្ញុំអាចយកឯកសារទៅមណ្ឌលបោះឆ្នោតបានដែរឬទេ?**

បាន អ្នកអាចយកឯកសារចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតបាន។ អ្នកអាចយកខិត្តប័ណ្ណបោះពុម្ពស្រេច ឬខិត្តប័ណ្ណ ឬកំណត់ត្រាផ្ទាល់ខ្លួនរបស់អ្នកមកជាមួយបាន ប៉ុន្តែអ្នកមិនអាចបង្ហាញឯកសារទាំងនោះនៅពេលស្ថិតក្នុងកន្លែងបោះឆ្នោតបានឡើយ។ អ្នកត្រូវយកកំណត់ចំណាំ ឬឯកសារណាមួយមកជាមួយអ្នកវិញ នៅពេលអ្នកចាកចេញពីបន្ទប់គូសសន្លឹកបោះឆ្នោត។

# សុវត្ថិភាពនៃការបោះឆ្នោត

ការបោះឆ្នោតក្នុងរដ្ឋម៉ាសាឈូសិត មានសុវត្ថិភាព អាចផ្ទៀងផ្ទាត់បាន និងមានតម្លាភាព។ ដោយមានការផ្លាស់ប្តូរក្នុងពេលថ្មីៗនេះទៅលើច្បាប់បោះឆ្នោតរបស់យើង អ្នកអាចមានសំណួរខ្លះអំពីការរក្សាសុវត្ថិភាពនៅនឹងកន្លែង ដើម្បីធានាថា ការបោះឆ្នោតទាំងអស់ត្រូវបានរាប់ចំនួនស្របតាមច្បាប់ និងត្រឹមត្រូវ។

## ក្រដាសឯកសារដែលអាចផ្ទៀងផ្ទាត់បាន

ក្នុងរដ្ឋម៉ាសាឈូសិត អ្នកបោះឆ្នោតទាំងអស់ បោះឆ្នោតលើសន្លឹកឆ្នោត។ សន្លឹកឆ្នោតអាចរាប់តាមម៉ាស៊ីនរាប់សន្លឹកឆ្នោតអេឡិចត្រូនិក ឬតាមរយៈបុគ្គលិករៀបចំការបោះឆ្នោត ដែលបូកសរុបលទ្ធផលបោះឆ្នោតដោយដៃ។

មិនថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានគេរាប់ដោយវិធីណានោះទេ បុគ្គលិករៀបចំការបោះឆ្នោត កត់ត្រារាល់សំឡេងឆ្នោតនៅលើសន្លឹករាប់សន្លឹកឆ្នោត នៅមណ្ឌលបោះឆ្នោតនីមួយៗ ក្រោយពេលបិទបញ្ចប់ការបោះឆ្នោត។ ការរាប់សន្លឹកឆ្នោតទាំងអស់ និងការបូកសរុបលទ្ធផល ធ្វើឡើងនៅកន្លែងសាធារណៈ ដែលមានការស្វាគមន៍ឱ្យមនុស្សគ្រប់គ្នាចូលរួមអង្កេតក្នុងដំណើរការនេះ។

ការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាននីមួយៗ ប្រើប្រាស់ក្រដាសបូកសរុបលទ្ធផលដើម្បីប្រមូលផ្តុំជាលទ្ធផលមិនផ្លូវការ។ លទ្ធផលបោះឆ្នោតអាចរាប់ជាផ្លូវការបានក្រោយពីបានត្រួតពិនិត្យល្អិតល្អន់ ដោយបានបញ្ជាក់ពីមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន ដោយបានរាយការណ៍ទៅកាន់ការិយាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ នឹងបានបញ្ជាក់ជាថ្មីដោយអភិបាលនិងទីប្រឹក្សាអភិបាលរដ្ឋ។

សវនកម្មក្រោយការបោះឆ្នោតត្រូវបានធ្វើឡើង មុនពេលលទ្ធផលត្រូវបានបញ្ជាក់ ហើយបេក្ខជនតែងតែមានសិទ្ធិដាក់ញត្តិសម្រាប់ការរាប់សន្លឹកឆ្នោតដោយដៃឡើងវិញ ដើម្បីផ្ទៀងផ្ទាត់ថាការរាប់ជាផ្លូវការត្រឹមត្រូវ។

## ម៉ាស៊ីនរាប់សន្លឹកឆ្នោត

រាល់ម៉ាស៊ីនរាប់សន្លឹកឆ្នោតទាំងអស់ក្នុងរដ្ឋម៉ាសាឈូសិត ត្រូវបានបញ្ជាក់សម្រាប់ប្រើប្រាស់ដោយគណៈកម្មាធិការជំនួយការបោះឆ្នោតរបស់សហព័ន្ធ និងរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ។

នៅមុនពេលការបោះឆ្នោតម្តងៗ មន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន ត្រូវរៀបចំការធ្វើតេស្តនៃដំណើរការតាមឡូហ្សិច និងភាពត្រឹមត្រូវនៃម៉ាស៊ីនរាប់សន្លឹកឆ្នោត ដែលនឹងត្រូវប្រើប្រាស់នៅក្នុងការបោះឆ្នោត។ ម៉ាស៊ីននីមួយៗត្រូវបានធ្វើតេស្តរួច ដើម្បីប្រាកដថាម៉ាស៊ីននោះរាប់សន្លឹកឆ្នោតបានត្រឹមត្រូវ។ កាលបរិច្ឆេទ ពេលវេលា និងទីតាំងធ្វើតេស្តត្រូវបានបិទផ្សាយជាសាធារណៈ ហើយសាធារណជនត្រូវបានស្វាគមន៍ឱ្យធ្វើអង្កេត។ គណៈកម្មការគណបក្សក្នុងមូលដ្ឋាន ក៏ត្រូវបានអញ្ជើញឱ្យចូលរួមអង្កេតការធ្វើតេស្តឧបករណ៍បោះឆ្នោតផងដែរ។

មានតែម៉ាស៊ីនរាប់សន្លឹកឆ្នោតប៉ុណ្ណោះដែលត្រូវបញ្ជាក់សម្រាប់ការប្រើប្រាស់នៅក្នុងរដ្ឋម៉ាសាឈូសិត។ គ្មានម៉ាស៊ីនរាប់សន្លឹកឆ្នោតណាក្នុងរដ្ឋម៉ាសាឈូសិត ត្រូវភ្ជាប់ទៅនឹងអ៊ីនធឺណិតឡើយ។

## ការបោះឆ្នោតតាមសំបុត្រ

ការបោះឆ្នោតតាមសំបុត្ររបស់អ្នក នឹងត្រូវត្រួតពិនិត្យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពីសន្លឹកឆ្នោតនោះបានមកដល់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន។ មន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក នឹងបើកស្រោមសំបុត្រប្រៃសណីយ៍ពីខាងក្រៅ និងពិនិត្យមើលសន្លឹកឆ្នោតនៅខាងក្នុងស្រោមសំបុត្រ រកមើលហត្ថលេខារបស់អ្នក។ ហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោត នឹងត្រូវយកមកផ្ទៀងផ្ទាត់ជាមួយហត្ថលេខានៅលើឯកសារនៅការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។

ប្រសិនបើស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នក មានចុះហត្ថលេខា ហើយត្រូវបានទទួលយក នោះមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋាន នឹងឆូតឈ្មោះរបស់អ្នកនៅលើបញ្ជីឈ្មោះ



អ្នកបោះឆ្នោត ដើម្បីកុំឱ្យអ្នកអាចបោះឆ្នោតបានម្តងទៀត។ បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលប្រើនៅមណ្ឌលបោះឆ្នោតរបស់អ្នក នឹងបង្ហាញថា អ្នកបានបោះឆ្នោតរួចហើយ។

ប្រសិនបើសន្លឹកឆ្នោតរបស់អ្នក មិនត្រូវបានទទួលយកទេ គេនឹងជូនដំណឹងទៅអ្នកថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានបដិសេធ ហើយអ្នកនឹងនៅតែអាចបោះឆ្នោតដោយផ្ទាល់បានដដែល។ ប្រសិនបើនៅមានពេល គេនឹងផ្ញើសន្លឹកឆ្នោតជំនួសថ្មីមួយសន្លឹកទៅអ្នកដើម្បីប្រើក្នុងការបោះឆ្នោតតាមសំបុត្រ។

សន្លឹកឆ្នោតដែលបានផ្ញើចូល ត្រូវបានពិនិត្យផ្ទៀងផ្ទាត់នឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅមុនពេលរាប់សន្លឹកឆ្នោតនោះ។ ការធ្វើបែបនេះ គឺដើម្បីបង្ការកុំឱ្យអ្នកបោះឆ្នោតណាម្នាក់អាចបោះឆ្នោតច្រើនជាងមួយលើក។ សន្លឹកឆ្នោតដែលបានផ្ញើចូល ដែលមកដល់បន្ទាប់ពីនរណាម្នាក់បានបោះឆ្នោតដោយផ្ទាល់រួច នឹងត្រូវបដិសេធចោល នៅពេលត្រួតពិនិត្យសន្លឹកឆ្នោតនោះ។

## ការរាប់សន្លឹកឆ្នោត

នៅពេលអ្នកបោះឆ្នោតដោយផ្ទាល់នៅមណ្ឌលបោះឆ្នោត អ្នកត្រូវដាក់សន្លឹកឆ្នោតនោះដោយផ្ទាល់ចូលទៅក្នុងហិបឆ្នោតដែលចាក់សោនៅទីនោះ សន្លឹកឆ្នោតត្រូវរក្សាទុករហូតដល់បិទបញ្ចប់ការបោះឆ្នោត។ សន្លឹកឆ្នោតដែលស៊កចូលទៅក្នុងម៉ាស៊ីនរាប់សន្លឹកឆ្នោត ត្រូវបានរាប់ចំនួននៅពេលដែលអ្នកស៊កសន្លឹកឆ្នោតចូល ចំណែកសន្លឹកឆ្នោតដែលបានស៊កចូលទៅក្នុងហិបឆ្នោតដទៃ នឹងត្រូវរាប់នៅក្នុងមណ្ឌលបោះឆ្នោត បន្ទាប់ពីបិទបញ្ចប់ការបោះឆ្នោត។

នៅពេលដែលអ្នកបោះឆ្នោតមុនថ្ងៃបោះឆ្នោតដោយផ្ទាល់ ឬបោះឆ្នោតតាមសំបុត្រ អ្នកដាក់សន្លឹកឆ្នោតចូលទៅក្នុងស្រោមសំបុត្រសន្លឹកឆ្នោត ដែលត្រូវរក្សាទុកក្នុងស្រោមសំបុត្របិទជិតនិងមានសុវត្ថិភាពរហូតដល់ពេលដែលអាចរាប់ចំនួនបាន។ សន្លឹកឆ្នោតមិនអាចគ្មានបិទស្រោមសំបុត្រជិតនោះទេ រហូតដល់ម៉ោងត្រូវរាប់សន្លឹកឆ្នោតបានចាប់ផ្តើម។

រាល់សន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់ចំនួនជាសាធារណៈ មិនថានៅកន្លែងរាប់សន្លឹកឆ្នោតកណ្តាល ឬនៅមណ្ឌលបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោតនោះទេ។ នៅមុនពេលរាប់សន្លឹកឆ្នោតបោះមុនថ្ងៃបោះឆ្នោត ឬសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោត ឈ្មោះនិងអាសយដ្ឋាននៅលើស្រោមសំបុត្រ ត្រូវអានឮៗ ហើយឈ្មោះអ្នកបោះឆ្នោត ត្រូវឆូតចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត។

អ្នកសង្កេតការត្រូវបានស្វាគមន៍ឱ្យចូលរួមក្នុងម៉ោងរាប់សន្លឹកឆ្នោត ដែលត្រូវផ្សព្វផ្សាយជាសាធារណៈដោយមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក។ សន្លឹកឆ្នោតណាមួយដែលមិនត្រូវបានរាប់ចំនួននៅកន្លែងរាប់សន្លឹកឆ្នោតកណ្តាល ត្រូវផ្ញើទៅកាន់មណ្ឌលបោះឆ្នោតដែលសមស្រប ដើម្បីបញ្ចូលទៅក្នុងហិបឆ្នោតនៅថ្ងៃបោះឆ្នោត។

អ្នកសង្កេតការក៏ត្រូវបានស្វាគមន៍ឱ្យចូលរួមនៅកន្លែងបោះឆ្នោតដើម្បីមើលដំណើរការនៃការបោះឆ្នោត និងដំណើរការនៃការរាប់សន្លឹកឆ្នោត រហូតដល់ជិតពាក់កណ្តាលអាធ្រាត្រ។ អ្នកសង្កេតការមិនត្រូវរំខានដល់ដំណើរការនៃការបោះឆ្នោតឡើយ ហើយត្រូវអង្កេតពីទីតាំងដែលបានកំណត់នៅខាងក្រៅនៃតំបន់បោះឆ្នោត។

# សុវត្ថិភាពនៃការបោះឆ្នោត (ត)

**លទ្ធផលបោះឆ្នោត**

សម្រាប់ការបោះឆ្នោតរបស់រដ្ឋនាថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024 លទ្ធផលបោះឆ្នោតមិនផ្លូវការដែលបានរាយការណ៍នៅយប់ថ្ងៃបោះឆ្នោត នឹងត្រូវរួមបញ្ចូលនូវចំនួនសន្លឹកឆ្នោតដែលបានរាប់ចំនួនទាំងអស់មកដល់ថ្ងៃទី 5 នេះដែរ។ លទ្ធផលទាំងនោះ នឹងរួមបញ្ចូលនូវ៖

- រាល់សន្លឹកឆ្នោតទាំងអស់ដែលបានបោះឆ្នោតក្នុងអំឡុងរយៈពេលនៃការបោះឆ្នោតមុនថ្ងៃបោះឆ្នោត
- រាល់សន្លឹកឆ្នោតផ្ញើចូលទាំងអស់ដែលបានប្រគល់ត្រឡប់មកវិញត្រឹមថ្ងៃទី 4 ខែវិច្ឆិកា
- រាល់សន្លឹកឆ្នោតទាំងអស់ដែលបានបោះដោយផ្ទាល់នៅថ្ងៃបោះឆ្នោត។

សន្លឹកឆ្នោតដែលបានប្រគល់ត្រឡប់មកវិញតាមប្រៃសណីយ៍ ឬប្រអប់ទម្លាក់សន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោត នឹងត្រូវផ្ញើទៅកាន់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានដើម្បីឱ្យគេអាចពិនិត្យមើលហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោត ហើយអាចផ្ទៀងផ្ទាត់ជាមួយបញ្ជីឈ្មោះអ្នកបោះឆ្នោតបាន។

សន្លឹកឆ្នោតផ្ញើចូលដែលមកដល់នៅថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ 2024 នឹងត្រូវរាប់បានលុះត្រាតែសន្លឹកឆ្នោតនោះត្រូវបានវាយត្រាប្រៃសណីយ៍នៅត្រឹមថ្ងៃបោះឆ្នោត។

បន្ទាប់ពីបានប្រគល់បញ្ជីឈ្មោះអ្នកបោះឆ្នោតពីកន្លែងបោះឆ្នោតទៅកាន់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានហើយ មន្ត្រីរៀបចំការបោះឆ្នោតនឹងពិនិត្យមើលសន្លឹកឆ្នោតដែលបានមកដល់នៅថ្ងៃ ឬក្រោយថ្ងៃបោះឆ្នោត ដោយផ្ទៀងផ្ទាត់ជាមួយបញ្ជីឈ្មោះនោះ ដើម្បីកំណត់ថាមិនមានអ្នកណាម្នាក់បោះឆ្នោតលើសពីមួយដងឡើយ។ សន្លឹកឆ្នោតពីបុគ្គលដែលបានបោះឆ្នោតរួចហើយ នឹងត្រូវបដិសេធចោល។

សន្លឹកឆ្នោតដែលបានទទួលនៅថ្ងៃ ឬក្រោយថ្ងៃបោះឆ្នោត នឹងត្រូវរាប់ចំនួនក្នុងម៉ោងរាប់សន្លឹកឆ្នោតជាសាធារណៈ ដែលត្រូវធ្វើឡើងក្រោយម៉ោង 5 ល្ងាច នៅថ្ងៃទី 8 ខែវិច្ឆិកា។ តារាងលទ្ធផលបោះឆ្នោត នឹងត្រូវកែប្រែដើម្បីឆ្លុះបញ្ចាំងពីសន្លឹកឆ្នោតបន្ថែមទាំងនោះនៅមុនពេលលទ្ធផលបោះឆ្នោតអាចក្លាយជាលទ្ធផលផ្លូវការបាន។

# ធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត!

វិធីដ៏ល្អមួយដែលអ្នកអាចជួយធានាថា រដ្ឋម៉ាសាឈូសិតរៀបចំការបោះឆ្នោតប្រកបដោយជោគជ័យបាននៅក្នុងឆ្នាំនេះ គឺតាមរយៈការលះបង់ពេលវេលារបស់អ្នកធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត។

បុគ្គលិករៀបចំការបោះឆ្នោត ត្រូវការជាចាំបាច់នៅទូទាំងរដ្ឋម៉ាសាឈូសិតនៅថ្ងៃទី 5 ខែវិច្ឆិកា ហើយសហគមន៍ភាគច្រើន ក៏នឹងត្រូវការបុគ្គលិកដើម្បីជួយដល់ការបោះឆ្នោតមុនថ្ងៃបោះឆ្នោតផងដែរ។

បុគ្គលិករៀបចំការបោះឆ្នោត ត្រូវបានមន្ត្រីរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានជួលឱ្យជួយត្រួតពិនិត្យចូលសម្រាប់អ្នកបោះឆ្នោត បូកសរុបសំឡេងឆ្នោត និងជួយអ្នកបោះឆ្នោតនៅមណ្ឌលបោះឆ្នោត។

ជាទូទៅ បុគ្គលិករៀបចំការបោះឆ្នោតត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួចនៅរដ្ឋម៉ាសាឈូសិត ក៏ប៉ុន្តែ មានបុគ្គលិករៀបចំការបោះឆ្នោតរហូតដល់ 2 នាក់ក្នុងមួយមណ្ឌល ដែលអាចមានអាយុពី 16 ឬ 17 ឆ្នាំ។

ប្រសិនបើអ្នកអាចលះបង់ពេលវេលាធ្វើជាបុគ្គលិករៀបចំការបោះឆ្នោត សូមចូលទៅកាន់គេហទំព័រនាយកដ្ឋានរៀបចំការបោះឆ្នោត **www.VoteInMA.com**



ដើម្បីស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នក ដែលអ្នកចង់ធ្វើការជាមួយ។ អ្នកពុំចាំបាច់ត្រូវតែជាពលរដ្ឋក្នុងទីក្រុង ឬសង្កាត់ ដើម្បីអាចក្លាយជាបុគ្គលិករៀបចំការបោះឆ្នោតនៅក្នុងក្រុងឬសង្កាត់នោះទេ។

# អ្នកបោះឆ្នោតជាមន្ត្រីយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស

ក្នុងរដ្ឋម៉ាសាឈូសិត សមាជិកផ្តល់សេវាកម្មមានឯកសណ្ឋានដែល**កំពុងកាន់ភារកិច្ច** ក្រុមគ្រួសាររបស់ពួកគេ ពលរដ្ឋអាមេរិកដែលរស់នៅក្រៅប្រទេស សុទ្ធតែមានសិទ្ធិក្នុងការបោះឆ្នោតទាំងអស់។ អ្នកបោះឆ្នោតទាំងនេះ **ពុំចាំបាច់ត្រូវចុះឈ្មោះបោះឆ្នោតដើម្បីស្នើសុំសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតនោះទេ។** សន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោត អាចស្នើសុំបានដោយប្រើពាក្យស្នើសុំប័ណ្ណប្រៃសណីយ៍របស់សហព័ន្ធ ឬទម្រង់នៃការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរណាមួយ។ **សមាជិកគ្រួសារក៏អាចស្នើសុំ**ឱ្យផ្ញើសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតទៅកាន់អ្នកបោះឆ្នោតបានផងដែរ។

អ្នកបោះឆ្នោតទាំងនេះ អាចស្នើសុំឱ្យផ្ញើសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតទៅកាន់ពួកគេតាមប្រៃសណីយ៍ ទូរសារ ឬអ៊ីមែលបាន។ សន្លឹកឆ្នោតក៏អាចប្រគល់ត្រឡប់មកកាន់ការិយាល័យរៀបចំការបោះឆ្នោតក្នុងមូលដ្ឋានតាមវិធីណាមួយដែលបានរៀបរាប់នេះផងដែរ។

រដ្ឋម៉ាសាឈូសិត ក៏អនុញ្ញាតឱ្យមន្ត្រីយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស ធ្វើការបោះឆ្នោតដោយអវត្តមានអ្នកបោះឆ្នោតនៅគ្រប់ការបោះឆ្នោតបានផងដែរ ដោយប្រើសន្លឹកឆ្នោតបំពេញចូលដែលបោះដោយអវត្តមានអ្នកបោះឆ្នោតរបស់សហព័ន្ធ (FWAB)។ សន្លឹកឆ្នោត FWAB អាចប្រើដើម្បីបោះឆ្នោតបានគ្រប់ពេលនៅមុនពេលបោះឆ្នោត ទោះបីជាអ្នកបោះឆ្នោតមិនបានដាក់ពាក្យស្នើសុំសន្លឹកឆ្នោតបោះដោយអវត្តមានអ្នកបោះឆ្នោតក៏ដោយ។ បន្ទាប់ពីបោះឆ្នោតលើសន្លឹកឆ្នោត FWAB រួច អ្នកបោះឆ្នោតអាចប្រគល់សន្លឹកឆ្នោតនោះតាមប្រៃសណីយ៍ ឬតាមអេឡិចត្រូនិក។ ទាំងពាក្យស្នើសុំប័ណ្ណប្រៃសណីយ៍របស់សហព័ន្ធ ទាំងសន្លឹកឆ្នោតបំពេញចូលដែលបោះដោយអវត្តមានអ្នកបោះឆ្នោតរបស់សហព័ន្ធ សុទ្ធតែអាចស្វែងរកបាននៅលើគេហទំព័រនៃកម្មវិធីជំនួយការបោះឆ្នោតរបស់សហព័ន្ធ **www.FVAP.gov** ។

# សេវានានារបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ

**នាយកដ្ឋានមូលបត្រ** បំពេញកិច្ចការដើម្បីការពារវិនិយោគិនក្នុងរដ្ឋម៉ាសាឈូសិត តាមរយៈការចុះឈ្មោះឈ្មួញកណ្ដាល-អ្នកជំនួញ និងអ្នកប្រឹក្សាយោបល់ការវិនិយោគ ដោយតម្រូវឱ្យមានការចុះបញ្ជីមូលបត្រដែលមានហានិភ័យខ្ពស់ បណ្ដឹងស៊ើបអង្កេត និងការអនុវត្តច្បាប់ដែលសមស្រប និងវិធានការវិន័យ។

លេខទូរសព្ទ៖ 617-727-3548 or 1-800-269-5428
គេហទំព័រ៖ **www.sec.state.ma.us/securities**
អ៊ីម៉ែល៖ securities@sec.state.ma.us

**សេវាព័ត៌មានពលរដ្ឋ** ដើរតួជាព័ត៌មានសំខាន់និងជាទីភ្នាក់ងារបញ្ជូនបន្តសម្រាប់រដ្ឋ ដោយផ្ដល់ព័ត៌មានស្ដីពីកម្មវិធីរបស់រដ្ឋ និងទីភ្នាក់ងាររបស់រដ្ឋ។ CIS ប៉ុនប៉ងក្នុងការឆ្លើយតបនឹងសំណើនានាដោយផ្ដល់នូវជំនួយដោយផ្ទាល់ ឬការបញ្ជូនបន្តភ្លាមៗទៅកាន់ទីភ្នាក់ដែលសមស្រប។ ជាផ្នែកមួយនៃគោលដៅរបស់ខ្លួនក្នុងការផ្ដល់ភាពងាយស្រួលឱ្យរដ្ឋាភិបាលផ្ដល់ព័ត៌មានដល់សាធារណជន CIS បានបង្កើតសៀវភៅឯកសារបោះពុម្ពផ្សាយនៅលើប្រធានបទជាក់លាក់ដែលមានការចាប់អារម្មណ៍ រួមមាន៖

- សៀវភៅណែនាំអំពីសេវារបស់រដ្ឋសម្រាប់ពលរដ្ឋ៖ បញ្ជីសម្រិតសម្រាំងនៃទីភ្នាក់ងារ និងកម្មវិធីរបស់រដ្ឋាភិបាល ដែលមានអាសយដ្ឋាន លេខទូរសព្ទ និងខ្លឹមសាររបស់ទីភ្នាក់ងារ។
- ស្វាគមន៍មកកាន់រដ្ឋម៉ាសាឈូសិត៖ សៀវភៅណែនាំជាក់ស្ដែងអំពីការរស់នៅក្នុងរដ្ឋ
- ពន្ធអាករលើយានយន្ត
- លំនៅដ្ឋានស្អាតនិងមានសុវត្ថិភាពសម្រាប់ពលរដ្ឋម៉ាសាឈូសិត
- សៀវភៅណែនាំអំពីច្បាប់អតីតយុទ្ធជន និងអត្ថប្រយោជន៍
- ខិត្តប័ណ្ណព័ត៌មានរដ្ឋម៉ាសាឈូសិត៖ ទិដ្ឋភាពទូទៅខាងប្រវត្តិសាស្ត្ររដ្ឋាភិបាល និងនិមិត្តរូបរបស់រដ្ឋ សម្រាប់សិស្សនៅអាយុរៀនអនុវិទ្យាល័យ និងវិទ្យាល័យ។

លេខទូរសព្ទ៖ 617-727-7030 ឬ 1-800-392-6090 (ខ្សែទូរសព្ទឥតគិតថ្លៃក្នុងរដ្ឋម៉ាសាឈូសិតតែប៉ុណ្ណោះ)
គេហទំព័រ៖ **www.sec.state.ma.us/cis**
អ៊ីម៉ែល៖ cis@sec.state.ma.us

**នាយកដ្ឋានបោះឆ្នោត** គ្រប់គ្រងរាល់ការបោះឆ្នោតរបស់រដ្ឋទាំងអស់ ផ្ដល់ព័ត៌មានអំពីការបោះឆ្នោត និងផ្គត់ផ្គង់ឯកសារបោះឆ្នោតជូនដល់សាធារណជន បេក្ខជន និងមន្ត្រីរដ្ឋាភិបាល។

លេខទូរសព្ទ៖ 617-727-2828 ឬ 1-800-462-VOTE (8683)
គេហទំព័រ៖ **www.sec.state.ma.us/elections**
អ៊ីម៉ែល៖: elections@sec.state.ma.us

**នាយកដ្ឋានកំណត់ត្រាសាធារណៈ** គ្រប់គ្រងច្បាប់កំណត់ត្រាសាធារណៈ ជួយដល់ទីភ្នាក់ងារ និងទីក្រុងក្នុងការគ្រប់គ្រងកំណត់ត្រា បញ្ជាក់ឯកសារសម្រាប់ប្រើប្រាស់នៅបរទេស ធ្វើការស្បថចូលកាន់តំណែង និងរក្សាកំណត់ត្រានៃការតែងតាំងតំណែងអភិបាល និងប្រធាននាយកដ្ឋាន។

លេខទូរសព្ទ៖ 617-727-2832
គេហទំព័រ៖ **www.sec.state.ma.us/publicrecords**
អ៊ីម៉ែល៖ pre@sec.state.ma.us

**កំណត់ត្រាអចលនទ្រព្យ**។ ព័ត៌មានអំពីបណ្ដឹងសុំផ្ដាច់ទ្រព្យបញ្ចាំ និងផ្ទះកំណើត - រដ្ឋម៉ាសាឈូសិតត្រូវបានបែងចែកជាមណ្ឌលចុះបញ្ជីចំនួន 21 ដោយមានអ្នកចុះបញ្ជីប័ណ្ណកម្មសិទ្ធិដែលបានជាប់ឆ្នោតជ្រើសតាំងឱ្យទទួលខុសត្រូវលើការិយាល័យនីមួយៗ។ ឯកសារពាក់ព័ន្ធនឹងម្ចាស់កម្មសិទ្ធិអចលនទ្រព្យនៅក្នុងសង្កាត់ ត្រូវបានកត់ត្រាទុកនៅក្នុងបញ្ជីប័ណ្ណកម្មសិទ្ធិ។

គេហទំព័រ៖ **www.masslandrecords.com**

**បណ្ណាសាររដ្ឋម៉ាសាឈូសិត** ប្រមូលផ្ដុំ ធ្វើកាតាឡុក និងរក្សាទុកកំណត់ត្រាដ៏មានតម្លៃពីរដ្ឋាភិបាលរដ្ឋអស់រយៈពេលជាង 400 ឆ្នាំមកហើយ។ បណ្ណាសារនេះបានដើរតួជាធនធានសម្រាប់អ្នកសិក្សា ពង្សាវលីវិទូ និងសិស្សានុសិស្ស និងដើរតួនាទីជាអ្នកប្រឹក្សាយោបល់មួយសម្រាប់កំណត់ត្រាប្រវត្តិសាស្ត្រសហគមន៍ក្នុងរដ្ឋម៉ាសាឈូសិត។

លេខទូរសព្ទ៖ 617-727-2816
គេហទំព័រ៖ **www.sec.state.ma.us/arc**
អ៊ីម៉ែល៖ archives@sec.state.ma.us

**សារមន្ទីរនៃរដ្ឋម៉ាសាឈូសិត** បានធ្វើឱ្យប្រវត្តិសាស្ត្ររដ្ឋម៉ាសាឈូសិតរស់ឡើងវិញតាមរយៈការតាំងពិពរណ៍ ការផ្សព្វផ្សាយ និងកម្មវិធីសិស្ស និងឯកសារបោះពុម្ពផ្សាយ។

លេខទូរសព្ទ៖ 617-727-9268
គេហទំព័រ៖ **www.commonwealthmuseum.org**

**គណៈកម្មាធិការប្រវត្តិសាស្ត្ររដ្ឋម៉ាសាឈូសិត** គឺជាទីភ្នាក់ងាររដ្ឋដែលទទួលខុសត្រូវសម្រាប់ការអភិរក្សប្រវត្តិសាស្ត្រក្នុងរដ្ឋម៉ាសាឈូសិតនេះ។ ទីភ្នាក់ងារបានផ្ដល់ជំនួយដល់សហគមន៍ក្នុងការចុះបញ្ជីទ្រព្យសម្បត្តិជាមួយមន្ទីរចុះបញ្ជីទីតាំងប្រវត្តិសាស្ត្រជាតិ និងបង្កើតជាសង្កាត់ប្រវត្តិសាស្ត្រក្នុងមូលដ្ឋាន។

លេខទូរសព្ទ៖ 617-727-8470
គេហទំព័រ៖ **www.sec.state.ma.us/mhc**
អ៊ីម៉ែល៖ mhc@sec.state.ma.us

# សេវានានារបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ (ត)

**ហាងសៀវភៅរបស់រដ្ឋ** ផ្តល់ជូននូវសៀវភៅ និងខិត្តប័ណ្ណជាច្រើនប្រភេទដែលបានបោះពុម្ពផ្សាយដោយរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ និងទីភ្នាក់ងាររដ្ឋដទៃផ្សេងទៀត រួមមានក្រមបទបញ្ញត្តិរដ្ឋម៉ាសាឈូសិតជាដើម។ កាតាឡុកហាងសៀវភៅឥតគិតថ្លៃ អាចស្វែងរកបាន។

លេខទូរសព្ទ៖ 617-727-2834
គេហទំព័រ៖ **www.sec.state.ma.us/bookstore**
អ៊ីម៉ែល៖ bookstore@sec.state.ma.us

**ការិយាល័យក្នុងតំបន់** ក្នុង Springfield និង Fall River ផ្តល់ជូននូវសេវាជាច្រើនដែលផ្តល់ជូនដោយការិយាល័យ Boston និងធ្វើឱ្យរដ្ឋាភិបាលរដ្ឋកាន់តែជិតស្និទ្ធនឹងពលរដ្ឋម៉ាសាឈូសិត។

Springfield: 413-784-1376
Fall River: 508-646-1374
គេហទំព័រ៖ **www.sec.state.ma.us/wso**

**នាយកដ្ឋានសហប្រតិបត្តិការ** ទទួលខុសត្រូវលើការចុះបញ្ជីស្ថាប័នអាជីវកម្មរកប្រាក់ចំណេញ និងស្ថាប័នអាជីវកម្មមិនរកប្រាក់ចំណេញនៅក្នុងរដ្ឋម៉ាសាឈូសិត និងផ្តល់ព័ត៌មានសង្ខេបភ្លាមៗអំពីស្ថាប័នជាង 400,000 កន្លែងដែលកំពុងធ្វើអាជីវកម្មនៅក្នុងរដ្ឋនេះ។

លេខទូរសព្ទ៖ 617-727-2850
គេហទំព័រ៖ **www.sec.state.ma.us/corporations**
អ៊ីម៉ែល៖ corpinfo@sec.state.ma.us

## នាយកដ្ឋានដទៃទៀត រួមមាន៖

**អ្នកបញ្ចុះបញ្ចូល៖**
លេខទូរសព្ទ៖ 617-727-9122
គេហទំព័រ៖ **www.sec.state.ma.us/lobbyist**
អ៊ីម៉ែល៖ lob@sec.state.ma.us

**ឯកសារបោះពុម្ពផ្សាយរបស់រដ្ឋ និងបទប្បញ្ញត្តិ**
លេខទូរស័ព្ទ៖ 617-727-2831
គេហទំព័រ៖ **www.sec.state.ma.us/publications**
អ៊ីម៉ែល៖ regs@sec.state.ma.us

**ដំណើរទស្សនកិច្ចវិមានរដ្ឋ៖**
លេខទូរសព្ទ៖ 617-727-3676
គេហទំព័រ៖ **www.sec.state.ma.us/tours**
អ៊ីម៉ែល៖ mastatehousetours@sec.state.ma.us

## ជំនួយសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

ប្រសិនបើអ្នកជាអ្នករស់រានមានជីវិតពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ឬការលួចតាមដាន ឬអ្នកជាអ្នកផ្តល់សេវាថែទាំសុខភាពដែលត្រូវបានការពារដោយស្របច្បាប់ រដ្ឋម៉ាសាឈូសិតប្រហែលជាអាចការពារអាសយដ្ឋានរបស់អ្នកពីជនល្មើសនៃអំពើហិង្សា។

ប្រសិនបើអ្នកកំពុងផ្លាស់ទីលំនៅដើម្បីគេចចេញពីស្ថានភាពហិង្សា ឬគ្រោះថ្នាក់ កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន (ACP) ដែលគ្រប់គ្រងដោយរដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ អាចធ្វើឱ្យអាសយដ្ឋានថ្មីរបស់អ្នកពិបាកស្វែងរក។

ក្នុងនាមជាអ្នកនៅរស់រានមានជីវិតពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ឬការតាមលួចមើល អ្នកអាចដាក់ពាក្យសុំឱ្យមានការបញ្ជាក់ជាអ្នកចូលរួមក្នុងកម្មវិធី ACP ។ អ្នកត្រូវតែបង្ហាញថា ការបញ្ចេញព័ត៌មានអាសយដ្ឋានរបស់អ្នកគំរាមកំហែងដល់សុវត្ថិភាពរបស់អ្នក ឬសុវត្ថិភាពរបស់កូនៗអ្នក។

ACP អនុញ្ញាតឱ្យអ្នកចូលរួមកម្មវិធីប្រើប្រាស់អាសយដ្ឋានប្រៃសណីយ៍ជំនួសនៅពេលទាក់ទងជាមួយទីភ្នាក់ងាររដ្ឋាភិបាល។ អាសយដ្ឋាននេះនឹងត្រូវបានប្រើជាលំនៅឋានស្របច្បាប់របស់អ្នក ក៏ដូចជាអាសយដ្ឋានរបស់អ្នកសម្រាប់ការងារ និង/ឬសាលារៀនដែរ។ ការណ៍នេះអនុញ្ញាតឱ្យកំណត់ត្រារដ្ឋាភិបាលអាចត្រូវបានបញ្ចេញឱ្យដឹងជាសាធារណៈដោយពុំកំណត់ពីទីតាំងថ្មីរបស់ជនរងគ្រោះឡើយ។

**តើខ្ញុំដាក់ពាក្យសុំដូចម្តេច?**

អ្នកអាចដាក់ពាក្យដោយទាក់ទងជំនួយការកម្មវិធី ដែលនឹងចាប់ផ្តើមដំណើរការដាក់ពាក្យជាមួយរូបអ្នក។ អ្នកអាចទូរសព្ទទៅ ACP តាមរយៈលេខ 1-866-SAFE-ADD ដើម្បីស្វែងរកទីតាំងរបស់អ្នកផ្តល់ជំនួយពាក្យស្នើសុំ។ អ្នកក៏អាចទាក់ទងទីភ្នាក់ងារ ឬកម្មវិធីមិនរកប្រាក់ចំណេញ ដែលផ្តល់ការប្រឹក្សាយោបល់ ការបញ្ជូនបន្ត ទីជម្រក ឬសេវាឯកទេសផ្សេងទៀត ជូនដល់ជនរងគ្រោះនៃអំពើហិង្សា ការចាប់រំលោភ ការរំលោភបំពានផ្លូវភេទ ឬការតាមលួចមើល។

# ✓ បញ្ជីត្រួតពិនិត្យសម្រាប់អ្នកបោះឆ្នោត ហែកចេញ រួចយកតាមខ្លួនទៅកន្លែងបោះឆ្នោត។

**សន្លឹកឆ្នោតសំណួរនៅលើ** ▶

| | | |
|---|---|---|
| សំណួរទី 1 | ☐ គាំទ្រ | ☐ ជំទាស់ |
| សំណួរទី 2 | ☐ គាំទ្រ | ☐ ជំទាស់ |
| សំណួរទី 3 | ☐ គាំទ្រ | ☐ ជំទាស់ |
| សំណួរទី 4 | ☐ គាំទ្រ | ☐ ជំទាស់ |
| សំណួរទី 5 | ☐ គាំទ្រ | ☐ ជំទាស់ |

**សន្លឹកឆ្នោតមុខតំណែង** ▶ **មុខតំណែងដែលត្រូវបោះឆ្នោតក្នុងឆ្នាំ 2024 មានតាមលំដាប់លំដោយខាងក្រោម៖**

**អ្នកបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតី** ____________________

**សមាជិកព្រឹទ្ធសភានៅក្នុងសភាជាន់ខ្ពស់** ____________________

**សមាជិកសភាសហរដ្ឋអាមេរិក** ____________________

**ទីប្រឹក្សាអភិបាលរដ្ឋ** ____________________

**សមាជិកព្រឹទ្ធសភាប្រចាំរដ្ឋម៉ាសាឈូសិត** ____________________

**សមាជិកសភាប្រចាំរដ្ឋម៉ាសាឈូសិត** ____________________

**មន្ត្រីចុះបញ្ជីកម្មសិទ្ធិ** ____________________

**ក្រឡាបញ្ជី** ____________________

**សមាជិកក្រុមប្រឹក្សាប្រចាំខោនធី** (ជ្រើសរើសខោនធី) ____________________

**មន្ត្រីតុលាការមរតកសាសន៍** (ខោនធី Hampshire និងខោនធី Suffolk) ____________________

**William Francis Galvin**
រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ
One Ashburton Place, Room 1705
Boston, MA 02108

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

ឯកសារផ្លូវការ

# *អតិថិជននៅតាមផ្ទះ*
# *អ្នកបោះឆ្នោត*

**ព័ត៌មានសម្រាប់អ្នកបោះឆ្នោត** ត្រូវបានផ្ញើតាមសំបុត្រទៅកាន់អាសយដ្ឋានស្នាក់នៅ ទៅកាន់អ្នកបោះឆ្នោតដែលបានស្នាក់នៅកន្លែងស្នាក់នៅជាក្រុម និងទៅកាន់ទីសាធារណៈដែលមានភាពងាយស្រួលនៅទូទាំងរដ្ឋម៉ាសាឈូសិត។ អាចទទួលបានសំណៅថតចម្លងក្នុងចំនួនមានកំណត់ ហើយសាលាក្រុង និងសាលាសង្កាត់ក្នុងមូលដ្ឋាន និងបណ្ណាល័យខ្លះ ឬដោយទូរសព្ទទៅនាយកដ្ឋានផ្នែកបោះឆ្នោតរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការរដ្ឋ លោក Galvin តាមរយៈលេខ 617-727-2828 ឬ 1-800-462-VOTE (8683); សេវាព័ត៌មានសម្រាប់ពលរដ្ឋ តាមរយៈលេខ 617-727-7030 ឬ 1-800-392-6090។ អ្នកប្រើប្រាស់ TTY អាចទូរសព្ទទៅ MassRelay តាមរយៈលេខ 800-720-3480។ **សូមកុំភ្លេចចូលមើលគេហទំព័ររបស់យើងនៅ www.sec.state.ma.us** ។ សំណៅឯកសារព័ត៌មានអ្នកបោះឆ្នោតជាភាសាអេស្ប៉ាញ ភាសាចិន និងភាសាខ្មែរ និងសំណៅឯកសារបោះពុម្ពជាអក្សរធំៗសម្រាប់អ្នកដែលមើលពុំសូវច្បាស់ ក៏អាចស្វែងរកបានផងដែរ តាមរយៈលេខទូរសព្ទដូចគ្នានេះ។ សំណៅឯកសារជាសំឡេងក៏អាចស្វែងរកបានផងដែរ រាប់ចាប់ពីអក្សរស្ទាប រហូតដល់បណ្ណាល័យសៀវភៅសំឡេងនៅក្នុងក្រុង Watertown តាមរយៈលេខ 1-800-852-3133។

♲ បោះពុម្ពនៅលើក្រដាសកែច្នៃឡើងវិញ